ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



# ឯកសារសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣

៣០ មិថុនា ២០២៥

# មាតិកា

ទំព័រ

**ក. សេចក្តីណែនាំស្តីពី ការចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក**........................១
**ខ. ឯកសារបង្ហាញផ្លូវសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិក**......................................................២
**គ. ការតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)**..................................................................................២
**ឃ. ឯកសារសម្រាប់មហាសន្និបាតភាគហ៊ុនិក**.......................................................................................២
១. របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៤.........................................................................២
២. ទិសដៅអាជីវកម្ម ឆ្នាំ២០២៥ ..................................................................................................២

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធ ១: របៀបចូលរួម និងនីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១៣

ឧបសម្ព័ន្ធ ២: ប្រវត្តិរូបអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដែលនឹងត្រូវបោះឆ្នោតអនុម័តបន្តអាណត្តិ

ឧបសម្ព័ន្ធ ៣: លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)

ឧបសម្ព័ន្ធ ៤: របាយការណ៍ប្រចាំឆ្នាំ២០២៤

ឧបសម្ព័ន្ធ ៥: ទិសដៅអាជីវកម្មឆ្នាំ២០២៥

ឧបសម្ព័ន្ធ ៦: សេចក្តីសម្រេចស្តីពី ការផ្ទេរសិទ្ធិលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១៣

ឧបសម្ព័ន្ធ ៧: សេចក្តីសម្រេចស្តីពី ការចាត់តាំងគណៈកម្មការរៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១៣

ឧបសម្ព័ន្ធ ៨: សម្រង់ខ្លឹមសារនៃលក្ខន្តិកៈ រ.ទ.ស.ភ

## ក. សេចក្តីណែនាំស្តីពី ការចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិក

- ភាគហ៊ុនិកដែលមានសិទ្ធិចុះឈ្មោះចូលរួមនៅក្នុងមហាសន្និបាតនេះ លុះត្រាតែមានលិខិតអញ្ជើញចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) និងបានធ្វើការបញ្ជាក់ការចូលរួមជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) ចាប់ពីថ្ងៃទី០៤ ដល់ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៥។

- ដំណើរការនៃការចុះឈ្មោះចូលរួមក្នុងមហាសន្និបាត ត្រូវបានកំណត់ដូចតទៅ ៖
  - **ការចុះឈ្មោះ** ប្រព្រឹត្តទៅដូចខាងក្រោម ៖
    - **ចូលរួមដោយផ្ទាល់** : សូមអញ្ជើញទៅចុះឈ្មោះនៅស្នាក់ការ រ.ទ.ស.ភ (សូមពិនិត្យឯកសារបង្ហាញផ្លូវ សម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិកដូចមានក្នុង ទំព័រទី២ នៃឯកសារនេះ)
    - **ចូលរួមតាមប្រព័ន្ធអនឡាញ** : សូមស្កេន QR Code នៅក្នុងលិខិតអញ្ជើញដែលបានភ្ជាប់ជូន ដើម្បីចុះឈ្មោះចូលរួម និងទាញយកឯកសារមហាសន្និបាតភាគហ៊ុនិក ដោយអនុវត្តតាមរបៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣ តាមរយៈកុំព្យូទ័រ និងស្មាតហ្វូន (ចំណុច ក ក្នុង **ឧបសម្ព័ន្ធ១**)។ អ្នកចូលរួមទាំងអស់ រួមទាំងភាគហ៊ុនិក ត្រូវមានទូរស័ព្ទដៃ ថេប្លេត ឬកុំព្យូទ័រ ព្រមទាំងត្រូវដំឡើងកម្មវិធី ZOOM ជាមុន។
  - **កាលបរិច្ឆេទ** : ថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥
  - **ពេលវេលា** : ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ០៩:០០ ព្រឹក

- ដំណើរការនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១៣ នឹងធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញទៅលើកម្មវត្ថុចំនួន៥គឺ (ទី១)ការបោះឆ្នោតអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក (ទី២)ការបោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល (ទី៣)ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលឯករាជ្យ (ទី៤)ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និង(ទី៥)ការបោះឆ្នោតអនុម័តលើការបង្កើនដើមទុនរបស់ រ.ទ.ស.ភ ។ ភាគហ៊ុនិកទាំងអស់ត្រូវមានទូរស័ព្ទដៃ ថេប្លេត ឬកុំព្យូទ័រ ព្រមទាំងត្រូវអនុវត្តតាមនីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១៣ ដូចមានក្នុង**ឧបសម្ព័ន្ធ១** នៃឯកសារនេះ។

- ភាគហ៊ុនិកដែលចូលរួមដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហក:(អ្នកតំណាង) ក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ ត្រូវភ្ជាប់មកជាមួយនូវលិខិតអញ្ជើញ នៅថ្ងៃប្រារព្ធមហាសន្និបាតភាគហ៊ុនិកនេះ តាមពេលវេលា និងកាលបរិច្ឆេទខាងលើ ដើម្បីចុះឈ្មោះចូលរួមនៅក្នុងមហាសន្និបាតភាគហ៊ុនិកនេះ។

## ខ. ឯកសារបង្ហាញផ្លូវសម្រាប់ចូលរួមមហាសន្និបាតភាគហ៊ុនិក




## គ. ការតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)

ភាគហ៊ុនិកដែលចូលរួមមហាសន្និបាតភាគហ៊ុនិក លើកទី១៣ របស់ រ.ទ.ស.ភ តាមរយៈអាណត្តិគាហកៈ ត្រូវតែងតាំងអាណត្តិគាហកៈតាមទម្រង់ **"លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)"** ដូចមានក្នុង **ឧបសម្ព័ន្ធ៣** នៃឯកសារនេះ។

ភាគហ៊ុនិកម្នាក់តែងតាំងអាណត្តិគាហកៈបានតែ ០១រូប ប៉ុណ្ណោះ។ ភាគហ៊ុនិកច្រើននាក់អាចតែងតាំងអាណត្តិគាហកៈរួមគ្នាបាន។

## ឃ. ឯកសារសម្រាប់មហាសន្និបាតភាគហ៊ុនិក

### ១. របាយការណ៍លទ្ធផលអាជីវកម្ម ឆ្នាំ២០២៤

លទ្ធផលអាជីវកម្ម ឆ្នាំ២០២៤ របស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុង **របាយការណ៍ប្រចាំឆ្នាំ២០២៤** ដូចមាននៅក្នុង **ឧបសម្ព័ន្ធ ៤** នៃឯកសារនេះ។

### ២. ទិសដៅអាជីវកម្ម ឆ្នាំ២០២៥

ទិសដៅអាជីវកម្ម ឆ្នាំ២០២៥ របស់ រ.ទ.ស.ភ ត្រូវបានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធ ៥** នៃឯកសារនេះ។

# ឧបសម្ព័ន្ធ ១
## របៀបចូលរួម និងនីតិវិធីនៃការបោះឆ្នោត
## មហាសន្និបាតភាគហ៊ុនិកលើកទី១៣

# របៀបចូលរួមមហាសន្និបាតភាគហ៊ុនិក
# លើកទី ១៣

# គ.ការចុះឈ្មោះ

## ការចូលរួមតាមរយៈ Online

- ស្កេន QR Code ដែលមានក្នុងលិខិតអញ្ជើញ សម្រាប់ Smart Phone។
- ឬចូលទៅកាន់គេហទំព័រ https://gms13.ppwsa.com.kh/ សម្រាប់ Computer។


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**លិខិតអញ្ជើញ**

**ក្រុមប្រឹក្សាភិបាល អាណត្តិទី៨**

មានកិត្តិយសសូមគោរពអញ្ជើញ
ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ឬអ្នកតំណាង
XXXX XXXX ដែលកាន់កាប់អត្តសញ្ញាណវិនិយោគិនលេខ XX777
ក្នុងនាមជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ចំនួន 0 ភាគហ៊ុន
គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
ដើម្បីចូលរួម

**មហាសន្និបាតភាគហ៊ុនិក លើកទី១៣ របស់ រ.ទ.ស.ភ**

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹង
**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥** ចាប់ពីវេលាម៉ោង ០៨:០០នាទីព្រឹក

**នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមរយៈប្រព័ន្ធអនឡាញ (Zoom)**

*បញ្ជាក់៖ សូមមេត្តាយកលិខិតអញ្ជើញនេះមកជាមួយ នាថ្ងៃមហាសន្និបាតដើម្បីចុះវត្តមានចូលរួមនៅទីស្នាក់ការ រ.ទ.ស.ភ ឬស្កេនដើម្បីចូលរួមតាមប្រព័ន្ធអនឡាញ និងទាញយកឯកសារមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ*

gms13.ppwsa.com.kh
Investor ID: XX777
Passcode: 7777

**INVITATION**
**The Board of Directors for the 8th Mandate**
has the honor to invite
Your Excellency, Lok Neak Oknha, Neak Oknha, Oknha, Ladies and Gentlemen, or the proxy of
XXXX XXXX holding Investor Identification No **XX777**
who owns PPWSA's ordinary shares of **0** , on May 30, 2025, to attend
**The 13th General Meeting of Shareholders of PPWSA**
to be held on **Monday, June 30, 2025, at 08:00 AM**
**at PPWSA's headquarters and via the online meeting (Zoom)**

***NOTE: Please kindly bring this invitation letter to register your attendance at PPWSA's headquarters or scan the QR code above to join the online meeting (Zoom) and download materials for the 13th General Meeting of Shareholders of PPWSA.***
*(Unofficial Translation)*

# គ.ការចុះឈ្មោះ

## ការចូលរួមតាមរយៈ Online

ចុចលើរូបទង់ជាតិដើម្បីជ្រើសរើសភាសាខ្មែរ ឬអង់គ្លេស។



# ក.ការចុះឈ្មោះ

## ការចូលរួមតាមរយៈ Online

វាយបញ្ចូល Passcode ទៅក្នុងប្រអប់លេខសម្ងាត់។



# គ.ការចុះឈ្មោះ

## ការចូលរួមតាមរយៈ Online

ចុចលើប៊ូតុង Submit ។



# គ.ការចុះឈ្មោះ

## ការចូលរួមតាមរយៈ Online

ផ្ទៀងផ្ទាត់ព័ត៌មានវិនិយោគិនផ្ទាល់ខ្លួនរបស់លោក-អ្នក។



# ក.ការចុះឈ្មោះ

## ការចូលរួមដោយផ្ទាល់

សូមបង្ហាញលិខិតអញ្ជើញរបស់លោក-អ្នក ទៅកាន់ភ្នាក់ងារទទួលភ្ញៀវនៅតាមបញ្ជរ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**លិខិតអញ្ជើញ**

**ក្រុមប្រឹក្សាភិបាល អាណត្តិទី៨**

មានកិត្តិយសសូមគោរពអញ្ជើញ
ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ឬអ្នកតំណាង
XXXX XXXX ដែលកាន់កាប់អត្តសញ្ញាណវិនិយោគិនលេខ XX777
ក្នុងនាមជាភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ ចំនួន 0 ភាគហ៊ុន
គិតត្រឹមថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
ដើម្បីចូលរួម

**មហាសន្និបាតភាគហ៊ុនិក លើកទី១៣ របស់ រ.ទ.ស.ភ**

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹង
**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥** ចាប់ពីវេលាម៉ោង ០៨:០០នាទីព្រឹក

**នៅទីស្នាក់ការ រ.ទ.ស.ភ និងតាមរយៈប្រព័ន្ធអនឡាញ (Zoom)**

*បញ្ជាក់៖ សូមមេត្តាយកលិខិតអញ្ជើញនេះមកជាមួយ នាថ្ងៃមហាសន្និបាតដើម្បីចុះវត្តមានចូលរួមនៅទីស្នាក់ការ រ.ទ.ស.ភ ឬស្កេនដើម្បីចូលរួមតាមប្រព័ន្ធអនឡាញ និងទាញយកឯកសារមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ*

gms13.ppwsa.com.kh
Investor ID: XX777
Passcode: 7777

**INVITATION**

**The Board of Directors for the 8th Mandate**

has the honor to invite
Your Excellency, Lok Neak Oknha, Neak Oknha, Oknha, Ladies and Gentlemen, or the proxy of
XXXX XXXX holding Investor Identification No **XX777**
who owns PPWSA's ordinary shares of **0**, on May 30, 2025, to attend
**The 13th General Meeting of Shareholders of PPWSA**
to be held on **Monday, June 30, 2025, at 08:00 AM**
**at PPWSA's headquarters and via the online meeting (Zoom)**

*NOTE: Please kindly bring this invitation letter to register your attendance at PPWSA's headquarters or scan the QR code above to join the online meeting (Zoom) and download materials for the 13th General Meeting of Shareholders of PPWSA.*
*(Unofficial Translation)*

## ខ.ការចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិក

លើទំព័រព័ត៌មានវិនិយោគិន ចុចប៊ូតុង Zoom ដើម្បីចូលរួមប្រជុំមហាសន្និបាតភាគហ៊ុនិកលើកទី១៣ ដោយតម្រូវឲ្យ លោក-អ្នក ដំឡើងកម្មវិធី Zoom ជាមុន។



# គ.ការបោះឆ្នោត

- ស្កេន QR Code ដែលមានក្នុងលិខិតអញ្ជើញ សម្រាប់ Smart Phone។
- ឬចូលទៅកាន់គេហទំព័រ http://gms13.ppwsa.com.kh/ សម្រាប់ Computer។
- លើទំព័រព័ត៌មានវិនិយោគិន ចុចប៊ូតុង Vote។



# គ.ការបោះឆ្នោត

- ចុចសញ្ញា ☑ លើជម្រើសក្នុងកម្មវត្ថុបោះឆ្នោតទាំង៥ ដែលលោក-អ្នកពេញចិត្ត។
- ចុចប៊ូតុង បោះឆ្នោត។



## គ.ការបោះឆ្នោត

- លោក-អ្នកអាចពិនិត្យសន្លឹកឆ្នោតដែលបានបោះរួច ដោយចុចប៊ូតុង ពិនិត្យសន្លឹកឆ្នោត។



# សូមអរគុណ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

# នីតិវិធីនៃការបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១៣

## ១) នីតិវិធីចុះឈ្មោះចូលរួមបោះឆ្នោត

ភាគហ៊ុនិកមានសិទ្ធិចូលរួមបោះឆ្នោតបាន លុះត្រាតែ ៖

១.១ បានបញ្ជាក់ការចូលរួមជាមួយ ធនាគារអេស៊ីលីដា។

១.២ បានចុះឈ្មោះចូលរួមមហាសន្និបាតតាមកម្មវិធីកំណត់ដូចមានក្នុងរបៀបវារៈ (ចាប់ផ្តើមពីម៉ោង៨:០០ព្រឹក ដល់ម៉ោង៩:០០ព្រឹក)។

## ២) នីតិវិធីបោះឆ្នោត

ដំណើរការនៃការបោះឆ្នោត ត្រូវប្រព្រឹត្តទៅតាមលំដាប់លំដោយដូចខាងក្រោម ៖

### ២.១ ការបោះឆ្នោត

ការបោះឆ្នោតត្រូវធ្វើឡើងតែមួយ(១)លើក និងមានប្រាំកម្មវត្ថុ ក្នុងនោះ៖

**២.១.១ កម្មវត្ថុទី១ : ការបោះឆ្នោតអនុម័តបែងចែកភាគលាភជូនភាគហ៊ុនិក**
កម្មវត្ថុនេះត្រូវបានចាត់ទុកថាបានទទួលការគាំទ្រ លុះត្រាតែទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ច្រើនជាងហាសិបភាគរយ(៥០%) ផ្ទុយទៅវិញត្រូវបានចាត់ទុកថា មិនបានទទួលការគាំទ្រ។

**២.១.២ កម្មវត្ថុទី២ : ការបោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល**
កម្មវត្ថុនេះត្រូវបានចាត់ទុកថាបានទទួលការគាំទ្រ លុះត្រាតែទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ច្រើនជាងហាសិបភាគរយ(៥០%) ផ្ទុយទៅវិញត្រូវបានចាត់ទុកថា មិនបានទទួលការគាំទ្រ។

**២.១.៣ កម្មវត្ថុទី៣ : ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលឯករាជ្យ**
កម្មវត្ថុនេះត្រូវបានចាត់ទុកថាបានទទួលការគាំទ្រ លុះត្រាតែទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ច្រើនជាងហាសិបភាគរយ(៥០%) ផ្ទុយទៅវិញត្រូវបានចាត់ទុកថា មិនបានទទួលការគាំទ្រ។

**២.១.៤ កម្មវត្ថុទី៤ : ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន**
កម្មវត្ថុនេះត្រូវបានចាត់ទុកថាបានទទួលការគាំទ្រ លុះត្រាតែទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ច្រើនជាងហាសិបភាគរយ(៥០%) ផ្ទុយទៅវិញត្រូវបានចាត់ទុកថា មិនបានទទួលការគាំទ្រ។

**២.១.៥ កម្មវត្ថុទី៥ : ការបោះឆ្នោតអនុម័តលើការបង្កើនដើមទុនរបស់ រ.ទ.ស.ភ**
កម្មវត្ថុនេះត្រូវបានចាត់ទុកថាបានទទួលការគាំទ្រ លុះត្រាតែទទួលបានសំឡេងបោះឆ្នោត "**គាំទ្រ**" ភាគច្រើន ២/៣ (ពីរភាគបី) ផ្ទុយទៅវិញត្រូវបានចាត់ទុកថា មិនបានទទួលការគាំទ្រ។

### ២.២ ដំណើរការនៃការបោះឆ្នោតចាប់ផ្តើមពីម៉ោង១០ និង៣០នាទី ដល់ម៉ោង១១ និង៣០នាទី។

### ២.៣ ការប្រកាសលទ្ធផលបោះឆ្នោត

លទ្ធផលនៃការបោះឆ្នោត នឹងត្រូវបង្ហាញជាក្រាហ្វិចដោយស្វ័យប្រវត្តិនៅក្នុងកិច្ចប្រជុំប្រព័ន្ធ Zoom ព្រមទាំងប្រកាសដោយអនុគណៈកម្មការទទួលបន្ទុកបោះឆ្នោត បន្ទាប់ពីដំណើរការបោះឆ្នោតត្រូវបានបញ្ចប់។

## ៣) កំណត់សម្គាល់នៅក្នុងនីតិវិធីបោះឆ្នោតមហាសន្និបាតភាគហ៊ុនិកលើកទី១៣

៣.១ មួយភាគហ៊ុន ស្មើនឹង "មួយសំឡេង" ។

៣.២ ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ត្រូវធ្វើឡើងដោយភាគហ៊ុនិកឯកជនតែប៉ុណ្ណោះ ដោយមិនអនុញ្ញាតឱ្យភាគហ៊ុនិកសាធារណៈចូលរួមបោះឆ្នោតឡើយ (យោងចំណុច ១០ "ខ"

នៃគោលការណ៍ណែនាំលេខ០០២/២២ ន.ម.ក/គ.ណ.ន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន របស់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ)។

៣.៣ ក្រៅពីកម្មវត្ថុបោះឆ្នោតដូចបញ្ជាក់ក្នុង**ចំណុច "៣.២"** ខាងលើ ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភ, ការបោះឆ្នោតអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល ,ការបោះឆ្នោតអនុម័តបន្តអាណត្តិជូនអភិបាលឯករាជ្ និងការបោះឆ្នោតអនុម័តលើការបង្កើនដើមទុនរបស់ រ.ទ.ស.ភ ត្រូវធ្វើឡើងដោយភាគហ៊ុនិកសាធារណៈ និងភាគហ៊ុនិកឯកជន ។

## ៤) ឯកសារយោងពាក់ព័ន្ធ

- លក្ខន្តិកៈរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២
- គោលការណ៍ណែនាំលេខ០០៥/២១ ន.ម.ក/គ.ណ.ន ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីមហាសន្និបាតភាគហ៊ុនិក សម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ
- គោលការណ៍ណែនាំលេខ០០២/២២ ន.ម.ក/គ.ណ.ន ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការជ្រើសតាំងអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន របស់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ
- សេចក្តីសម្រេចលេខ០០៨ ក្រប្រក/សសរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការអនុញ្ញាតឱ្យលើកសំណើសុំបន្តអាណត្តិជូនអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន ដើម្បីដាក់ជូនមហាសន្និបាតភាគហ៊ុនិកបោះឆ្នោតអនុម័តគាំទ្រ
- ប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។

## ៥) របៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣

សូមអនុវត្តតាមរបៀបចូលរួមមហាសន្និបាតភាគហ៊ុនិកលើកទី១៣ ដូចមានឯកសារជូនភ្ជាប់មកជាមួយ។

# ឧបសម្ព័ន្ធ ២

## ប្រវត្តិរូបអភិបាលឯករាជ្យ
## និងអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន
## ដែលនឹងត្រូវបោះឆ្នោតអនុម័តបន្តអាណត្តិ

# ប្រវត្តិរូបសង្ខេប
## របស់បេក្ខជនអភិបាលឯករាជ្យ



លោក : ស្រេង សំឱក
អាយុ : ៦៣ឆ្នាំ (ឆ្នាំកំណើត ១៩៦២)
សញ្ជាតិ : ខ្មែរ
មុខរបរបច្ចុប្បន្ន : ទីប្រឹក្សាធុរកិច្ច និងអភិបាលឯករាជ្យ
មុខរបរចុងក្រោយ : អ្នកគ្រប់គ្រងជាន់ខ្ពស់
សមាជិកភាព : គ្មាន

ខ្លឹមសារសង្ខេបនៃប្រវត្តិរូប (ការសិក្សានិងបទពិសោធន៍ការងារ):

លោក ស្រេង សំឱក បានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពីសាកលវិទ្យាល័យ West Coast University នៃរដ្ឋកាលីហ្វ័រញ៉ា (១៩៩៤) និងបរិញ្ញាបត្រវិទ្យាសាស្ត្រផ្នែកវិស្វកម្មអគ្គិសនី (១៩៨៨) ពីសាកលវិទ្យាល័យ California State University of Long Beach នៃសហរដ្ឋអាមេរិក។

លោក ស្រេង សំឱក ជាទីប្រឹក្សាធុរកិច្ចនៅក្រុមហ៊ុន Axis Investment Consulting Co. Ltd. នៅកម្ពុជា។ លោកផ្តល់សេវាកម្មប្រឹក្សាធុរកិច្ចលើផ្នែកនៃការគ្រប់គ្រងទូទៅ យុទ្ធសាស្ត្រ ប្រតិបត្តិការ ហិរញ្ញវត្ថុ ការលក់និងទីផ្សារ ការអភិវឌ្ឍន៍អាជីវកម្មថ្មី និងធនធានមនុស្សដល់ក្រុមហ៊ុន និងអង្គការក្នុងស្រុក និងពហុជាតិក្នុងប្រទេសកម្ពុជា។ លោកក៏មានតួនាទីជាអភិបាលឯករាជ្យ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC) ផងដែរ។ ក្នុងនាមជាប្រធានគណៈកម្មាធិការសវនកម្មរបស់ក្រុមប្រឹក្សាភិបាលនៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ លោកបានចូលរួមចំណែក និងជួយអង្គភាពសវនកម្មផ្ទៃក្នុង កែលម្អប្រព័ន្ធរាយការណ៍របស់ខ្លួន និងបានធ្វើការណែនាំ ដើម្បីជួយអភិវឌ្ឍអង្គភាពសវនកម្មផ្ទៃក្នុងឱ្យក្លាយជាអង្គការវិជ្ជាជីវៈ។ គាត់បានបង្ហាញពីជំហរឯករាជ្យភាពរបស់គាត់ ក្នុងការធ្វើការសម្រេចចិត្ត និងបាននាំយកទស្សនវិស័យឯកជនមកក្រុមប្រឹក្សាភិបាល។

ក្នុងអាជីពដែលមានរយៈពេលជាង២០ឆ្នាំ លោកបានកាន់តួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងវិស័យផ្សេងៗគ្នា រួមមានហិរញ្ញវត្ថុនិងធនាគារ គ្រប់គ្រងអាជីវកម្មក្នុងព្រលានយន្តហោះ ការងារអភិវឌ្ឍន៍ និងលើទំនិញប្រើប្រាស់រហ័ស (FMCG) នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងអាជីពការងារ លោកបានទទួលពានរង្វាន់ជាច្រើនសម្រាប់ការដឹកនាំដ៏រឹងមាំ និងសមិទ្ធិផលឆ្នើមពីស្ថាប័ន ដែលលោកបានធ្វើការ។ លោកធ្លាប់មានតួនាទីជាប្រធានគណៈកម្មាធិការសវនកម្ម ប្រធានគណៈកម្មាធិការតែងតាំងនិងកំណត់ប្រាក់ឈ្នួល សមាជិកគណៈកម្មាធិការត្រួតពិនិត្យហានិភ័យ និងជាសមាជិកក្រុមប្រឹក្សា អភិបាលឯករាជ្យ នៅអម្រឹត ភីអិលស៊ី (Amret Plc.)។ វិភាគទានរបស់គាត់បានជួយប្រែក្លាយ អម្រឹត ភីអិលស៊ី ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមាននិរន្តរភាពបំផុត និងឈានមុខគេមួយនៅក្នុងប្រទេស។

បទពិសោធន៍គ្រប់គ្រងចម្រុះ និងប្រវត្តិអប់រំរឹងមាំរបស់គាត់ គឺជាទ្រព្យសម្បត្តិដ៏មានតម្លៃសម្រាប់ស្ថាប័នដែលគាត់បានចូលរួម។ ជាមួយនឹងចំណេះដ៏ជ្រាលជ្រៅអំពីវិស័យហិរញ្ញវត្ថុ និងបរិយាកាសទីផ្សារក្នុងប្រទេសកម្ពុជា លោកបានដើរតួយ៉ាងសំខាន់ ក្នុងការចាប់ផ្តើមបង្កើតធនាគារ (ANZ Royal) ដំបូងក្នុងប្រទេស ដោយទទួលខុសត្រូវលើការពង្រីកបណ្តាញសាខាទាំងនៅធនាគារ ANZ Royal និងធនាគារពាណិជ្ជកម្មក្រៅប្រទេសនៅកម្ពុជា FTB ។ បន្ថែមពីលើការគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម លោកទទួលបន្ទុកលើផែនការរួម និងអនុវត្តការពង្រីកសាខា ដែលរួមមានការរៀបចំទីតាំង ការរៀបចំប្រព័ន្ធនិងនីតិវិធី និងការជ្រើសរើសបុគ្គលិកសំខាន់ៗ។ លោកក៏បានធ្វើការនៅក្នុងគម្រោងទូទាត់ប្រាក់តាមទូរស័ព្ទ

លើកដំបូង ក្នុងអំឡុងពេលចាប់ផ្តើមជានាយកផ្នែកលក់និងទីផ្សារ នៅ WING (Cambodia) Ltd. ដែលឥឡូវនេះបានប្រែក្លាយខ្លួនទៅជាអ្នកផ្តល់សេវាទូទាត់ប្រាក់តាមទូរស័ព្ទដ៏ធំបំផុត និងជាធនាគារឯកទេសក្នុងប្រទេសកម្ពុជាដែលផ្តល់សេវាហិរញ្ញវត្ថុដល់ប្រជាជនដែលមិនមានធនាគារ និងបង្កើនការចូលរួមប្រើប្រាស់សេវាហិរញ្ញវត្ថុនៅក្នុងតំបន់ជនបទ។

លោក ស្រេង សំឌិក ក៏បានបម្រើការជានាយកពាណិជ្ជកម្មនៅអាកាសយានដ្ឋានកម្ពុជា (ភ្នំពេញ សៀមរាប និងព្រះសីហនុ)។ ក្នុងចំណោមសមិទ្ធផលជាច្រើន គាត់បានទទួលខុសត្រូវចំពោះការចរចាដ៏ជោគជ័យជាមួយក្រុមហ៊ុន Air France ដើម្បីបន្តការហោះហើរត្រង់មកកម្ពុជាវិញ (ក្នុងឆ្នាំ២០១១) និងធ្វើឱ្យក្រុមហ៊ុនអាកាសចរណ៍បញ្ចូលពន្ធព្រលានយន្តហោះ ទៅក្នុងសំបុត្រជំនួសឱ្យការបង់នៅបញ្ជរពន្ធមុនពេលចេញដំណើរ។

គាត់ក៏បានធ្វើការជាមន្ត្រីវិនិយោគជាមួយ Mekong Project Development Facility (MPDF) ដែលជាផ្នែកមួយនៃគម្រោងហិរញ្ញវត្ថុអន្តរជាតិ IFC ។ គាត់បានជួយសហគ្រាសធុនតូច និងមធ្យម ដើម្បីទទួលបានហិរញ្ញប្បទាន និងជំនាញអាជីវកម្មចាំបាច់ ដោយជ្រើសរើស និងគ្រប់គ្រងទីប្រឹក្សា ឱ្យមកធ្វើការជាមួយសហគ្រាស ដើម្បីពង្រឹងអាជីវកម្មរបស់ពួកគេ និងធានានិរន្តរភាព។

ក្នុងអាជីពដំបូងរបស់គាត់ គាត់បានបម្រើការជាប្រធានផ្នែកលក់ប្រចាំប្រទេសនៃក្រុមហ៊ុនភេសជ្ជៈកម្ពុជា (កូកា-កូឡា) ដែលគាត់ទទួលខុសត្រូវលើមុខងារចែកចាយ លក់ និងទីផ្សារសម្រាប់ប្រទេសកម្ពុជាទាំងមូល។ ក្រោមការដឹកនាំរបស់គាត់ កូកា-កូឡា ទទួលបានចំណែកទីផ្សារធំជាងគេនៅក្នុងទីផ្សារកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥
ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**



# ជីវប្រវត្តិសង្ខេប

**លោក ណាំ ចន្ទ្រី** ជាជនជាតិខ្មែរដែលមានបទពិសោធន៍ការងារជាង១៧ឆ្នាំនៅក្នុងវិស័យជាច្រើន។ លោកបាននឹងកំពុងបម្រើការងារជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជននៃ រ.ទ.ស.ភ ហើយបច្ចុប្បន្នលោកក៏មានតួនាទីជាភ្នាក់ងារគ្រប់គ្រងមូលនិធិឯកជននៅក្រុមហ៊ុន អូបរ ដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករមូលបត្រកម្ពុជា។ លោកបាននឹងកំពុងជួយគាំទ្រមូលនិធិ២ធំៗមានដូចជា OBOR Capital និង AXS Ventures ដោយផ្តោតលើការវិនិយោគលើគម្រោងចំនួន៧នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្នុងរយៈពេល៣ឆ្នាំនៃការកាន់តំណែងជាអភិបាលមិនប្រតិបត្តិតំណាងភាហ៊ុនិកឯកជននៃ រ.ទ.ស.ភ លោក ណាំ ចន្ទ្រី បានចូលរួមយ៉ាងសកម្មជាមួយក្រុមប្រឹក្សាភិបាលក្នុងការដឹកនាំ ពិនិត្យ តម្រង់ទិស និងផ្តល់ជាធាតុចូលក្នុងការអនុវត្តផែនការអាជីវកម្ម ដោយឈរលើស្មារតី និងសម្លេងឯករាជ្យនៃតំណាងភាហ៊ុនិកឯកជន។ បន្ថែមពីនេះលោកបានចូលរួមអនុម័តលើគោលនយោបាយ និតិវិធីអនុវត្ត ផែនការយុទ្ធសាស្ត្រ រួមទាំងតាមដាននូវការអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីធានាបានថាក្រុមប្រឹក្សាភិបាលមានប្រសិទ្ធិភាពក្នុងការដឹកនាំ និងសម្រេចនូវគោលដៅរួមរបស់ រ.ទ.ស.ភ ព្រមទាំងផ្តល់នូវទស្សនវិស័យស្តីពីប្រសិទ្ធភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក។ លោក ណាំ ចន្ទ្រី ក៏ជាសមាជិកគណៈកម្មាធិការសវនកម្មផ្ទៃក្នុងនៃ រ.ទ.ស.ភ ដែលកន្លងមក លោកបានចូលរួមដឹកនាំអង្គភាពនេះឱ្យកាន់តែមានភាពល្អប្រសើរដូចជា៖ ពង្រឹងគុណភាពធនធានមនុស្ស ពង្រឹងការងារត្រួតពិនិត្យផ្ទៃក្នុងឱ្យត្រូវតាមច្បាប់ដែលកំណត់ ណែនាំ បង្រៀន ចែករម្លែកបទពិសោធន៍ និងគាំទ្រជម្រុញស្មារតីនៃអង្គភាពសវនកម្មផ្ទៃក្នុងដើម្បីជួយក្រុមប្រឹក្សាភិបាលក្នុងការត្រួតពិនិត្យ វិភាគហានិភ័យ និងធ្វើការជាមួយសវនករឯករាជ្យដើម្បីធានាបាននូវរបាយការណ៍សវនកម្មដែលគ្រប់ជ្រុងជ្រោយ ស្របតាមច្បាប់ បទបញ្ញាតិ និងមានគណនេយ្យភាពចំពោះភាគហ៊ុនិក។

លោក ណាំ ចន្ទ្រី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ-ហិរញ្ញវត្ថុ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុនៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រវិទ្យាសាស្រសេដ្ឋកិច្ច។ លោកមានបទពិសោធន៏ ចំណេះ និងជំនាញផ្នែកទីផ្សារមូលធន និងបានចូលរួមជួយសហគ្រាសធនតូច និងមធ្យមជាច្រើនក្នុងការគៀរគរទុនដើម្បីពង្រីកអាជីវកម្ម លើសពីនេះលោកបានជួយគាំទ្ររៀបចំបណ្តុះបណ្តាលអ្នកវិនិយោគក្នុងស្រុកឱ្យក្លាយជាអ្នកវិនិយោគដែលមានវិជ្ជាជីវៈ។

ជាមួយនិងបទពិសោធន៍ចម្រុះរបស់លោក ណាំ ចន្ទ្រី ដែលបានគ្របដណ្តប់លើវិស័យជាច្រើនរួមមាន៖ ក្រុមហ៊ុនផលិត និងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ក្រុមហ៊ុនគ្រប់គ្រងសំរាម ក្រុមហ៊ុនពាណិជ្ជកម្មអេឡិចត្រូនិច ក្រុមហ៊ុនដឹកជញ្ជូន ក្រុមហ៊ុនកសិកម្ម-អាហារ និងក្រុមហ៊ុននាំចេញកសិផលជាដើម លោកជាធនធានមនុស្សមួយដែលល្អ និងមានសក្តានុពលសម្រាប់កម្ពុជា ក៏ដូចជាសម្រាប់ រ.ទ.ស.ភ ផងដែរ។ លោកមានការសហការយ៉ាងល្អជាមួយស្ថាប័នជាច្រើនក្នុងការអនុវត្តគម្រោងដូចជា៖ សហគ្រិនខ្មែរ (Khmer Enterprise) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាកបាទក្រហមកម្ពុជា កាកបាទក្រហមស្វីស និងគណៈកម្មាធិការជាតិអភិវឌ្ឍន៍ប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាដើម និងដៃគូរអភិវឌ្ឍន៍មួយចំនួនផងដែរ។

រាជធានី ភ្នំពេញ, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥

**ហត្ថលេខា**

**ណាំ ចន្ទ្រី**

# ឧបសម្ព័ន្ធ ៣

## លិខិតតែងតាំងអាណត្តិគាហកៈ ( អ្នកតំណាង )

# លិខិតតែងតាំងអាណត្តិគាហកៈ (អ្នកតំណាង)
# Proxy Letter

ធ្វើនៅ ........................................
Written at

ថ្ងៃ.................... ខែ.................... ឆ្នាំ...............
Date Month Year

**លេខអត្តសញ្ញាណវិនិយោគិនចេញដោយគណៈកម្មការមូលបត្រកម្ពុជា ឬនិយ័តករមូលបត្រកម្ពុជា**........................................
Investor ID number issued by Securities and Exchange Commission of Cambodia or Securities and Exchange Regulator of Cambodia

- ☐ រូបវន្តបុគ្គល / Individual
- ☐ នីតិបុគ្គល / Legal Person

ខ្ញុំ/យើងខ្ញុំ........................................ សញ្ជាតិ....................
I / We Nationality

មានអាសយដ្ឋានលេខ.................... ផ្លូវ.................... ឃុំ/សង្កាត់....................
address no. Street Commune/Sangkat

ស្រុក/ក្រុង/ខណ្ឌ.................... ខេត្ត/រាជធានី.................... ប្រទេស....................
District/Town/Khan Province/Capital Country

គឺជាភាគហ៊ុនិករបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ("រ.ទ.ស.ភ") **នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥** (កាលបរិច្ឆេទកំណត់ទុក) កាន់កាប់
am/are a shareholder of Phnom Penh Water Supply Authority ("PPWSA") on **MAY 30, 2025** (Record Date ), holding

ភាគហ៊ុនធម្មតាសរុបចំនួន....................ភាគហ៊ុនមានសិទ្ធិចូលរួម និងបោះឆ្នោតក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ របស់ រ.ទ.ស.ភ
the total number of ordinary share share(s) entitled to attend and vote in the 13th General Meeting of Shareholders of PPWSA.

**តែងតាំង**
**hereby appoint**

ឈ្មោះ........................................ ភេទ.......... អាយុ.......... ឆ្នាំ សញ្ជាតិ....................
Name Gender Age Year Nationality

កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ.................... មានអាសយដ្ឋានលេខ.......... ផ្លូវ....................
holding identity card or passport number address no. Street

ឃុំ/សង្កាត់.................... ស្រុក/ក្រុង/ខណ្ឌ....................
Commune/Sangkat District/Town/Khan

ខេត្ត/រាជធានី.................... ប្រទេស....................
Province/Capital Country

ជាអាណត្តិគាហកៈរបស់ ខ្ញុំ/យើងខ្ញុំ ដើម្បីចូលរួម និងបោះឆ្នោតក្នុងនាម ខ្ញុំ/យើងខ្ញុំ ក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ០៨:០០ព្រឹក ☐ នៅទីស្នាក់ការ រ.ទ.ស.ភ ឬ ☐ តាមប្រព័ន្ធអនឡាញ(ZOOM) ឬកាលបរិច្ឆេទ ពេលវេលា ទីកន្លែង ឬទម្រង់អនឡាញណាមួយ ដែលមហាសន្និបាតភាគហ៊ុនិកលើកទី១៣ នេះអាចប្រព្រឹត្តទៅ។ រាល់សកម្មភាពទាំងឡាយរបស់អាណត្តិគាហកៈខាងលើ នៅក្នុងមហាសន្និបាតភាគហ៊ុនិកលើកទី១៣ គឺជាសកម្មភាពស្របច្បាប់តំណាងឱ្យ ខ្ញុំ/យើងខ្ញុំ ដែលជាភាគហ៊ុនិករបស់ រ.ទ.ស.ភ។
As my/our proxy to attend and vote on my/our behalf at the 13th General Meeting of Shareholders to be held on Monday, June 30, 2025 at 08:00AM ☐ at PPWSA headquarters or ☐ through an online meeting (ZOOM) or such other date, time and place or other online platforms as this 13th General Meeting of Shareholders may be held. Any act performed by the above proxy in this 13th General Meeting of Shareholders shall be the legal actions performed by myself/ourselves as PPWSA's shareholder.

| | |
|---|---|
| **ហត្ថលេខា ត្រា[1] និងឈ្មោះភាគហ៊ុនិក** | **ហត្ថលេខា និងឈ្មោះអាណត្តិគាហកៈ** |
| **Signature Stamp[1] and Name of shareholder** | **Signature and Name of the proxy** |

*[1] ក្នុងករណីភាគហ៊ុនិកជាស្ថាប័ន*
*In case of the institutional shareholder*

*Unofficial Translation*

# ឧបសម្ព័ន្ធ ៤

## របាយការណ៍ប្រចាំឆ្នាំ ២០២៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



# របាយការណ៍ប្រចាំឆ្នាំ២០២៤

**គោលដៅយុទ្ធសាស្រ្តចម្បងរបស់ រ.ទ.ស.ភ មានដូចខាងក្រោម៖**

ពង្រីកការផ្គត់ផ្គង់ទឹកទៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដារដូចគ្នានៅក្នុងរាជធានីភ្នំពេញ។ វិភាគថ្លៃដើម និងកំណែទម្រង់ដំណើការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក បង្កើនប្រសិទ្ធិភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស។ តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និង បរិស្ថាន។ ប្រៀបធៀបបែបយុទ្ធសាស្រ្តជាមួយបណ្តាអង្គភាពទឹកស្អាតនានា ដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក។


លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ: (៨៥៥)៣១ ៩៣៥ ០៨ ០៨
(៨៥៥)៣១ ៦២៥ ០៧ ០៧

អ៊ីម៉ែល:
ir@ppwsa.com.kh

# ទស្សនវិស័យ
# និងបេសកកម្ម

## ទស្សនវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឱ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួលដើម្បីឱ្យប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោក មានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺជានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោង លើ ២៤ម៉ោង ក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ។ ក្រៅពីនេះ រ.ទ.ស.ភ បាននឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួន ដល់បណ្តារដ្ឋាករទឹកខេត្ត-ក្រុងមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជាព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោក តាមសំណូមពរសំដៅសម្រេចអោយបាននូវ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (CSDGs)។

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ (កំណត់ឡើងវិញ) | ឆ្នាំ២០២២ (កំណត់ឡើងវិញ) |
|---|---|---|---|
| ទ្រព្យសកម្មសរុប(ពាន់រៀល) | ៣.២៧៩.១៦៥.២៨១ | ៣.០៣៨.៣៦៥.១៧៧ | ២.៦២៣.៤០៥.១៩៨ |
| បំណុលសរុប(ពាន់រៀល) | ១.៩១៤.០៩២.៦៦៨ | ១.៧៥៣.៧៦៩.៣៨៦ | ១.៤០៧.១៥១.៨២១ |
| មូលធនសរុប(ពាន់រៀល) | ១.៣៦៥.០៧២.៦១៣ | ១.២៨៤.៥៩៥.៧៩១ | ១.២១៦.២៥៣.៣៧៧ |

| លទ្ធផលហិរញ្ញវត្ថុ | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ (កំណត់ឡើងវិញ) | ឆ្នាំ២០២២ |
|---|---|---|---|
| ចំណូលសរុប(ពាន់រៀល) | ៣៤៧.៦៩៧.៧៧៨ | ៣៣៣.៤០៨.៨៣០ | ៣៤៧.២៨៣.៨៥៦ |
| ចំណេញមុនបង់ពន្ធប្រាក់ចំណេញ(ពាន់រៀល) | ១០៧.១៧៤.៣៦១ | ៩៨.៩៣៨.០៤៧ | ១៣០.៥១៥.៨៩២ |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ | ១០៨.១៨៥.៨៦៥ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ(ពាន់រៀល) | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ | ១០៨.១៨៥.៨៦៥ |

| អនុបាតហិរញ្ញវត្ថុ | | ឆ្នាំ២០២៤ | ឆ្នាំ២០២៣ (កំណត់ឡើងវិញ) | ឆ្នាំ២០២២ (កំណត់ឡើងវិញ) |
|---|---|---|---|---|
| អនុបាតសាធនភាព | | | | |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត(ចំនួនដង) | ០,៣៨ | ០,៧៦ | ២,០៨ |
| | អនុបាតចរន្តលឿន(ចំនួនដង) | ០,១៨ | ០,៣៨ | ១,៣២ |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ២,៦៩ | ២,៥៧ | ៤,៣៩ |
| | អនុបាតចំណេញធៀបនឹងមូលធន (ភាគរយ) | ៦,៤២ | ៥,៨១ | ៩,០៨ |
| | អនុបាតគម្លាតចំណេញដុល (ភាគរយ) | ២៥,៦០ | ២៥,៧២ | ៣៧,២៨ |
| | អនុបាតគម្លាតចំណេញភាព (ភាគរយ) | ២៤,៤៦ | ២១,៧៩ | ៣១,១៥ |
| | ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៩៧៧,៨១ | ៨៣៥,២៩ | ១.២៤៣,៩០ |
| អនុបាតលទ្ធភាពសងការប្រាក់ (ចំនួនដង) | | ២,២៨ | ៣,៣២ | ៣៥,៨៦ |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប

## បម្រែបម្រួលតម្លៃភាគហ៊ុន (គិតជារៀល) និងទំហំជួញដូរ




## ប្រាក់ចំណេញតាមបណ្ដាឆ្នាំនីមួយៗ (លានរៀល)




## ប្រាក់ចំណេញសម្រាប់ឆ្នាំ២០២៤ (លានរៀល)



# សមាសភាព
# ក្រុមប្រឹក្សាភិបាល



**ឯកឧត្តម ឯក សុនចាន់**
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
**ប្រធានក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឡុង ណារ៉ូ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
អគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ម៉ី វ៉ាន់**
រដ្ឋលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សមាជិកក្រុមប្រឹក្សាភិបាល**



**ឯកឧត្តម ឆាយ ធីរៈ**
អភិបាលរង
នៃគណៈអភិបាលរាជធានីភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ម៉ា ណូរ៉ាវីន**
តំណាងនិយោជិត
នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ណាំ ចន្ទ្រី**
អភិបាលមិនប្រតិបត្តិតំណាង
ភាគហ៊ុនិកឯកជន

**សមាជិកក្រុមប្រឹក្សាភិបាល**



**លោក ស្រេង សំឌិក**
អភិបាលឯករាជ្យ

**សមាជិកក្រុមប្រឹក្សាភិបាល**

# សេចក្តីថ្លែង
# របស់ប្រធានក្រុមប្រឹក្សាភិបាល
## ក្នុងឆ្នាំ២០២៤ នេះ



**ឯកឧត្តម ឯក សុនចាន់**
រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
**ប្រធានក្រុមប្រឹក្សាភិបាល**

" ក្រោមការដឹកនាំគាំទ្ររបស់ក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលប្រកាន់ខ្ជាប់នូវភារកិច្ចរបស់ខ្លួនក្នុងការដឹកនាំចង្អុលបង្ហាញគណៈគ្រប់គ្រងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឱ្យយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្ត សមត្ថភាព និងធនធាន ដើម្បីបំពេញភារកិច្ចក្នុងការផ្គត់ផ្គង់ទឹកស្អាតដែលមាន "**គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ**" ជូនប្រជាជនដែលកំពុងរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។ "

ក្នុងឆ្នាំ២០២៤ នេះ រ.ទ.ស.ភ ផលិតទឹកស្អាតបាន ៣១២.៩៥១.៨៦២ម$^{៣}$, តបណ្តាញជូនអតិថិជនបានចំនួន ២៨.៨៩៩បណ្តាញ ក្នុងនោះអតិថិជនចំណូលទាបមានចំនួន ២.៥៩២បណ្តាញ និងលក់ទឹកបានចំនួន ២២៧.៨១៣.៣៤៨ម$^{៣}$។ ម្យ៉ាងទៀត ប្រាក់ចំណូលសរុបបានកើនឡើងចំនួន ១៤.២៨៨.៩៤៨.០០០រៀល ស្មើនឹង ៤,២៩% និងចំណេញពិតកើនឡើងចំនួន ១២.៣៩៥.៣៤១.០០០រៀល ស្មើនឹង ១៧,០៦% បើធៀបនឹងឆ្នាំ២០២៣។

ជាមួយគ្នានេះ ផ្អែកតាមផែនការមេដំណាក់កាលទី៣ (២០២១-២០៣០) រ.ទ.ស.ភ គ្រោងនឹងបង្កើនសមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតរបស់ខ្លួនរហូតដល់ ១.៤៨៨.០០០ម$^{៣}$/ថ្ងៃ នៅឆ្នាំ២០៣០ ខណៈសមត្ថភាពបច្ចុប្បន្នមានត្រឹមតែ ១.០០០.០០០ម$^{៣}$/ថ្ងៃ តាមរយៈការវិនិយោគលើការសាងសង់រោងចក្រផលិតទឹកស្អាតបន្ថែមចំនួន៤គម្រោង ជាមួយនឹងការពង្រីកបណ្តាញមេនាំទឹក និងចែកចាយទឹកប្រវែង ២.១៣០គ.ម បន្ថែមពីលើប្រវែងបណ្តាញដែលមានស្រាប់ (៥.២៨៤គ.ម)។

ជាងនេះទៀត ក្នុងគោលបំណងឈានទៅសម្រេចគោលដៅទី៦ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅឱ្យបាន១០០% រ.ទ.ស.ភ នឹងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ រួមមានទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA), ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD), ធនាគារវិនិយោគអឺរ៉ុប (EIB), សហគមន៍អឺរ៉ុប (EU) និង Korea Eximbank ជាដើម ដើម្បីធ្វើការវិនិយោគទៅលើប្រព័ន្ធផលិតកម្ម និងប្រព័ន្ធចែកចាយទឹក ព្រមទាំងបំពាក់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការគ្រប់គ្រងទឹកគ្មានចំណូលឱ្យបានទាបបំផុតតាមដែលអាចធ្វើទៅបាន, ធ្វើទំនើបកម្ម និងប្រើប្រាស់ប្រព័ន្ធនវានុវត្តន៍ក្នុងការគ្រប់គ្រងការងារអាជីវកម្ម និងការផ្តល់សេវាគ្រប់បែបយ៉ាងពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត ដែលជួយសម្រួល និងផ្តល់ភាពកក់ក្តៅបំផុតដល់អតិថិជនគ្រប់ៗរូប។

សម្រាប់ឆ្នាំ២០២៥ រ.ទ.ស.ភ គ្រោងផលិតទឹកស្អាត ៣១៧.០៥០.០០០ម$^{៣}$, តបណ្តាញជូនអតិថិជនចំនួន ៣០.០០០បណ្តាញ និងលក់ទឹកឱ្យបានចំនួន ២៥៣.៦៣៩.៨០០ម$^{៣}$ ព្រមទាំងគ្រោងរកចំណូលសរុបឱ្យបានចំនួន ៤៣០.៧០៥.៨៣១.០០០រៀល និងគ្រោងចំណាយសរុបចំនួន ៣២៩.២១៣.៤៧៩.០០០រៀល។

ជាទីបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងមន្ត្រី-និយោជិតនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ យើងខ្ញុំសូមប្តេជ្ញាយកអស់ប្រាជ្ញាស្មារតី កម្លាំងកាយ កម្លាំងចិត្ត បំពេញភារកិច្ចដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបម្រើអតិថិជន ដោយខិតខំផ្គត់ផ្គង់ទឹកដែលមានគុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ឱ្យសមទៅនឹងទំនុកចិត្តរបស់ថ្នាក់ដឹកនាំនៃក្រសួងអាណាព្យាបាលទាំងពីរ។ ទន្ទឹមគ្នានេះដែរ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់ព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរជ័យជូនចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងរាជរដ្ឋាភិបាល ព្រមទាំងប្រជាជនកម្ពុជាទាំងអស់ សមប្រកបតែនឹងពុទ្ធពរទាំង៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ៧កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២៥

**ជ. ប្រធានក្រុមប្រឹក្សាភិបាល**
**អគ្គនាយក**

**ឡុង ណារ៉ូ**

# សេចក្ដីថ្លែងរបស់អគ្គនាយក




**ឯកឧត្តម ឡុង ណារ៉ូ**
អគ្គនាយក

## សមិទ្ធិផលសម្រេចបាន ក្នុងឆ្នាំ២០២៤

" តាងនាម រ.ទ.ស.ភ ខ្ញុំមានកិត្តិយសនិងក្ដីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២៤ និងរបាយការណ៍ហិរញ្ញវត្ថុ របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ រ.ទ.ស.ភ បានកត់ត្រានូវរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២៤ នេះ ដោយទទួលបានចំណូលសរុបចំនួនប្រមាណ ៣៤៨ប៊ីលានរៀល និងចំណេញមុនបង់ពន្ធលើប្រាក់ចំណូលចំនួនប្រមាណ ១០៧ប៊ីលានរៀល និងលទ្ធផលលម្អិតសរុបរបស់ភាគហ៊ុនិកចំនួនប្រមាណ ៨៥ប៊ីលានរៀល។ "

### សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០២៤

ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាល ក្រសួងអាណាព្យាបាល និង ក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងឆ្នាំនេះ រ.ទ.ស.ភ នៅតែមានការរីកចំរើនយ៉ាងខ្លាំងក្លា ដោយការគ្រប់គ្រងហានិភ័យបានល្អប្រសើរបានប្រើប្រាស់ នូវធនធានហិរញ្ញវត្ថុមានប្រសិទ្ធភាពខ្ពស់ និងគ្រប់គ្រងការចំណាយបានយ៉ាងហ្មត់ចត់ ជាពិសេសដោយការយកចិត្ត ទុកដាក់ខ្ពស់លើការកាត់បន្ថយអត្រាទឹកគ្មានចំណូល។ ទោះបីសកម្មភាពជួសជុលនិងពង្រីកថ្នល់ទូទាំងរាជធានីភ្នំពេញ ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្ដាលឱ្យមានការលេចធ្លាយបំពង់ទឹក ដូចបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យរួច ក៏នៅក្នុងឆ្នាំ២០២៤ នេះ រ.ទ.ស.ភ ទទួលបានចំណូលសរុបចំនួន ៣៤៧.៦៩៧.៧៧៨.០០០រៀល ហើយប្រាក់ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញមានចំនួន ១០៧.១៧៤.៣៦១.០០០រៀល និងប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ភាគហ៊ុនិកមានចំនួន ៩៧៧,៨១រៀល។ នាចុងការិយបរិច្ឆេទនេះទ្រព្យសកម្មសរុបបានកើនឡើងរហូតដល់ចំនួន ៣.២៧៩.១៦៥.២៨១.០០០រៀល ចំណែកឯដើមទុនវិញបានកើនឡើងរហូតដល់ចំនួន ១.៣៦៥.០៧២.៦១៣.០០០រៀល។ ការកាត់បន្ថយទឹកគ្មានចំណូលជាកត្តាស្លាប់-រស់ របស់ រ.ទ.ស.ភ ក្នុងដំណើរការប្រព្រឹត្តកម្មនិងអាជីវកម្មរបស់ខ្លួន។ ជាមួយគ្នានេះដែរ ដើម្បីសម្របទៅតាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្នដែលធ្វើឱ្យយើងនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ ដែលអាចបង្កលក្ខណៈឱ្យយើងមានទឹកស្អាតសម្រាប់ផ្គត់ផ្គង់ និងអាចផឹកបានពីក្បាលរ៉ូប៊ីណេដល់រាប់ម៉ឺនគ្រួសាររួមទាំងគ្រួសារមានចំណូលទាបក្នុងតម្លៃមួយដ៏សមរម្យ ដើម្បីចូលរួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ រ.ទ.ស.ភ មានសមត្ថភាពផ្គត់ផ្គង់ទឹក ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្ដាហ៍ ដោយក្នុងឆ្នាំនេះអាចធ្វើការផលិតទឹកស្អាតបានចំនួន ៣១២.៩៥១.៨៦២ម³ ។

ការធ្វើប្រព្រឹត្តកម្មទឹកស្អាត គឺគោរពតាមស្តង់ដារគុណភាពទឹកជាតិ និងអង្គការសុខភាពពិភពលោក(WHO) ដោយមានបន្ទប់ពិសោធន៍គុណភាពទឹកអាចវិភាគបាន៥៣មុខ ជាមួយគ្នានេះយើងតែងតែបានធ្វើការវិភាគគុណភាពទឹក ពីមន្ទីរពិសោធន៍ ក្រៅប្រទេស(មន្ទីរពិសោធន៍ សិង្ហបុរី និងសៀងហៃ) ផងដែរ។ ការយកចិត្តទុកដាក់លើគុណភាពទឹកនេះធ្វើ

ឱ្យ រ.ទ.ស.ភ អាចជានាជូនអតិថិជនបាននូវការផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីចូលរួមចំណែកក្នុងការទទួលខុសត្រូវចំពោះសង្គមក្នុងគោលដៅជំរុញឱ្យប្រជាជនគ្រប់រូបមានទឹកស្អាតប្រើប្រាស់ ដែលជាកម្មវិធីទឹកស្អាតសម្រាប់ទាំងអស់គ្នា (Water for All) ដោយមានសេវាអនាម័យត្រឹមត្រូវ ដើម្បីការរស់នៅប្រកបដោយសុខមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ។

ទិសដៅនៃការពង្រីកបណ្ដាញចែកចាយទឹក គឺទៅតំបន់មានសក្ដានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាប ដោយក្នុងឆ្នាំ២០២៤ នេះ រ.ទ.ស.ភ ដាក់បំពង់បានប្រវែង ៥៦២.៥០៨,២៩ម៉ែត្រ ដែលធ្វើឱ្យប្រវែងបំពង់មេ និងបំពង់ចែកចាយទឹកបច្ចុប្បន្នសរុបស្មើនឹងប្រមាណ ៥.២៨៤គីឡូម៉ែត្រ និងរក្សាសម្ពាធជាមធ្យម២០ម៉ែត្រក្នុងបណ្ដាញចែកចាយទឹកទាំងមូល ដែលបំពង់ចាប់ពីទំហំ៩០ម.ម ដល់ទំហំ១.៦០០ម.ម ដោយ រ.ទ.ស.ភ បានធ្វើការដាក់ដោយខ្លួនឯង។យើងបានខិតខំធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាព សេវាអតិថិជនដើម្បីស្វែងរក និងបង្កើនចំនួនអតិថិជនធំៗដែលមានតម្រូវការទឹកច្រើន ដើម្បីជានាបាននូវប្រសិទ្ធភាពនៃការប្រមូលប្រាក់ថ្លៃទឹកដែលអត្រាទារប្រាក់ក្នុងឆ្នាំនេះ រក្សាបានជាអតិបរិមា ហើយកំណើនបណ្ដាញអតិថិជនសម្រាប់ចុងឆ្នាំ២០២៤នេះ បានកើនឡើងដល់ចំនួន ៥០១.២៨៩បណ្ដាញ។

## **ការរំពឹងទុកសម្រាប់ឆ្នាំ២០២៥**

ចំពោះឆ្នាំ២០២៥ ខាងមុខ យើងនឹងខិតខំប្រឹងប្រែងព្យាយាមបន្ថែមទៀតដើម្បីធ្វើឱ្យកាន់តែប្រសើរក្នុងការពង្រឹងនូវអភិបាលកិច្ចសាជីវកម្មល្អរបស់ រ.ទ.ស.ភ ហើយនៅតែប្រកាន់ខ្ជាប់នូវ ទស្សនវិស័យ និងបេសកកម្ម ដែលបានលើកពីបណ្ដាឆ្នាំមុនដដែល។ ទិសដៅសម្រាប់ឆ្នាំ២០២៥ រ.ទ.ស.ភ សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញពិតប្រមាណ ៨១.១៩៣.៨៨២.០០០រៀល ដែលក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលបានអនុម័ត។

រ.ទ.ស.ភ. ក៏នៅតែប្ដេជ្ញាចិត្តផ្តល់សេវាកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាពនិងប្រសិទ្ធភាព ដើម្បីផ្ដល់ការជឿជាក់ពីអតិថិជន។ ជាងនេះទៅទៀត រ.ទ.ស.ភ នៅតែខិតខំផ្ដល់បណ្ដាញទឹកជូនប្រជាពលរដ្ឋដែលមាន ចំណូលទាបតាមរូបភាព ឧបត្ថម្ភថ្លៃសិទ្ធិជាវទឹក ស្របទៅតាមកម្រិតជីវភាពគ្រួសារនីមួយៗ ពី៣០% ៥០% ៧០% និង ១០០% ដើម្បីអនុវត្តគម្រោងចែកចាយទឹក ពិសេសជូនសហគមន៍ក្រីក្រ ដោយប្រើថវិការបស់ រ.ទ.ស.ភ ដើម្បីប្រយោជន៍ប្រជាជន។

## **សេចក្តីថ្លែងអំណរគុណ**

ជាថ្មីម្តងទៀត រ.ទ.ស.ភ មានសេចក្តីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រពីរាជរដ្ឋាភិបាលក៏ដូចជាអាណាព្យាបាលទាំងពីរគឺ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសូមសម្តែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការគាំទ្រ និងការដឹកនាំល្អសម្រាប់ឆ្នាំ២០២៤ និងសូមថ្លែងអំណរគុណជូនចំពោះអតិថិជនទាំងអស់ដែលបានគាំទ្រធ្វើឱ្យ រ.ទ.ស.ភ បានទទួលជោគជ័យដូចសព្វថ្ងៃនេះ។

ថ្ងៃព្រហស្បតិ៍ ៣កើតខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥

**អគ្គនាយក រ.ទ.ស.ភ**

**ឡុង ណារ៉ូ**

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម i

ព័ត៌មានហិរញ្ញវត្ថុសង្ខេប ii

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប iii

សមាសភាពក្រុមប្រឹក្សាភិបាល iv

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល vi

សេចក្តីថ្លែងរបស់អគ្គនាយក viii

**ផ្នែកទី១: ព័ត៌មានទូទៅពាក់ព័ន្ធនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១**

ក- អត្តសញ្ញាណរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១

ខ- លក្ខណៈនៃធុរកិច្ច ០១

គ- សម្ព័ន្ធភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ០១

ឃ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ០២

ង- ស្ថានភាពទីផ្សារ ០៤

ច- ស្ថានភាពប្រកួតប្រជែង ០៤

ឆ- ផែនការអនាគត ០៥

ជ- កត្តាហានិភ័យ ០៥

**ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ១០**

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ១០

ខ- រចនាសម្ព័ន្ធចំណូល ១២

**ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម ១៣**

ក- អង្គការលេខ ១៣

ខ- ក្រុមប្រឹក្សាភិបាល ១៤

គ- បុគ្គលិកជាន់ខ្ពស់ ១៤

**ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិករបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ១៦**

ក- ព័ត៌មានអំពីមូលបត្រ ១៦

ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ ១៦

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ១៦

ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ១៦

ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ ១៧

**ផ្នែកទី៥: របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ១៨**

**ផ្នែកទី៦: របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ២០**

**ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍** ២២
ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ២២
ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់ ២២
គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម ២២
ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល បុគ្គលិកជាន់ខ្ពស់
និងភាគហ៊ុនិកដែមានភាគហ៊ុនចាប់ពី៥(ប្រាំ)ភាគរយឡើងទៅ ២២
ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជី
លក់មូលបត្រក្រុមហ៊ុនបុត្រសម្ព័ន្ធឬក្រុមហ៊ុនហូលឌីងរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ២២
ច- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល
ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជា អភិបាល ២២
ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម
ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ. ២២
ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ.
ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ ២២

**ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ២៣
ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ២៣
ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ២៧
គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ២៨
ឃ- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ២៨
ង- ផលប៉ះពាល់នៃអតិផរណា ២៨
ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ២៩

**ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន** ២៩

**ហត្ថលេខាអភិបាលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** ៣០

ឧបសម្ព័ន្ធ១ ៖ របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២៤
ឧបសម្ព័ន្ធ២ ៖ របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការប្រចាំឆ្នាំ២០២៤
ឧបសម្ព័ន្ធ៣ ៖ របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករឯករាជ្យ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤
ឧបសម្ព័ន្ធ៤ ៖ លទ្ធផលពិនិត្យគុណភាពទឹកពីរោងចក្រផលិតទឹកស្អាតបាក់ខែង របស់ រ.ទ.ស.ភ
Test Report: 7191347954-CHM25-PN

# ផ្នែកទី១: ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ក- អត្តសញ្ញាណ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

### រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

### PHNOM PENH WATER SUPPLY AUTHORITY (PPWSA)

- លេខកូដស្តង់ដារ: KH1000010004
- ទីស្នាក់ការ: អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- លេខទូរស័ព្ទ: (៨៥៥) ៣១ ៣២២ ៦៣៤៥
- គេហទំព័រ: www.ppwsa.com.kh អ៊ីម៉ែល: ir@ppwsa.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម: Co.០៨៣៩Et/២០១២
  កាលបរិច្ឆេទ: ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២
- លេខអាជ្ញាបណ្ណអាជីវកម្ម: អនុក្រឹត្យលេខ៥២អនក្រ.បក ចេញដោយ: រាជរដ្ឋាភិបាលកម្ពុជា
  កាលបរិច្ឆេទ: ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ: ០១២/១២គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ: ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១២
- ឈ្មោះបុគ្គលតំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ: **ឯកឧត្តម ឡុង ណារ៉ូ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ខ- លក្ខណៈនៃធុរកិច្ច

- វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សាមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត និងអនាម័យ
- ប្រើប្រាស់នូវគ្រប់វិធានការដើម្បីបង្កើន ផលិតម្មសេវាកម្ម និង ធានាគុណភាព ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការសម្រាប់ជីវភាពរស់នៅ អាជីវកម្មសេវាកម្មនិងឧស្សាហកម្ម ធ្វើអាជីវកម្ម សេវាកម្ម និងការងារផ្សេងៗដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យនៅក្នុងឬក្រៅប្រទេស តាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងដោយអនុលោមតាមច្បាប់
- សហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍក្នុង និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម
- ពង្រីកការផ្គត់ផ្គង់ទឹកនៅតំបន់ជុំវិញរាជធានីភ្នំពេញ ដោយរក្សាអត្រា និងស្តង់ដាដូចគ្នានៅក្នុងរាជធានីភ្នំពេញ
- បង្កើនប្រសិទ្ធភាពបុគ្គលិក និងបន្តកសាងសមត្ថភាពរបស់សហគ្រាស
- វិភាគកត្តាថ្លៃដើម និងកំណែទម្រង់ដំណើរការ និងបែបបទដើម្បីកាត់បន្ថយថ្លៃដើមទឹក
- ប្រៀបធៀបបែបយុទ្ធសាស្ត្រជាមួយបណ្តាញអង្គភាពទឹកស្អាតនានាដែលមានប្រសិទ្ធភាពបំផុតក្នុងពិភពលោក
- តាំងចិត្តខ្ពស់ ចំពោះការទទួលខុសត្រូវដល់សង្គម និងបរិស្ថាន។

## គ- សម្ព័ន្ធភាព រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពុំមានសម្ព័ន្ធភាពជាមួយក្រុមហ៊ុនណាមួយឡើយ។

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ

**១. ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកស្អាតបាក់ខែងទី២ និងបើកការដ្ឋានសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី៣ របស់ រ.ទ.ស.ភ។**

នៅវេលាព្រឹកថ្ងៃអង្គារ ៤រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ រ.ទ.ស.ភ បានប្រារព្ធពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី២ និងបើកការដ្ឋានសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ស្ថិតនៅរោងចក្រផលិតទឹកស្អាតបាក់ខែង សង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

អនុវត្តទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG) ដោយធានាឱ្យបាននូវ ការទទួលបានទឹកស្អាត ដែលមានគុណភាព សុវត្ថិភាព និរន្តភាព និងថ្លៃសមរម្យ សម្រាប់ប្រជាពលរដ្ឋប្រមាណជាង ២លាននាក់ នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល។ ហេតុដូចនេះ ក្រសួងអាណាព្យាបាល និងក្រុមប្រឹក្សាភិបាល បានអនុម័តឱ្យ រ.ទ.ស.ភ អនុវត្តគម្រោងវិនិយោគសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងជំហានទី២ និងទី៣។

ការងារសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ ទី២ និងទី៣ គឺស្ថិតនៅលើផ្ទៃដី១៥ហិចតា ដែលមានសមត្ថភាពផលិតសរុប ៥៨៥.០០០ម$^3$/ថ្ងៃ។ គិតត្រឹមខែមិថុនា ឆ្នាំ២០២៤ គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ និងទី២ អនុវត្តការងារបានសម្រេច ១០០%។ សម្រាប់ជំហានទី១ បានដាក់ឱ្យដំណើរការជាផ្លូវការកាលពីខែមិថុនា ឆ្នាំ២០២៣ រីឯជំហានទី២ បានបញ្ចប់ការសាងសង់ និងបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤នេះ។ សម្រាប់ការអនុវត្តគម្រោងជំហានទី៣ នឹងចាប់ផ្តើមដំណើរការសាងសង់ពីខែមិថុនា ឆ្នាំ២០២៤ ដោយគ្រោងបញ្ចប់ការសាងសង់នាត្រីមាសទី៣ ឆ្នាំ២០២៧ ដែលសាងសង់ដោយក្រុមហ៊ុន VINCI Construction Grands Projets មកពីប្រទេសបារាំង ស្ថិតក្រោមការត្រួតពិនិត្យរបស់ រ.ទ.ស.ភ និងការជួយផ្តល់យោបល់ពីទីប្រឹក្សាបច្ចេកទេស SAFEGE Construction Engineers មកពីប្រទេសបារាំង។ គម្រោងសាងសង់នេះ ត្រូវបានអនុវត្តកិច្ចសន្យាក្នុងក្របខណ្ឌ រចនា និងប្លង់។

គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែងជំហានទី៣ គឺជាគម្រោងមួយក្នុងចំណោមគម្រោងសំខាន់ៗដែលគ្រោងនឹងចាប់ផ្តើមដំណើរការសាងសង់ ដោយអនុវត្តយោងទៅតាមការធ្វើបច្ចុប្បន្នភាពផែនការមេទី៣ ឆ្នាំ២០២១-២០៣០ របស់ រ.ទ.ស.ភ ដើម្បីត្រៀមឆ្លើយតបទៅនឹងកំណើនតម្រូវការទឹកស្អាត នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល នាពេលខាងមុខ ដែលគ្រោងនឹងកើនឡើងដល់ប្រមាណ ១,៨លានម៉ែត្រគូបក្នុងមួយថ្ងៃ។

គម្រោងទាំង៣ នេះមានទំហំការងារសំខាន់ៗដូចខាងក្រោម៖

១. ការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង៖
- ជំហានទី១ សមត្ថភាពផលិត ១៩៥.០០០ម$^3$/ថ្ងៃ បានបញ្ចប់ដំណើរការសាងសង់ និងដាក់ឱ្យដំណើរការជាផ្លូវការនាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៣
- ជំហានទី២ សមត្ថភាពផលិត ១៩៥.០០០ម$^3$/ថ្ងៃ បានបញ្ចប់ដំណើរការសាងសង់ និងដាក់ឱ្យដំណើរការជាផ្លូវការនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤
- ជំហានទី៣ សមត្ថភាពផលិត ១៩៥.០០០ម$^3$/ថ្ងៃ បានចាប់ផ្តើមសាងសង់នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ និងគ្រោងបញ្ចប់ការសាងសង់ នៅត្រីមាសទី៣ ឆ្នាំ២០២៧។ ដំឡើងបំពង់ចែកចាយប្រវែងប្រមាណ ៧៥០គីឡូម៉ែត្រ និងបំពង់នាំទឹកស្អាតប្រវែងប្រមាណ ៥១គីឡូម៉ែត្រ

២. សេវាប្រឹក្សាបច្ចេកទេសលើការងារត្រួតពិនិត្យគម្រោង

រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី១ និងទី២ អាចផលិតទឹកស្អាតបានចំនួន ៣៩០.០០០ម$^3$/ថ្ងៃ និងបានបន្ថែមផ្គត់ផ្គង់ជូនប្រជាពលរដ្ឋបានប្រមាណជា ២៦៣.០០០គ្រួសារ។ ការដាក់ឱ្យដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី២នេះ នឹងធ្វើអោយប្រជាពលរដ្ឋដែលរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ទទួលបានការផ្គត់ផ្គង់ទឹកស្អាតដែលធានាបាននូវសម្ពាធទឹកដែលកាន់តែប្រសើរជាងមុន។ ទន្ទឹមនឹងនេះ បន្ទាប់ពីរោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី៣ ត្រូវបានបញ្ចប់ដំណើរការសាងសង់ នោះការផលិតទឹកស្អាតគ្រោងនឹង

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ (ត)

ទទួលបានការផលិតបន្ថែមចំនួន ១៩៥.០០០ម$^{៣}$/ថ្ងៃ ព្រមទាំងបានបន្ថែមការផ្គត់ផ្គង់ជូនប្រជាពលរដ្ឋបានប្រមាណ ១៤៧.០០០គ្រួសារ។ ការណ៍នេះ រ.ទ.ស.ភ អាចនឹងផលិតទឹកសរុបបានប្រមាណ ១.១៧៧.០០០ម$^{៣}$/ថ្ងៃ ដោយផ្គត់ផ្គង់ចេញពីរោងចក្រផលិតទឹកស្អាតទាំងប្រាំ សម្រាប់អតិថិជនសរុប គ្រោងប្រមាណ ៥៨៧.០០០គ្រួសារ និងមានបំពង់ចែកចាយសរុបប្រមាណ ៦.២០០គីឡូម៉ែត្រ នៅឆ្នាំ២០២៧។

២. **ពិធី Kick-off ceremony ដើម្បីចាប់ផ្តើមអនុវត្តគម្រោងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតវៃវាង រ.ទ.ស.ភ និង ក្រុមហ៊ុន K-Water។**

នារសៀលថ្ងៃព្រហស្បតិ៍ ១២កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤នេះ **ឯកឧត្តម ឡុង ណារ៉ូ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងថ្នាក់ដឹកនាំ រ.ទ.ស.ភ បានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាជាផ្លូវការ ដើម្បីចាប់ផ្តើមអនុវត្តគម្រោង "គ្រប់គ្រងប្រព័ន្ធចែកចាយទឹកវៃឆ្លាត" រវាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងក្រុមហ៊ុនអន្តរជាតិ សារជីវកម្មធនធានទឹកកូរ៉េ (K-Water) ក្រោមអធិបតីភាព **ឯកឧត្តម ឯក សុនចាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** និង ជាប្រធានក្រុមប្រឹក្សាភិបាល អាណត្តិទី៨ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និង **លោក AN-JUNG HO** អនុប្រធានក្រុមហ៊ុន K-Water នៃសាធារណរដ្ឋកូរ៉េ។

៣. **ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកបឹងធំ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន - ២០០៩ (JAPAN XIII) និងថវិកាបដិភាគរបស់ រ.ទ.ស.ភ។**

នាថ្ងៃចន្ទ ១រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ រ.ទ.ស.ភ បានប្រារព្ធពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការរោងចក្រផលិតទឹកស្អាតបឹងធំរបស់ រ.ទ.ស.ភ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** និង **ឯកឧត្តម AMAKAWA HIROFUMI អនុរដ្ឋមន្ត្រី ទទួលបន្ទុកដែនដី ហេដ្ឋារចនាសម្ព័ន្ធ និងកិច្ចការអភិវឌ្ឍន៍ហុកកៃដូ នៃក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ នៃប្រទេសជប៉ុន** ស្ថិតនៅរោងចក្រផលិតទឹកស្អាតបឹងធំរបស់ រ.ទ.ស.ភ នៅភូមិបឹងធំ២ សង្កាត់បឹងធំ ខណ្ឌកំបូល រាជធានីភ្នំពេញ។ រោងចក្រផលិតទឹកស្អាតនេះមានសមត្ថភាពផលិត ៦.០០០ម$^{៣}$/ថ្ងៃ ធ្វើឱ្យ រ.ទ.ស.ភ មានសមត្ថភាពផលិតសរុបកើនដល់ចំនួន ៩៨៨.០០០ម$^{៣}$/ថ្ងៃ ដើម្បីផ្គត់ផ្គង់ទៅដល់ប្រជាពលរដ្ឋដែលរស់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅជាមួយគុណភាពសុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ។ រោងចក្រផលិតទឹកស្អាតនេះគ្រោងនឹងផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិចំនួន១០ ក្នុងសង្កាត់បឹងធំ សង្កាត់ប្រទះឡាង និងសង្កាត់ពងទឹក ក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ ស្មើនឹងប្រមាណ ៣.០០០គ្រួសារ។ សមិទ្ធផលថ្មីនេះ បានចូលរួមជាចំណែកឈានទៅសម្រេចបាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព នៃការធានាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យបាន ១០០% សម្រាប់ប្រជាពលរដ្ឋចាប់ពីឆ្នាំ ២០៣០ តទៅ ដោយបច្ចុប្បន្ន រ.ទ.ស.ភ ផ្គត់ផ្គង់ទឹកស្អាតបានប្រមាណ ៩៦% នៃប្រជាពលរដ្ឋដែលរស់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាល។

គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបឹងធំ បានចាប់ផ្តើមសាងសង់នៅក្នុងខែមីនា ឆ្នាំ២០២៣ ដោយអនុវត្តការសាងសង់ និងត្រួតពិនិត្យផ្ទាល់ដោយមន្ត្រីជំនាញរបស់ រ.ទ.ស.ភ បានចំណាយរយៈពេល ២២ខែ ក្នុងការលេចចេញនូវសមិទ្ធផលមួយនេះ។ ប្រភពហិរញ្ញប្បទានសម្រាប់ការសាងសង់រោងចក្រមួយនេះ គឺទទួលបានជំនួយហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន តាមរយៈស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចំនួន ១.៤៩៤.០០០ដុល្លារអាមេរិក និងថវិកាបដិភាគរបស់ រ.ទ.ស.ភ ផ្ទាល់។

ហេដ្ឋារចនាសម្ព័ន្ធនៃគម្រោង៖

- ស្ថានីយបូមទឹកឆៅ ត្រូវបានរចនាជាប្រភេទស្ថានីយបណ្តែត មានសមត្ថភាពបូមបាន ៦.៣០០ម$^{៣}$/ថ្ងៃ ដែលបូមចេញពីប្រភពទឹកស្ទឹងព្រែកត្នោត។ ស្ថានីយបូមទឹកឆៅនេះ បានបំពាក់ទៅដោយប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តិ SCADA ទៅលើការបញ្ជា និងការកំណត់លំហូរទឹក។
- បំពង់មេនាំទឹកឆៅ ប្រភេទ HDPE ទំហំ ៣១៥មម ប្រវែង ០,២គីឡូម៉ែត្រ

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឃ- ព្រឹត្តការណ៍សំខាន់ៗប្រចាំឆ្នាំ (ត)

- រោងចក្រផលិតទឹកស្អាតដែលមានសមត្ថភាពផលិត ៦.០០០ម៣/ថ្ងៃ នេះមាន៖
  - – អគារគីមី : ដំឡើងធុងគីមីចំនួន ៦ ដែលមានទំហំ២ម៣ និងម៉ាស៊ីនបូម (Dosing pumps) ចំនួន១២
  - – ធុងបន្សុទ្ធ : អាងរង Lamella Settler (LS) ចំនួន៤ មានសមត្ថភាពផលិត ១.៥០០ម៣/ថ្ងៃ
  - – អាងត្រង : អាងច្រោះ Auto Siphon Filter (ASF) ចំនួន៤ មានសមត្ថភាពផលិត ១.៥០០ម៣/ថ្ងៃ
  - – អាងស្តុកទឹកស្អាត : មានសមត្ថភាពស្តុក ១.៥០០ម៣/ថ្ងៃ
  - – អាងស្តុកកក់ : មានសមត្ថភាពស្តុក ១៨០ម៣
  - – ស្ថានីយបូមទឹកស្អាត : មានម៉ាស៊ីនបូម ៣គ្រឿង ដែលបានដំឡើង (បើកដំណើរការ២គ្រឿង និងបម្រុង១គ្រឿង)
- បំពង់មេនាំទឹក និងចែកចាយទឹកស្អាតមានប្រវែងសរុប ៩១គីឡូម៉ែត្រ ប្រើប្រាស់ទាំងទុយោដែក និងបំពង់ HDPE

**ឯកឧត្តម ឡុង ណារ៉ូ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃ រ.ទ.ស.ភ** បានសំដែងនូវមនោសញ្ចេតនារំភើបរីករាយយ៉ាងក្រៃលែង និងបានបញ្ជាក់ផងដែរថា "ភាពជោគជ័យនេះ គឺជាចំណងមិត្តភាពដ៏ជ្រាលជ្រៅរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលជប៉ុន ក្នុងការរួមចំណែកអភិវឌ្ឍន៍ព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះ សមិទ្ធិផលនៃរោងចក្រផលិតទឹកស្អាតបឹងធំនេះ ក៏ទទួលបានការគាំទ្រពីសំណាក់ក្រសួងអាណាព្យាបាលទាំងពីរ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងក្រុមប្រឹក្សាភិបាល នៃ រ.ទ.ស.ភ អភិបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌកំបូល និងអង្គភាពគ្រប់លំដាប់ថ្នាក់។ ភាពជោគជ័យនេះ នឹងបានជួយជាប្រយោជន៍ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិចំនួន១០ ក្នុងសង្កាត់បឹងធំ សង្កាត់ប្រទះឡាង និងសង្កាត់ពងទឹក ក្នុងខណ្ឌកំបូល រាជធានីភ្នំពេញ ស្មើនឹងប្រមាណ ៣.០០០គ្រួសារ ទទួលបានទឹកស្អាតរបស់ រ.ទ.ស.ភ បានលឿនជាគម្រោងដែលបានគ្រោងទុកពីមុន។ ក្នុងករណីប្រសិនបើ រ.ទ.ស.ភ ពុំបានអនុវត្តគ្រោងនេះទេ ប្រជាពលរដ្ឋដែលរស់តំបន់ដូចបានរៀបរាប់ខាងលើ នឹងត្រូវរង់ចាំដល់ប៉ុន្មានឆ្នាំក្រោយទៀត ទើប រ.ទ.ស.ភ មានលទ្ធភាពផ្គត់ផ្គង់ជូនបានស្របតាមផែនការមេ របស់ រ.ទ.ស.ភ។ ដើម្បីចូលរួមចំណែកក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា រ.ទ.ស.ភ នៅតែប្តេជ្ញាចិត្តក្នុងការពង្រីក កែលម្អ និងបង្កើនសមត្ថភាពផលិតកម្ម និងការចែកចាយទឹកស្អាត ជាពិសេសអនុវត្តតាមការធ្វើបច្ចុប្បន្នភាពនៃផែនការមេទី៣ របស់ រ.ទ.ស.ភ ឆ្នាំ២០២១-២០៣០ ដើម្បីធានាបាននូវពាក្យស្លោក "**ទឹកស្អាតសម្រាប់ទាំងអស់គ្នា**" និងការផ្គត់ផ្គង់ទឹកស្អាតប្រកបដោយនិរន្តរភាព។

## ង- ស្ថានភាពទីផ្សារ

ទីផ្សារផ្គត់ផ្គង់ទឹកស្អាតរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺគ្រប់គ្រងតាមរយៈ "ផ្ទៃសេវាទាំង ១៤ខណ្ឌ ក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ" ឱ្យផ្គត់ផ្គង់ទឹកស្អាត ២៤ម៉ោង ជូនប្រជាពលរដ្ឋរស់នៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដោយមានសម្ពាធទឹកគ្រប់គ្រាន់ មានគុណភាពទឹកស្អាតស្របតាមស្តង់ដាទឹកផឹកថ្នាក់ជាតិ និងអង្គការ WHO ព្រមទាំងថ្លៃលក់ទឹកសមស្រប។

## ច- ស្ថានភាពប្រកួតប្រជែង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ គឺជាសហគ្រាសសាធារណៈតែមួយគត់ (Monopoly) ក្នុងការធ្វើអាជីវកម្មនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ដែលមានលក្ខណៈបច្ចេកទេស និងសេដ្ឋកិច្ច។ រ.ទ.ស.ភ មិនធ្វើការប្រកួត-ប្រជែងលើថ្លៃលក់ទឹកនៅក្នុងទីផ្សារទេ និងមិនរងសម្ពាធផ្នែកនយោបាយ ទោះស្ថិតក្នុងដំណាក់កាលណាក៏ដោយ។

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ឆ- ផែនការអនាគត

- ជំរុញការតាមដាន និងអនុវត្តបច្ចុប្បន្នភាពផែនការមេលើកទី៣ ឆ្នាំ២០២១-២០៣០ ក្នុងការពង្រឹងសក្តានុពល និងវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ។
- បន្តជំរុញការធ្វើនវានុវត្តន៍លើបច្ចេកទេស និងបច្ចេកវិទ្យាលើវិស័យទឹកស្អាត ដើម្បីឱ្យស្របទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ លើអាទិភាពគន្លឹះចំនួន២ ក្នុងចំណោម ៥ គឺ ទឹក និងបច្ចេកវិទ្យា ព្រមទាំងនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជាក្នុងការធានាឱ្យបាននូវនិរន្តរភាព លើការគ្រប់គ្រងប្រព័ន្ធផលិតកម្ម និងចែកចាយទឹកប្រកបដោយប្រសិទ្ធភាព។
- បន្តកាត់បន្ថយការចំណាយណាដែលមិនចាំបាច់ និងបង្កើនប្រសិទ្ធភាពទារប្រាក់ថ្លៃទឹក ព្រមទាំងខិតខំរកចំណូលពីសេវាកម្ម និងចំណូលផ្សេងៗ ឱ្យបានតាមផែនការ។
- ជំរុញ និងផ្សព្វផ្សាយបន្ថែមអំពីគុណសម្បត្តិនៃការប្រើប្រាស់ Mobile App របស់អង្គភាព ដល់អតិថជនឱ្យបានទូលំទូលាយ។
- បន្តបង្កើនប្រសិទ្ធភាពក្នុងការជួសជុលថែទាំប្រព័ន្ធប្រព្រឹត្តកម្ម និងប្រព័ន្ធផ្គត់ផ្គង់ដើម្បីរក្សាអាយុកាលឱ្យបានយូរអង្វែង និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ២៤ម៉ោង/៧ ថ្ងៃ។
- សិក្សា និងរៀបចំលើឯកសារបទដ្ឋានបច្ចេកទេសឱ្យមានលក្ខណៈស្តង់ដារ សម្រាប់ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។
- បន្តជំរុញការគ្រប់គ្រងធនធានមនុស្ស ដើម្បីអនុវត្តការងារប្រកបដោយស្មេរភាព និងប្រសិទ្ធភាពជាពិសេសក្នុងរបត់នៃបរិវត្តន៍លើបច្ចេកវិទ្យាឌីជីថល។
- បន្តកិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ជាពិសេសសាលារាជធានីភ្នំពេញ ក្នុងការជួយអន្តរាគមន៍ពន្លឿនលើសំណើសុំជីកដាក់បំពង់រួមមាន៖ បំពង់មេនាំទឹកស្អាត និងបំពង់ចែកចាយទឹកស្អាតទៅតាមបណ្តាទីតាំងការដ្ឋានគម្រោងក្នុងរាជធានីភ្នំពេញ។
- ជំរុញ និងពន្លឿនការងារដំឡើងបំពង់មេនាំទឹក យុទ្ធសាស្ត្រដើម្បីធានាការគ្រប់គ្រងសម្ពាធផ្គត់ផ្គង់ទឹកឱ្យកាន់តែមានភាពប្រសើរឡើងនាពេលអនាគត។
- ធ្វើការកាត់បន្ថយអត្រាទឹកបាត់បង់ឱ្យបានកាន់តែទាប និងក្នុងកម្រិតដែលអាចធ្វើទៅបាន។

## ជ- កត្តាហានិភ័យ (ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់)

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ទទួលបន្ទុកការងារផលិតកម្ម និងចែកចាយទឹកសម្រាប់ប្រើប្រាស់ទូទៅក្នុងការបម្រើដល់ផ្នែកសេវាកម្មសាធារណៈជាលក្ខណៈរដ្ឋបាល និងបច្ចេកទេស ដោយមានការធានាទាំងបរិមាណ និងគុណភាពទឹកស្អាតគ្មានមេរោគ ព្រមទាំងអាចផឹកបានពីបណ្តាញដោយផ្ទាល់។ ទោះជាយ៉ាងណាក៏នៅមានកត្តាហានិភ័យមួយចំនួន ដែលកំពុងជួបប្រទះ និងមានវិធានការទប់ស្កាត់ ដូចខាងក្រោម៖

# ផ្នែកទី១:ព័ត៌មានទូទៅរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ត)

## ជ- កត្តាហានិភ័យ "ការវិភាគ និងទស្សនៈអ្នកគ្រប់គ្រង និងវិធានការទប់ស្កាត់" (ត)

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| **១- ការងារផែនការ និងគម្រោង** | |
| ▪ ទោះបីជាពេលថ្មីៗកន្លងមកនេះ រ.ទ.ស.ភ បាន ដាក់ឱ្យដំណើរការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មី ចំនួនពីរបន្ថែមទៀតក៏ដោយ ប៉ុន្តែនៅតាមតំបន់មួយចំនួន ក្នុងរាជធានីភ្នំពេញ នៅមានបញ្ហាប្រឈមនឹងអតុល្យភាពលើសម្ពាធផ្គត់ផ្គង់ទឹកស្អាត។ | ▪ បន្តធ្វើនវានុវត្តន៍លើបច្ចេកទេស និងបច្ចេកវិទ្យាលើវិស័យទឹកស្អាត ដើម្បីឱ្យសមស្របទៅនឹងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ក្នុងការធានាឱ្យបាននូវនិរន្តរភាពលើការគ្រប់គ្រងប្រព័ន្ធចែកចាយទឹក ព្រមទាំងកាត់បន្ថយអត្រាទឹកបាត់បង់ប្រកបដោយប្រសិទ្ធភាព<br>▪ បន្តដំឡើងបំពង់មេនាំទឹក និងបំពង់ចែកចាយទឹក<br>▪ ជម្រុញដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងបណ្តាញទឹកស្អាតវៃឆ្លាត<br>▪ ការគ្រប់គ្រងធនធានមនុស្ស ដើម្បីអនុវត្តការងារប្រកបដោយស្ថិរភាព និងប្រសិទ្ធភាព ជាពិសេសក្នុងបរិបទនៃបរិវត្តកម្មលើបច្ចេកវិទ្យាឌីជីថល។ |
| ▪ កំណើនយ៉ាងលឿននៃប្រជាជនតាមរយៈការពង្រីកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងការពង្រីកផ្ទៃសេវារដ្ឋបាលនៃរាជធានីភ្នំពេញ បានធ្វើឱ្យមានកំណើននៃតម្រូវការទឹកស្អាតខ្ពស់។ | ▪ ជម្រុញ និងអនុវត្តស្របតាមបច្ចុប្បន្នភាពផែនការមេលើកទី៣ ឆ្នាំ២០២១-២០៣០ របស់ រ.ទ.ស.ភ<br>▪ បន្តកិច្ចសហការឱ្យមានប្រសិទ្ធភាពជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួងពាក់ព័ន្ធសំដៅយ៉ាងណាពន្លឿនលើគ្រប់មុខសញ្ញានៃការងារលទ្ធកម្មគម្រោងបរទេស<br>▪ បង្កើនប្រសិទ្ធភាពក្នុងការជួសជុលថែទាំប្រព័ន្ធប្រព្រឹត្តកម្មសំដៅរក្សាការផលិត និងផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្តាហ៍។ |
| **២- ការងារគ្រប់គ្រងប្រព័ន្ធផលិតកម្ម** | |
| ▪ ស្ថិតក្នុងកាលៈទេសៈ ដែលអាកាសធាតុមានការប្រែប្រួល រ.ទ.ស.ភ បានគិតគូរពិចារណាក្នុងការធ្វើយ៉ាងណា "ត្រូវតែផលិតទឹកចេញពីរោងចក្រឱ្យអស់សមត្ថភាព និងប្រកបដោយសុវត្ថិភាពជូនអតិថិជនរបស់ រ.ទ.ស.ភ"។ | ▪ **មនុស្ស** (Operator) : និយោជិតដំណើរការរោងចក្របានអនុវត្តការងារដោយមានប្រសិទ្ធិភាពខ្ពស់ និងកាត់បន្ថយភាពអសកម្មនៃដំណើរការប្រព័ន្ធផលិតកម្ម<br>▪ **គ្រឿងចក្រ** (Machine and Spair Part) : គ្រឿងចក្រនៅតាមរោងចក្រ ត្រូវតែដំណើរការមិនឱ្យអសកម្ម និងមានគ្រឿងបន្លាស់គ្រប់គ្រាន់ សម្រាប់ជួសជុលផ្លាស់ប្តូរក្នុងករណីមានគ្រឿងចក្រណាមួយអសកម្មកើតមានឡើងដាយថាហេតុ<br>▪ **វត្ថុធាតុដើម** (PAC, Salt, Chlorine & Reagent): ទឹកផលិតចេញពីរោងចក្រ ត្រូវមានគុណភាពស្របតាមស្តង់ដាទឹកផឹកថ្នាក់ជាតិ និង WHO ដូច្នេះវត្ថុធាតុដើមបម្រើឱ្យការផលិតទឹកត្រូវតែមានបរិមាណប្រើប្រាស់គ្រប់គ្រាន់នៅក្នុងឃ្លាំងស្តុក។ |

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| ▪ ការងារគ្រប់គ្រងថែទាំ-ជួសជុល ឧបករណ៍-បរិក្ខារបម្រើដល់ការងារផលិតកម្ម និងដំណើរការកម្មវិធីប្រព័ន្ធគ្រប់គ្រង Asset Management & Maintenance ដែលបានដាក់ឱ្យ Go Live សម្រាប់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងនៅចុងឆ្នាំ២០២៤ នៅមិនទាន់មានភាពល្អប្រសើរ។ | ▪ រៀបចំក្រុមការងារជំនាញ សម្រាប់ចូលរួមក្នុងការងាររៀបចំប្រព័ន្ធគ្រប់គ្រង Asset Management and Maintenance ក្នុងការត្រួតពិនិត្យ និងការងារជួសជុល-ថែទាំគ្រឿងចក្រឧបករណ៍បរិក្ខារផ្សេងៗ ដើម្បីជាការស្វែងយល់ឱ្យកាន់តែច្បាស់ មុននឹងឈានទៅដល់ការស្នើសុំរៀបចំ សម្រាប់តាមបណ្ដារោងចក្រទាំងអស់។<br>▪ ផ្ដល់មតិជំនាញ ទៅកាន់ក្រុមហ៊ុនរៀបចំប្រព័ន្ធដើម្បីធ្វើការកែសម្រួល ឱ្យប្រព័ន្ធកាន់តែមានភាពងាយស្រួល និងអាចឱ្យការងារអនុវត្តបានប្រកបដោយប្រសិទ្ធិភាព។ |
| ▪ កត្តាប្រែប្រួលអាកាសធាតុ និងកត្តាមនុស្សបាន ធ្វើឱ្យប៉ះពាល់ទៅលើគុណភាពទឹកឆៅព្រមទាំងកម្ពស់ទឹកទន្លេ។ | ▪ បង្កើនការចំណាយក្នុងការប្រព្រឹត្តកម្មទឹកស្អាតតាមរយៈ៖<br>➢ បង្កើនក្នុងការប្រើប្រាស់វត្ថុធាតុដើម ដើម្បីឱ្យគុណភាពទឹកមានលក្ខណល្អប្រសើរស្របតាមស្តង់ដាទឹកផឹកថ្នាក់ជាតិ និង WHO<br>➢ បង្កើនសមត្ថភាពក្នុងការបូមទឹកឆៅ ដើម្បីយកមកប្រព្រឹត្តកម្មទឹកស្អាតឱ្យគ្រប់គ្រាន់ទៅតាមតម្រូវការ |
| **៣- ការងារគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក** | |
| ▪ កត្តាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ ក្នុងរាជធានីភ្នំពេញគ្រប់ទីកន្លែងដូចជា៖ ការកែសម្រួល ប្រព័ន្ធលូធ្វើផ្លូវ និងពង្រីកផ្លូវ ជីកដាក់ប្រព័ន្ធខ្សែក្រោមដីគ្រប់ប្រភេទ ដោយមិនមានការជូនដំណឹងឱ្យបានទាន់ពេលវេលាដែលធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ | ▪ រៀបចំក្រុមការងារ ដើម្បីសហការជាមួយអាជ្ញាធរមូលដ្ឋាន និងចុះតាមបណ្ដាការដ្ឋានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជូនដំណឹងឱ្យបានទាន់ពេលវេលា និងកាត់បន្ថយផលប៉ះពាល់។ ទន្ទឹមនឹងនេះដែរ ក៏មានការពិន័យយ៉ាងធ្ងន់ធ្ងរ ចំពោះអ្នកបង្កផលប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ |
| **៤- ការងារដំឡើងបណ្ដាញផ្គត់ផ្គង់ទឹក** | |
| ▪ ផ្អែកលើបទពិសោធន៍ដែលទទួលបានក្នុងឆ្នាំ ២០២៤ កត្តាទីតាំងជីកដាក់បំពង់មេនាំទឹក និងបំពង់ចែកចាយដែលមានភាពស្មុគស្មាញ ជាពិសេសប្រព័ន្ធក្រោមដី មានដូចជា៖ ខ្សែភ្លើង ខ្សែអុបទិច ប្រព័ន្ធបណ្ដាញលូ ជាដើម។ | ▪ ដើម្បីដោះស្រាយនូវភាពស្មុគស្មាញ ដែលកើតមានឡើងក្នុងប្រព័ន្ធក្រោមដី នៅពេលអនុវត្តការងារជីកដាក់បំពង់ ត្រូវមានមន្ត្រីជំនាញពាក់ព័ន្ធចូលរួមសហការ និងមានការប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងសិក្សាឱ្យបានច្បាស់លាស់មុនពេលអនុវត្ត។ |
| **៥- ការងារអាជីវកម្ម** | |
| ▪ អត្រាថ្លៃលក់ទឹកជាមធ្យម ប្រឈមនឹងការធ្លាក់ចុះ ដែលអាចបណ្ដាលមកពីបញ្ហាប្រឈមសម្រាប់ភាពនៅទ្រឹងនៃការអភិវឌ្ឍវិស័យអចលនទ្រព្យ និងដំណើរការអាក់ខាននៃវិស័យឧស្សាហកម្ម សិប្បកម្ម អាជីវកម្ម ក្នុងឆ្នាំ ២០២៣-២០២៤។ | ▪ បានដាក់ផែនការ ក្នុងការស្វែងរកអតិថិជនដែលមានសក្ដានុពលមានតម្រូវការប្រើប្រាស់ទឹកស្អាតខ្ពស់។<br>▪ បានពង្រឹង នៃការអនុវត្តកិច្ចសន្យាអតិថិជនដែលប្រើប្រាស់នាឡិកាធំៗ ប្រភេទអាជីវកម្ម។ |
| **៦- ការងារគណនេយ្យ** | |
| ▪ ការកើនឡើងនៃបន្ទុកចំណាយការងារជួសជុលទឹកធ្លាយ និងថែទាំ បរិក្ខាប្រព័ន្ធផ្គត់ផ្គង់ទឹក | ▪ ចាត់ចែង និងរៀបចំក្នុងការគ្រប់គ្រងសម្ពាធទឹកឱ្យបានសមស្រប ដើម្បីឈានទៅដល់កាត់បន្ថយបញ្ហាលេចធ្លាយ និងបន្ទុកចំណាយក្នុងការជួសជុលទឹកធ្លាយ ក៏ដូចជាការ |

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| ▪ បន្ទុកចំណាយជួសជុលថែទាំ បរិក្ខាប្រព័ន្ធចែកចាយទឹកស្អាតមានការកើនឡើង បន្ទាប់ពីការដាក់ឱ្យដំណើរការ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី ១ និងទី ២។ ការកើនឡើងនៃសម្ពាធទឹកនាំឱ្យការលេចធ្លាយកើនឡើង ដែលទាមទារឱ្យមានការជួសជុលច្រើនជាមួយគ្នាផងដែរ ដោយសារការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ប្រព័ន្ធលូទឹក នៅក្នុងរាជធានីភ្នំពេញ ក៏បានធ្វើឱ្យប៉ះពាល់ដល់ប្រព័ន្ធផ្គត់ផ្គង់ទឹក ដែលនាំឱ្យការចំណាយ រើ-រៀប បំពង់កើនឡើងផងដែរ។ | សហការជាមួយអាជ្ញាធរដែនដី ក្នុងការត្រួតពិនិត្យការអនុវត្តគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ក្នុងរាជធានីភ្នំពេញ សំដៅធ្វើយ៉ាងណាឱ្យផលប៉ះពាល់លើប្រព័ន្ធផ្គត់ផ្គង់ទឹក កាន់តែតិចតាមដែលអាចធ្វើទៅបាន។ |
| **៧- ការងាររដ្ឋបាល និងធនធានមនុស្ស** | |
| ▪ ជំនាញបច្ចេកទេស នៅមានតម្រូវការបណ្តុះបណ្តាលបន្ថែម។ | ▪ រ.ទ.ស.ភ បានរៀបចំចាត់ចែងមន្ត្រី-និយោជិត ដើម្បីទៅស្វែងយល់ និងបណ្តុះបណ្តាលបន្ថែមនៅ Office International de l'Eau (OiEau) នៅប្រទេសបារាំង។ |
| ▪ កង្វះអគារការិយាល័យ សម្រាប់មន្ត្រីនិយោជិត ក្នុងការបំពេញភារកិច្ច។ | ▪ ដៃគូអភិវឌ្ឍន៍ AFD បានឯកភាពក្នុងការអនុញ្ញាតប្រើប្រាស់កញ្ចប់ថវិកាស្ថិតនៅក្នុងហិរញ្ញប្បទាន នៃគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំហានទី ៣ និងរួមជាមួយបដិភាគពី រ.ទ.ស.ភ ដើម្បីប្រើប្រាស់សម្រាប់សាងសង់អគាររដ្ឋបាលថ្មី ។ |
| **៨- ការងារព័ត៌មានវិទ្យា** | |
| ▪ ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យាកាន់តែទំនើបពីមួយថ្ងៃទៅមួយថ្ងៃ បានបណ្តាលឱ្យមានការគម្រាមកំហែងទៅលើសន្តិសុខសាយប័រ។ ការគម្រាមកំហែងទាំងនេះ អាចមានចាប់ពីការវាយប្រហារបន្លំ (Phishing) និងមេរោគចាប់ជម្រិត (Ransomware) ដល់ការបំពានទិន្នន័យ និងការគម្រាមកំហែងខាងក្នុងដែលបណ្តាលឱ្យខូចខាតដល់ហិរញ្ញវត្ថុ កេរ្តិ៍ឈ្មោះ និងប្រតិបត្តិការការងារយ៉ាងធ្ងន់ធ្ងរ។ | ▪ អនុវត្តវិធីសាស្ត្រសុវត្ថិភាពរឹងមាំ (Strong Security Protocols)៖<br>➢ ប្រើប្រាស់ប្រព័ន្ធសុវត្ថិភាព (Firewall) ប្រព័ន្ធរកឃើញ/ការពារការឈ្លានពាន (IDS/IPS) និងកម្មវិធីកម្ចាត់មេរោគ<br>➢ ប្រើវិធីសាស្ត្រ End-to-end encryption សម្រាប់ការរក្សាទុក និងបញ្ជូនទិន្នន័យ<br>➢ អនុវត្តការផ្ទៀងផ្ទាត់ពហុកត្តា (MFA) សម្រាប់ប្រព័ន្ធសំខាន់ៗទាំងអស់។<br>▪ ធ្វើសវនកម្មសុវត្ថិភាពជាប្រចាំ៖<br>➢ វាយតម្លៃភាពងាយរងគ្រោះ តាមរយៈការធ្វើតេស្តជ្រៀតចូល<br>➢ ធ្វើបច្ចុប្បន្នភាពកម្មវិធីជាប្រចាំ ដើម្បីកាត់បន្ថយការកេងប្រវ័ញ្ច (Exploits)។<br>▪ អប់រំ និងបណ្តុះបណ្តាលបុគ្គលិក<br>➢ បើកវគ្គបណ្តុះបណ្តាលការយល់ដឹងពីសុវត្ថិភាព ជាកាតព្វកិច្ចសម្រាប់បុគ្គលិក<br>➢ បណ្តុះបណ្តាលបុគ្គលិកឱ្យយល់ដឹងពីការប៉ុនប៉ងបន្លំ និងរក្សាព័ត៌មានដោយការទទួលខុសត្រូវ។<br>▪ ការគ្រប់គ្រងការចូលប្រើប្រាស់៖ |

| កត្តាហានិភ័យ/កត្តាប្រឈម | វិធានការទប់ស្កាត់ និងដំណោះស្រាយ |
|---|---|
| | ➢ អនុវត្តគោលការណ៍ នៃសិទ្ធិតិចតួចបំផុត (POLP) ដើម្បីរឹតបន្តឹងការចូលប្រើទិន្នន័យ<br>➢ ពិនិត្យ និងធ្វើបច្ចុប្បន្នភាពការអនុញ្ញាតចូលប្រើរបស់អ្នកប្រើប្រាស់ជាប្រចាំ។<br>▪ ការថតចម្លងទិន្នន័យរក្សាទុក និងការស្តារគ្រោះមហន្តរាយ៖<br>➢ កំណត់កាលវិភាគ នៃការបម្រុងទុកដោយស្វ័យប្រវត្តិនៃទិន្នន័យសំខាន់ៗ<br>➢ សាកល្បងផែនការស្តារគ្រោះមហន្តរាយជាប្រចាំ ដើម្បីធានាប្រសិទ្ធិភាព។<br>▪ តាមដាន និងឆ្លើយតបទៅនឹងការគម្រាមកំហែង៖<br>➢ ប្រើប្រាស់ប្រព័ន្ធព័ត៌មានសុវត្ថិភាព និងការគ្រប់គ្រងព្រឹត្តិការណ៍ (SIEM) ដើម្បីតាមដានព្រឹត្តិការណ៍សុវត្ថិភាពក្នុងពេលជាក់ស្តែង<br>➢ បង្កើតក្រុមឆ្លើយតបឧបទ្ទវហេតុ ដើម្បីដោះស្រាយការបំពានឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាព។ |

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកគ្មានចំណូល

### ក.១.១- លទ្ធផលការងារប្រព្រឹត្តកម្ម

ការប្រព្រឹត្តកម្មទឹកស្អាតនៅក្នុងឆ្នាំ២០២៤ នេះ មានដូចក្នុងតារាងខាងក្រោម៖

| **រោងចក្រផលិតទឹកស្អាត** | **ប្រភពទឹក** | **ផែនការ** (គិតជាម៉ែត្រគុប) | **អនុវត្តជាក់ស្តែង** (គិតជាម៉ែត្រគុប) | **អត្រា** (គិតជា %) |
|---|---|---|---|---|
| ភូមិព្រៃក | ទន្លេសាប | ៥៩.៤៤១.០០០ | ៥៦.៣៩៣.១៤០ | ៩៥ |
| ជ្រោយចង្វារ | ទន្លេមេគង្គលើ | ៤១.៤២០.០០០ | ៥០.៥៨៥.០០២ | ១២២ |
| ចំការមន | ទន្លេបាសាក់ | ១៩.៦៣៩.០០០ | ១៧.៩៤៣.៣៨៤ | ៩១ |
| និរោធ | ទន្លេមេគង្គក្រោម | ៩៦.៩២១.០០០ | ៩៨.៥០៥.៣៤៦ | ១០២ |
| បាក់ខែង | ទន្លេមេគង្គលើ | ៩១.៩០២.០០០ | ៨៨.១២០.៨៣២ | ៩៦ |
| បឹងធំ | បឹងធំ | ៧៩៧.០០០ | ៣០៦.៤៤៥ | ៣៨ |
| ម្លេច | ទំនប់ម្លេច | ៥៥៨.០០០ | ៥២៤.៨៩៦ | ៩៤ |
| ត្បូងឃ្មុំ | បឹងតាវ៉ាន់ | ៥៤៦.៣០០ | ៥៧២.៨១៧ | ១០៥ |
| | **សរុប** | **៣១១.២២៤.៣០០** | **៣១២.៩៥១.៨៦២** | **១០១** |

ការប្រើប្រាស់វត្ថុធាតុដើម និងអគ្គិសនីក្នុងការផលិតទឹកស្អាតនៅក្នុងឆ្នាំ២០២៤៖

| បរិយាយ | រោងចក្រផលិតទឹកស្អាត | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ភូមិព្រៃក | ជ្រោយចង្វារ | ចំការមន | និរោធ | បាក់ខែង | បឹងធំ | ម្លេច | ត្បូងឃ្មុំ | |
| PAC (គីឡូក្រាម) | ៧៣២.០០០ | ៣៧០.៨០០ | ២៤៤.៧០០ | ១.១១៤.៥០០ | ១.៣៥៥.១៣០ | ១០.៨២៥ | ៨.៣០០ | ២២.២២១ | **៣.៨៥៨.៤៧៦** |
| អំបិល (គីឡូក្រាម) | ១៣៧.៣០០ | ២៥៥.៤៥០ | ១៣៤.៥៧៥ | ០ | ៨៩០.៦៥០ | ០ | ០ | ០ | **១.៤១៧.៩៧៥** |
| ក្លរីន (គីឡូក្រាម) | ២៩.៣៨៤ | ៤៦.៥១៦ | ២៤.៤៨៩ | ០ | ២១៦.៦១៧ | ០ | ០ | ០ | **៣១៧.០០៦** |
| ក្លរឧស្ម័ន(គីឡូក្រាម) | ១៥៦.៣៧០ | ១០៣.៧៣៧ | ០ | ៣១៨,២០៩ | ០ | ០ | ០ | ០ | **៥៧៨.៣១៦** |
| ក្លរម្សៅ (គីឡូក្រាម) | ០ | ០ | ៦៣.៩១០ | ០ | ០ | ២.៩៦០ | ៣.៣០៨ | ៦.២៩៤ | **៧៦.៤៧២** |
| កំបោរ (គីឡូក្រាម) | ៤៥៧.៨២០ | ០ | ៣៦.៦០០ | ៦៥០.២០០ | ៣៤២.៦០៨ | ៦.៥០០ | ០ | ០ | **១.៤៩៣.៧២៨** |
| អគ្គិសនី(គីឡូវ៉ាត់ម៉ោង) | ១៧.០៦២.៣០០ | ១៥.៤០៣.៣៧០ | ៤.៣៣១.៣៦៦ | ២៨.២៩៩.០២០ | ១៨.៦៧៣.០០០ | ៨១.១៤០ | ១១៩.០៦៧ | ២០៣.២៤៦ | **៨៤.១៧២.៥០៩** |

គុណភាពទឹកតាមបណ្តារោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងបណ្តាញចែកចាយ៖

| មុខវិភាគ | ឯកតា | CNDWQS | WHO | រោងចក្រផលិតទឹកស្អាត | | | | | | | | បណ្តាញចែកចាយ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ភូមិព្រៃក | ជ្រោយចង្វារ | ចំការមន | និរោធ | បាក់ខែង | បឹងធំ | ម្លេច | ត្បូងឃ្មុំ | |
| **ភាពល្អក់** | NTU | ≤ ៥ | ≤ ៥ | ០,២៧ | ០,១៩ | ០,១៨ | ០,៣៧ | ០,០៨ | ០,៨០ | ០,៣១ | ០,២៤ | ០,៣០ |
| **តម្លៃប៉េហាស់** | pH | ៦,៥-៨,៥ | ៦,៥-៨,៥ | ៧,៥៨ | ៧,៦២ | ៧,៦៤ | ៧,៥០ | ៧,៧៣ | ៧,០៨ | ៧,៣១ | ៧,៣៩ | ៧,៥៥ |
| **ក្លរសេរី** | mg/l | ០,១-១,០ | ៥ | ១,៦២ | ១,២៩ | ១,១៥ | ១,៤២ | ១,២២ | ១,២៣ | ១,២៦ | ១,០៦ | ០,៤៦ |
| **ក្លរសរុប** | mg/l | - | - | ១,៨៤ | ១,៤៣ | ១,៣០ | ១,៧៥ | ១,៣៤ | ១,៤៦ | ១,៦៩ | ១,២២ | ០,៥៩ |
| **មេរោគកូលីហ្វម** | cfu/100ml | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| **មេរោគអ៊ីកូលី** | cfu/100ml | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |

# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ( ត )

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

## ក.១- លទ្ធផលការងារប្រព្រឹត្តកម្មប្រព័ន្ធចែកចាយទឹកនិងការងារកាត់បន្ថយទឹកគ្មានចំណូល (ត)

### ក.១.២- លទ្ធផលការងាររៀបចំ ប្រព័ន្ធចែកចាយទឹកស្អាត

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ (គិតជាគីឡូម៉ែត្រ)




### ក.១.៣- លទ្ធផលការងារកាត់បន្ថយទឹកគ្មានចំណូល

ទឹកគ្មានចំណូលរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅក្នុងឆ្នាំ២០២៤ មានអត្រាដូចខាងក្រោម៖

- រាជធានីភ្នំពេញ និងក្រុងតាខ្មៅ : ២៧,២៧%
- ខេត្តកំពត, រោងចក្រផលិតទឹកស្អាតម្លេច : ០,២៩%
- ខេត្តត្បូងឃ្មុំ, រោងចក្រផលិតទឹកស្អាតត្បូងឃ្មុំ : ១៤,៥៩%

## ក.២- សកម្មភាព និងលទ្ធផលការងារអាជីវកម្ម

### ក.២.១- ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋមានចំណូលទាប



# ផ្នែកទី២: ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច (ត)

## ក- លទ្ធផលប្រតិបត្តិការធុរកិច្ចដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក (ត)

### ក.២.២- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន

| ប្រភេទអតិថិជន | ២០១៩ (ចំនួនបណ្តាញ) | ២០២០ (ចំនួនបណ្តាញ) | ២០២១ (ចំនួនបណ្តាញ) | ២០២២ (ចំនួនបណ្តាញ) | ២០២៣ (ចំនួនបណ្តាញ) | ២០២៤ (ចំនួនបណ្តាញ) | ២០២៤ (ភាគរយ) |
|---|---|---|---|---|---|---|---|
| ជីវភាព | ៣២១.២១២ | ៣៣៣.០៩៩ | ៣៥០.៤៦៣ | ៣៦០.៩៤៨ | ៣៨១.៧៥២ | ៣៩៧.៤៧៩ | ៧៩,២៩១៤ |
| អាជីវកម្ម | ៦២.៣៦៦ | ៦៨.១៣៦ | ៧៤.៣៤៤ | ៨៣.៨៧៤ | ៨៩.៧០២ | ៩៧.២៣៤ | ១៩,៣៩៦៨ |
| អង្គភាពរដ្ឋ | ៦៩៦ | ៧៤៤ | ៨២៣ | ៩១៣ | ៩១៨ | ៨៤០ | 0,១៦៧៦ |
| អ្នកលក់ទឹក | ០៧ | ១០ | ១១ | ០៩ | ០៦ | ០៦ | 0,00១២ |
| តំណាងចែកចាយ | ១៧ | ១៤ | ១៦ | ០៥ | ០៣ | ០៣ | 0,000៦ |
| Standpipe | ១៧ | ១៧ | ១៦ | ១៦ | ១៤ | ១៣ | 0,00២៦ |
| បន្ទប់ជួល | ៥.៧៥២ | ៥.៧៥៩ | ៥.៧២៨ | ៥.៧៨៩ | ៥.៧៤៦ | ៥.៧១៤ | ១,១៣៩៩ |
| | ៣៩០.០៦៧ | ៤០៧.៧៧៩ | ៤៣១.៤០១ | ៤៥១.៥៥៤ | ៤៧៨.១៤១ | ៥០១.២៨៩ | |

## ក.៣- ការងារគ្រប់គ្រងធនធានមនុស្ស




*សរុបចំនួនមន្ត្រី-និយោជិតក្នុងឆ្នាំ២០២៤: ១.៤៣៤រូប (ស្រី: ២៤៨រូប)*

## ខ- រចនាសម្ព័ន្ធចំណូល

| ល. រ | ប្រភពចំណូល | ឆ្នាំ២០២៤ (ពាន់រៀល) | ឆ្នាំ២០២៤ ភាគរយ | ឆ្នាំ២០២៣ (កំណត់ឡើងវិញ) (ពាន់រៀល) | ឆ្នាំ២០២៣ ភាគរយ | ឆ្នាំ២០២២ (ពាន់រៀល) | ឆ្នាំ២០២២ ភាគរយ |
|---|---|---|---|---|---|---|---|
| ១ | ចំណូលពីការលក់ | ៣១៧.៧៧៨.៩៩៦ | ៨៩,១៨% | ២៩៧.៤១៦.១៤១ | ៨៩,១៨% | ២៩៩.៧២៣.៥០៧ | ៨៦,៣១% |
| ២ | កម្រៃពីសេវាសាងសង់ | ១១.៣៩២.១១២ | ៤,២៥% | ១៤.៨៥៤.៥៣៩ | ៤,៤៦% | ២៤.៩៧៦.៣១៦ | ៧,១៩% |
| ៣ | ចំណូលពីការប្តូររូបិយប័ណ្ណ-សុទ្ធ | - | - | - | - | ១.១០៥.៧០០ | 0,៣១% |
| ៤ | ចំណូលផ្សេងៗ | ១៨.៥២៦.៦៧០ | ៥,៥២% | ២១.១៣៨.១៥០ | ៦.៣៤% | ២១.៤៧៨.៣៣៣ | ៦,១៨% |
| | ចំណូលសរុប | ៣៤៧.៦៩៧.៧៧៨ | | ៣៣៣.៤០៨.៨៣០ | | ៣៤៧.២៨៣.៨៥៦ | |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម

## ក- អង្គការលេខ



# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## ខ- ក្រុមប្រឹក្សាភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ឯក សុនចាន់ | ប្រធានក្រុមប្រឹក្សាភិបាល | ២១ ឧសភា ២០២៤ | ០៦ មករា ២០២៦ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦ មករា ២០២៣ | ០៦ មករា ២០២៦ |
| ៣ | ឯកឧត្តម ឡុង ណារ៉ូ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦ មករា ២០២៣ | ០៦ មករា ២០២៦ |
| ៤ | ឯកឧត្តម ឆាយ វីរៈ | សមាជិកក្រុមប្រឹក្សាភិបាល | ១៧ កញ្ញា ២០២៤ | ០៦ មករា ២០២៦ |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកក្រុមប្រឹក្សាភិបាល | ២៧ កុម្ភៈ ២០២៣ | ២៧ កុម្ភៈ ២០២៦ |
| ៦ | លោក ស្រេង សំឱក | អភិបាលឯករាជ្យ | ១៣ ឧសភា ២០២២ | ១៣ ឧសភា ២០២៥ |
| ៧ | លោក ណាំ ចន្ទ្រី | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ១៣ ឧសភា ២០២២ | ១៣ ឧសភា ២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញៈ
  - **លោក ហួត សុខហេង**

## គ- បុគ្គលិកជាន់ខ្ពស់

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម ឡុង ណារ៉ូ | ប្រុស | អគ្គនាយក |
| ២ | ឯកឧត្តម នេត មុន្នី | ប្រុស | មន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ |
| ៣ | លោក ម៉ា ណូរ៉ាវីន | ប្រុស | អគ្គនាយករង |
| ៤ | លោកស្រី រឿន ណារី | ស្រី | អគ្គនាយករង |
| ៥ | លោក ជា សតិភទ្ទ | ប្រុស | អគ្គនាយករង |
| ៦ | លោក ផេង ទី | ប្រុស | អគ្គនាយករង |
| ៧ | លោក ដេង ប៉ូលីដេន | ប្រុស | អគ្គនាយករង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ៨ | លោក ជូ ផល្លា | ប្រុស | អគ្គនាយករង និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន |
| ៩ | លោក អ៊ូ គុណវឌ្ឍន៍ | ប្រុស | អគ្គនាយករង |
| ១០ | លោក កាំង សោភីណា | ប្រុស | ជំនួយការអគ្គនាយក |
| ១១ | លោក ហួត សុខហេង | ប្រុស | លេខាធិការសហគ្រាស |
| ១២ | លោក សុខ ណារ៉េត | ប្រុស | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ |
| ១៣ | លោក ទុយ ប៊ុនសេរីទ្ធ | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក |
| ១៤ | លោក កែម កានវិចិត្រ | ប្រុស | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម |
| ១៥ | លោក រាំង ចាន់ភិរម្យ | ប្រុស | ប្រធាននាយកដ្ឋានសាខាសេវាកម្មទឹកស្អាត និងអនាម័យ |
| ១៦ | លោក ខឹម រិទ្ធិ៍យនីន | ប្រុស | ប្រធាននាយកដ្ឋានផែនការ និងគម្រោង |
| ១៧ | លោក សំអូន សិរីសុមនុ | ប្រុស | ប្រធាននាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| ១៨ | លោក អៀ លុច | ប្រុស | ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស |
| ១៩ | កញ្ញា ឈឹម កក្កដា | ស្រី | ប្រធាននាយកដ្ឋានអាជីវកម្ម |
| ២០ | លោកស្រី សេង គាតារា | ស្រី | ប្រធានសវនកម្មផ្ទៃក្នុង |

# ផ្នែកទី៣: ព័ត៌មានអំពីអភិបាលកិច្ចសាជីវកម្ម (ត)

## គ- បុគ្គលិកជាន់ខ្ពស់ (ត)

សមាសភាពបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | ភេទ | តំណែង |
|---|---|---|---|
| ២១ | លោក សារ៉ុផ វឌ្ឍនា | ប្រុស | ប្រធានមណ្ឌលព័ត៌មានវិទ្យា |
| ២២ | លោក ឈឹម សេរីវ៉ុធ | ប្រុស | ប្រធាននីតិកម្ម និងដោះស្រាយវិវាទ |
| ២៣ | លោកស្រី ប្រាក់ ចាន់មករា | ស្រី | ជំនួយការអគ្គនាយករងទទួលបន្ទុករដ្ឋបាល និងធនធានមនុស្ស |
| ២៤ | លោកស្រី ស៊ឹម វល្លិកា | ស្រី | ប្រធានអង្គភាពលទ្ធកម្ម |
| ២៥ | លោក មាស កុសល | ប្រុស | ជំនួយការអគ្គនាយករងទទួលបន្ទុកផែនការ និងគម្រោង |
| ២៦ | លោក រស់ បូរិទ្ធ | ប្រុស | ជំនួយការអគ្គនាយក |
| ២៧ | លោក ប៉ា សំវឌ្ឍនះ | ប្រុស | ជំនួយការអគ្គនាយក |
| ២៨ | លោក យៀប ប៊ុនថា | ប្រុស | ជំនួយការអគ្គនាយក |
| ២៩ | លោកស្រី សេង ពុទ្ធារី | ស្រី | ប្រធានលេខាធិការ នៃអង្គភាពលេខាធិការសហគ្រាស |
| ៣០ | លោក សោម សុវណ្ណ | ប្រុស | ប្រធានអង្គភាពច្រកចេញចូលតែមួយ |

សម្គាល់: ព័ត៌មានលម្អិតពាក់ព័ន្ធអភិបាលកិច្ចសាជីវកម្មមានភ្ជាប់ជាមួយឧបសម្ព័ន្ធ១។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក

## ក- ព័ត៌មានអំពីមូលបត្រ

## ១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

- ឈ្មោះមូលបត្រកម្មសិទ្ធិ: ភាគហ៊ុនធម្មតា
- និមិត្តសញ្ញាមូលបត្រកម្មសិទ្ធិ: PWSA
- ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ: មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
- តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ: ១.០០០រៀល
- ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (IPO Price): ៦.៣០០រៀល
- បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ: ១៣.០៤៥.៩៧៥មូលបត្រកម្មសិទ្ធិ
- មូលធនូបនីយកម្មទីផ្សារ: ៥៥៣.១៤៩.៣១០.៣២០រៀល (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)
- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត: ផ្សារមូលបត្រកម្ពុជា (ផមក)
- កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ: ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

## ខ- ថ្លៃ និងបរិមាណជួញដូរមូលបត្រ

| មូលបត្រកម្មសិទ្ធិ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.២៨០ | ៧.៣០០ | ៧.២៨០ | ៧.២៤០ | ៧.៣៨០ | ៧.៣៦០ |
| | មធ្យម | ៧.២៦៥ | ៧.២៣៤ | ៧.២៥១ | ៧.១៧១ | ៧.២១៥ | ៧.០៤០ |
| | អប្បបរមា | ៧.២២០ | ៧.២៤០ | ៧.១៨០ | ៧.០០០ | ៧.០០០ | ៦.៩៤០ |
| បរិមាណជួញដូរ | អតិបរមា | ២១.៥៥៣ | ៦.៦៥៤ | ៣.៣១០ | ១៩.៥៦១ | ១៤.២៨២ | ២៩.៥០១ |
| | មធ្យម | ២.១៧១ | ១.៤៦៩ | ១.១១១ | ៣.៥៦០ | ៧.១៨២ | ៩.១៤៧ |
| | អប្បបរមា | ២៨ | ៨៨ | ៨៧ | ១៩៧ | ៤១១ | ១.៦១៦ |

| មូលបត្រកម្មសិទ្ធិ | | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមា | ៧.០៨០ | ៧.០០០ | ៦.៨៤០ | ៦.៤៦០ | ៦.៤៨០ | ៦.៣៨០ |
| | មធ្យម | ៧.០៣០ | ៦.៩១៧ | ៦.៦៨៨ | ៦.២៩៣ | ៦.២៧៩ | ៦.២០៩ |
| | អប្បបរមា | ៦.៩៨០ | ៦.៨០០ | ៦.៥០០ | ៦.១៨០ | ៦.១៨០ | ៦.១៦០ |
| បរិមាណជួញដូរ | អតិបរមា | ៣៣.៤២២ | ២០.៦៧៧ | ៨៣.០៥២ | ២១.៥៨៥ | ១៨.៩៣៣ | ២៤.៣៨៩ |
| | មធ្យម | ៧.១៤៣ | ៣.៧៧១ | ១៥.៨១៨ | ៧.៦៨២ | ៦.៣៧៧ | ៧.៤៧៥ |
| | អប្បបរមា | ៤០០ | ១៨២ | ១.១១៧ | ១.១៧១ | ១.០៤១ | ៧៧៦ |

## គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ជាតិ | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|
| ១ | រដ្ឋ តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ៧៣.៩២៧.១៨៧ | ៨៥% |
| សរុប | | | ៧៣.៩២៧.១៨៧ | ៨៥% |

## ឃ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ រ.ទ.ស.ភ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើននោះទេ។

# ផ្នែកទី៤: ព័ត៌មានអំពីការជួញដូរមូលបត្រ និងភាគហ៊ុនិក (ត)

## ង- ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ

| ពិពណ៌នាលំអិតអំពី ការបែងចែកភាគលាភ | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|
| ចំណេញសុទ្ធ (ពាន់រៀល) | ១២៦.៦០៩.៥៨២ | ១០៨.១៨៥.៨៦៥ | ១២៩.២៧៣.៩១៧ |
| ភាគលាភជាសាច់ប្រាក់សរុប (ពាន់រៀល) | ៣០.៤៤០.៦០៦ | ២៨.៧០១.១៤៣ | ២៦.៩៦១.៦៨០ |
| ភាគលាភជាមូលបត្រកម្មសិទ្ធិសរុប | គ្មាន | គ្មាន | គ្មាន |
| ភាគលាភផ្សេងៗទៀត | គ្មាន | គ្មាន | គ្មាន |
| អនុបាតនៃការបែងចែកភាគលាភ | ២៤,០៤ % | ២៦,៥៣ % | ២០,៨៦ % |
| ទិន្នផលភាគលាភ | * ៤,៨១ % | * * ៤,៣៧ % | * * * ៤,៣៣ % |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | ៣៥០ រៀល | ៣៣០ រៀល | ៣១០ រៀល |

*ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ គឺ ៧.២៨០រៀល
* *ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ គឺ ៧.៥៦០រៀល
* * * ថ្លៃបិទទីផ្សារប្រចាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ គឺ ៧.១៦០រៀល

## ផ្នែកទី៥:

# របាយការណ៍សវនកម្ម
# របស់សវនករផ្ទៃក្នុង

## លើការត្រួតពិនិត្យផ្ទៃក្នុង

# របាយការណ៍សវនកម្មផ្ទៃក្នុង

## ស្ដីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

### ប្រចាំឆ្នាំ២០២៤

### ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ២

# ផ្នែកទី៦:

# របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយ

## សវនករឯករាជ្យ

# របាយការណ៍ហិរញ្ញវត្ថុ
# និង
# របាយការណ៍របស់សវនករឯករាជ្យ

**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**

**ត្រូវបានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ៣**

# ផ្នែកទី៧: ព័ត៌មានអំពីប្រតិបត្តិការ ជាមួយភាគីជាប់ពាក់ព័ន្ធ និងទំនាស់ផលប្រយោជន៍

ក- ប្រតិបត្តិការសំខាន់ៗជាមួយភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ នៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរលើទីផ្សារ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ខ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

គ- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិកពាក់ព័ន្ធនឹងការទិញ-លក់ទ្រព្យសកម្ម និងសេវាកម្ម

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឃ- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិកដែលមានភាគហ៊ុនចាប់ពី៥ (ប្រាំ) ភាគរយឡើងទៅ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ង- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់បុគ្គលចុះបញ្ជី

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់បុគ្គលបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គល ទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយ រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ច- ប្រតិបត្តិការសំខាន់ៗជាមួយ បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធ ជាមួយបុគ្គលធ្លាប់ជាអភិបាល

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ឆ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀតក្រៅពី រ.ទ.ស.ភ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

ជ- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ពី រ.ទ.ស.ភ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ

គិតត្រឹមការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើយចំពោះ រ.ទ.ស.ភ ទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

រ.ទ.ស.ភ មានចំណូល៣ប្រភេទធំៗ គឺចំណូលបានមកពីការលក់ទឹក សេវាសាងសង់ និងចំណូលផ្សេងៗ៖

- ចំណូលបានមកពីការលក់ទឹករួមមាន:ចំណូលពីការប្រើប្រាស់ប្រភេទជីវភាព អាជីវកម្ម ឧស្សាហកម្ម អង្គភាពរដ្ឋ បន្ទប់ជួល និងអ្នកលក់ទឹកបន្ត។ ចំណូលទាំងនេះត្រូវបានរាយការណ៍តាមតម្លៃទទួលបានសុទ្ធ ក្រោយការកាត់កងជាមួយ អប្បហារវិភាជន៍ និងឥណទានហើយត្រូវបានទទួលស្គាល់តាមបរិមាណទឹកដែលបានផ្គត់ផ្គង់ជូនអតិថិជនរបស់ខ្លួន។ ការធ្វើវិក្កយបត្រនៃការប្រើប្រាស់ទឹក ត្រូវបានធ្វើឡើងក្នុងរយៈពេលរៀងរាល់២ខែម្តង។

- ចំណូលបានពីសេវាសាងសង់: គឺជាចំណូលបានមកពីសេវាសាងសង់ ទាក់ទិនទៅនឹងការប្តូរ និងការពង្រីកប្រព័ន្ធចែកចាយទឹកដែល រ.ទ.ស.ភ បានសាងសង់ជូនក្រុមហ៊ុនសំណង់មួយ។

- ចំណូលផ្សេងៗរួមមាន: ចំណូលបានមកពីការថែទាំនាឡិកា លក់សម្ភារតបណ្តាញទឹក ការផាកពិន័យលើការប្រើប្រាស់ទឹកពុំមានការអនុញ្ញាតពី រ.ទ.ស.ភ និងផ្សេងៗ។

- **ចំណូលថែទាំនាឡិកា៖** គឺចំណូលបានពីថ្លៃឈ្នួលថែទាំនាឡិកាដោយគិតថ្លៃ៥០រៀលក្នុង១មីលីម៉ែត្រក្នុងមួយខែនៃទំហំនាឡិកាទឹកក្នុងអំឡុងវដ្តនៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល។ ចំណូលនេះត្រូវបានប្រើប្រាស់សម្រាប់ផ្លាស់ប្តូរនាឡិកាជូនអតិថិជននាពេលអនាគត។
- **ចំណូលពីការលក់សម្ភារតបណ្តាញទឹក៖** គឺជាចំណូលទទួលបានពីការលក់នាឡិកាស្ទង់ទឹក បំពង់ និងសម្ភារតភ្ជាប់។
- **ចំណូលពីការផាកពិន័យ៖** គឺជាចំណូលទទួលបានពីការផាកពិន័យលើការបង់ថ្លៃប្រើប្រាស់ទឹកយឺតយ៉ាវ និងពិន័យលើបទល្មើសតបណ្តាញទឹកដោយពុំមានការអនុញ្ញាតពី រ.ទ.ស.ភ។
- **ចំណូលផ្សេងៗ៖** គឺជាចំណូលទទួលបានមកពីការរួមចំណែករបស់អតិថិជនប្រភេទពាណិជ្ជកម្ម និងឧស្សាហកម្មក្នុងការវិនិយោគសម្រាប់ការភ្ជាប់បណ្តាញពិសេសចូលទីតាំងផ្ទាល់របស់ពួកគេ។ក្រៅពីនោះ គឺជាចំណូលដែលទទួលបានពីកម្រៃសេវាលើការទារថ្លៃថែទាំលូទឹកស្អុយរបស់សាលារាជធានីភ្នំពេញ។

➢**ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| បរិយាយ | ឆ្នាំ២០២៤ ពាន់រៀល | ឆ្នាំ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | បម្រែបម្រួល ពាន់រៀល | បម្រែបម្រួល ភាគរយ |
|---|---|---|---|---|
| | (ក) | (ខ) | (ក-ខ) | (ក-ខ)/ខ*១០០ |
| ចំណូលសរុប | ៣៤៧.៦៩៧.៧៧៨ | ៣៣៣.៤០៨.៨៣០ | ១៤.២៨៨.៩៤៨ | ៤,២៩% |

រ.ទ.ស.ភ មានចំណូលសរុប ៣៤៧.៦៩៧.៧៧៨.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ៣៣៣.៤០៨.៨៣០.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ១៤.២៨៨.៩៤៨.០០០រៀល ស្មើនឹង ៤,២៩%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងនៃចំណូលសរុបនេះ ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ២០.៣៦២.៨៥៥.០០០រៀល ស្មើនឹង ៦,៨៥%។

### ២- ការវិភាគចំណូលតាមផ្នែក

ការវិភាគចំណូលតាមផ្នែករបស់ រ.ទ.ស.ភ មានដូចខាងក្រោម:

| បរិយាយ | ឆ្នាំ២០២៤ ពាន់រៀល | ភាគរយ | ឆ្នាំ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | ភាគរយ |
|---|---|---|---|---|
| ចំណូលពីការលក់ | ៣១៧.៧៧៨.៩៩៦ | ៩១,៤០% | ២៩៧.៤១៦.១៤១ | ៨៩,២០% |
| កម្រៃពីការសាងសង់ | ១១.៣៩២.១១២ | ៣,២៨% | ១៤.៨៥៤.៥៣៩ | ៤,៤៦% |
| ចំណូលផ្សេងៗ | ១៨.៥២៦.៦៧០ | ៥,៣៣% | ២១.១៣៨.១៥០ | ៦,៣៤% |
| **ចំណូលសរុប** | ៣៤៧.៦៩៧.៧៧៨ | | ៣៣៣.៤០៨.៨៣០ | |

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ២- ការវិភាគចំណូលតាមផ្នែក (ត)

មានតែប្រាក់ចំណូលតាមប្រភេទជាសារវន្តត្រូវបានលើកឡើងសម្រាប់ការវិភាគខាងក្រោម៖

➤ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| បរិយាយ | ឆ្នាំ២០២៤ | | ឆ្នាំ២០២៣ | | បម្រែបម្រួល | | |
|---|---|---|---|---|---|---|---|
| | បរិមាណ | ទឹកប្រាក់ | បរិមាណ | ទឹកប្រាក់ (កំណត់ឡើងវិញ) | បរិមាណ | ទឹកប្រាក់ | ភាគរយ |
| | (ម$^{៣}$) | (ពាន់រៀល) | (ម$^{៣}$) | (ពាន់រៀល) | (ម$^{៣}$) | (ពាន់រៀល) | |
| | (ក) | (ខ) | (គ) | (ឃ) | (ក-គ) | (ខ-ឃ) | (ខ-ឃ)/ឃ*១០០ |
| ជីវភាព | ១១០.៦១៥.៦១៥ | ១១០.៦២០.៣២០ | ១២៩.៣០៩.៥៣៤ | ១០៥.១៥៦.០៣២ | (១៨.៦៩៣.៩១៩) | ៥.៤៦៤.២៨៨ | ៥,២០% |
| អាជីវកម្ម | ៩៤.៨០៤.៩០៨ | ១៦០.១២៨.៣៦៧ | ៩២.៩៧៣.៤៥៤ | ១៤៥.៨៧៤.៨១២ | ១.៨៣១.៤៥៤ | ១៤.២៥៣.៥៥៥ | ៩,៧៧% |
| គ្រឹះស្ថានសាធារណៈ | ៩.២៩១.០១៥ | ២៣.០៥៤.២៧០ | ១០.២១៣.៨៦១ | ២១.៥៨៦.២៤០ | (៩២២.៨៤៦) | ១.៤៦៨.០៣០ | ៦,៨០% |
| តំណាងចែកចាយ និងបន្ទប់ជួល | ១៣.១០១.៨១០ | ៩.៩១០.៥៨៧ | ១៦.៦៨៣.៥៤៧ | ៩.៦៧៩.៨៩៥ | (៣.៥៨១.៧៣៧) | ២៣០.៦៩២ | ២,៣៨% |

💧 **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់តាមផ្ទះ (ប្រភេទជីវភាព)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទជីវភាពមានចំនួន ១១០.៦២០.៣២០.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ១០៥.១៥៦.០៣២.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ៥.៤៦៤.២៨៨.០០០រៀល ស្មើនឹង ៥,២០%។ យើងឃើញថាទោះបីជា បរិមាណទឹកប្រើប្រាស់ក្នុង១បណ្តាញក្នុង១ខែបានថយចុះចំនួន ៥,៣៣ម$^{៣}$ (ពី ៣០,៤៦ម$^{៣}$ មក ២៥,១៣ម$^{៣}$) ប៉ុន្តែថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ១៨៦,៨៣រៀល/ម$^{៣}$ (ពី ៨១៣,២១រៀល/ម$^{៣}$ ទៅ ១.០០០,០៤រៀល/ម$^{៣}$)។

💧 **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម (ប្រភេទអាជីវកម្ម និងឧស្សាហកម្ម)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអាជីវកម្មចំនួន ១៦០.១២៨.៣៦៧.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ១៤៥.៨៧៤.៨១២.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ១៤.២៥៣.៥៥៥.០០០រៀល ស្មើនឹង ៩,៧៧%។ យើងឃើញថាទោះបីជា បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានថយចុះចំនួន ៥,៦០ម$^{៣}$ (ពី ៨៩,៣៣ម$^{៣}$ មក ៨៣,៧៣ម$^{៣}$) ប៉ុន្តែថ្លៃលក់ទឹកជាមធ្យមបានកើនឡើងចំនួន ១២០,០៤រៀល/ម$^{៣}$ (ពី ១.៥៦៨,៩៩រៀល/ម$^{៣}$ ទៅ ១.៦៨៩,០៣រៀល/ម$^{៣}$)។

💧 **ចំណូលពីការលក់ទឹកស្អាតជូនអ្នកប្រើប្រាស់គ្រឹះស្ថានសាធារណៈ (ប្រភេទអង្គភាពរដ្ឋ)**

ចំណូលថ្លៃលក់ទឹកជូនអតិថិជនប្រភេទអង្គភាពរដ្ឋចំនួន ២៣.០៥៤.២៧០.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ២១.៥៨៦.២៤០.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ១.៤៦៨.០៣០.០០០រៀល ស្មើនឹង ៦,៨០%។ យើងឃើញថាទោះបីជា បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានថយចុះចំនួន ១៤០,៨៤ម$^{៣}$ (ពី ១.០៣២,៥៩ម$^{៣}$ មក ៨៩១,៧៥ម$^{៣}$) ប៉ុន្តែថ្លៃលក់ទឹកជាមធ្យមថេរ ២.៥០០រៀល/ម$^{៣}$។

💧 **ចំណូលបានពីការលក់ទឹកស្អាតជូនតំណាងចែកចាយ និងបន្ទប់ជួល**

ចំណូលពីការលក់ទឹកស្អាតជូនតំណាងចែកចាយ/បន្ទប់ជួលចំនួន ៩.៩១០.៥៨៧.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ៩.៦៧៩.៨៩៥.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ២៣០.៦៩២.០០០រៀល ស្មើនឹង ២,៣៨%។ យើងឃើញថាទោះបីជា បរិមាណទឹកប្រើប្រាស់ក្នុងមួយបណ្តាញក្នុងមួយខែបានថយចុះចំនួន ៥០,៩៨ម$^{៣}$ (ពី ២៣៩,៣៥ម$^{៣}$ មក ១៨៨,៣៧ម$^{៣}$) ប៉ុន្តែថ្លៃលក់ទឹកជាមធ្យមកើនឡើងចំនួន ១៧៦,២២រៀល/ម$^{៣}$ (ពី ៥៨០,២១រៀល/ម$^{៣}$ ទៅ ៧៥៦,៤៣រៀល/ម$^{៣}$)។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៣- ការវិភាគគម្លាតចំណេញដុល

រ.ទ.ស.ភ បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួនក្នុងទម្រង់ជារបាយការណ៍លទ្ធផលតាមប្រភេទ ដូចនេះពុំមានការបង្ហាញ ឲ្យឃើញនៅចំណេញដុលនោះទេ។ ប៉ុន្តែក្នុងទម្រង់របាយការណ៍នេះអាចឲ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញប្រតិបត្តិការ ដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។

ចំណាយប្រត្តិបត្តិការនឹងលើកយកមកពិភាក្សានៅចំណុចទី ៤- ការវិភាគចំណេញ/(ខាត)មុនបង់ពន្ធខាងក្រោម។

### ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

ការចំណេញមុនបង់ពន្ធគឺជាលទ្ធផលដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ និង ចំណូល (ចំណាយ) ការប្រាក់សុទ្ធ។ ក្នុងការពិភាក្សា និងការវិភាគនៃចំណាយប្រតិបត្តិការ យើងលើកយកតែចំណាយរំលស់ ទ្រព្យសកម្មរូបីនិងអរូបី ចំណាយលើការប្រើប្រាស់អគ្គិសនី និងចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត ចំណាយសេវាសាងសង់ ចំណូល (ចំណាយ) ការប្រាក់ យកមកពិភាក្សាដូចខាងក្រោម៖

- **ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| បរិយាយ | ឆ្នាំ២០២៤ ពាន់រៀល | ឆ្នាំ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ពាន់រៀល | ភាគរយ |
| | ក | ខ | ក - ខ | (ក-ខ)/ខ*១០០ |
| ចំណូលសរុប | ៣៤៧.៦៩៧.៧៧៨ | ៣៣៣.៤០៨.៨៣០ | ១៤.២៨៨.៩៤៨ | ៤,២៩% |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និង ទ្រព្យសកម្មអរូបី | (៥៩.៥១៥.៩១៤) | (៦១.៩៧៨.១៣៤) | ២.៤៦២.២២០ | (៣,៩៧%) |
| ចំណាយការប្រើប្រាស់អគ្គិសនី | (៤៨.៦៥៣.០៦៣) | (៤២.២៩១.៤៤៦) | (៦.៣៦១.៦១៧) | ១៥,០៤% |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | (៨៥.៥៥២.៥១០) | (៨០.២៩២.៤៣៨) | (៥.២៦០.០៧២) | ៦,៥៥% |
| ចំណាយវត្ថុធាតុដើមសម្រាប់ ផលិតទឹកស្អាត | (១៨.៩៧៦.៥៩០) | (១៥.៨៧៥.៣១៣) | (៣.១០១.២៧៧) | ១៩,៥៤% |
| ចំណាយសេវាសាងសង់ | (៨.៩៦១.៥៩៦) | (៩.៧៣១.៥១៨) | ៧៦៩.៩២២ | (៧,៩១%) |
| ចំណូលហិរញ្ញវត្ថុ | ៥៧.១៦៩.៣៨៧ | ៣៩.០៣៨.៥៩១ | ១៨.១៣០.៧៩៦ | ៤៦,៤៤% |
| ចំណាយហិរញ្ញវត្ថុ | (៣៩.០០១.៤៧៦) | (២៥.៨៦០.៥៩៧) | (១៣.១៤០.៨៧៩) | ៥០,៨១% |
| **ចំណេញមុនបង់ពន្ធ** | **១០៧.១៧៤.៣៦១** | **៩៨.៩៣៨.០៤៧** | **៨.២៣៦.៣១៤** | **៨,៣២%** |

រ.ទ.ស.ភ មានចំណេញមុនបង់ពន្ធចំនួន ១០៧.១៧៤.៣៦១.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ៩៨.៩៣៨.០៤៧.០០០រៀល សម្រាប់ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ៨.២៣៦.៣១៤.០០០រៀល ស្មើនឹង ៨,៣២%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងចំណេញមុនបង់ពន្ធ ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ១៤.២៨៨.៩៤៨.០០០រៀល ស្មើនឹង ៤,២៩% និងចំណូលហិរញ្ញវត្ថុបានកើនឡើងចំនួន ១៨.១៣០.៧៩៦.០០០រៀល ស្មើនឹង ៤៦,៤៤% ទោះបីជាចំណាយហិរញ្ញវត្ថុបានកើនឡើងចំនួន ១៣.១៤០.៨៧៩.០០០រៀល ស្មើនឹង ៥០,៨១%។

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

រ.ទ.ស.ភ ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ចត្រូវបង់ពន្ធលើប្រាក់ចំណូលអត្រា ២០%។ ដោយឡែកពន្ធលើប្រាក់ចំណូលដែលជាប់អត្រា ២០% បានមកពីលទ្ធផលនៃប្រាក់ចំណេញគណនេយ្យទូទាត់ជាមួយនឹងចំណាយដែលមិនអាចកាត់កងបានក្នុងអត្រាពន្ធ ២០%។

# ផ្នែកទី៥: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៥- ការវិភាគចំណេញ/(ខាត) និងលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (ត)

**ដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ប្រៀបធៀបជាមួយដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| បរិយាយ | ឆ្នាំ២០២៤ ពាន់រៀល | ឆ្នាំ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | បម្រែបម្រួល | |
|---|---|---|---|---|
| | | | ពាន់រៀល | ភាគរយ |
| | គ | ឃ | គ - ឃ | (គ-ឃ)/ឃ*១០០ |
| ចំណេញមុនបង់ពន្ធ (ក) | ១០៧.១៧៤.៣៦១ | ៩៨.៩៣៨.០៤៧ | ៨.២៣៦.៣១៤ | ៨,៣២% |
| ចំណាយពន្ធ (ខ) | (២២.១៣១.៤៤៨) | (២៦.២៩០.៤៧៥) | ៤.១៥៩.០២៧ | (១៥,៨២%) |
| ចំណេញក្នុងការិយបរិច្ឆេទ | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ | ១២.៣៩៥.៣៤១ | ១៧,០៦% |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ | ១២.៣៩៥.៣៤១ | ១៧,០៦% |
| អត្រាពន្ធប្រសិទ្ធភាពលើប្រាក់ចំណេញ (ខ)/(ក) | ២០,៦៥% | ២៦,៥៧% | | |

រ.ទ.ស.ភ មានចំណេញក្នុងការិយបរិច្ឆេទចំនួន ៨៥.០៤២.៩១៣.០០០រៀល នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និង ៧២.៦៤៧.៥៧២.០០០រៀល នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់កើនឡើងចំនួន ១២.៣៩៥.៣៤១.០០០រៀល ស្មើនឹង ១៧,០៦%។ យើងឃើញថាកត្តាចម្បងនៃការកើនឡើងចំណេញក្នុងការិយបរិច្ឆេទ ដោយសារចំណូលពីការលក់បានកើនឡើងចំនួន ១៤.២៨៨.៩៤៨.០០០រៀល ស្មើនឹង ៤,២៩% និងចំណូលហិរញ្ញវត្ថុបានកើនឡើងចំនួន ១៨.១៣០.៧៩៦.០០០រៀល ស្មើនឹង ៤៦,៤៤% ព្រមទាំងចំណាយពន្ធបានថយចុះចំនួន ៤.១៥៩.០២៧.០០០រៀល ស្មើនឹង ១៥,៨២%។

### ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ស្ថានភាពអូសបន្លាយពេលនៃសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ក៏ដូចជាស្ថានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកបានបន្តធ្វើអោយប៉ះពាល់ដល់ការរីកចំរើននៃសេដ្ឋកិច្ចពិភពលោក និងនៅក្នុងតំបន់ផងដែរ ប៉ុន្តែទោះជាយ៉ាងណា រ.ទ.ស.ភ នៅតែបន្តប្រតិបត្តិការប្រចាំថ្ងៃ និងនៅតែមានផលចំណេញ ក្នុងឆ្នាំ២០២៤។ ការបន្តរក្សាបាននូវផលចំណេញនេះ ដោយសារចំណូលពីការលក់នៅតែមានកំណើនដែរ គឺដោយសារតែមានកត្តាគាំទ្រ ដូចខាងក្រោម៖

- **ការបង្កើនចំនួនអតិថិជន៖** ដើម្បីទទួលបាននូវចំណូលពីការលក់ទឹកស្អាត រ.ទ.ស.ភ. បានបង្កើនចំនួនអតិថិជន របស់ខ្លួន ដោយពង្រីកផ្ទៃសេវាផ្គត់ផ្គង់ទឹកស្អាតទៅតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់ទឹកស្អាត ដូចជាការបំពេញផ្ទៃសេវាឲ្យបាន ១០០% នៅក្នុងរាជធានីភ្នំពេញ តំបន់ជុំវិញរាជធានីភ្នំពេញ ជាពិសេសតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ច។

- **ការបង្កើនថ្លៃលក់ទឹកមធ្យម៖** តាមរយៈការស្វែងរកអតិថិជន ដែលជាប្រភេទអាជីវកម្ម-ឧស្សាហកម្ម ធ្វើឲ្យថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ កើនឡើងដោយសារតែថ្លៃប្រើប្រាស់ទឹករបស់អតិថិជនប្រភេទនេះ មានកម្រិតខ្ពស់ជាងអតិថិជនប្រភេទផ្សេងទៀត។

- **ការគ្រប់គ្រងលើការចំណាយប្រតិបត្តិការ៖** រ.ទ.ស.ភ ធ្វើការគ្រប់គ្រងលើការចំណាយនេះ ពិសេសការចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនីដែលជាចំណាយដ៏ធំ និងសំខាន់ក្នុងដំណើរការផលិតទឹកស្អាត តាមរយៈការប្រើប្រាស់នូវ បច្ចេកវិទ្យាថ្មីៗ ដូចជាជ្រើសរើសយកការប្រើប្រាស់ម៉ាស៊ីនបូមទឹកដែលអាចប្រែប្រួលទៅតាមសំពាធទឹក ក៏ដូចជាការចាត់ចែងការប្រើប្រាស់នូវវត្ថុធាតុដើមក្នុងការផលិតទឹកប្រកបដោយប្រសិទ្ធភាព និងសន្សំសំចៃខ្ពស់។

ចំពោះការចំណាយដំណើរការសហគ្រាស រ.ទ.ស.ភ ក៏បានខិតខំកាត់បន្ថយនូវការចំណាយដែលមិនចាំបាច់ ដូចជាចំណាយរដ្ឋបាលទូទៅ ចំណាយលើការជួសជុលថែទាំទូទៅ ដែលអង្គភាពបានយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យ និងថែទាំឧបករណ៍បរិក្ខាប្រើប្រាស់ជាប្រចាំ ដើម្បីធានាបានគុណភាពប្រើប្រាស់ និងកាត់បន្ថយការចំណាយជួសជុលនានា។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ( ត )

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ (ត)

### ៦- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ (ត)

- **ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវដំណើរការកិច្ចលទ្ធកម្ម៖** រ.ទ.ស.ភ បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់បញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗសម្រាប់ដំណើរការកិច្ចលទ្ធកម្មក្នុងការទិញសម្ភារ បរិក្ខារ និងវត្ថុធាតុដើម ដែលដំណើរការនេះឆ្លុះបញ្ចាំងឱ្យឃើញពី តម្លាភាព និងការប្រកួតប្រជែងថ្លៃទំនិញនៅលើទីផ្សារដែលជាហេតុធ្វើឲ្យ រ.ទ.ស.ភ ទទួលបានការទិញទំនិញមានតម្លៃសមរម្យ គុណភាពអាចទទួលយកបាន។

- **ការគ្រប់គ្រងសាច់ប្រាក់៖** តាមរយៈអត្រាទារប្រាក់ដែលមានកម្រិតខ្ពស់៩៩,៩០% បានធ្វើឲ្យ រ.ទ.ស.ភ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ដោយទទួលបាននូវប្រសិទ្ធភាពខ្ពស់។ ក្នុងការគ្រប់គ្រង រ.ទ.ស.ភ បានរក្សាទុកនូវសាច់ប្រាក់សម្រាប់ប្រើប្រាស់ជាទុនបង្វិលក្នុងរយៈពេល ២ទៅ៣ខែ ឯសាច់ប្រាក់ដែលទំនេរពុំមានតម្រូវការប្រើប្រាស់ រ.ទ.ស.ភ បានធ្វើការវិនិយោគរយៈពេលខ្លី ដោយដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលខ្លីនៅធនាគារពាណិជ្ជ ជាមួយនឹងការទទួលបាននូវអត្រាការប្រាក់ខ្ពស់ ប៉ុន្តែ រ.ទ.ស.ភ ក៏បានធ្វើការថ្លឹងថ្លែងពីហានិភ័យ និងផលចំណេញពីអត្រាការប្រាក់ខ្ពស់នេះផងដែរ។

- **ការជ្រើសរើសយកនូវអ្នកផ្តល់ហិរញ្ញប្បទានដែលផ្តល់អត្រាការប្រាក់ទាប៖** ដោយសារមានតម្រូវការប្រើប្រាស់ទឹកស្អាត កើនឡើងខ្ពស់ ធ្វើឲ្យ រ.ទ.ស.ភ មានតម្រូវការហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគដូចជាការ សាងសង់រោងចក្រផលិតទឹកស្អាត ការតបណ្តាញមេនាំទឹក និងបណ្តាញចែកចាយ។ រ.ទ.ស.ភ បានស្វែងរកដៃគូអភិវឌ្ឍអន្តរជាតិ ដូចជាទីភ្នាក់ងារបារាំង សម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីទទួលបាននូវហិរញ្ញប្បទាន ដែលមានអត្រាការប្រាក់ទាប។

- **ស្ថានភាពសេដ្ឋកិច្ច៖** ទោះបីជាសង្គ្រាមរវាងប្រទេសរុស្ស៊ី និងអ៊ុយក្រែន ក៏ដូចសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន នៅតែបន្តអូសបន្លាយ បានធ្វើឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោក ក៏ដូចប្រទេសកម្ពុជា ក៏ថ្លៃលក់ទឹកមធ្យមរបស់ រ.ទ.ស.ភ ពុំមានការប៉ះពាល់ខ្លាំងឡើយ។

## ខ- កត្តាសំខាន់ដែលប៉ះពាល់លើប្រាក់ចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

ដោយយោងទៅតាមការសិក្សា នៃតម្រូវការប្រើប្រាស់ទឹកធៀបទៅនឹងកំណើនប្រជាជន នៅក្នុងរាជធានីភ្នំពេញ ដោយសារការពង្រីកតំបន់ជុំវិញរាជធានីភ្នំពេញ រ.ទ.ស.ភ បានធ្វើការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហាន១ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ និងបានប្រកាសដាក់ឱ្យដំណើរការកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ និងកំពុងបន្តសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហាន២ ដែលមានសមត្ថភាពផលិត ១៩៥.០០០ម៣/ថ្ងៃ ដូចគ្នា ដែលគ្រោងនឹងដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០២៤ និងរោងចក្រផលិតទឹកស្អាតបឹងធំ ដែលមានសមត្ថភាពផលិត ៥.០០០ម៣/ថ្ងៃ គ្រោងដាក់ឱ្យដំណើរការពាក់កណ្តាលឆ្នាំ២០២៤ ផងដែរ ដើម្បីបំពេញតម្រូវការទឹកស្អាតនាបច្ចុប្បន្ន និងពេលអនាគត។

### ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត អាចប៉ះពាល់ដល់ថ្លៃដើមផលិត ប៉ុន្តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរនោះទេ ដោយសារការចំណាយនេះមានអត្រាមិនលើសពី១០% នៃចំណាយប្រតិបត្តិការ។ ទោះជាយ៉ាងណាក៏ដោយ រ.ទ.ស.ភ ក៏បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវនីតិវិធីលទ្ធកម្ម ដើម្បីធានាថ្លៃវត្ថុធាតុដើមសមស្របទៅតាមតម្លៃលើទីផ្សារជាក់ស្តែង ហើយនីតិវិធីនេះ ក៏ផ្តល់លទ្ធភាពសម្រាប់ រ.ទ.ស.ភ ទទួលបាននូវតម្លៃប្រកួតប្រជែងដែលមានតម្លៃទាប។

### ៣- ការវិភាគលើពន្ធ

រ.ទ.ស.ភ. ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារ និងអាករ ដូចនេះ រ.ទ.ស.ភ មានកាតព្វកិច្ច ត្រូវបង់ពន្ធអាករទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ រ.ទ.ស.ភ មានកាតព្វកិច្ចបង់ពន្ធអាករ ទៅតាមរបបស្វ័យប្រកាស និង ជាសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ នេះ គណៈគ្រប់គ្រងយល់ថា រ.ទ.ស.ភ ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ រ.ទ.ស.ភ គឺចំណូលពីការលក់ (ចំណូលលក់ទឹក និងភ្ជាប់បណ្តាញ) ដែលជាតម្រូវការចាំបាច់របស់ប្រជាជននៅក្នុងរាជធានីភ្នំពេញ។ ចំណូលនេះបានចូលរួមចំណែកប្រមាណ ៩១.៤០% នៃចំណូលសរុបនៅក្នុងឆ្នាំ២០២៤ ហើយ រ.ទ.ស.ភ ក៏ជាអ្នកផ្គត់ផ្គង់ផ្តាច់មុខនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ។ ប្រាក់ចំណូលនេះអាចមានការកើនឡើង អាស្រ័យទៅតាមកំណើននៃចំនួនប្រជាពលរដ្ឋដែលរស់នៅ ក្នុងរាជធានីភ្នំពេញ និងតំបន់ទីក្រុងតាខ្មៅផងដែរ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ឃ.១- ផលប៉ះពាល់នៃអត្រាប្តូរប្រាក់

រ.ទ.ស.ភ បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ"ប្រាក់រៀល"។ប្រតិបត្តិការជារូបិយប័ណ្ណបរទេសត្រូវបានប្តូរទៅជារូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះការប្តូរទ្រព្យសកម្ម និងបំណុលរូបិយប័ណ្ណបរទេសត្រូវបានកត់ត្រានៅក្នុងរបាយ-ការណ៍លទ្ធផលលម្អិត។ ចំពោះការទូទាត់ទំនិញរបស់ រ.ទ.ស.ភ ភាគច្រើនធ្វើឡើងដោយប្រាក់រៀល ដូចនេះពុំមានផលប៉ះពាល់ខ្លាំងដោយអត្រាប្តូរប្រាក់នោះទេ។

### ឃ.២- ផលប៉ះពាល់នៃអត្រាការប្រាក់

#### ឃ.២.១- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណូលការប្រាក់

ដោយសារនៅប្រទេសកម្ពុជាពុំមានទីផ្សាររូបិយប័ណ្ណ ដូច្នេះ រ.ទ.ស.ភ មានលទ្ធភាពត្រឹមតែវិនិយោគរយៈពេលខ្លី លើការដាក់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៣ខែ ទៅ៩ខែ ទៅ១២ខែ នៅធនាគារពាណិជ្ជក្នុងស្រុកតែប៉ុណ្ណោះ។

#### ឃ.២.២- ផលប៉ះពាល់នៃអត្រាការប្រាក់លើចំណាយការប្រាក់

រ.ទ.ស.ភ មានប្រភពហិរញ្ញប្បទានពីរ ដែលមានអត្រាការប្រាក់ថេរ និងប្រែប្រួល។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ ថេរមាន ហិរញ្ញប្បទានដែលទទួលតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មានកម្រិតអត្រា១,៦៥% និងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA)មានកម្រិតអត្រា០,៦៦% ក្នុងមួយឆ្នាំ។ ហិរញ្ញប្បទានដែលមានអត្រាការប្រាក់ប្រែប្រួលមាន ហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) នៅអត្រា EURIBOR ៦ខែ ដក១,៣៥ពិន្ទុ។ តែអត្រានេះមិនឲ្យទាបជាង០,២៥% និងមិនខ្ពស់ជាង៥,២១% ក្នុងឆ្នាំនោះទេ។

### ឃ.៣- ផលប៉ះពាល់នៃថ្លៃទំនិញ

តាមរយៈដំណើរការកិច្ចលទ្ធកម្មរបស់ រ.ទ.ស.ភ ដែលអនុលោមទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន រួមផ្សំនឹងគោលការណ៍ណែនាំផ្សេងៗ ដែលតម្រូវឲ្យ រ.ទ.ស.ភ ធ្វើកិច្ចសន្យាជាមួយអ្នកផ្គត់ផ្គង់សម្ភារ និង វត្ថុធាតុដើមទៅតាមតម្លៃប្រកួតប្រជែងឬតម្លៃចរចាររួច។ ការអូសបន្លាយនៃសង្គ្រាមរវាងប្រទេសរុស្សីនិងអ៊ុយក្រែន និងសង្គ្រាមរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីនបានធ្វើអោយតម្លៃសម្ភារ និងវត្ថុធាតុដើមនៅលើទីផ្សារក្នុងស្រុក និងក្រៅស្រុកមានការកើនឡើង។ ការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើម ក៏បានជះឥទ្ធិពលដល់ចំណាយវិនិយោគ និងចំណាយដំណើរការរបស់ រ.ទ.ស.ភ ផងដែរ។ ប៉ុន្តែទោះបីជាការកើនឡើងនៃតម្លៃសម្ភារ និងវត្ថុធាតុដើមដូចនេះក្តីក៏គណៈគ្រប់គ្រងបានគិតគូរយ៉ាងហ្មត់ចត់លើផែនការ និងតម្រូវការសម្ភារ បរិក្ខា វត្ថុធាតុដើម ដើម្បីធានាអោយការប្រើប្រាស់បានទាន់ពេល និងមានតម្លៃសមរម្យ ដោយអនុវត្តតាមច្បាប់លទ្ធកម្មសាធារណៈជាធរមាន។

## ង- ផលប៉ះពាល់នៃអតិផរណា

រ.ទ.ស.ភ បានរក្សានូវថ្លៃលក់ទឹកថេរមិនប្រែប្រួលចាប់តាំងពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០១៩។ ដើម្បីធ្វើការកែសម្រួលទៅ តាមការប្រែប្រួលនៃអតិផរណា យើងបានធ្វើការកែសម្រួលនូវថ្លៃលក់ទឹកស្អាតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់បច្ចុប្បន្ន ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុបានយ៉ាងល្អប្រសើរ។

# ផ្នែកទី៨: ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង (ត)

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល

ធុរកិច្ចរបស់ រ.ទ.ស.ភ ទទួលការជះឥទ្ធិពលពីគោលនយោបាយមួយចំនួន ដែលកំណត់ដោយរាជរដ្ឋាភិបាលដូចជា៖

- **ការពង្រីកផ្ទៃសេវា៖** ការពង្រីកផ្ទៃសេវាបន្ថែមដើម្បីផ្គត់ផ្គង់ទឹកស្អាត ត្រូវបានរឹតត្បិតដោយបេសកកម្មរបស់ រ.ទ.ស.ភ ដែលអនុញ្ញាតឲ្យផលិត និងចែកចាយទឹកសម្រាប់ការប្រើប្រាស់របស់សាធារណជននៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ការរឹតត្បិតនេះត្រូវបានកំណត់ដោយអនុក្រឹត្យលេខ៥២អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើត រ.ទ.ស.ភ។
- **ការពង្រីករាជធានីភ្នំពេញ៖**រាជរដ្ឋាភិបាលមានគោលនយោបាយពង្រីករាជធានីភ្នំពេញ ដោយបញ្ចូលឃុំ បន្ថែមចំនួន២០ឃុំ ទៀត ទៅក្នុងតំបន់រាជធានីភ្នំពេញដែលធ្វើឲ្យផ្ទៃសេវារបស់ រ.ទ.ស.ភ ក្នុងការផ្គត់ផ្គង់ទឹកស្អាតក៏ត្រូវពង្រីកបន្ថែមដែរ។
- **គោលនយោបាយពន្ធលើអចលនទ្រព្យ៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ឱ្យអនុវត្តនូវប្រកាសលេខ ៤៩៣សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពី "ការប្រមូលពន្ធលើអចលនទ្រព្យ" ។ អចលនទ្រព្យរបស់ រ.ទ.ស.ភ គឺសម្រាប់បម្រើឱ្យប្រព័ន្ធផលិតកម្មទឹកស្អាត ដែលអចលនទ្រព្យប្រភេទនេះ ត្រូវបានលើកលែងពន្ធតាមរយៈសេចក្តីជូនដំណឹងលេខ០០៦សហវ. អពជ. ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ផ្នែកទី៩: ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

រ.ទ.ស.ភ បាន និងកំពុង ខិតខំប្រឹងប្រែងផលិតទឹកស្អាតប្រកបដោយគុណភាព និងមានសុវត្ថិភាពជូនប្រជាពលរដ្ឋដែលប្រើប្រាស់ទឹកស្អាតរបស់ រ.ទ.ស.ភ។ ដើម្បីទទួលបានទំនុកចិត្តបន្ថែមពីប្រជាពលរដ្ឋ ដែលជាអតិថិជនរបស់ខ្លួននៅក្នុងត្រីមាសទី៤ ឆ្នាំ២០២៤ រ.ទ.ស.ភ បានបញ្ជូនទឹកគំរូសាកដែលចេញពី *រោងចក្រផលិតទឹកស្អាតបាក់ខែង* ទៅពិនិត្យគុណភាពនៅមន្ទីរពិសោធន៍ឯករាជ្យ TUV SUD PSB Pte Ltd. នៃប្រទេសសិង្ហបុរី ដែលមាន មុខវិភាគចំនួន **១២៦មុខ** ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ប៉ារ៉ាម៉ែត្រមីក្រូជីវសាស្ត្រ | (Microbiological Parameter) | ចំនួន | ១ មុខ |
| ២. | ប៉ារ៉ាម៉ែត្រលក្ខណៈរូប | (Physical Parameters) | ចំនួន | ៦ មុខ |
| ៣. | ប៉ារ៉ាម៉ែត្រវិទ្យុសកម្ម | (Radiological Parameters) | ចំនួន | ២ មុខ |
| ៤. | ប៉ារ៉ាម៉ែត្រលក្ខណៈគីមី | (Chemical Parameters) | ចំនួន | ១១៧ មុខ |

ជាលទ្ធផល ទឹកស្អាតដែលផលិតពី *រោងចក្រផលិតទឹកស្អាតបាក់ខែង* របស់ រ.ទ.ស.ភ គឺបានអនុលោមទៅតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងស្តង់ដាររបស់ អង្គការសុខភាពពិភពលោក ២០២២ សម្រាប់គុណភាពទឹកផឹក ដូចមានបង្ហាញលទ្ធផលលម្អិតទាំងស្រុងនៅក្នុងឧបសម្ព័ន្ធ TEST REPORT: 7191347954-CHM25-PN ។

# ហត្ថលេខាអភិបាល
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ថ្ងៃ ចន្ទ ៧កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ២០២៥
បានអាន និងឯកភាព

ជ. ប្រធានក្រុមប្រឹក្សាភិបាល

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

ថ្ងៃ ព្រហស្បតិ៍ ៣កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ឡុង ណារ៉ូ**
អភិបាល

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ី វ៉ាន់**
អភិបាល

ថ្ងៃ ចន្ទ ៧កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ឆាយ វីរៈ**
អភិបាល

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ម៉ា ណូរ៉ាទីន**
អភិបាល

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ណាំ ចន្ទ្រី**
អភិបាល

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំម្សាញ់
សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥
បានអាន និងឯកភាព

ហត្ថលេខា
**ស្រេង សំឱក**
អភិបាល

# ឧបសម្ព័ន្ធ ១

## របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ២០២៤

# មាតិកា

ផ្នែកទី១: ភាគហ៊ុនិក ១
ក- រចនាសម្ព័ន្ធភាគហ៊ុនិក ១
ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក ២
គ- មហាសន្និបាតភាគហ៊ុនិក ២
ឃ- ការបែងចែកភាគលាភ ៣

ផ្នែកទី២: ក្រុមប្រឹក្សាភិបាល ៥
ក- ក្រុមប្រឹក្សាភិបាល ៥
ខ- គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ១០
គ- លាភការ ឬប្រាក់បំណាច់ ១២
ឃ- ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល ១៣
ង- ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ១៣

ផ្នែកទី៣: ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៦
ក- គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ១៦
ខ- ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ដោយនិយោជិត (Whistle Blower) ១៩
គ- យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ១៩
ឃ- ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ១៩

ផ្នែកទី៤: ការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម ២០
ក- សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ ២០
ខ- សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ២០
គ- ការធ្វើសវនកម្ម ២១

ផ្នែកទី៥: ភាគីពាក់ព័ន្ធ ២៣
ក- បង្ហាញពីគោលនយោបាយ និងសកម្មភាព ២៣
ខ- ពិពណ៌នាអំពីទំនួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ ២៧

ផ្នែកទី៦: ការបង្ហាញព័ត៌មាន និងតម្លាភាព ៣០
ក- ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំ ៣០
ខ- យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលព័ត៌មាន ៣០
គ- ទំនាក់ទំនងជាមួយវិនិយោគិន ៣១

# ឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ២០២៤
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# របាយការណ៍អភិបាលកិច្ចសាជីវកម្មប្រចាំឆ្នាំ

## ផ្នែកទី១. ភាគហ៊ុនិក

ក- រចនាសម្ព័ន្ធភាគហ៊ុនិក(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤)

១. ព័ត៌មានភាគហ៊ុនិក

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៤.៥៣៥ | ៥.៦១០.១៤០ | ៥,៩៩១% |
| | | នីតិបុគ្គល | ៦ | ២.០៨៤.៥៤៦ | ២,៣៩៧% |
| | មិនមែន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៦២៣ | ៥.២៩៥.១៤៨ | ៦,០៨៨% |
| | | នីតិបុគ្គល | ៦ | ៤៥៦.១៤១ | ០,៥២៤% |
| ចាប់ពី៥% ដល់ តិចជាង៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមែន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៣០%ឡើង ទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ៧៣.៩២៧.១៨៧ | ៨៥% |
| | មិនមែន សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

២. ភាគហ៊ុនិកជាអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត រ.ទ.ស.ភ

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|
| អភិបាល | ៤ | ៤៦.៥៦៤ | ០,០៥៤% |
| បុគ្គលិកជាន់ខ្ពស់ | ២៣ | ១៣៣.០៩៧ | ០,១៥៣% |
| និយោជិត | ២៩១ | ៥៤៨.៩៩៤ | ០,៦៣១% |
| **សរុប** | **៣១៨** | **៧២៨.៦៥៥** | **០,៨៣៨%** |

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ខ- សិទ្ធិរបស់ភាគហ៊ុនិក និងការការពារសិទ្ធិរបស់ភាគហ៊ុនិក

### ១. សិទ្ធិរបស់ភាគហ៊ុនិក

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ រ.ទ.ស.ភ មានសិទ្ធិស្មើៗគ្នា ដែលសិទ្ធិទាំងនោះរួមមាន៖

- សិទ្ធិទទួលបានព័ត៌មានដែលផ្តល់ដោយ រ.ទ.ស.ភ ស្របតាមច្បាប់ និងបញ្ញតិជាធរមាន។
- សិទ្ធិចូលរួមមហាសន្និបាតភាគហ៊ុនិករបស់ រ.ទ.ស.ភ ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក ដោយត្រូវអនុវត្តតាមសេចក្តីណែនាំសម្រាប់ការចូលរួមមហាសន្និបាតភាគហ៊ុនិក។
- សិទ្ធិទទួលភាគលាភ ដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ តាមសមាមាត្រភាគហ៊ុនដែលខ្លួនកាន់កាប់។
- សិទ្ធិក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ រ.ទ.ស.ភ នៅពេលមានការរំលាយតាមសមាមាត្រភាគហ៊ុន។
- សិទ្ធិផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងបញ្ញតិជាធរមាន។

### ២. ការការពារសិទ្ធិរបស់ភាគហ៊ុនិក និងការអនុវត្តក្នុងឆ្នាំ២០២៤

សិទ្ធិរបស់ភាគហ៊ុនិក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានការពារដោយលក្ខន្តិកៈរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ និងតាមរយៈការបង្កើតឱ្យមាននូវក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

ក្នុងឆ្នាំ២០២៤ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១២ ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ ដែលភាគហ៊ុនិកទាំងអស់ ទទួលបានព័ត៌មានស្មើគ្នា មានសិទ្ធិចូលរួមស្មើគ្នា ដោយគោរពតាមនីតិវិធី នៃការចូលរួមមហាសន្និបាតភាគហ៊ុនិក របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងធ្វើការបោះឆ្នោតលើរបៀបវារៈ ដែលបានលើកឡើង។

ទន្ទឹមនេះដែរ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក៏បានធ្វើការបែងចែកភាគលាភប្រចាំឆ្នាំ២០២៣ ជូនដល់ភាគហ៊ុនិក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដោយធ្វើការទូទាត់នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ កន្លងមក។

### ៣. ការការពារសិទ្ធិរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិច និងការអនុវត្តក្នុងឆ្នាំ២០២៤

ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនភាគតិចរបស់ រ.ទ.ស.ភ ទទួលបានស្មើគ្នានូវការការពារ និងការអនុវត្តដូចទៅនឹងភាគហ៊ុនិកដទៃដូចបានរៀបរាប់ខាងលើ ដោយពុំមានការរិតត្បិតសិទ្ធិណាមួយទេ។

## គ- មហាសន្និបាតភាគហ៊ុនិក

### ១. និតិវិធីនៃការរៀបចំសន្និបាតភាគហ៊ុនិក និងការបោះឆ្នោត

ការរៀបចំមហាសន្និបាតភាគហ៊ុនិក និងការបោះឆ្នោតត្រូវបានអនុវត្តទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## គ- មហាសន្និបាតភាគហ៊ុនិក (ត)

### ២. ព័ត៌មានមហាសន្និបាតភាគហ៊ុនិកលើកទី១២

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | កូរ៉ុមនៃកិច្ចប្រជុំ | របៀបវារៈ | សេចក្ដីសម្រេច |
|---|---|---|---|---|---|
| ១ | ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤ | សាមញ្ញ | ចំនួន ១៩៨នាក់ (៧៥.២០៤.០៨៦ ភាគហ៊ុន) ស្មើនឹង៩៩,៦៣% | ១. របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២៣ និងទិសដៅអាជីវកម្មឆ្នាំ២០២៤<br>២. សំនួរ-ចម្លើយ<br>៣. កម្មវិធីបោះឆ្នោតអនុម័តលើ៖<br>ក ការបោះឆ្នោតអនុម័តលើការបែងចែកភាគលាភជូនភាគ-ហ៊ុនិកសម្រាប់ឆ្នាំ២០២៣<br>ខ ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាលឆ្នាំ២០២៤ | លទ្ធផលនៃការបោះឆ្នោត៖<br>➢ ឯកភាពបែងចែកភាគលាភឆ្នាំ២០២៣ ដែលបានមកពីប្រាក់ចំណេញឆ្នាំ២០២៣ គិតជាសាច់ប្រាក់ចំនួន ៣០.៤៤០.៦០៦.៧០០រៀល៖<br>▪ ចំនួន ៣៥០រៀល/ភាគហ៊ុន<br>▪ កាលបរិច្ឆេទកំណត់ទុក: ថ្ងៃទី៧ខែមិថុនា ឆ្នាំ២០២៤<br>▪ កាលបរិច្ឆេទទូទាត់: ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤<br>➢ ឯកភាពលើលាភការរបស់ក្រុមប្រឹក្សាភិបាល ៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋ ១រូប សម្រាប់ឆ្នាំ២០២៤ ដែលមានទឹកប្រាក់សរុបចំនួន ១.១០៧.៩៧៩.០០០រៀល។ |

## ឃ- ការបែងចែកភាគលាភ

### ១- គោលនយោបាយបែងចែកភាគលាភ

ក្រោយពីបានអនុម័តលើគណនីបើពិនិត្យឃើញថាមានចំណេញ ក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

១.១. ការទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅ

១.២. បន្ទាប់ពីបានទូទាត់ការខាតបង់នៅក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើមានប្រាក់ចំណេញ នោះប្រាក់ចំណេញនេះត្រូវបែងចែកសម្រាប់៖

ក ថ្លៃងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌ៖

- ក្នុងករណីប្រាក់ចំណេញនៅសល់មានចំនួនពី ៥% ដល់ ១០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងមួយខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ១០% ដល់ ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងពីរខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និង និយោជិតម្នាក់ៗ។
- ក្នុងករណីប្រាក់ចំណេញលើសពី ២០% នៃចំណាយដំណើរការរបស់ រ.ទ.ស.ភ សរុបក្នុងឆ្នាំ នោះការថ្លៃងសរសើរត្រូវស្មើនឹងបីខែនៃប្រាក់បៀវត្សសុទ្ធសាធរបស់ថ្នាក់ដឹកនាំ និងនិយោជិតម្នាក់ៗ។

ខ ចំនួន ២% សម្រាប់ប្រាក់សោធននិវត្ត និងអសមត្ថភាពវិជ្ជាជីវៈ។

គ បង្កើតភាគបម្រុងតាមច្បាប់ ៥%។

ឃ បង្កើតភាគបម្រុងសេរីចំនួន ៥%។

ង មូលនិធិ ៥% លើប្រាក់ចំណេញសម្រាប់បម្រើផលប្រយោជន៍សង្គម ដែលត្រូវកត់ត្រាចូលក្នុងបន្ទុកក្នុងឆ្នាំដែលធ្វើប្រតិបត្តិការចំណាយនោះ។

# ផ្នែកទី១. ភាគហ៊ុនិក (ត)

## ឃ- ការបែងចែកភាគលាភ (ត)

### ១- គោលនយោបាយបែងចែកភាគលាភ (ត)

១.៣. ចំនួនប្រាក់ដែលនៅសល់បន្ទាប់ពីការបែងចែកខាងលើនេះត្រូវ៖

ក ដកប្រាក់រក្សាទុកដើម្បីធ្វើការវិនិយោគនាពេលខាងមុខ ដែលចំនួននេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល។

ខ ប្រាក់នៅសល់ក្រោយពីការរក្សាទុកសម្រាប់ធ្វើការវិនិយោគត្រូវធ្វើការបែងចែក ៨៥% ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ១៥% ទៅភាគហ៊ុនិកដែលជាវិនិយោគិនសាធារណៈ។

## ២. ព័ត៌មានអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ

| ល.រ | ពិពណ៌នាលម្អិតអំពីការបែងចែកភាគលាភ | ២០២៣ | ២០២២ | ២០២១ |
|---|---|---|---|---|
| ១ | កាលបរិច្ឆេទប្រកាសបែងចែកភាគលាភ | ២៤ ឧសភា ២០២៤ | ២៦ ឧសភា ២០២៣ | ១៣ ឧសភា ២០២២ |
| ២ | កាលបរិច្ឆេទកំណត់ទុក | ០៧ មិថុនា ២០២៤ | ០៩ មិថុនា ២០២៣ | ៣០ ឧសភា ២០២២ |
| ៣ | កាលបរិច្ឆេទទូទាត់ភាគលាភ | ១៩ មិថុនា ២០២៤ | ២០ មិថុនា ២០២៣ | ០៨ មិថុនា ២០២២ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល

## ក. ក្រុមប្រឹក្សាភិបាល

### ១. សមាសភាពក្រុមភិបាល

| ល.រ. | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១ | ឯកឧត្តម ឯក សុនចាន់ | ប្រធានក្រុមប្រឹក្សាភិបាល | ២១ ឧសភា ២០២៤ | ០៦ មករា ២០២៦ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦ មករា ២០២៣ | ០៦ មករា ២០២៦ |
| ៣ | ឯកឧត្តម ឡុង ណារ៉ូ | សមាជិកក្រុមប្រឹក្សាភិបាល | ០៦ មករា ២០២៣ | ០៦ មករា ២០២៦ |
| ៤ | ឯកឧត្តម ឆាយ រីវៈ | សមាជិកក្រុមប្រឹក្សាភិបាល | ១៧ កញ្ញា ២០២៤ | ០៦ មករា ២០២៦ |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកក្រុមប្រឹក្សាភិបាល | ២៧ កុម្ភៈ ២០២៣ | ២៧ កុម្ភៈ ២០២៦ |
| ៦ | លោក ស្រេង សំឱក | អភិបាលឯករាជ្យ | ១៣ ឧសភា ២០២២ | ១៣ ឧសភា ២០២៥ |
| ៧ | លោក ណាំ ចន្រ្ទី | អភិបាលមិនប្រតិបត្តិ តំណាងភាគហ៊ុនិកឯកជន | ១៣ ឧសភា ២០២២ | ១៣ ឧសភា ២០២៥ |

- ឈ្មោះលេខាធិការសហគ្រាសរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញៈ
  - **លោក ហួត សុខហេង**

### ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ

#### - ជីវប្រវត្តិរូបសង្ខេបរបស់ឯកឧត្តម ឯក សុនចាន់

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៥០ និងបានទទួលជាវិស្វករជំនាញពីវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត ក្នុងឆ្នាំ១៩៧៥ (វិស្វករអគ្គីសនី)។ ឯកឧត្តមជានាយករដ្ឋាករទឹកភ្នំពេញ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៦ និងជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២០១២។ នៅឆ្នាំ២០១២ ឯកឧត្តម បានក្លាយជាអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយបន្ទាប់មកជារដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅឆ្នាំ២០១៣។ ចាប់តាំងពីឆ្នាំ២០១៨ ឯកឧត្តមត្រូវបានតែងតាំងជារដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី, អនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាអនុប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។ នៅខែឧសភា ឆ្នាំ២០២៤ ឯកឧត្តមត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨។

#### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ម៉ី វ៉ាន់

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៦៩ និងបានទទួលអនុបណ្ឌិតគោលនយោបាយសេដ្ឋកិច្ចនៃសកលវិទ្យាល័យ D'AUVERGNE ប្រទេសបារាំងនៅឆ្នាំ១៩៩៩។ ឯកឧត្តមបានទទួលបណ្ឌិតសេដ្ឋកិច្ចពាណិជ្ជកម្មនៃសកលវិទ្យាល័យ PRESTON សហរដ្ឋអាមេរិក នៅឆ្នាំ២០០៩។ ចាប់ពីឆ្នាំ២០១៣ ឯកឧត្តមបានបម្រើការងារឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងឆ្នាំ២០១៧ ឯកឧត្តមត្រូវបានតែងតាំងជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ឋានៈស្មើអនុរដ្ឋលេខាធិការ។ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ ឯកឧត្តម បានក្លាយជាទីប្រឹក្សា នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានឋានៈស្មើរដ្ឋលេខាធិការ។ ចាប់ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន ឯកឧត្តមត្រូវបានតែងតាំងជារដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០២១ ដល់បច្ចុប្បន្ន ឯកឧត្តមក្លាយសមាជិកក្រុមប្រឹក្សា និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ **ឯកឧត្តម ម៉ី វ៉ាន់** ចូលជាសមាជិក ក្រុមប្រឹក្សាភិបាល អាណត្តិទី៥ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

### ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

#### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ឡុង ណារ៉ូ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦។ ឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៨៨ សិក្សានៅសាលា Engineering School for Plant and Construction " Georgi Dimitroff " Glauchau (East Germany) ដោយទទួលបានសញ្ញាបត្រវិស្វករយន្តសាស្ត្រ។ នៅឆ្នាំ២០០៤ ទទួលបានអនុបណ្ឌិតរដ្ឋបាល ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យឆ្នាំ១៩៨៩ និង ទទួលបានការតែងតាំងជាប្រធាននាយកដ្ឋានបច្ចេកទេស ផលិតកម្ម និងផ្គត់ផ្គង់ទឹកនៅឆ្នាំ១៩៩៧។ ចាប់ពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៦ ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានបច្ចេកទេស និង ផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០១២ ជាអគ្គនាយករងទទួលបន្ទុកត្រួតពិនិត្យ និងគ្រប់គ្រងគម្រោងសាង់សង់រោងចក្រផលិតទឹកស្អាតជ្រោយចង្វារ និងនិរោធ។ ឆ្នាំ២០១២ ដល់ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ជាអគ្គនាយករងទទួលបន្ទុកសាខាសេវាកម្ម ទឹកស្អាត និងអនាម័យ និងចាប់ពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ ដល់បច្ចុប្បន្ន ជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ព្រមទាំងបានតែងតាំង និងផ្តល់ឋានៈជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពី **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** កាលពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន។

#### - ជីវប្រវត្តិសង្ខេបរបស់ឯកឧត្តម ឆាយ វីរៈ

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨៣ ឯកឧត្តមបានទទួលសញ្ញាបត្រនីតិសាស្ត្រពីសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងសញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០៤ និងបរិញ្ញាបត្រជាន់ខ្ពស់ជំនាញហិរញ្ញវត្ថុ ពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។ ឯកឧត្តមបានចូលបម្រើការងារនៅសាលារាជធានីភ្នំពេញ នៅឆ្នាំ២០០៧ ជាមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋាន និងត្រូវបានតែងតាំងជាអនុប្រធានការិយាល័យផែនការនៅឆ្នាំ២០១០, និងជាប្រធានការិយាល័យកិច្ចការច្បាប់ និងដោះស្រាយវិវាទនៅមូលដ្ឋាននៅឆ្នាំ២០១៥ បន្ទាប់មកជានាយករងទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្សនៅឆ្នាំ២០១៨។ ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៤, ឯកឧត្តមជា នាយករងរដ្ឋបាលសាលារាជធានីភ្នំពេញ។ ចាប់ពីខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តមត្រូវបានតែងតាំងជាអភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ។ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២៤ ឯកឧត្តមត្រូវបានតែងតាំងជា សមាជិកក្រុមប្រឹក្សាភិបាល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់អាណត្តិទី៨។

#### - ជីវប្រវត្តិសង្ខេបរបស់លោក ម៉ា ណូរ៉ារីន

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រលើជំនាញផ្នែកវារីសាស្ត្រនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ បន្ទាប់មក នៅឆ្នាំ២០០៨ លោកទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញ Socio-Environmental Engineering នៅប្រទេសជប៉ុន។ លោកចូលបម្រើការនៅ រ.ទ.ស.ភ នៅឆ្នាំ១៩៩៧ និងទទួលការតែងតាំងជាប្រធានការិយាល័យសិក្សាគម្រោង នាឆ្នាំ២០០៣។ នៅឆ្នាំ២០០៨ បានទទួលការតែងតាំងជាអនុប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក និងពីឆ្នាំ២០១២ ដល់ ឆ្នាំ២០១៨ ជាប្រធាននាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២១ លោកជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក បន្ទាប់មកពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ លោកជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម។ ទន្ទឹមនឹងនេះ លោកត្រូវបានផ្ទេរភារកិច្ចជា អគ្គនាយករងទទួលបន្ទុកនាយកដ្ឋាអាជីវកម្មវិញ ចាប់ពីឆ្នាំ២០២៤ រហូតដល់បច្ចុប្បន្ន។ លោក ម៉ា ណូរ៉ារីន បានចូលជាសមាជិកក្រុមប្រឹក្សាភិបាល អាណត្តិទី៧ នៃ រ.ទ.ស.ភ ពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

## ២. ជីវប្រវត្តិរូបសង្ខេបរបស់អភិបាលនីមួយៗ (ត)

### - ជីវប្រវត្តិសង្ខេបរបស់លោក ស្រេង សំឌិក

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៦២ ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែក គ្រប់គ្រងពាណិជ្ជកម្មអន្តរជាតិពី West Coast University នៃរដ្ឋកាលីហ្វ័រញ៉ា ក្នុងឆ្នាំ១៩៩៤ និងបរិញ្ញាបត្រ វិទ្យាសាស្ត្រផ្នែកវិស្វកម្មអគ្គិសនី California State University of Long Beach ក្នុងឆ្នាំ១៩៨៨ នៃសហរដ្ឋ អាមេរិក។ លោក ស្រេង សំឌិក បានចាប់ផ្តើមការងារនៅក្រុមហ៊ុនភេសជ្ជៈកូកាកូឡា ជាប្រធានផ្នែកលក់ប្រចាំប្រទេស ឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០២។ ក្នុងឆ្នាំ២០០២ លោកបានក្លាយជាមន្ត្រីវិនិយោគ នៃគម្រោង MPDF របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ឆ្នាំ២០០៣ លោកបានចាប់ផ្តើមការងារនៅ ធនាគារអេអិនហ្សិត រ៉ូយ៉ាល់ ជានាយកគ្រប់គ្រងជាន់ខ្ពស់។ ឆ្នាំ២០១០ ដល់២០១១ លោកមានតួនាទីជានាយកពាណិជ្ជកម្ម នៃអាកាសយានដ្ឋានកម្ពុជា (ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ)។ ឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ លោកមានតួនាទីជានាយកគ្រប់គ្រងបណ្តាញសាខា នៃធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា។ ឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ លោក បានក្លាយអភិបាលឯករាជ្យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ភីអិលស៊ី ហើយបានក្លាយជាប្រធានគណៈកម្មការសវនកម្ម ក្នុងអំឡុងឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ គិតមកដល់ពេលបច្ចុប្បន្ន លោកជាទីប្រឹក្សាធុរកិច្ចរបស់ក្រុមហ៊ុន អេកស៊ីស អិនវែសមេន ខនសាល់ធីង ចាប់ពីឆ្នាំ២០១៦ ជាអភិបាលឯករាជ្យ នៃសាជីវកម្មធានាឥណទានកម្ពុជា ចាប់ពីឆ្នា២០២៣ និងចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ លោកក៏បានក្លាយជាអភិបាលឯករាជ្យ សមាជិកក្រុមប្រឹក្សាភិបាលនៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

### - ជីវប្រវត្តិសង្ខេបរបស់លោក ណាំ ចន្ទ្រី

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៨៦ ទទួលបានបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រង អាជីវកម្មឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុង ឆ្នាំ ២០១៣។ នៅឆ្នាំ២០០៨ ដល់ឆ្នាំ២០១៣ លោក ណាំ ចន្ទ្រី បានបម្រើការងារជាប្រធានគណនេយ្យ និងហិរញ្ញវត្ថុសម្រាប់គម្រោងទឹកស្អាត និងអនាម័យនៅកាកបាទក្រហមកម្ពុជា សហការជាមួយកាកបាទក្រហមស្វិស។ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥ លោកបានក្លាយជាទីប្រឹក្សាហិរញ្ញវត្ថុ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់គម្រោងមូលនិធិសកល (Global Fund) និងអង្គការ MAGNA Children at Risk ។ ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ លោកជាទីប្រឹក្សាហិរញ្ញវត្ថុ នៅគម្រោងអភិវឌ្ឍកសិកម្ម និងជម្រុញកំណើនសេដ្ឋកិច្ច នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ លោកជាប្រធានរដ្ឋបាល គណនេយ្យហិរញ្ញវត្ថុ និងពន្ធ នៅក្រុមហ៊ុន KC JSM Service Co Ltd ជាគម្រោងអភិវឌ្ឍន៍ និងវិនិយោគអចលនទ្រព្យ។ រហូតមកដល់ពេលបច្ចុប្បន្ន លោកបម្រើការជាប្រធានហិរញ្ញវត្ថុ នៅក្រុមហ៊ុន AXS Ventures Co Ltd និងជាភ្នាក់ងារគ្រប់គ្រងមូលនិធិឯកជននៅក្រុមហ៊ុន អូបរ មេនេចម៉ិន ឯ.ក ចាប់ពីឆ្នាំ២០១៩, ជានាយកប្រតិបត្តិនៃក្រុមហ៊ុន ព្រីនស៍ លេប៉រ ប្ស៊ូ ចាប់ពីឆ្នាំ២០២២, ជាសហស្ថាបនិកនៃក្រុមហ៊ុន អ៊ែតមីត អ៊ិនវេសម៉ិន អេន អ៊ិនធើណេសិនណលត្រេដ ចាប់ពីឆ្នាំ២០២៣, ជាស្ថាបនិកនៃក្រុមហ៊ុន អ៊ិចស្ពីត ប៊ីស្សនេស សេនធ័រ និងជាសហស្ថាបនិក នៃក្រុមហ៊ុន អ៊ែតមីត ហ្វូដ មេនូហ្វេកធឺរីង ឯ.ក ចាប់ពីឆ្នាំ២០២៤ និងក្លាយជាអភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន សមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ ចាប់ពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

### ៣. ករណីអភិបាលណាម្នាក់ជាអភិបាលជាភាគហ៊ុនិក ឬសហកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងទៀត

| ល.រ | ឈ្មោះអភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬសហកម្មសិទ្ធិករ |
|---|---|---|---|
| ១ | ឯកឧត្តម ម៉ី វ៉ាន់ | សាជីវកម្មធានាឥណទានកម្ពុជា | សមាជិកក្រុមប្រឹក្សាភិបាល |
| ២ | លោក ស្រេង សំឱក | សាជីវកម្មធានាឥណទានកម្ពុជា | អភិបាលឯករាជ្យ |
| ៣ | លោក ណាំ ចន្ទ្រី | ១. ADMIT GROUP<br>២. ក្រុមហ៊ុន ព្រីនស៍ លេប៉រ ឃ្យូរ<br>៣. អ៊ិចស្ព្រីត ប៊ីស្សនេស សេនធ័រ | អភិបាល និងជាសហកម្មសិទ្ធិករ<br>អភិបាល និងកម្មសិទ្ធិករ<br>អភិបាល និងកម្មសិទ្ធិករ |

### ៤. តួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល និងការអនុវត្ត

- កំណត់គម្រោងអភិវឌ្ឍន៍សហគ្រាស ដោយអនុលោមតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល យោងតាមសំណើរបស់អគ្គនាយក
- កំណត់គម្រោងថវិកាប្រចាំឆ្នាំ និងកម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានបម្រុងសម្រាប់សម្រេច កម្មវិធីវិនិយោគ
- អនុម័តលើរបាយការណ៍គណនេយ្យ (របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងរបាយការណ៍លទ្ធផលលម្អិត)
- កំណត់នូវរចនាសម្ព័ន្ធចាត់តាំងចំនួនក្របខ័ណ្ឌការបែងចែកមុខងារទូទៅ និង ប្រាក់បៀវត្សរ៍របស់និយោជិតតាមសំណើរបស់អគ្គនាយក
- អនុញ្ញាតឱ្យបើក ឬសម្រេចឱ្យបិទសកម្មភាពរបស់ការិយាល័យភ្នាក់ងារ ឬតំណាង
- អនុញ្ញាតឱ្យទិញអចលនទ្រព្យគ្រប់ប្រភេទ ដោយគោរពតាមប្រកាសលេខ៩៩៧ សហវ.ទរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងលទ្ធកម្មនៅសហគ្រាសសាធារណៈ
- ជ្រើសរើសស្នងការគណនី និងកំណត់នូវលាភការជូនចំពោះស្នងការគណនី
- សម្រេចយល់ព្រមលើកិច្ចសន្យា ឬសន្និសញ្ញាផ្សេងៗ
- ធ្វើការពិនិត្យក្នុងចន្លោះពេលទៀងទាត់មួយ លើទិសដៅដែលបានកំណត់ឱ្យសហគ្រាស និងលើកឡើងនូវបណ្តាវិធានការកែសម្រួលលើកសំណើសុំកែប្រែលក្ខន្តិកៈ។

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ១ | ១៥ មីនា ២០២៤ | សាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ារីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឱក |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ក. ក្រុមប្រឹក្សាភិបាល (ត)

### ៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល (ត)

| ល.រ | កាលបរិច្ឆេទ | ប្រភេទកិច្ចប្រជុំ | ឈ្មោះអភិបាលដែលបានចូលរួម |
|---|---|---|---|
| ២ | ២៧ មីនា ២០២៤ | វិសាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម ក.ទ.ស.ភ) |
| ៣ | ៣ មេសា ២០២៤ | វិសាមញ្ញ | ▪ ឯកឧត្តម ស៊ឹម ស៊ីថា<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម ក.ទ.ស.ភ) |
| ៤ | ២៧ មិថុនា ២០២៤ | សាមញ្ញ | ▪ ឯកឧត្តម ឯក សុនចាន់<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម នួន ផារ័ត្ន<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក |
| ៥ | ១៩ កញ្ញា ២០២៤ | សាមញ្ញ | ▪ ឯកឧត្តម ឯក សុនចាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម ក.ទ.ស.ភ) |
| ៦ | ១៩ ធ្នូ ២០២៤ | សាមញ្ញ | ▪ ឯកឧត្តម ឯក សុនចាន់<br>▪ ឯកឧត្តម ម៉ី វ៉ាន់<br>▪ ឯកឧត្តម ឡុង ណារ៉ូ<br>▪ ឯកឧត្តម ឆាយ វីរៈ<br>▪ លោក ម៉ា ណូវ៉ាវីន<br>▪ លោក ណាំ ចន្ទ្រី<br>▪ លោក ស្រេង សំឌិក<br>▪ ឯកឧត្តម នេត មុន្នី (មន្ត្រីត្រួតពិនិត្យរដ្ឋ អម ក.ទ.ស.ភ) |

## ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

### ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល

#### ១-១ គណៈកម្មាធិការសវនកម្ម

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | លោក ស្រេង សំឌិក | ប្រធានគណៈកម្មាធិការ - អភិបាលឯករាជ្យ | ២៨-មីនា-២០២៣ | ៦ | ៦ |
| ២ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកគណៈកម្មាធិការ - អភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៨-មីនា-២០២៣ | ៥ | |
| ៣ | លោក ណាំ ចន្ទ្រី | សមាជិកគណៈកម្មាធិការ -អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | ២៨-មីនា-២០២៣ | ៦ | |
| ៤ | ឯកឧត្តម នេត មុន្នី | សមាជិកគណៈកម្មាធិការ - មន្ត្រីត្រួតពិនិត្យរដ្ឋអមរ.ទ.ស.ភ | ២៨-មីនា-២០២៣ | ៤ | |
| ៥ | លោក ម៉ា ណូរ៉ាវីន | សមាជិកគណៈកម្មាធិការ - តំណាងនិយោជិត រ.ទ.ស.ភ | ២៨-មីនា-២០២៣ | ៦ | |

### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម៖

១- ពិនិត្យលើរបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ
២- ពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង
៣- ពិនិត្យលើការធ្វើសវនកម្មផ្ទៃក្នុង
៤- ពិនិត្យលើការធ្វើសវនកម្មខាងក្រៅ
៥- ពិនិត្យលើការគ្រប់គ្រងហានិភ័យ ករណីមិនមានគណៈកម្មាធិការគ្រប់គ្រងហានិភ័យ
៦- រាយការណ៍ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាភិបាល
៧- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

### លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម

បានផ្តល់អនុសាសន៍ ដូចខាងក្រោម៖

១- ស្នើធ្វើការកែសម្រួលខ្លឹមសារពីរបាយការណ៍ ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង មកជារបាយការណ៍សវនកម្មផ្ទៃក្នុងវិញ។
២- ស្នើឱ្យធ្វើការគូសសម្គាល់ចំណុច (Highlights) ដែលមានកំហុសឆ្គង និងមានផលប៉ះពាល់អ្វីខ្លះ? តើសវនដ្ឋានបានធ្វើការឯកភាពទទួលយកដើម្បីធ្វើការកែលម្អ ឬទេ។
៣- ស្នើឱ្យបន្ថែមនិយមន័យនៃការវាយតម្លៃចំណាត់ថ្នាក់នីមួយៗជាឧបសម្ព័ន្ធ ដើម្បីឱ្យសវនដ្ឋានងាយយល់ពីអត្ថន័យដែលបានធ្វើការវាយតម្លៃ។
៤- ស្នើឱ្យរៀបចំពីសមិទ្ធផលដែលសវនកម្មទទួលបានក្នុងឆ្នាំ២០២៣ កន្លងមក។
៥- ស្នើឱ្យរៀបចំផែនការលម្អិតចាប់ពីដើមត្រីមាសទី២ រហូតដល់ដាច់ឆ្នាំ២០២៤។
៦- ធ្វើរបាយការណ៍លម្អិតបង្ហាញជូនគណៈកម្មាធិការសវនកម្មនៅក្នុងត្រីមាសទី២។ ក្នុងផែនការគួរមានការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការចុះធ្វើសវនកម្ម និងផែនការនីតិវិធីសម្រាប់កែលម្អគុណភាព និងប្រសិទ្ធភាពរបស់សវនកម្មផ្ទៃក្នុង។ ធ្វើការសិក្សាឈ្វេងយល់នូវចំណុចខ្វះខាតពីនីតិវិធីដែលសវនកម្មផ្ទៃក្នុងមាននាពេលបច្ចុប្បន្ន ប្រៀបធៀបទៅនឹងការណែនាំដែលមានចែងក្នុងអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង សម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងផែនការការងារផ្សេងៗទៀតពាក់ព័ន្ធទៅនឹងការងាររដ្ឋបាលរបស់សវនកម្មផ្ទៃក្នុង។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១- របាយការណ៍សម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

#### ១-១ គណៈកម្មាធិការសវនកម្ម (ត)

៧- គួរបានបែងចែកឱ្យដាច់ពីគ្នានៅចំណុចណាដែលបានអនុវត្តរួច និងចំណុចណាដែលបាននឹងកំពុងអនុវត្ត។ ដោយពេលបច្ចុប្បន្នពិនិត្យឃើញថាសវនករ ពុំទាន់អនុវត្តបានពេញលេញស្របទៅនឹងផែនការនីតិវិធីសម្រាប់កែលម្អគុណភាព និងប្រសិទ្ធភាព របស់សវនកម្មផ្ទៃក្នុង (បណ្តុះបណ្តាលធនធានមនុស្ស) នៅឡើយ។

៨- ផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំ ឃើញថាគ្រាន់តែជាផែនការនៃការចុះអនុវត្តដោយដកស្រង់ចេញជាផែនការប្រចាំឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែជាក់ស្តែងពុំទាន់បានឆ្លើយតបទៅនឹងតម្រូវការនោះទេ ក្នុងនោះយើងត្រូវរៀបចំផែនការតម្រូវការដែលបានគ្រោងទៅលើទីកន្លែង និងវគ្គបណ្តុះបណ្តាល។

៩- សម្រាប់ការរៀបចំស្តង់ដានីតិវិធីប្រតិបត្តិការការងារសវនកម្មផ្ទៃក្នុង SOP បច្ចុប្បន្នកំពុងរង់ចាំ External Audit Consultant រៀបចំឡើងវិញ ដោយបញ្ជាក់ពីកាលបរិច្ឆេទដែលរំពឹងនឹងអាចអនុវត្តបាន នាចុងឆ្នាំ ២០២៤ ឬដើមឆ្នាំ ២០២៥។

១០- ការរៀបចំផែនការប្រចាំឆ្នាំត្រង់វិសាលភាពសវនកម្មត្រូវពិនិត្យ និងកែសម្រួលឡើងវិញឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែង។

១១- លទ្ធផលការងារអនុវត្តក្រៅផែនការ (ក្នុងរបៀបវារៈទី៣) គួរបានយកមកបង្ហាញនៅក្នុងការងារតាមដានអនុសាសន៍របស់គណៈកម្មាធិការសវនកម្មវិញ។

១២- ការរៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំ (២០២៥-២០២៧) ហាក់ដូចជាពុំមែនជាផែនការយុទ្ធសាស្ត្រសវនកម្ម គឺគ្រាន់តែជាផែនការសវនកម្មធម្មតា ៣ ឆ្នាំ តែប៉ុណ្ណោះ។

១៣- សម្រាប់ការងារតាមដាន គួរបានលើកយកមកបង្ហាញត្រឹមរយៈពេល ៥ឆ្នាំចុងក្រោយ ប៉ុន្តែករណីលទ្ធផលនៅតែស្ថិតក្នុងការវាយតម្លៃ "អខ" (បានអនុវត្តតាមអនុសាសន៍ខ្លះ និងហានិភ័យសំណល់ស្ថិតក្នុងកម្រិតមួយមិនអាចទទួលយកបាន) ទើបធ្វើការរាយការណ៍បន្ថែម ដើម្បីបង្ហាញពីវឌ្ឍនភាពនៃការអនុវត្ត និងតម្រូវឱ្យធ្វើការកែសម្រួលឡើងវិញតាមការណែនាំ។

១៤- ការពិនិត្យទៅលើសៀវភៅលិខិតចេញ-ចូល ករណីដែលពុំមានផលប៉ះពាល់ ពុំចាំបាច់បញ្ចូលចំណុចនេះទៅក្នុងកម្មវិធីការងារសវនកម្មឡើយ។ ប៉ុន្តែប្រសិនបើដំណើរការនៃលិខិតធ្វើឱ្យមានផលប៉ះពាល់ទៅនឹងដំណើរការផ្សេងៗ នោះចាំបាច់ត្រូវតែលើកឡើង។

១៥- ស្នើឱ្យបញ្ជាក់បន្ថែមពីពេលវេលាអនុវត្ត និងធនធានមនុស្សក្នុងកិច្ចដំណើរការការងារ ក្រៅផែនការ និងត្រូវបន្ថែមការវាយតម្លៃទៅលើលទ្ធផលដែលបានអនុវត្ត ដើម្បីងាយស្រួលក្នុងការតាមដាន។

#### ១-២ គណៈកម្មាធិការតែងតាំង និងលាភការ

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទតែងតាំង | ចំនួននៃការចូលរួមកិច្ចប្រជុំ | ចំនួនកិច្ចប្រជុំសរុប |
|---|---|---|---|---|---|
| ១ | ឯកឧត្តម ឯក សុនចាន់ * | ប្រធានគណៈកម្មាធិការ - ប្រធានក្រុមប្រឹក្សាភិបាល | ២០ វិច្ឆិកា ២០២៤ | ១ | ២ |
| ២ | ឯកឧត្តម ស៊ឹម ស៊ីថា | | ២៨ មីនា ២០២៣ | ១ | |
| ៣ | ឯកឧត្តម ម៉ី វ៉ាន់ | សមាជិកគណៈកម្មាធិការ - សមាជិកក្រុមប្រឹក្សាភិបាល | ២០ វិច្ឆិកា ២០២៤ | ២ | |
| ៤ | ឯកឧត្តម ឆាយ វីរៈ ** | | | ១ | |
| ៥ | ឯកឧត្តម នួន ផារ័ត្ន | | ២៨ មីនា ២០២៣ | ១ | |
| ៦ | ឯកឧត្តមអគ្គនាយក រ.ទ.ស.ភ | សមាជិកគណៈកម្មាធិការ - សមាជិកក្រុមប្រឹក្សាភិបាល | ២០ វិច្ឆិកា ២០២៤ | ២ | |
| ៧ | លេខាធិការសហគ្រាស | លេខា | ២៨-មីនា-២០២៤ | ២ | |

សម្គាល់៖ * ឯកឧត្តម ឯក សុនចាន់ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ អាណត្តិទី៨ និងជាប្រធានគណៈកម្មាធិការតែងតាំង និងលាភការ ជំនួសឯកឧត្តម ស៊ឹម ស៊ីថា។

** ឯកឧត្តម ឆាយ វីរៈ ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល និងជាសមាជិកនៃគណៈកម្មាធិការតែងតាំង និងលាភការ ជំនួសឯកឧត្តម នួន ផារ័ត្ន។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ខ. គណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១- រចនាសម្ព័ន្ធគណៈកម្មាធិការក្រុមប្រឹក្សាភិបាល (ត)

### ១-២ គណៈកម្មាធិការតែងតាំង និងលាភការ (ត)

#### តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការតែងតាំងនិងលាភការ

- ពិនិត្យ និងផ្តល់អនុសាសន៍លើលក្ខខណ្ឌគុណវឌ្ឍិ និងនីតិវិធីការជ្រើសរើសបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់
- វាយតម្លៃបេក្ខភាពជាអភិបាល និងបុគ្គលិកជាន់ខ្ពស់ ដើម្បីដាក់ស្នើទៅក្រុមប្រឹក្សាភិបាល
- ពិនិត្យ និងធ្វើបច្ចុប្បន្នកម្មលើយន្តការ និងវាយតម្លៃប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាភិបាល អភិបាល និងគណៈកម្មាធិការនានាយ៉ាងហោចណាស់១(មួយ)ដងក្នុង១ឆ្នាំ
- រៀបចំនីតិវិធីពិនិត្យ និងផ្តល់អនុសាសន៍លើលាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់
- អនុវត្តកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

#### លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំងនិងលាភការ

- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៤ : បានបើកកិច្ចប្រជុំដើម្បីពិនិត្យលើសំណើចំនួន៣ ដូចខាងក្រោម៖
  ១. សំណើសុំពិនិត្យលើបេក្ខភាពបុគ្គលិកជាន់ខ្ពស់ សម្រាប់បំពេញប្រអប់នៅក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ន
  ២. សំណើសុំពិនិត្យជាមុនលើបេក្ខភាពបុគ្គលិកជាន់ខ្ពស់ សម្រាប់ប្រអប់ដែលស្នើសុំបង្កើតថ្មី
  ៣. សំណើសុំការពិនិត្យលើការដំឡើងឋានៈស្មើអគ្គនាយករង ជូនបុគ្គលិកជាន់ខ្ពស់។
- ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ : បានបើកកិច្ចប្រជុំដើម្បីពិនិត្យលើសំណើចំនួន២ ដូចខាងក្រោម៖
  ១. សំណើសុំពិនិត្យពិភាក្សាលើសំណើសុំពិនិត្យ-អនុម័តតែងតាំងបុគ្គលិកជាន់ខ្ពស់
  ២. សំណើសុំពិនិត្យពិភាក្សាលើលទ្ធផលវាយតម្លៃការងាររបស់ក្រុមប្រឹក្សាភិបាល ប្រចាំឆ្នាំ២០២៤។

### ២. ការប្រែប្រួលសមាជិកនៅក្នុងគណៈកម្មាធិការ

| គណៈកម្មាធិការ | ឈ្មោះ | មូលហេតុ |
|---|---|---|
| គណៈកម្មាធិការតែងតាំង និងលាភការ | ឯកឧត្តម ឯក សុនចាន់ | ឯកឧត្តម ឯក សុនចាន់ ត្រូវបានតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាលជំនួសឱ្យ ឯកឧត្តម ស៊ឹម ស៊ីថា។ |
| | ឯកឧត្តម ឆាយ វីរៈ | ឯកឧត្តម ឆាយ វីរៈ ត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលជំនួសឱ្យ ឯកឧត្តម នួន ផារ័ត្ន។ |

## គ. លាភការ ឬប្រាក់បំណាច់

### ១. បុគ្គលទទួលលាភការ ឬប្រាក់បំណាច់

| ល.រ | បុគ្គលទទួលបានលាភការ ឬប្រាក់បំណាច់ | ចំនួនលាភការ ឬប្រាក់បំណាច់ | ផ្សេងៗ |
|---|---|---|---|
| ១ | អភិបាល | ១២៧.៨២៩.៣៥៣រៀល | |
| ២ | អភិបាលប្រតិបត្តិ | ៥៧.៦២៥.៣៤១រៀល | |
| ៣ | បុគ្គលិកជាន់ខ្ពស់ | ៣៦៥.៧២១.៦៦០រៀល | |
| ៤ | បុគ្គលិកដែលទទួលបានលាភការ ឬប្រាក់បំណាច់ខ្ពស់បំផុត ៥រូប | ១០១.៩១៤.៨៨៧រៀល | |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ឃ. ការវាយតម្លៃលទ្ធផលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល

| ល.រ | បរិយាយ | ដំណើរការនៃការវាយតម្លៃ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាភិបាល | ក្រុមប្រឹក្សាភិបាលបានវាយតម្លៃលើលទ្ធផលការងារប្រចាំឆ្នាំ២០២៤ | ▪ រចនាសម្ព័ន្ធ និងលក្ខណៈរបស់ក្រុមប្រឹក្សាភិបាល<br>▪ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល<br>▪ កិច្ចប្រជុំក្រុមប្រឹក្សាភិបាល<br>▪ ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល<br>▪ ទំនាក់ទំនងជាមួយគណៈគ្រប់គ្រង<br>▪ ស្វ័យអភិវឌ្ឍន៍របស់អភិបាល និងការអភិវឌ្ឍន៍របស់បុគ្គលិកជាន់ខ្ពស់ |

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| **ការបណ្តុះបណ្តាលក្នុងប្រទេស: សម្រាប់អភិបាលចំនួន ៣រូប (ស្រី: ០រូប)** | | | | |
| ១ | លោក ម៉ា ណូរ៉ារីន | ភាពជាអ្នកដឹកនាំ និងការជម្រុញការលើកទឹកចិត្ត | ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ | រ.ទ.ស.ភ |
| ២ | ឯកឧត្តម ឡុង ណារ៉ូ<br>លោក ម៉ា ណូរ៉ារីន<br>លោក ណាំ ចន្ទ្រី<br>លោក ស្រេង សំឌិក | ការគ្រប់គ្រងទឹកបាត់បង់ (រៀបចំដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) | ថ្ងៃទី១៦, ១៧, និង២៣ ខែកក្កដា ឆ្នាំ២០២៤ | រ.ទ.ស.ភ |
| ៣ | លោក ម៉ា ណូរ៉ារីន | ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី «ការងារវាយតម្លៃទទួលស្គាល់» | ថ្ងៃទី០៧ និង០៨ ខែកក្កដា ឆ្នាំ២០២៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៤ | លោក ណាំ ចន្ទ្រី<br>លោក ម៉ា ណូរ៉ារីន<br>លោក ស្រេង សំឌិក | ភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត | ថ្ងៃទី០៤ និង០៥ ខែកញ្ញា ឆ្នាំ២០២៤ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ (ត)

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| **ការបណ្តុះបណ្តាលក្នុងប្រទេស: សម្រាប់បុគ្គលិកជាន់ខ្ពស់ ចំនួន ២៨រូប (ស្រី: ៦រូប)** | | | | |
| ១ | លោក ចាន់ ពិសិដ្ឋ*<br>លោក ជា សតិភទ្ទ<br>លោក ដេង ប៉ូលីដែន<br>លោក ផេង ទី<br>លោក ជូ ផល្លា<br>លោក សោម សុវណ្ណ<br>លោក ហេង សុផាន់ណារ៉ាត**<br>លោក អ៊ូ គុណវឌ្ឍន៍<br>លោក សុខ ណារ៉េត<br>លោក ទុយ ប៊ុនសេរីវិទ្ធ<br>លោក កាំង សោភីណា<br>លោក កែម កានវិចិត្រ<br>លោកស្រី សេង គាតារា<br>លោក សារុំជ វឌ្ឍនា<br>លោក ហួត សុខហេង<br>លោក ឈឹម សេរីរ៉ុជ<br>លោកស្រី ប្រាក់ ចាន់មករា<br>លោកស្រី ស៊ឹម វល្លិកា<br>លោក មាស កុសល<br>លោក រស់ បូរិន្ទ | ភាពជាអ្នកដឹកនាំ និងការជម្រុញការលើកទឹកចិត្ត | ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ | រ.ទ.ស.ភ |
| ២ | លោក ដេង ប៉ូលីដែន<br>លោក ជូ ផល្លា | កម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យមូលបត្រ | ថ្ងៃទី២៦ ខែកុម្ភៈ ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤ | និយ័តករមូលបត្រកម្ពុជា |
| ៣ | លោក ផេង ទី<br>លោក កែម កានវិចិត្រ | ការគ្រប់គ្រងទឹកបាត់បង់ | ថ្ងៃទី១៦, ១៧ និង២៣ ខែកក្កដា ឆ្នាំ២០២៤ | រ.ទ.ស.ភ |

* លោក ចាន់ ពិសិដ្ឋ បានលាឈប់ពីការងារនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤។

** លោក ហេង សុផាន់ណារ៉ាត់ បានចូលនិវត្តន៍ក្នុងខែកញ្ញា ឆ្នាំ២០២៤។

# ផ្នែកទី២. ក្រុមប្រឹក្សាភិបាល (ត)

## ង. ការបណ្តុះបណ្តាលសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ (ត)

| ល.រ | ឈ្មោះ | មុខជំនាញ | កាលបរិច្ឆេទ | ទីកន្លែង |
|---|---|---|---|---|
| ៤ | លោក ចាន់ ពិសិដ្ឋ*<br>លោកស្រី រឿន ណារី<br>លោក ជា សតិភទ្ទ<br>លោក ដេង ប៉ូលីដែន<br>លោក ផេង ទី<br>លោក ជូ ផល្លា<br>លោក អ៊ុំ គុណវឌ្ឍន៍<br>លោក សោម សុវណ្ណ<br>លោក ទុយ ប៊ុនសេរីវុទ្ធ<br>លោក កែម កានវិចិត្រ<br>លោក សុខ ណារ៉េត<br>លោក រាំង ចាន់ភិរម្យ<br>លោក សំអូន សិរីសុមនុ<br>លោក ខឹម រិទ្ធិយនីន<br>លោកស្រី សេង គាតារា<br>លោក ឈឹម សេរីវុធ<br>លោកស្រី ស៊ឹម វល្លិកា<br>កញ្ញា ឈឹម កក្កដា | ភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត | ថ្ងៃទី០៤ និង០៥ ខែកញ្ញា ឆ្នាំ២០២៤ | រ.ទ.ស.ភ |
| ៥ | លោក កាំង សោភីណា<br>លោក កែម កានវិចិត្រ<br>លោក សោម សុវណ្ណ<br>លោក ទុយ ប៊ុនសេរីវុទ្ធ<br>លោក សំអូន សិរីសុមនុ<br>កញ្ញា ឈឹម កក្កដា<br>លោក យៀប ប៊ុនថា | ភាសាអង់គ្លេស | ចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៥ | វិទ្យាស្ថានអប់រំភាសាអង់គ្លេស អ៊ី អិល ធី |
| ៦ | លោកស្រី សេង ពុទ្ធារី | រៀបចំរបាយការណ៍ និងធ្វើកំណត់ហេតុប្រកបដោយប្រសិទ្ធភាព | ថ្ងៃ២៦ និង២៧ ខែតុលា ឆ្នាំ២០២៤ | ខេមាបិស្ស (ខេមបូឌា) ឯ.ក |
| **ការបណ្តុះបណ្តាលក្រៅប្រទេស : សម្រាប់បុគ្គលិកជាន់ខ្ពស់ ចំនួន ៣រូប (ស្រី: ០រូប)** | | | | |
| ១ | លោក ខឹម រិទ្ធិយនីន<br>លោក សំអូន សិរីសុមនុ | The Third Country Training Programme (TCTP) cource entitled "Practice in Innovation and Digital Technology for Sustainable Water Management" | ថ្ងៃទី០៧ ដល់២០ ខែកក្កដា ឆ្នាំ២០២៤ | ប្រទេសថៃ |
| ២ | លោក ផេង ទី<br>លោក សំអូន សិរីសុមនុ | ទស្សនកិច្ចសិក្សាមណ្ឌលបណ្តុះបណ្តាល | ថ្ងៃទី១៦ ដល់២០ ខែកញ្ញា ឆ្នាំ២០២៤ | ប្រទេសបារាំង |

* លោក ចាន់ ពិសិដ្ឋ បានលាឈប់ពីការងារនៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៤។

** លោក ហេង សុផាន់ណារ៉ាត់ បានចូលនិវត្តន៍ក្នុងខែកញ្ញា ឆ្នាំ២០២៤។

# ផ្នែកទី៣.- ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត៖

### ការអនុវត្តច្បាប់ និងបទបញ្ញត្តិជាធរមាន

ក្នុងពេលបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែអនុវត្ត និងព្យាយាមធ្វើឱ្យ រ.ទ.ស.ភ អនុវត្តតាមច្បាប់ និងបទបញ្ញត្តិជាធរមាន។ ប្រសិនបើអភិបាល ឬ បុគ្គលិកជាន់ខ្ពស់ណាមួយបានដឹងពីព័ត៌មានដែលខ្លួនជឿជាក់ថា រ.ទ.ស.ភ អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតណាមួយបានបំពានច្បាប់ និងបទបញ្ញត្តិជាធរមាន អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ដែលបានដឹងត្រូវផ្តល់ព័ត៌មាននេះជូន អគ្គនាយក ប្រធានក្រុមប្រឹក្សាភិបាល ប្រធានគណៈកម្មាធិការសវនកម្ម ឬ សវនករផ្ទៃក្នុង។

### អំពើទំនាស់ផលប្រយោជន៍

បន្ថែមលើបទបញ្ញត្តិទាំងឡាយនៃមាត្រា ១៣៤ ១៣៥ ១៣៦ និងមាត្រា ១៣៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងនូវរាល់អំពើទំនាស់ផលប្រយោជន៍ដែលអាចកើតមានជាមួយ រ.ទ.ស.ភ។

ជាទូទៅទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែលផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬ ផលប្រយោជន៍របស់សមាជិកគ្រួសារផ្ទាល់របស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ បានជ្រៀតចូលក្នុង ឬ អាចនឹងជះឥទ្ធិពលធ្ងន់ធ្ងរដល់៖

(ក) ផលប្រយោជន៍ទូទៅ ឬអាជីវកម្មរបស់ រ.ទ.ស.ភ ។

(ខ) លទ្ធភាពរបស់អភិបាល ឬ បុគ្គលិកជាន់ខ្ពស់ផ្សេងទៀតក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវផ្តល់ព័ត៌មានទៅក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ហើយត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈនូវប្រតិបត្តិការឬទំនាក់ទំនងណាមួយ ដែលខ្លួនគិតថានឹងនាំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយ រ.ទ.ស.ភ តាមការកំណត់របស់និយ័តករមូលបត្រកម្ពុជា ឬ ផ្សារមូលបត្រកម្ពុជា។

អភិបាល ឬ បុគ្គលិកជាន់ខ្ពស់របស់ រ.ទ.ស.ភ ត្រូវបង្ហាញនូវផលប្រយោជន៍របស់ខ្លួនជាលាយលក្ខណ៍អក្សរទៅ រ.ទ.ស.ភ ឬ ស្នើឱ្យមានសេចក្តីប្រកាស ដែលបានដាក់ចូលទៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលក្នុងករណីដែល៖

(ក) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ ជាភាគីនៃកិច្ចសន្យា ឬ ជាអ្នកស្នើធ្វើកិច្ចសន្យាជាមួយនឹង រ.ទ.ស.ភ ឬ

(ខ) អភិបាល ឬ បុគ្គលិកជាន់ខ្ពស់នោះ មានផលប្រយោជន៍សំខាន់ជាមួយនឹងបុគ្គល ឬ នីតិបុគ្គលដែលជាភាគីក្នុងកិច្ចសន្យា ឬ ភាគីដែលស្នើធ្វើកិច្ចសន្យាជាមួយ រ.ទ.ស.ភ ។

ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាលឯករាជ្យមិនត្រូវមានផលប្រយោជន៍ណាមួយនៅក្នុង រ.ទ.ស.ភ ដែលធ្វើឱ្យប៉ះពាល់ឯករាជ្យភាពរបស់ខ្លួន និងមិនត្រូវកាន់កាប់ភាគហ៊ុនលើសពីមួយ (១)ភាគរយនៃភាគហ៊ុនសរុបរបស់ រ.ទ.ស.ភ ឡើយ។

### កាលានុវត្តភាពអាជីវកម្ម

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវយកចិត្តទុកដាក់ជាអាទិភាពដល់ផលប្រយោជន៍ស្របច្បាប់របស់ រ.ទ.ស.ភ នៅពេលសមស្រប។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាង៖

(ក) ឆ្លៀតឱកាសធ្វើកិច្ចការដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលខ្លួនបានដឹងក្នុងពេលអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុង រ.ទ.ស.ភ ។

(ខ) ប្រើប្រាស់ទ្រព្យសម្បត្តិ ឬព័ត៌មានរបស់ រ.ទ.ស.ភ ឬឋានៈ និងមុខតំណែងរបស់ខ្លួន ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។

(គ) ប្រកួតប្រជែងជាមួយ រ.ទ.ស.ភ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

ក្រុមប្រឹក្សាភិបាលនិងកំណត់ពីទង្វើដែលផ្ទុយពីខ្លឹមសារនៃប្រការនេះ ដោយពិចារណាលើអង្គហេតុ និងស្ថានការណ៍ដែលពាក់ព័ន្ធទាំងឡាយនៃទង្វើនោះ។

### ទំនាក់ទំនងដោយស្មើភាព

នៅក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវធ្វើឱ្យមានភាពស្មើគ្នាក្នុងទំនាក់ទំនងរវាងគ្នា និងជាមួយអតិថិជន អ្នកផ្គត់ផ្គង់ គូប្រជែង អ្នកម៉ៅការ និងនិយោជិត រ.ទ.ស.ភ ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវទាញយកប្រយោជន៍ពីបុគ្គលណាម្នាក់ដោយមិនស្មោះត្រង់ ដោយប្រើប្រាស់ឧបាយកល ការលាក់បាំង ការបំភ័ន្តព័ត៌មានសំខាន់ ការបង្ហាញហេតុការណ៍ដែលខុសពីការពិត ឬដោយអំពើមិនស្មោះត្រង់ផ្សេងទៀតក្នុងអាជីវកម្ម។

ការប្រើប្រាស់ ព័ត៌មានអំពីសិទ្ធិព័ត៌មានសម្ងាត់នៃអាជីវកម្មរបស់ រ.ទ.ស.ភ ឬការបញ្ចុះបញ្ចូល អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ រ.ទ.ស.ភ ទាំងអតីត និងបច្ចុប្បន្នឱ្យទម្លាយនូវព័ត៌មានទាំងនោះ ត្រូវបានហាមឃាត់ដាច់ខាត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដោយសុចរិត និងដើម្បីផលប្រយោជន៍របស់ រ.ទ.ស.ភ និងភាគហ៊ុនិកទាំងអស់របស់ រ.ទ.ស.ភ ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មិនត្រូវទាញយកផលប្រយោជន៍ពីមុខតំណែងរបស់ខ្លួនជាអភិបាល ឬ ជាបុគ្គលិកជាន់ខ្ពស់ និងមិនត្រូវទទួលអំណោយណាមួយពីតតិយជន ដោយសារមុខតំណែងជាអភិបាល ឬ បុគ្គលិកជាន់ខ្ពស់។

### ការការពារ និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ

នៅក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជំរុញឱ្យមានការត្រួតពិនិត្យ និងការប្រើប្រាស់ឱ្យបានត្រឹមត្រូវ ដោយមានការទទួលខុសត្រូវ នូវទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ រួមទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ។

ទ្រព្យសម្បត្តិរបស់ រ.ទ.ស.ភ មានដូចជា ព័ត៌មាន សម្ភារៈ គ្រឿងបរិក្ខារ កម្មសិទ្ធិបញ្ញា ឧបករណ៍ ប្រភពធនធាន ប្រព័ន្ធព័ត៌មានវិទ្យា និងទ្រព្យដទៃទៀត ដែលជាកម្មសិទ្ធិរបស់ រ.ទ.ស.ភ ឬ ទ្រព្យដែល រ.ទ.ស.ភ ជួលពីគេ ឬ ទ្រព្យដែលស្ថិតក្រោមការកាន់កាប់របស់ រ.ទ.ស.ភ ត្រូវបានប្រើប្រាស់សម្រាប់តែគោលដៅអាជីវកម្មស្របច្បាប់របស់ រ.ទ.ស.ភ តែប៉ុណ្ណោះ។

### បណ្ដឹងពាក់ព័ន្ធនឹងគណនេយ្យ

គណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ ត្រូវទទួលខុសត្រូវក្នុងការរៀបចំនីតិវិធីសមស្របមួយសម្រាប់ទទួលពាក្យបណ្ដឹង និងរក្សាទុកនូវពាក្យបណ្ដឹង និងពិនិត្យលើពាក្យបណ្ដឹងទាក់ទងនឹងគណនេយ្យ ការត្រួតពិនិត្យគណនេយ្យផ្ទៃក្នុង ឬបញ្ហាផ្សេងទៀតដែលទាក់ទងទៅនឹងសវនកម្ម។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ អាចដាក់ពាក្យបណ្ដឹងពីបញ្ហាខាងលើ ទៅគណៈកម្មាធិការសវនកម្ម ឬសវនករផ្ទៃក្នុងរបស់ រ.ទ.ស.ភ។ ការស្នើសុំឱ្យពិនិត្យបណ្ដឹងជាសម្ងាត់ អាចធ្វើឡើងបានតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ការលើកទឹកចិត្តឱ្យរាយការណ៍ពីទង្វើខុសច្បាប់ ឬអសីលធម៌

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវខិតខំជម្រុញឱ្យ រ.ទ.ស.ភ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងលើកទឹកចិត្តនិយោជិតឱ្យរាយការណ៍ពីកស្ដុតាងនៃទង្វើខុសច្បាប់ ឬ អសីលធម៌ទៅនាយកដ្ឋាន ឬ បុគ្គលដែលមានសមត្ថកិច្ចនៅក្នុង រ.ទ.ស.ភ ។

### ការជួញដូរផ្ទៃក្នុង

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្ត និងប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិ ជាធរមាន បទបញ្ជាផ្ទៃក្នុង និងគោលនយោបាយរបស់ រ.ទ.ស.ភ ពាក់ព័ន្ធនឹងការលក់-ទិញភាគហ៊ុន របស់ រ.ទ.ស.ភ ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

### ការរក្សាការសម្ងាត់

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាការសម្ងាត់នៃព័ត៌មានសម្ងាត់របស់ រ.ទ.ស.ភ ដែលខ្លួនបានដឹងលើកលែងតែក្នុងករណីដែល រ.ទ.ស.ភ អនុញ្ញាតឱ្យផ្តល់ព័ត៌មាន ឬការផ្តល់ព័ត៌មាននេះត្រូវបានតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិជាធរមាន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យថា "ព័ត៌មានសម្ងាត់" រួមមានជាអាទិ៍ ព័ត៌មានមិនមែនសាធារណៈ ដែលអាចត្រូវបានប្រើដោយគូប្រកួតប្រជែងរបស់ រ.ទ.ស.ភ ឬព័ត៌មានមិនមែនសាធារណៈដែលធ្វើឱ្យប៉ះពាល់ដល់ រ.ទ.ស.ភ ឬ អតិថិជនរបស់ រ.ទ.ស.ភ ប្រសិនបើព័ត៌មាននោះត្រូវបានបង្ហាញ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវពិភាក្សាជាមុនជាមួយអគ្គនាយក ឬ ប្រធានក្រុមប្រឹក្សាភិបាល ប្រសិនបើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ គិតថាខ្លួនមានកាតព្វកិច្ចតាមច្បាប់ក្នុងការបង្ហាញព័ត៌មានសំងាត់នោះ។

### ការផ្តល់ព័ត៌មាន

អភិបាល និងបុគ្គលិកជាន់ខ្ពស់តម្រូវឱ្យយល់ច្បាស់ពីនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដើម្បីឱ្យសេចក្តីប្រកាសជាសាធារណៈ របាយការណ៍ និងឯកសារផ្តល់ព័ត៌មាន ដែលត្រូវចុះបញ្ជីជាមួយអាជ្ញាធររដ្ឋ រួមបញ្ចូលទាំងនិយ័តករមូលបត្រកម្ពុជា អាចរៀបចំធ្វើឡើងដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន រួមទាំងគោលការណ៍ណែនាំរបស់និយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។

ម្យ៉ាងវិញទៀត ក្នុងទំហំនៃតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមានអំណាចដឹកនាំ ឬ គ្រប់គ្រងការចុះបញ្ជីឯកសារជាមួយ និយ័តករមូលបត្រកម្ពុជា និង/ឬ ផ្សារមូលបត្រកម្ពុជា ឬ ការជូនដំណឹងជាសាធារណៈផ្សេងទៀតរបស់ រ.ទ.ស.ភ ពាក់ព័ន្ធអាជីវកម្មទូទៅលទ្ធផលលក្ខខណ្ឌ និងលទ្ធភាពហិរញ្ញវត្ថុ ត្រូវពិភាក្សាជាមួយនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ផ្សេងទៀត និងជាមួយនិយោជិតពាក់ព័ន្ធ ហើយចាត់វិធានការសមស្របសម្រាប់នីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មាន ដើម្បីឱ្យការផ្តល់ព័ត៌មានធ្វើបានពេញលេញ ច្បាស់លាស់ ត្រឹមត្រូវ ទាន់ពេល និងអាចយល់បាន។

ក្នុងទំហំដែលពាក់ព័ន្ធនឹងនីតិវិធី និងការត្រួតពិនិត្យការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ អភិបាល និងបុគ្គលិកជាន់ខ្ពស់ម្នាក់ៗ៖

- ត្រូវយល់ច្បាស់អំពីលក្ខខណ្ឌតម្រូវនៃការផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ក៏ដូចជាប្រតិបត្តិការអាជីវកម្ម និងហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ។
- មិនត្រូវធ្វើសេចក្តីថ្លែងខុសពីការពិត ឬ ធ្វើឱ្យអ្នកដទៃថ្លែងខុសពីការពិតទាក់ទងអំពីព័ត៌មានរបស់ រ.ទ.ស.ភ ប្រាប់អ្នកដទៃ ទោះបីជាអ្នកនោះនៅក្នុង ឬ នៅក្រៅ រ.ទ.ស.ភ រួមទាំងសវនករឯករាជ្យ និយ័តករ របស់រាជរដ្ឋាភិបាល និងស្ថាប័នផ្សេងទៀត។

### វិសោធនកម្ម និងការលើកលែង

ក្រមសីលធម៌នេះអាចត្រូវបានធ្វើវិសោធនកម្មឬលើកលែងមិនអនុវត្តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ ជាវិធានទូទៅក្រុមប្រឹក្សាភិបាលនឹងមិនផ្តល់ការលើកលែងមិនអនុវត្តប្រការណាមួយនៃក្រមសីលធម៌នេះឡើយ ប្រសិនបើគ្មានមូលហេតុសមស្រប និងចាំបាច់ទេនោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់មានកាតព្វកិច្ចយល់ដឹងពីក្រមសីលធម៌នេះ និងស្វែងរកការពន្យល់ និងការផ្តល់ប្រឹក្សាបន្ថែមទាក់ទងនឹងការបកស្រាយខ្លឹមសារ និងលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌នេះជាពិសេសនៅពេលមានហេតុការណ៍ណាមួយដែលអាចមានទំនាស់ជាមួយនឹងក្រមសីលធម៌នេះ។

ក្រុមប្រឹក្សាភិបាលត្រូវបានចាត់វិធានការសមស្រប ក្នុងករណីដែលមានការបំពានក្រមសីលធម៌នេះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់អាចសាកសួរដោយផ្ទាល់ទៅអគ្គនាយក ទាក់ទងនឹងការអនុវត្ត ឬ ការបកស្រាយក្រមសីលធម៌នេះ។

# ផ្នែកទី៣. ការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច (ត)

## ក. គោលនយោបាយពាក់ព័ន្ធនឹងក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត (ត)

### អានុភាព

ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ ជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រមសីលធម៌នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ និងមានអានុភាពអនុវត្តចាប់ពី រ.ទ.ស.ភ ទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដោយនិយ័តករមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។

## ខ. ការផ្សព្វផ្សាយក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ចដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

ក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ បានអនុម័តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច ដោយត្រូវបានផ្សព្វផ្សាយ និងមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ ជូនដល់អភិបាល បុគ្គលិកជាន់ខ្ពស់ និយោជិត ភាគហ៊ុនិករបស់ រ.ទ.ស.ភ និងសាធារណជន។

## គ. យន្តការ និងនីតិវិធីតាមដានការអនុវត្តក្រមសីលធម៌សម្រាប់អនុវត្តធុរកិច្ច

ពុំមាន

## ឃ. ប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១- គោលនយោបាយរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ សម្រាប់គ្រប់គ្រងលើប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

| ល.រ | ភាគីជាប់ពាក់ព័ន្ធ | គោលនយោបាយ |
|---|---|---|
| ១ | ក្រុមហ៊ុនហូលឌីង | គ្មាន |
| ២ | កិច្ចព្រមព្រៀងវិនិយោគចម្រុះ | គ្មាន |
| ៣ | ក្រុមហ៊ុនបុត្រសម្ព័ន្ធ | គ្មាន |
| ៤ | ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងច្រើនលើសលប់ | គ្មាន |
| ៥ | អភិបាល និងសមាជិកគ្រួសារផ្ទាល់របស់អភិបាល | គ្មាន |
| ៦ | បុគ្គលិក និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលិក | គ្មាន |
| ៧ | ផ្សេងៗ | គ្មាន |

### ២- ប្រតិបត្តិការសំខាន់ៗ ជាមួយភាគីជាប់ពាក់ព័ន្ធ

ពុំមាន

# ផ្នែកទី៤. គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម

## ក. សង្ខេបអំពីប្រព័ន្ធគ្រប់គ្រងហានិភ័យ ឬគោលនយោបាយគ្រប់គ្រងហានិភ័យ

១- ការស្នើសុំទូទាត់ចំណាយលើការងារជួសជុលប្រព័ន្ធផលិតកម្ម អនុវត្តយឺត។ **ការឆ្លើយបំភ្លឺតប៖** ការិយាល័យនឹងធ្វើការពិនិត្យកែសម្រួលឯកសារទូទាត់ឱ្យបានលឿន និងត្រឹមត្រូវតាមបែបបទគណនេយ្យ និងហិរញ្ញវត្ថុ។

២- ការលាងសម្អាតតាមបណ្តាញចូលផ្ទះ ក្នុងទីតាំងតែមួយតែលាងច្រើនដង។ **ការឆ្លើយបំភ្លឺតប ៖** បំពង់ដែលបង្ហូរលាងមានទំហំតូច តម្រូវឱ្យធ្វើការបង្ហូរលាងច្រើនថ្ងៃ ហើយប្រើរយៈពេលយូរ (ពុំមានប្រអប់បង្ហូរលាងចុងបំពង់) និងការកត់ត្រាក្នុងរបាយការណ៍បង្ហាញថាបានថ្លាប្រសើរហើយនៅថ្ងៃទី១ ប៉ុន្តែថ្ងៃបន្ទាប់ទឹកមានខ្យាច់កើតឡើងម្តងទៀត ដែលតម្រូវឱ្យធ្វើការបង្ហូរលាងឡើងវិញ តែការកត់ត្រាពុំបានបញ្ជាក់លំអិតក្នុងរបាយការណ៍។

៣- ការគ្រប់គ្រងស្តុកសម្ភារ អនុវត្តពុំសមស្របរវាងសម្ភារជាក់ស្តែងជាមួយនឹងបញ្ជីសន្និធិស្តុក ដោយមានភាពលម្អៀងលើស ចំនួន០៨ មុខ។ **ការឆ្លើយបំភ្លឺតប៖** ដោយសារជាងមានសម្ភារដែលអាចប្រើប្រាស់បានយកទៅដាក់ឱ្យអតិថិជន (ទីតាំងនៅឆ្ងាយ)។ ការិយាល័យ នឹងបង្វែរសម្ភារទាំងនោះចូលក្នុងស្តុកឃ្លាំងជំវិញ នៅខែមិថុនា ឆ្នាំ២០២៤។

៤- ការប្រើប្រាស់អាជ្ញាប័ណ្ណ និងសេវាកម្មបច្ចេកវិទ្យា សម្រាប់រយៈពេល ០១ ឆ្នាំ អនុវត្តពុំសមស្របដោយការស្នើសុំគោលការណ៍ក្រោយថ្ងៃផុតសុពលភាព។ **ការឆ្លើយបំភ្លឺតប៖** ជាកង្វះខាតរបស់និយោជិតអនុវត្តការងារ យើងខ្ញុំនឹងអនុវត្តតាមអនុសាសន៍។

៥- ការប្រគល់-ទទួលទំនិញ ពុំមានកំណត់ហេតុរបស់គណៈកម្មាធិការលទ្ធកម្ម និងកាលបរិច្ឆេទ មុនកំណត់ហេតុការប្រគល់-ទទួលទំនិញ។ **ការឆ្លើយបំភ្លឺតប ៖** អង្គភាពលទ្ធកម្ម នឹងធ្វើការកែលម្អឱ្យស្របតាមអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ចាប់ពីឆ្នាំ២០២៤ តទៅ។

៦- ការបញ្ចូលសម្ភារនៅសល់ពីការអនុវត្តន៍គម្រោង ពុំមានភ្ជាប់ប័ណ្ណបញ្ចេញសម្ភារ (៤០គម្រោង)។ **ការឆ្លើយបំភ្លឺតប៖** របាយការណ៍អនុវត្ត ចំនួន ១៤ គម្រោង : ភ្ជាប់ឯកសារមិនទាន់ផ្លូវការ (ការខ្វះចន្លោះរបស់មន្ត្រីទទួលបន្ទុកពុំបានភ្ជាប់ឯកសារដែលមានហត្ថលេខាត្រឹមត្រូវ) ជាក់ស្តែងរាល់ឯកសារមានរបាយការណ៍អនុវត្តគម្រោងដែលមានចុះហត្ថលេខា និងគម្រោងសម្រាប់អនុវត្ត (Job Budget and Quotation) ចំនួន ២៦ គម្រោង (ការខ្វះចន្លោះរបស់មន្ត្រីទទួលបន្ទុក ពុំបានភ្ជាប់ប័ណ្ណបញ្ចេញសម្ភារ) ជាក់ស្តែងមានប័ណ្ណបញ្ចេញសម្ភារត្រឹមត្រូវ។ នាយកដ្ឋានទទួលយកនូវចំណុចខ្វះខាត ព្រមទាំងកែលម្អឱ្យបានត្រឹមត្រូវ បន្ទាប់ពីទទួលបានអនុសាសន៍។

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង

ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាដំណើរការនៃប្រតិបត្តិការដោយក្រុមប្រឹក្សាភិបាល, គណៈកម្មាធិការសវនកម្ម, សវនកម្មផ្ទៃក្នុង, សវនកម្មខាងក្រៅ, គណៈគ្រប់គ្រង និងបុគ្គលិក ក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព ភាពត្រឹមត្រូវនៃប្រតិបត្តិការ និងភាពជឿទុកចិត្តលើការរាយការណ៍ព័ត៌មានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ក្នុងនោះរក្សាសុវត្ថិភាពទ្រព្យសកម្ម ព្រមទាំងអភិបាលកិច្ចសមស្របរបស់សហគ្រាស។ ដើម្បីឱ្យដំណើរការនៃការត្រួតពិនិត្យផ្ទៃក្នុងសម្រេចបានត្រូវមានសមាសធាតុ ដូចជាបរិយាកាសគ្រប់គ្រង, ការវាយតម្លៃហានិភ័យ, ការគ្រប់គ្រងសកម្មភាព, ព័ត៌មានទំនាក់ទំនង និងសកម្មភាពត្រួតពិនិត្យ។

ផែនការសកម្មភាពសវនកម្មប្រចាំឆ្នាំ ២០២៤ ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការទទួលបានការឯកភាពពីប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ បានចុះត្រួតពិនិត្យនៅ ៖

| | |
|---|---|
| ១- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម និង នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក | ត្រីមាសទី ១ |
| ២- នាយកដ្ឋានអាជីវកម្ម | ត្រីមាសទី ២ |
| ៣- មណ្ឌលព័ត៌មានវិទ្យា និងអង្គភាពលទ្ធកម្ម | ត្រីមាសទី ៣ |
| ៤- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | ត្រីមាសទី ៤ |

# ផ្នែកទី៤. គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម (ត)

## ខ. សង្ខេបអំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (ត)

អនុសាសន៍ណែនាំរបស់គណៈកម្មាធិការសវនកម្ម និងកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល លើកទី១ អាណត្តិទី៨ តម្រូវឱ្យសវនកម្មផ្ទៃក្នុងបញ្ចូលកម្មវិធីចុះធ្វើសវនកម្មពុំព្រាងទុក (Surprise Audit)។ សវនកម្មផ្ទៃក្នុងយើងខ្ញុំបាន៖

១- ចុះរាប់បំពង់ (PIPE) ឃ្លាំងសម្ភារ នៅរោងចក្រនិរោធន៍ និងរោងចក្រភូមិព្រែក នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្នុងត្រីមាសទី១។

២- ពិនិត្យលើការប្រកាសវិក្កយបត្ររបស់ភ្នាក់ងារអានលេខនាឡិកា និងចែកវិក្កយបត្រ វគ្គ០៥-០៦/២៤ (ខែឧសភា និងខែមិថុនា) នៃនាយកដ្ឋានអាជីវកម្ម ក្នុងត្រីមាសទី៣។

អនុសាសន៍ណែនាំរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំលើកទី១២ អាណត្តិទី៨ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ តម្រូវឱ្យសវនកម្មផ្ទៃក្នុងចុះពិនិត្យលើការងារអានលេខនាឡិកាទឹករបស់ភ្នាក់ងារ វគ្គ ០៩-១០/២៤ (ខែកញ្ញា និងខែតុលា) ក្នុងត្រីមាសទី៤។

## គ. ការធ្វើសវនកម្ម

### ១- សវនកម្មផ្ទៃក្នុង

#### ១-១ កាតព្វកិច្ច និងការទទួលខុសត្រូវរបស់សវនករផ្ទៃក្នុង៖

១- រៀបចំផែនការយុទ្ធសាស្ត្រសវនកម្ម ៣ឆ្នាំ, ផែនការសវនកម្មប្រចាំឆ្នាំ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្ម ពិនិត្យ-សម្រេច និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២- ពិនិត្យឡើងវិញនូវបណ្តាបែបបទ, គោលការណ៍ រួមទាំងបទដ្ឋានបច្ចេកទេស ដែលបានដាក់ចេញឱ្យអនុវត្ត និងផ្តល់អនុសាសន៍ក្នុងការកែលម្អ។

៣- កំណត់ភាពសមស្រប គ្រប់គ្រាន់ និងការផ្តល់លទ្ធផលល្អ លើកិច្ចប្រតិបត្តិការរបស់អង្គភាព។

៤- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបាន លើអនុលោមភាព និងកិច្ចប្រតិបត្តិការ តាមបណ្តានាយកដ្ឋាន/អង្គភាព ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណ វាស់វែង ចំណាត់ថ្នាក់ និងរាយការណ៍អំពីព័ត៌មានទាំងនោះ។

៥- ត្រួតពិនិត្យលើការធ្វើសវនកម្មប្រចាំត្រីមាស និងឆ្នាំផ្ញើជូនផ្នែកនីមួយៗ របស់អង្គភាពដែលទទួលបន្ទុកកែលម្អតាមអនុសាសន៍ និងដាក់ជូនគណៈកម្មាធិការសវនកម្ម ពិនិត្យ-សម្រេច, រាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ, អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងពាក់ព័ន្ធ។

៦- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធដែលកំពុងប្រើប្រាស់ ដើម្បីធានាបានតាមច្បាប់ និងបទបញ្ញត្តិនានារបស់រដ្ឋ និងអង្គភាពលើកិច្ចប្រតិបត្តិការ និងរបាយការណ៍។

៧- វាយតម្លៃឡើងវិញលើការគ្រប់គ្រង, ថែទាំ, ការពារ, ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ, វាយតម្លៃភាពសន្សំសំចៃ, ប្រសិទ្ធភាពប្រើប្រាស់ធនធាន, កំណត់កែលម្អលើការអនុវត្តន៍ និងផ្តល់អនុសាសន៍។

៨- សិក្សា និងវិភាគហានិភ័យ ដាក់ជូនប្រធានគណៈកម្មាធិការសវនកម្ម និងក្រុមប្រឹក្សាភិបាល ពិនិត្យ-សម្រេច ដើម្បីរកដំណោះស្រាយតាមស្ថានភាពជាក់ស្តែង។

៩- រៀបចំផែនការចំណាយការផ្តល់សេវាសវនកម្ម និងត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

១០- សម្របសម្រួលការងារសវនកម្មជាមួយអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាទំហំការងារឱ្យបានគ្រប់គ្រាន់ និងកាត់បន្ថយការងារស្ទួនគ្នា។

១១- អនុវត្តរាល់ការងារ និងភារកិច្ចផ្សេងៗ ដែលថ្នាក់ដឹកនាំប្រគល់ជូន។

# ផ្នែកទី៤. គ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង និងការធ្វើសវនកម្ម (ត)

## គ. ការធ្វើសវនកម្ម (ត)

### ១- សវនកម្មផ្ទៃក្នុង (ត)

### ១-២ ការតែងតាំង និងការដកហូត/ការលាលែងតំណែងរបស់ប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

| ល.រ | ឈ្មោះ | កាលបរិច្ឆេទតែងតាំង | កាលបរិច្ឆេទដកហូត/លាលែង | មូលហេតុ |
|---|---|---|---|---|
| ១ | លោកស្រី សេង គាតារា | ១១ កក្កដា ២០២៤ | ០៩ កក្កដា ២០២៤ (ហួសសុពលភាព) | បន្តអាណត្តិ |

### ១-៣ ការតែងតាំងថ្មីប្រធាន និង/ឬអនុប្រធានសវនករផ្ទៃក្នុង

ពុំមាន

### ២- សវនកម្មខាងក្រៅ

| ល.រ | ឈ្មោះក្រុមហ៊ុន | កាលបរិច្ឆេទជ្រើសតាំង | តម្លៃសេវាសវនកម្ម(រៀល) | តម្លៃសេវាមិនមែនសវនកម្ម |
|---|---|---|---|---|
| ១ | ប៊ី ឌី អូ (ខេមបូឌា) លីមីធីត | ២១ មីនា ២០២៤ | ៦០២.៧០០.០០០ | |

មូលហេតុនៃការផ្លាស់ប្តូរ, ការផ្អាក និងការបញ្ឈប់ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រគឺពុំមានទេ។

# ផ្នែកទី៥. ភាគីពាក់ព័ន្ធ

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម៖

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ១ | សុខមាលភាពរបស់អតិថិជន | - ផ្តល់សេវា និងផ្តល់ទឹកស្អាតជូនអតិថិជនដោយធានាគុណភាពទៅតាម ស្តង់ដារជាតិ និងស្តង់ដារអន្តរជាតិ | នៅក្នុងឆ្នាំ២០២៤ រ.ទ.ស.ភ បានផ្តល់សេវាជូនអតិថិជនក្នុងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងខេត្តត្បូងឃ្មុំ បានតបណ្តាញថ្មីសរុបចំនួន ២៨.៨៩៩បណ្តាញ។<br>– ផ្តល់សេវាបណ្តាញទឹកជូនអតិថិជនប្រភេទឧបត្ថម្ភធនចំនួន ២.៥៩២ បណ្តាញ ក្នុងនោះ៖<br>▪ ឧបត្ថម្ភធន ៣០% ចំនួន ២៤៦ បណ្តាញ<br>▪ ឧបត្ថម្ភធន ៥០% ចំនួន ១.២៨៨ បណ្តាញ<br>▪ ឧបត្ថម្ភធន ៧០% ចំនួន ៦១២ បណ្តាញ<br>▪ ឧបត្ថម្ភធន ១០០% ចំនួន ៤៤៦ បណ្តាញ<br>– សរុបកំណើនអតិថិជនគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានចំនួន ៥០១.២៨៩ អតិថិជន (Active)<br>– ធានាគុណភាពទឹកស្អាត ជូនអតិថិជនប្រើប្រាស់ប្រចាំថ្ងៃ និងទទួលស្គាល់ពីថ្នាក់អន្តរជាតិ<br>– ដំណោះស្រាយជូនអតិថិជន ចែកចេញជាពីរផ្នែក៖<br>១. ទទួលព័ត៌មានពីអតិថិជនផ្ទាល់ និងតាមរយៈប្រព័ន្ធ Hotline របស់អង្គភាព<br>២. ទទួលព័ត៌មាន តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់អង្គភាព |
| | | - ផលិត និងផ្គត់ផ្គង់ទឹកជូនអតិថិជនដោយធានាគុណភាពទឹកស្អាតគ្មានមេរោគអាចបរិភោគបានដោយផ្ទាល់ពីបណ្តាញស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងអង្គការសុខភាពពិភពលោក ដើម្បីចូលរួមក្នុងការកាត់បន្ថយ ជំងឺដែលបង្កឡើងតាមរយៈការបរិភោគទឹកមិនស្អាត។ | - ទឹកផលិតសរុបទាំង ៨រោងចក្រ ក្នុងឆ្នាំ២០២៤ មានបរិមាណ ៣១២.៩៥១.៨៦២ម៉ែត្រគូប។<br>- គុណភាពទឹកស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និង អង្គការសុខភាពពិភពលោក (WHO)។<br>- មន្ទីរពិសោធន៍ទឹកបានធ្វើការត្រួតពិនិត្យគុណភាពទឹក ៣ដងក្នុងមួយថ្ងៃ និងមានឧបករណ៍តាមដាន Real times Monitoring ដោយប្រព័ន្ធ SCADA ។<br>- ពិនិត្យតាមដានគុណភាពទឹកស្អាត តាមបណ្តាញចែកចាយចំនួន ៨០គំរូសាក រៀងរាល់សប្តាហ៍។<br>- មន្ទីរពិសោធន៍ទឹកបានបញ្ជូនទឹកស្អាត ទៅមន្ទីរពិសោធន៍ឯករាជ្យនៅប្រទេសសិង្ហបុរី ជារៀងរាល់ឆ្នាំ ហើយលទ្ធផល ដែលទទួលបានជាអំណះ អំណាងបញ្ជាក់អំពីគុណភាពទឹករបស់ រ.ទ.ស.ភ គឺជាទឹកស្អាតផឹកបាន ដោយផ្ទាល់ពីបណ្តាញ។<br>- មន្ទីរពិសោធន៍ទឹកនិពេធទទួលបានវិញ្ញាបនបត្រ ISO/IEC 17025 : 2017។<br>- មានយន្តការឆ្លើយតប និងដោះស្រាយជូនអតិថិជនបន្ទាន់ក្នុងករណីមានបញ្ហាពាក់ពន្ធ័នឹងគុណភាពទឹកតាមរយៈ ចុះទៅពិនិត្យគុណភាពទឹក និងធ្វើការពន្យល់ជូនអតិថិជនដល់ទីតាំងផ្ទាល់ ។<br>- រៀងរាល់មួយត្រីមាសម្តង មានសកម្មភាពចុះយកសំណាកទឹកឆៅពីប្រភពទឹកទាំង៥ ក្នុងរាជធានីភ្នំពេញ ដើម្បីពិនិត្យគុណភាពទឹកឆៅ។ |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ២ | ការជ្រើសរើសអ្នកផ្គត់ផ្គង់/អ្នកម៉ៅការ | - លទ្ធកម្មក្នុងស្រុក: ការដេញថ្លៃប្រកួតប្រជែងជាសាធារណៈ គឺជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/ សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា។ | សម្រាប់ការដេញថ្លៃជ្រើសរើសក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ ក្រុមហ៊ុនចូលរួមដេញថ្លៃត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម៖<br>- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>- ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>- ច្បាប់អនុញ្ញាតឱ្យធ្វើអាជីវកម្ម ចេញដោយក្រសួងជំនាញពាក់ព័ន្ធ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)<br>- ប៉ាន់គម្រូ ឬកាតាឡុក (ប្រសិនបើមាន)<br>- លិខិតប្រគល់សិទ្ធិរបស់រោងចក្រផលិតទំនិញ (ច្បាប់ដើម) (ប្រសិនបើការដេញថ្លៃតម្រូវ)<br>- ឯកសារភស្តុតាងសម្រាប់បញ្ជាក់ពីសមត្ថភាព «ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍» (ចម្លងតាមច្បាប់ដើម)<br>គ្រប់ឯកសារភ្ជាប់ខាងលើដែលចម្លងត្រឹមត្រូវតាមច្បាប់ដើម ត្រូវមានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬស្ថាប័នពាក់ព័ន្ធ។ ក្រុមហ៊ុនដែលអាចជ្រើសរើសឱ្យ ផ្គត់ផ្គង់ទំនិញបានលុះណាតែ៖<br>១. មានការឆ្លើយតបតាមការណែនាំនៃឯកសារដេញថ្លៃ (ការវាយតម្លៃបឋម)<br>២. តម្លៃទាបសមស្របបន្ទាប់ពីការកែតម្រូវលេខនព្វន្តរួច (រៀបពីទាបទៅខ្ពស់)<br>៣. ភាពឆ្លើយតបតាមតម្រូវការបច្ចេកទេស/លក្ខខណ្ឌពាណិជ្ជកម្ម<br>៤. មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្នុងការអនុវត្តកិច្ចសន្យា (ការត្រួតពិនិត្យលក្ខណៈសម្បត្តិតាមក្រោយ) |
| | | - លទ្ធកម្មបរទេស | ការគ្រប់គ្រង និងការអនុវត្ត កិច្ចសន្យា<br>អនុលោមទៅតាមនីតិវិធីរួម សម្រាប់គ្រប់គ្រងការរៀបចំ និងតាមដានការអនុវត្តគម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងនីតិវិធីគោលការណ៍ណែនាំ ស្ដីពីការដេញថ្លៃរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ (AFD, JICA, EIB, EDCF, EU) |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ៣ | ការងារគ្រប់គ្រង និងការពារនិយោជិត | - លក្ខន្តិកៈបុគ្គលិក<br><br>- កិច្ចសន្យាការងារ<br><br>- បទបញ្ជាផ្ទៃក្នុង និងវិន័យ | អនុវត្តបានយ៉ាងខ្ជាប់ខ្ជួននូវបណ្តាចំណុចដែលមានចែងក្នុង លក្ខន្តិកៈបុគ្គលិកដូចជា ៖<br>១- ការផ្តល់នូវថ្នាក់-កាំប្រៀវត្សរ៍តាមតួនាទី និងភារកិច្ច និងបើកប្រៀវត្សរ៍យ៉ាងទៀងទាត់ជូន ២ដង ក្នុងមួយខែ<br>២- ផ្តល់នូវប្រាក់ផ្សេងៗដូចជាប្រាក់បំណាច់មុខងារ, ប្រាក់ប៉ះពាល់សុខភាព, ប្រាក់លើសម៉ោង, ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់បុព្វលាភ ប្រចាំឆ្នាំ ជាដើម<br>៣- ផ្តល់នូវសម្លៀកបំពាក់ឯកសណ្ឋាន និងសម្ភារៈសុវត្ថិភាពពលកម្ម<br>៤- ធានាសុវត្ថិភាពការងារជូននិយោជិត ដោយអង្គភាពបានបង់ប្រាក់ទៅបេឡាជាតិរបបសន្តិសុខសង្គម ផ្នែកគ្រោះថ្នាក់ការងារ, ថែទាំសុខភាព និងផ្នែកសោធន<br>៥- ផ្តល់នូវប្រាក់ឧបត្ថម្ភបន្ថែមជូនដល់មន្ត្រី-និយោជិត ដែលជួបគ្រោះថ្នាក់ ក្នុងម៉ោងការងារ។<br><br>បានចុះកិច្ចសន្យាការងារជាមួយ៖<br>• និយោជិតជាប់កិច្ចសន្យា<br>• និយោជិតសាកល្បងការងារ<br>• និយោជិតក្របខណ្ឌពេញសិទ្ធិ<br><br>និយោជិតគ្រប់រូប គោរពបានតាមបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពដូចជា៖<br>• ពេលវេលាធ្វើការពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៤:៣០ល្ងាច<br>• សំលៀកបំពាក់ឯកសណ្ឋានមាន៤ប្រភេទតាមការកំណត់ គោរពឋានានុក្រមក្នុងការបំពេញការងារ |
| ៤ | ការគាំពារបរិស្ថាន | - ស្របតាមគោលនយោបាយរបស់ រាជរដ្ឋាភិបាលជាពិសេសក្រសួង បរិស្ថាន លើការគិតគូរ និងគាំពារ បរិស្ថាន | - ការអនុវត្តគម្រោងពង្រីកប្រព័ន្ធផលិតកម្ម និងប្រព័ន្ធមេនាំទឹករបស់ រ.ទ.ស.ភ គឺចាប់ផ្តើមឡើង ដោយអង្គភាពបានរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថាន និងសង្គមដំបូងព្រមទាំងស្នើសុំការឯកភាពពីក្រសួងបរិស្ថាន។ ក្រោយពីទទួលបានឯកភាព និងនៅពេលដែលអនុវត្តគម្រោង រ.ទ.ស.ភ តែងតែធ្វើ ការត្រួតពិនិត្យលើផលប៉ះពាល់បរិស្ថានរបស់គម្រោង ជារៀង រាល់ឆមាស ព្រមទាំងរៀបចំជារបាយការណ៍ជូនម្ចាស់ហិរញ្ញប្បទាន និងក្រសួងបរិស្ថាន។<br>- ប្រើប្រាស់ថាមពលកកើតឡើងវិញ (Renewable Energy) ដើម្បីកាត់បន្ថយការបំភាយឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) ទៅក្នុងបរិយាកាស។<br>- កាត់បន្ថយការប្រើប្រាស់ថាមពល ដោយប្រើប្រាស់ឧបករណ៍បំប្លែងចរន្តអគ្គីសនី ដោយប្រព័ន្ធស្កាដាដើម្បីប្រមូល និងវិភាគទិន្នន័យតាមពេលវេលាជាក់ស្តែង។<br>- កាត់បន្ថយការប្រើប្រាស់វត្ថុធាតុដើម ដើម្បីកាត់បន្ថយកាកសំណល់រឹង និងកាកសំណល់ជីវសាស្ត្រក្នុងបរិស្ថាន។ |

# ផ្នែកទី៥.- ភាគីពាក់ព័ន្ធ (ត)

## ក. បង្ហាញពីគោលនយោបាយ និងសកម្មភាពទាក់ទងនឹងចំណុចដូចខាងក្រោម (ត)

| ល.រ | ខ្លឹមសារ | គោលនយោបាយ | សកម្មភាព |
|---|---|---|---|
| ៥ | អន្តរកម្មជាមួយសហគមន៍ | ពង្រីកផ្ទៃសេវាដល់សហគមន៍ ទៅតាមលទ្ធភាពជាក់ស្តែង | រ.ទ.ស.ភ បានធ្វើការពង្រីកផ្ទៃសេវាជូនប្រជាពលរដ្ឋដែល រស់នៅតាមបណ្តាសហគមន៍ទាំង១២ខណ្ឌ ស្មើនឹង ២.៥៩២បណ្តាញ៖<br>១- ខណ្ឌ ៧មករា ចំនួន ០២ បណ្តាញ<br>២- ខណ្ឌ ចំការមន ចំនួន ០១ បណ្តាញ<br>៣- ខណ្ឌ ទួលគោក ចំនួន ០៧ បណ្តាញ<br>៤- ខណ្ឌ ឫស្សីកែវ ចំនួន ២៨២ បណ្តាញ<br>៥- ខណ្ឌ ជ្រោយចង្វារ ចំនួន ៩១ បណ្តាញ<br>៦- ខណ្ឌ ព្រែកព្នៅ ចំនួន ៥៤ បណ្តាញ<br>៧- ខណ្ឌ សែនសុខ ចំនួន ២៣ បណ្តាញ<br>៨- ខណ្ឌ មានជ័យ ចំនួន ២៦ បណ្តាញ<br>៩- ខណ្ឌ ច្បារអំពៅ ចំនួន ២៩៤ បណ្តាញ<br>១០- ខណ្ឌ ដង្កោ ចំនួន ៩៤៧ បណ្តាញ<br>១១- ខណ្ឌពោធិ៍សែនជ័យ ចំនួន ៧៦៦ បណ្តាញ<br>១២- ក្រុងតាខ្មៅ ចំនួន ៩៩ បណ្តាញ |
| ៦ | ការការពារសិទ្ធិរបស់ម្ចាស់បំណុល | មានការធានាពីរាជរដ្ឋាភិបាល | - លិខិតធានាផ្លូវច្បាប់ចេញដោយក្រសួងយុត្តិធម៌លេខ ០៧១៨ MOJ.ILC/២៤ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ របស់គម្រោងសាងសង់រោងចក្រចាក់ខែង ជំហានទី៣។ |
| ៧ | កម្មវិធីប្រឆាំងអំពើពុករលួយ | - អនុវត្តការងារអាជីវកម្មជាមួយអតិថិជនដោយមានតម្លាភាព<br>- អនុវត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល | - ផ្តល់សេវាជូនអតិថិជនទាំងអស់ មិនប្រកាន់វណ្ណៈ ពណ៌សម្បុរ ឬបក្សពួកឡើយ។<br>- គ្រប់បុគ្គលិកជាន់ខ្ពស់ចាប់ពីប្រធាននាយកដ្ឋានឡើង ត្រូវប្រកាសទ្រព្យសម្បត្តិរៀងរាល់ ០២ឆ្នាំម្តង។ |

# ផ្នែកទី៥.- គោលការណ៍ (ត)

## ខ. ព័ត៌មានអំពីការទទួលខុសត្រូវសង្គមរបស់ រ.ទ.ស.ភ

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| ១ | ការកសាងហេដ្ឋារចនាសម្ព័ន្ធ | ទឹកប្រាក់សរុបប្រមាណ ១.៤៣២.៥៤៣.៥៥៦រៀល | - ឧបត្ថម្ភដល់ការសាងសង់របងការពារទីបញ្ចុះសពបងប្អូនខ្មែរឥស្លាម ស្ថិតនៅ ភូមិព្រែកថ្មី ឃុំជ័យធំ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។<br>- ទូទាត់បង់ថ្លៃបណ្ដាញនាឡិកាទំហំ ១៥ម.ម. ដល់អតិថិជននៅបុរីម៉ែនដានី ចំនួន ១៣ គម្រោង ស្ថិតនៅសង្កាត់ស្ពោរ ខណ្ឌកំបូល រាជធានីភ្នំពេញ ស្មើនឹង១.៦៨៣ បណ្ដាញ។<br>- ទូទាត់ថ្លៃទិញសម្ភារទីផ្សារសេរីរៀបចំតភ្ជាប់បណ្ដាញទឹក និងបង់ថ្លៃនាឡិកាទំហំ៤០ម.ម ចំនួន ០៣ទីតាំង មានចំនួន ៨៥គ្រួសារ ស្ថិតនៅភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។<br>- ទូទាត់ថ្លៃបង្វែរ ទីតាំងនាឡិកាទឹកចំនួន០២ ទីតាំងស្ថិតនៅក្នុងទីបញ្ជាការកងទ័ពជើងគោក តាមបណ្ដោយផ្លូវជាតិលេខ៤ ភូមិអង្គ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ។<br>- ទូទាត់បំណុលថ្លៃទឹក ឆ្នាំ២០២២ របស់ប្រជាពលរដ្ឋមានជីវភាពខ្វះខាត ផ្ទះចាក់សោរ និងដីឡូតិ៍គ្មានអ្នកប្រចាំការមិនអាចទាក់ទងបាន ចំនួន១០ទីតាំងក្នុងខណ្ឌចំនួន០៥ ក្នុង រាជធានីភ្នំពេញ។<br>- ឧបត្ថម្ភប្រេងឥន្ធនៈចំនួន ១.៧៩១លីត្រ សម្រាប់ចំណាយបេសកកម្មដល់មន្ត្រី ២៤រូបក្នុង យុទ្ធនាការផ្សព្វផ្សាយ និងតបណ្ដាញជូនអតិថិជននៅខេត្តត្បូងឃ្មុំ។<br>- ទូទាត់ថ្លៃបង់បណ្ដាញ នាឡិកាទំហំ ២៥ម.ម ចំនួន០២បណ្ដាញជូនរដ្ឋបាលខេត្តត្បូងឃ្មុំ សម្រាប់ប្រើប្រាស់ និងស្រោចស្រពសួនរង្វង់មូលហ្លួងព្រះស្ដេចកន ខេត្តត្បូងឃ្មុំ។<br>- ទូទាត់ថ្លៃរៀបចំតភ្ជាប់បណ្ដាញទឹក និងបង់ថ្លៃបណ្ដាញនាឡិកាទំហំ៤០ម.ម ចំនួន០៣ ទីតាំងជូនតំណាងចែកចាយទឹកដើម្បីធ្វើការចែកចាយទឹកបន្តជូនដល់ប្រជាពលរដ្ឋចំណុល។<br>- ទាបចំនួន ៨៥គ្រួសារ ស្ថិតនៅភូមិប៉ប្រកខាងជើង សង្កាត់កាកាបទី១ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។<br>- ឧបត្ថម្ភការរៀបចំប្រព័ន្ធបំពង់ចែកចាយទឹកថ្មី ក្រោយនាឡិកាទៅអាងតំកល់ទឹក ចូលតាមបន្ទប់អាគារស្នាក់នៅ ចំនួន១៩បន្ទប់ ដោយប្រើប្រាស់សម្ភារ និងពលកម្មទីផ្សារសេរី នៅបញ្ជាការដ្ឋានអង្គរក្សប្រចាំការនៅវិមានឯករាជ្យ ។<br>- ទូទាត់ថ្លៃទិញសម្ភារផ្សារសេរី និងបង់ថ្លៃបណ្ដាញនាឡិកាទំហំ ៤០ម.ម ចំនួន ១បណ្ដាញ ចូលសកលវិទ្យាល័យការពារជាតិ ដើម្បីប្រើប្រាស់នៅតាមអគារសហសិក្សា អគារស្នាក់នៅ និង អគារអាហារដ្ឋាន។<br>- ទូទាត់ថ្លៃបង់បណ្ដាញនាឡិកាទំហំ៤០ម.ម ចំនួន០១បណ្ដាញ ចូលទីតាំងមជ្ឈមណ្ឌល ហ្វឹកហ្វឺនភូមិសាស្ត្រយោធា នាយកដ្ឋានភូមិសាស្ត្រ ក្រសួងការពារជាតិ។<br>- ទូទាត់បង់ថ្លៃបណ្ដាញនាឡិកា ទំហំ៤០ម.ម ចំនួន០១បណ្ដាញ ចូលទីតាំងខុទ្ទកាល័យថ្មី របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ |

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| | | | - ឧបត្ថម្ភការរៀបចំដំឡើងនាឡិកាទឹកទំហំ ៨០ម.ម ចំនួន១គ្រឿង ជូនអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ស្ថិតនៅបឹងតាមោក (បឹងកប់ស្រូវ) សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។<br>- ទូទាត់បង់ថ្លៃបណ្តាញនាឡិកាទំហំ ១៥ ម.ម ដល់អតិថិជននៅ បុរីម៉ានដានី គម្រោង ១០-២២ ស្ថិតនៅសង្កាត់ស្ពានថ្ម ខណ្ឌកំបូល រាជធានីភ្នំពេញ ស្មើនឹង៧៤២ បណ្តាញ។<br>- ទូទាត់បង់ថ្លៃបណ្តាញនាឡិកាទំហំ ១៥ ម.ម ដល់អតិថិជននៅ បុរីម៉ានដានី គម្រោង១៤ (ខាងជើង) ស្ថិតនៅសង្កាត់ស្ពានថ្ម ខណ្ឌកំបូល រាជធានីភ្នំពេញ ស្មើនឹង៦៥បណ្តាញ។<br>- ឧបត្ថម្ភបន្ថែមដល់ការសាងសង់អគារសិក្សា១ខ្នង ៥បន្ទប់ រួមទាំងសម្ភារ-បរិក្ខារបំពាក់ក្នុងអគារ នៅអនុវិទ្យាល័យក្រាំងតាសែន ស្ថិតក្នុងភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។<br>- ឧបត្ថម្ភការជួសជុលកំណាត់ផ្លូវលំប្រវែង៤០០ម៉ែត្រ ចុះពីផ្លូវជាតិលេខ២១ ចូលទៅ ភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។ |
| ២ | ការឧបត្ថម្ភជួយសង្គ្រោះ | ទឹកប្រាក់សរុបប្រមាណ ៥២៤.៥១៦.៥០០រៀល | - ទូទាត់ទឹកប្រាក់បង្គ្រប់ជូនអតិថិជនជាតំណាងចែកចាយប្រកាសវគ្គ ១១-១២/២០២៣។<br>- ទូទាត់ទឹកប្រាក់បង្គ្រប់ជូនអតិថិជនជាតំណាងចែកចាយប្រកាសវគ្គ ០១-០២/២០២៤។<br>- ឧបត្ថម្ភថវិកាដើម្បីចូលរួមជាជំនួយមនុស្សធម៌ដល់សកម្មភាពកាកបាទក្រហមកម្ពុជាក្នុង ឱកាសខួបលើកទី១៦១ ទិវាពិភពលោកកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៤ ។<br>- ឧបត្ថម្ភថវិកាបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈរដ្ឋបាលខេត្តត្បូងឃ្មុំ។<br>- ឧបត្ថម្ភថវិកាបរិច្ចាគជូន «មូលនិធិគន្ធបុប្ផាកម្ពុជា» សម្រាប់ឆ្នាំ ២០២៤ តាមរយៈមូល និធិគន្ធបុប្ផាកម្ពុជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។<br>- ឧបត្ថម្ភថវិកាចូលរួមជាជំនួយមនុស្សធម៌ដល់សកម្មភាពកាកបាទក្រហមកម្ពុជាក្នុង ឱកាស ខួបលើកទី១៦១ ទិវាពិភពលោកកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៤ តាមរយៈគណៈកម្មការសាខាកាកបាតក្រហមកម្ពុជាខេត្តបាត់ដំបង។<br>- ទូទាត់ទឹកប្រាក់បង្គ្រប់ជូនអតិថិជនជាតំណាងចែកចាយប្រកាសវគ្គ ០៥,០៦,០៧ និង ០៨/២០២៤។<br>- ឧបត្ថម្ភថវិកាថ្លៃទិញអង្ករចំនួន២តោន ជូនសមាគមនវិទ្យុ និងទូរទស្សន៍អនឡាញសំឡេង ជនពិការភ្នែក ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។<br>- ឧបត្ថម្ភក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទឹកគ្មានចំណូល (លើកទី២) សម្រាប់មន្ត្រីជំនាញរបស់មន្ទីរនានា នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍។ |

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| | | | - ចូលរួមបរិច្ចាគក្នុងកម្មវិធីសប្បុរសធម៌ «ក្ដីសង្ឃឹមនៃជីវិត» ប្រចាំឆ្នាំ២០២៤ ដែលនឹងប្រព្រឹត្តទៅកាលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ដើម្បីរួមចំណែកជួយដល់កុមារដែល ខ្វះខាតទីជម្រក និងអាហារបរិភោគ ក៏ដូចជាការថែទាំសុខភាព និងការសិក្សា។ |
| ៣ | ឧបត្ថម្ភជួយសង្គ្រោះដល់និយោជិត | ទឹកប្រាក់សរុបប្រមាណ ១៤៧.៤០០.០០០រៀល | នៅក្នុងឆ្នាំ២០២៤ គណៈកម្មការមូលនិធិបានចំណាយថវិកាឧបត្ថម្ភដល់និយោជិតចំនួន ៨៤ រូបក្នុងនោះ៖<br>- ជំងឺកម្រិតស្រាល ៤៨ រូប<br>- ជំងឺកម្រិតមធ្យម ២២ រូប<br>- ជំងឺកម្រិតធ្ងន់ ០៥ រូប<br>- លំហែលមាតុភាព ០៤ រូប<br>- អ្នកជំងឺធ្ងន់ធ្ងរអាចឈានដល់មរណភាព ០១ រូប<br>- មរណភាព ០៣ រូប |
| ៤ | ឧបត្ថម្ភអតិថិជនចំណូលទាប | ទឹកប្រាក់សរុបប្រមាណ ៥៥៨.៩២៩.០០០រៀល | នៅក្នុងឆ្នាំ២០២៤ រ.ទ.ស.ភ ចំណាយថវិកាដើម្បីភ្ជាប់បណ្ដាញឧបត្ថម្ភធនជូនអតិថិជនចំណូលទាប (កម្រិត៣០%, កម្រិត៥០%, កម្រិត ៧០% និងកម្រិត១០០%) **សរុបចំនួន ២.៤៨៩ បណ្ដាញ** ក្នុងនោះ (ពីខែមករា ដល់ខែធ្នូ)<br>- ឧបត្ថម្ភធន ៣០% ចំនួន ២៣៣ អតិថិជន<br>- ឧបត្ថម្ភធន ៥០% ចំនួន ១.២៣៤ អតិថិជន<br>- ឧបត្ថម្ភធន ៧០% ចំនួន ៥៩៨ អតិថិជន<br>- ឧបត្ថម្ភធន ១០០% ចំនួន ៤២៤ អតិថិជន |
| ៥ | ឧបត្ថម្ភផ្សេងៗ | ទឹកប្រាក់សរុបប្រមាណ ១.៤៥៣.២៨៣.៩៨០រៀល | - ឧបត្ថម្ភការរៀបចំ«ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍» ឆ្នាំ២០២៤ ដែលនឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២៤ ដល់២៦ ខែមីនា ឆ្នាំ២០២៤ នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៌កោះពេជ្រ។<br>- ចំណាយថវិកាទូទាត់ជូនទីតាំងបង្គោលពន្លត់អគ្គិភ័យប្រចាំខែមករា និងកុម្ភៈ ឆ្នាំ២០២៤។<br>- ចំណាយថវិកាទូទាត់ជូនទីតាំងបង្គោលពន្លត់អគ្គិភ័យប្រចាំខែមីនា និងមេសា ឆ្នាំ២០២៤។<br>- ឧបត្ថម្ភថ្លៃទិញកុំព្យូទ័រយួរដៃចំនួន១០គ្រឿង និងម៉ាស៊ីនព្រីនចំនួន១គ្រឿង សម្រាប់បម្រើការងារនៅខុទ្ទកាល័យរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។<br>- ឧបត្ថម្ភថវិកាក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី "ការគ្រប់គ្រងទឹកបាត់បង់" ដែលបាន ប្រព្រឹត្តទៅនៅថ្ងៃទី១៦,១៧ និង២៣ ខែកក្កដា ឆ្នាំ២០២៤ ដែលមានសិក្ខាកាមចូលរួម ចំនួន៥០រូប ក្រោមអធិបតីភាព **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង **ឯកឧត្តម ឯក សុនចាន់** ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ។<br>- ឧបត្ថម្ភជូននិវត្តជន ចំនួន១៥១រូប និងសម្រាប់ទិញវត្ថុអនុស្សាវរីយ៍ក្នុងពិធីជួបសំណេះ សំណាលជាមួយ ឯកឧត្តមប្រតិភូ កាលពីថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤។<br>- ឧបត្ថម្ភថវិកាក្នុងការរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **"ភាពជាអ្នកដឹកនាំក្នុងវិស័យទឹកស្អាត"** ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី០៤ និង០៥ខែកញ្ញា ឆ្នាំ២០២៤ ដែលមានសិក្ខាកាមចូលរួមចំនួន១០០រូប ក្រោមអធិបតីភាព **ឯកឧត្តម ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួង |

| ល.រ | ខ្លឹមសារ | ទំហំនៃការបរិច្ចាគ | សកម្មភាព |
|---|---|---|---|
| | | | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង**ឯកឧត្តម ឯក សុនចាន់** ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ។<br>- ទូទាត់ជូនទីតាំងបង្គោលពន្លត់អគ្គិភ័យប្រចាំខែឧសភា និងមិថុនា ឆ្នាំ២០២៤។<br>- ឧបត្ថម្ភលើពលកម្ម កម្មករទីផ្សារសេរី រៀបចំបណ្តាញទឹកស្អាតសម្រាប់ផ្គត់ផ្គង់ដល់កីឡាករ កីឡាការិនីអុំទូក នៅទីតាំងខាងកើតវិថីអូស៊ីអាយស៊ី,ខាងលិចមហាវិថីអូស៊ីអាយស៊ី, ខាងជើងការដ្ឋានផ្សាររាត្រី និងខាងត្បូងការដ្ឋានផ្សាររាត្រី ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៤ ។ |

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព

## ក. ការបង្ហាញព័ត៌មានក្នុងរបាយការណ៍ប្រចាំឆ្នាំដូចខាងក្រោម៖

| ល.រ | ព័ត៌មាន | មាន/គ្មានបង្ហាញ |
|---|---|---|
| ១ | ចក្ខុវិស័យ/បេសកកម្ម/គោលដៅអាជីវកម្ម | មានបង្ហាញ |
| ២ | សូចនាករហិរញ្ញវត្ថុ | មានបង្ហាញ |
| ៣ | សូចនាករមិនមែនហិរញ្ញវត្ថុ | មានបង្ហាញ |
| ៤ | កត្តាហានិភ័យសំខាន់ៗ | មានបង្ហាញ |
| ៥ | គោលនយោបាយភាគលាភ | មានបង្ហាញ |
| ៦ | ជីវប្រវត្តិរបស់អភិបាល | មានបង្ហាញ |
| ៧ | ការបណ្តុះបណ្តាលសម្រាប់អភិបាល | មានបង្ហាញ |
| ៨ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ៩ | វត្តមានរបស់អភិបាលក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល | មានបង្ហាញ |
| ១០ | លាភការ ឬប្រាក់បំណាច់សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ | មានបង្ហាញ |

## ខ. យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន

**លោក ផេង ប៉ូលីផែន** អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច និង **លោក ជូ ផល្លា** អគ្គនាយករងទទួលបន្ទុកផែនការ និងគម្រោង ជាបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មានរបស់ រ.ទ.ស.ភ ដែលមានការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ជាជំនួយការក្នុងការផ្តល់ព័ត៌មានសាជីវកម្ម។

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន រៀបចំរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីដាក់ជូនសុំការអនុម័តពីក្រុមប្រឹក្សាភិបាល រួចផ្ញើជូននិយ័តករមូលបត្រកម្ពុជា (ទម្រង់PDF) ដើម្បីស្នើសុំការអនុញ្ញាតផ្សព្វផ្សាយរបាយការណ៍ទាំងនេះជាសាធារណៈ បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើសំណើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិនត្រូវបញ្ជូនរបាយការណ៍នេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

# ផ្នែកទី៦.- ការបង្ហាញព័ត៌មាន និងតម្លាភាព (ត)

## ខ. យន្តការនៃការបង្ហាញព័ត៌មាន មធ្យោបាយ នីតិវិធី និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន (ត)

ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ផ្តល់ព័ត៌មានពិសេស និងព័ត៌មានតាមការស្នើសុំជូននិយ័តករមូលបត្រកម្ពុជា បន្ទាប់ពីទទួលបានការត្រួតពិនិត្យរបស់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន និងការអនុញ្ញាតរបស់ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**។ ក្រោយពីបានទទួលការអនុញ្ញាតពី និយ័តករមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

ដោយឡែកព័ត៌មានទាន់ពេល និងព័ត៌មានតាមការស្ម័គ្រចិត្តត្រូវបានបញ្ជូនទៅ ផ្សារមូលបត្រកម្ពុជា តាមប្រព័ន្ធ E-Disclosure របស់ផ្សារមូលបត្រកម្ពុជា ដោយការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន បន្ទាប់ពីការត្រួតពិនិត្យរបស់ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និងបុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន។ ក្រោយពីទទួលបានការអនុញ្ញាតរបស់ផ្សារមូលបត្រកម្ពុជា លើព័ត៌មានដែលបានស្នើសុំរួចមក ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន ត្រូវបញ្ជូនព័ត៌មាននេះ ទៅនាយកដ្ឋានអាជីវកម្ម ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័រផ្លូវការរបស់ រ.ទ.ស.ភ ជូនវិនិយោគិន និងសាធារណជន។

## គ. ទំនាក់ទំនងជាមួយវិនិយោគិន

### ១- យន្តការ និងនីតិវិធីនៃការទំនាក់ទំនងជាមួយវិនិយោគិន

រ.ទ.ស.ភ ធ្វើការទំនាក់ទំនងទៅវិនិយោគិន តាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ រ.ទ.ស.ភ ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ និងមហាសន្និបាតភាគហ៊ុនិក។ ចំពោះវិនិយោគិនដែលមានបំណងស្វែងយល់អំពី រ.ទ.ស.ភ ត្រូវដាក់សំណើជាមុនមកកាន់ រ.ទ.ស.ភ ដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្ររបស់ខ្លួន ដើម្បីឲ្យ រ.ទ.ស.ភ មានលទ្ធភាពរៀបចំតាមសំណើរបស់វិនិយោគិន។

ក្រៅពីយន្តការទំនាក់ទំនងខាងលើ វិនិយោគិនអាចធ្វើការទំនាក់ទំនងមកកាន់បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាននិង/ឬ ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន នៃនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ តាមរយៈសារអេឡិចត្រូនិកដូចខាងក្រោម៖

- បុគ្គលិកទទួលបន្ទុកផ្តល់ព័ត៌មាន: Dpolyden@ppwsa.com.kh ឬ cphalla@ppwsa.com.kh
- ការិយាល័យទំនាក់ទំនងផ្សារមូលបត្រ និងវិនិយោគិន: Ksokuntheary@ppwsa.com.kh ឬ ir@ppwsa.com.kh

### ២- ទំនាក់ទំនងជាមួយនឹងវិនិយោគិនក្នុងឆ្នាំ២០២៤

នៅក្នុងឆ្នាំ២០២៤ រ.ទ.ស.ភ បានធ្វើការទំនាក់ទំនងជាមួយនឹងវិនិយោគិនតាមរយៈ ធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងការផ្តល់ព័ត៌មានអំពី ការបែងចែកភាគលាភប្រចាំឆ្នាំ២០២៣ និងមហាសន្និបាតភាគហ៊ុនលើកទី១២ របស់ រ.ទ.ស.ភ។

# ឧបសម្ព័ន្ធ ២

## របាយការណ៍សវនកម្មផ្ទៃក្នុង

## ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ

**ប្រចាំឆ្នាំ២០២៤**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សវនកម្មផ្ទៃក្នុង
លេខ ..០០.៣...វ.ស.ក

# របាយការណ៍សវនកម្មផ្ទៃក្នុង
# ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ
# ប្រចាំឆ្នាំ២០២៤

ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដ៏មានសារៈសំខាន់ដែលជួយដល់អង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រាប់អនុវត្តការងារប្រចាំថ្ងៃប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅផ្គត់ផ្គង់ទឹកស្អាត ជូនអតិថិជនរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ប្រកបដោយសុខុមាលភាព។

ក្នុងឆ្នាំ២០២៤ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានមន្ត្រី-និយោជិត សរុបចំនួន ១.៤៣៤ នាក់ (នារី ២៤៨ នាក់) ក្នុងនោះ ៖

- មន្ត្រីក្របខណ្ឌរដ្ឋ ចំនួន ០១ នាក់ **ឯកឧត្តមប្រតិភូ**
- មន្ត្រី-និយោជិតក្របខណ្ឌសហគ្រាស ចំនួន ១.៣៣៦ នាក់ (នារី ២៣២ នាក់)
- និយោជិតសាកល្បងការងារ ចំនួន ៣០ នាក់ (នារី ១២ នាក់)
- និយោជិតជាប់កិច្ចសន្យា ចំនួន ៦៧ នាក់ (នារី ០៤ នាក់)

ផែនការសកម្មភាពសវនកម្ម ប្រចាំឆ្នាំ២០២៤ ស្តីពីការត្រួតពិនិត្យលើអនុលោមភាព និងប្រតិបត្តិការ ទទួលបានការឯកភាពពីប្រធានគណៈកម្មាធិការសវនកម្ម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្នុងនោះ៖

១- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម និង នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក ត្រីមាសទី១

២- នាយកដ្ឋានអាជីវកម្ម ត្រីមាសទី២

៣- មណ្ឌលព័ត៌មានវិទ្យា និង អង្គភាពលទ្ធកម្ម ត្រីមាសទី៣

៤- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ត្រីមាសទី៤

អនុសាសន៍ណែនាំពីគណៈកម្មាធិការសវនកម្ម និងកំណត់ហេតុប្រជុំក្រុមប្រឹក្សាភិបាល លើកទី១ អាណត្តិទី៨ ចុះថ្ងៃទី១៥/មីនា/២០២៣ តម្រូវឱ្យសវនកម្មផ្ទៃក្នុងបញ្ចូលកម្មវិធីចុះធ្វើសវនកម្មពុំព្រាងទុក (Surprise Audit)។ សវនកម្មផ្ទៃក្នុងយើងខ្ញុំ បាន៖

១- ចុះរាប់បំពង់ (PIPE) ឃ្លាំងសម្ភារ នៅរោងចក្រនិរោធន៍ និងរោងចក្រភូមិព្រែក នៃនាយកដ្ឋាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្នុងត្រីមាសទី១។

២- ពិនិត្យលើការប្រកាសវិក្កយបត្ររបស់ភ្នាក់ងារអានលេខនាឡិកា និងចែកវិក្កយបត្រ វគ្គ ០៥-០៦/២៤ (ខែឧសភា និងខែមិថុនា) នៃនាយកដ្ឋានអាជីវកម្ម ក្នុងត្រីមាសទី៣។

អនុសាសន៍ណែនាំរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំលើកទី១២ អាណត្តិទី៨ ចុះថ្ងៃទី១៩/កញ្ញា/២០២៤ តម្រូវឱ្យសវនកម្មផ្ទៃក្នុងចុះធ្វើការពិនិត្យលើការងារអានលេខនាឡិកាទឹករបស់ភ្នាក់ងារវគ្គ ០៩-១០/២៤ (ខែកញ្ញា និងខែតុលា) ក្នុងត្រីមាសទី៤។

## I. របាយការណ៍លទ្ធផលការងារសវនកម្មផ្ទៃក្នុង

## ក- ការអនុវត្តន៍អនុសាសន៍សវនកម្មគ្រាមុន

| អនុសាសន៍សវនកម្ម | បានអនុវត្ត/ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| **i. ក- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម**<br>**ការិយបរិច្ឆេទ ២០២១** | | | |
| **របាយការណ៍អនុវត្តការងារលើសម៉ោងប្រចាំសប្តាហ៍ របស់និយោជិតនៅរោងចក្រទាំង ០៤ អនុវត្តពុំស្របតាមលក្ខន្តិកៈបុគ្គលិក**<br>មន្ត្រីទទួលបន្ទុក ត្រូវសហការជាមួយនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស ក្នុងការរៀបចំរបាយការណ៍អនុវត្តការងារលើសម៉ោងប្រចាំសប្តាហ៍ របស់និយោជិតរោងចក្រឱ្យស្របតាមលក្ខន្តិកៈបុគ្គលិក ដើម្បីងាយស្រួលក្នុងការតាមដាន។ | អនុវត្តបានពេញលេញ | | |
| **ខ- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក**<br>**ការិយបរិច្ឆេទ ២០១៥** | | | |
| **ការងារថែទាំប្រព័ន្ធចែកចាយទឹក អនុវត្តពុំសមស្របលើបរិមាណទឹកបង្ហូរលាងចុងបំពង់, ពុំបញ្ជាក់លេខផ្លូវ, តួលេខនៃការលេចធ្លាយពុំច្បាស់លាស់ និងតួលេខសរសេរខ្មៅដៃ**<br>ការិយាល័យ ត្រូវធ្វើការវិភាគ-តាមដាន និងកត់ត្រាក្នុងរបាយការណ៍ប្រចាំថ្ងៃឱ្យបានច្បាស់លាស់ពីបរិមាណទឹកបង្ហូរលាង (ចុងបំពង់, បង្គោលអគ្គីភ័យ, នាឡិកាតំបន់), បញ្ជាក់ពីលេខផ្លូវ, ទំហំបំពង់ក្នុងប្លង់ និងត្រូវកត់ត្រាជាប៊ិចពណ៌ខៀវ។ **ករណី មានការលាងសម្អាតច្រើនលើក ត្រូវមានរបាយការណ៍បញ្ជាក់ពីមូលហេតុនៃការបង្ហូរលាង។** | ការកោសលុប ក្នុងការបំពេញបរិមាណទឹកលាងចុងបំពង់ ការិយាល័យនឹងធ្វើការកែតម្រូវ ចាប់ពីឆ្នាំ២០២៤។ | ការិយាល័យ ត្រូវកត់ត្រាព័ត៌មាន នៅក្នុងរបាយការណ៍ជាប៊ិចពណ៌ខៀវ, បញ្ជាក់លេខផ្លូវ និងទំហំបំពង់ក្នុងប្លង់ឱ្យបានច្បាស់។ | ទាប |
| **ការិយបរិច្ឆេទ ២០១៦** | | | |
| **ការរៀបចំរបាយការណ៍ជួសជុលទឹកធ្លាយ ពុំបានត្រឹមត្រូវទៅតាមខែនីមួយៗ**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់ក្នុងការប្រមូលឯកសារឱ្យបានគ្រប់ចំនួនតាមខែនីមួយៗមុននឹងធ្វើការរៀបចំរបាយការណ៍ ដើម្បីឱ្យការរៀបចំបានត្រឹមត្រូវ និងងាយស្រួលក្នុងការគ្រប់គ្រង។ | មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការអនុវត្ត។ ការិយាល័យនឹងធ្វើការកែតម្រូវ ចាប់ពីឆ្នាំ២០២៤។ | ការិយាល័យ ត្រូវរៀបចំរបាយការណ៍ឱ្យបានត្រឹមត្រូវ។ | ទាប |
| **ការិយបរិច្ឆេទ ២០២១** | | | |
| **១- ការកំណត់ទំហំមុខកាត់វ៉ាន ក្នុងការគណនាបរិមាណទឹកលាងចុងបំពង់ទំហំ ៦៣ មម ពុំទាន់មានភាពត្រឹមត្រូវ**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់ក្នុងការពិនិត្យទៅលើការកំណត់មុខកាត់បង្ហូរលាងចុងបំពង់ឱ្យបានត្រឹមត្រូវ ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការគណនា។ | អនុវត្តបានពេញលេញ | | |
| **២- ការកំណត់រូបមន្តសម្រាប់គណនាទំហំប្រេះធ្លាយ លើការងារជួសជុលទឹកធ្លាយ ពុំទាន់មានភាពត្រឹមត្រូវ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការកំណត់ព័ត៌មានឱ្យបានច្បាស់ និងត្រឹមត្រូវមុនធ្វើការគណនា។ | អនុវត្តបានពេញលេញ | | |
| **៣- ការបំពេញព័ត៌មានក្នុងព្រឹត្តិប័ត្រតាមដានការងារជួសជុលទឹកធ្លាយ ពុំបានគ្រប់គ្រាន់**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការកត់ត្រាព័ត៌មាននៃការលេចធ្លាយឱ្យបានច្បាស់ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវ, ពេញលេញ និងស្របតាមស្តង់ដានីតិវិធីប្រតិបត្តិការការងារដែលបានកំណត់។ | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | បានអនុវត្ត/ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| **៤- ការកត់ត្រាព័ត៌មានក្នុងរបាយការណ៍ជួសជុលទឹកធ្លាយ ពុំត្រូវជាមួយនឹងព្រឹត្តិប័ត្រតាមដានការងារប្រចាំថ្ងៃ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ មុននឹងបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍ជួសជុលទឹកធ្លាយ។ | អនុវត្តបានពេញលេញ | | |
| **ii. នាយកដ្ឋានអាជីវកម្ម**<br>**ការិយបរិច្ឆេទ ២០១៥** | | | |
| **១- ការគ្រប់គ្រងស្តុកសម្ភាររបស់ការិយាល័យតបណ្តាញចូលផ្ទះ អនុវត្តពុំបានត្រឹមត្រូវ ដោយប័ណ្ណបញ្ចេញសម្ភារពុំមានចុះហត្ថលេខាពីអ្នកទទួល និងប្រធានការិយាល័យ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការពិនិត្យតាមដាន និងផ្ទៀងផ្ទាត់ប័ណ្ណសម្ភារឱ្យបានត្រឹមត្រូវមុននឹងធ្វើការបើកជូនទៅអ្នកអនុវត្តការងារ។ | ដោយសារ ប្រព័ន្ធមានបញ្ហា (ខូច) ធ្វើឱ្យទិន្នន័យដែលបញ្ចូលទៅក្នុងប្រព័ន្ធពុំអាចព្រីនបាន។ បច្ចុប្បន្នសាមីការិយាល័យ បានទំនាក់ទំនងទៅមណ្ឌលព័ត៌មានវិទ្យា ដើម្បីរៀបចំកែសម្រួល ឱ្យបានប្រសើរឡើងវិញ។ អនុវត្តចាប់ពីថ្ងៃទី០១/កក្កដា/២៤។ | ការិយាល័យ ត្រូវសហការជាមួយមណ្ឌលព័ត៌មានវិទ្យា ក្នុងការកែសម្រួលប្រព័ន្ធ ឱ្យបានកាន់តែឆាប់រហ័ស។ | ទាប |
| **២- ការគ្រប់គ្រងបណ្តាញទឹក ដែលមានបរិមាណទឹកប្រើប្រាស់ ចាប់ពី ៥០០.០០០ រៀលឡើង អនុវត្តពុំស្របតាមគោលការណ៍កំណត់ ដោយអតិថិជនមួយចំនួនពុំទាន់បានបង់ប្រាក់កក់បន្ថែម**<br>គ្រប់ការិយាល័យចំណូល ត្រូវធ្វើការតាមដាន និងធ្វើលិខិតអញ្ជើញអតិថិជនដែលបានប្រើប្រាស់បរិមាណទឹកច្រើន ហើយពុំទាន់បានបង់ប្រាក់កក់ធានាលើការប្រើប្រាស់ទឹកបន្ថែម ស្មើនឹង ០៣ខែ ធៀបនឹងបរិមាណទឹកប្រើប្រាស់ក្នុងវគ្គ ដើម្បីធានាលើការប្រើប្រាស់ទឹករបស់អតិថិជន និងស្របតាមគោលការណ៍។ | គ្រប់ការិយាល័យចំណូល បានធ្វើការតាមដាន និងធ្វើលិខិតអញ្ជើញអតិថិជនឱ្យមកបង់ប្រាក់កក់បន្ថែមជាបណ្តើរៗ ដើម្បីធានាលើការប្រើប្រាស់ទឹក និងស្របតាមគោលការណ៍។ | គ្រប់ការិយាល័យចំណូល ត្រូវធ្វើលិខិតអញ្ជើញអតិថិជន ឱ្យមកបង់ប្រាក់កក់បន្ថែមឱ្យបានឆាប់រហ័ស | ទាប |
| **ការិយបរិច្ឆេទ ២០១៦** | | | |
| **ការផ្លាស់ប្តូរទំហំនាឡិកាពីតូចទៅធំ អនុវត្តពុំស្របតាមគោលការណ៍ ដោយការប្រើប្រាស់ទឹករបស់អតិថិជន ពុំស្របតាមកិច្ចសន្យាកំណត់**<br>រាល់ការផ្លាស់ប្តូរទំហំនាឡិកា តាមការស្នើសុំរបស់អតិថិជន គ្រប់ការិយាល័យចំណូល ត្រូវតាមដានពីការប្រើប្រាស់ទឹករបស់អតិថិជនដូចដែលបានកំណត់ក្នុងកិច្ចសន្យា។ ក្នុងករណី អតិថិជនពុំអាចប្រើប្រាស់តាមចំនួនកំណត់បានត្រូវធ្វើការគិតបន្ថែមបង្គ្រប់បរិមាណទឹកជាមធ្យមក្នុងមួយថ្ងៃ ឱ្យបានត្រឹមត្រូវតាមការព្រមព្រៀងក្នុងកិច្ចសន្យា។ | បន្ទាប់ពីដាក់ដំណើរការរោងចក្របាក់ខែង ជំហាន១ សម្ពាធទឹក មានការកើនឡើង ការិយាល័យបណ្តាញចូលផ្ទះ ទទួលអនុសាសន៍ណែនាំពី **ឯកឧត្តមប្រតិភូ** ចំពោះនាឡិកាទំហំចាប់ពី២០ ម.ម ដល់ ៤០ ម.ម ជំនាញ ត្រូវចុះសិក្សាវាយតម្លៃពីតម្រូវការប្រើប្រាស់ទឹក និងមានលិខិតធានាការប្រើប្រាស់ពីអតិថិជនជាមុន ទើបដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេច។ | ការិយាល័យ ត្រូវអនុវត្ត តាមអនុសាសន៍ណែនាំរបស់ **ឯកឧត្តមប្រតិភូ** ឱ្យបានត្រឹមត្រូវ។ | ទាប |

| អនុសាសន៍សវនកម្ម | បានអនុវត្ត/ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| **ការិយបរិច្ឆេទ ២០១៩** | | | |
| **ការផ្តល់សេវាតបណ្តាញទឹកថ្មីជូនអតិថិជន អនុវត្តយឺតពុំស្របតាមនីតិវិធីស្តង់ដាការងារ SOP ដែលបានកំណត់**<br>ការិយាល័យ ត្រូវយកចិត្តទុកដាក់ក្នុងការរៀបចំកម្មវិធីចុះអនុវត្តការងារឱ្យបានច្បាស់ស្របតាមគោលការណ៍ដែលបានកំណត់ក្នុង SOP និងត្រូវធ្វើការកែសម្រួលនីតិវិធីស្តង់ដាការងារឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ | ការិយាល័យ កំពុងធ្វើការកែសម្រួលនីតិវិធីស្តង់ដាការងារតបណ្តាញទឹក ឱ្យស្របតាមស្ថានភាពការងារជាក់ស្តែង និងខិតខំធ្វើការផ្តល់សេវាជូនអតិថិជន ឱ្យកាន់តែប្រសើរ និងទាន់ពេល។ (គ្រោងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេចត្រឹមាសទី៤ ឆ្នាំ២០២៤) | ការិយាល័យ ត្រូវធ្វើការកែសម្រួល SOP ឱ្យបានកាន់តែឆាប់រហ័ស។ | ទាប |
| **ការិយបរិច្ឆេទ ២០២០** | | | |
| **ការត្រួតពិនិត្យវាស់ស្ទង់ និងលាងសម្អាតនាឡិកាទឹកទំហំ ៤០ មម ឡើង អនុវត្តពុំស្របតាម SOP**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួនឱ្យស្របទៅតាមស្តង់ដានីតិវិធីប្រតិបត្តិការ SOP ដែលបានកំណត់។ ករណី អនុវត្តលើសត្រូវបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ ឬធ្វើបច្ចុប្បន្នភាពទៅលើ SOP ឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ | ការិយាល័យ បានរៀបចំកម្លាំងឱ្យស្របតាមកម្មវិធីប្រចាំឆ្នាំ។ បច្ចុប្បន្ន កំពុងធ្វើការកែសម្រួលស្តង់ដានីតិវិធីប្រតិបត្តិការការគ្រប់គ្រងនាឡិកាទឹក SOP ឱ្យស្របទៅនឹងស្ថានភាពជាក់ស្តែង និងខិតខំអនុវត្តការងារឱ្យបានកាន់តែប្រសើរ និងទាន់ពេលវេលា។ (គ្រោងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ-សម្រេច នៅត្រីមាសទី៤ ឆ្នាំ២០២៤) | ការិយាល័យ ត្រូវធ្វើការកែសម្រួល SOP ឱ្យបានកាន់តែឆាប់រហ័ស។ | ទាប |
| **ការិយបរិច្ឆេទ ២០២២** | | | |
| **១- របាយការណ៍តបណ្តាញទឹកជូនអតិថិជន ពុំទាន់មានភាពពេញលេញ ដោយពុំមានហត្ថលេខាប្រធានផ្នែកបច្ចេកទេស, ពុំបញ្ជាក់សម្ភារប្រើប្រាស់, ថ្ងៃចុះវាស់វែងខុសពីថ្ងៃណាត់ និងប្រើប្រាស់សម្ភារខុសពីកំណត់បង្ហាញ**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការផ្ទៀងផ្ទាត់រាល់ការយកសម្ភារទៅប្រើប្រាស់, បរិយាយឱ្យត្រូវគ្នាជាមួយនឹងគំនូសប្លង់នៅក្នុងកំណត់បង្ហាញ និងធ្វើការកត់ត្រាព័ត៌មានពីការតបណ្តាញឱ្យបានច្បាស់ ដើម្បីឱ្យរបាយការណ៍មានភាពត្រឹមត្រូវជាមួយការអនុវត្តន៍ជាក់ស្តែង និងមានភាពពេញលេញ។ | មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងចុះហត្ថលេខា។ ការិយាល័យនឹងកែលម្អចំណុចខ្វះខាត ឱ្យបានប្រសើរឡើងវិញ និងអនុវត្តចាប់ពី ខែមិថុនា ឆ្នាំ២០២៤។ | មន្ត្រីទទួលបន្ទុក ត្រូវពង្រឹងការងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ | ទាប |
| **២- ការងារចុះផ្អាកការផ្គត់ផ្គង់ទឹកបណ្តោះអាសន្ន អនុវត្តពុំទាន់មានភាពច្បាស់លាស់ ដោយរក្សាគម្លាតរយៈពេលយូរ**<br>មន្ត្រីទទួលបន្ទុក ត្រូវរៀបចំកម្មវិធីអនុវត្តការងារឱ្យមានស្តង់ដាត្រឹមត្រូវ និងត្រូវរំលេចរយៈពេលកំណត់ចុះផ្អាកការផ្គត់ផ្គង់ទឹកជាបណ្តោះអាសន្ន។ ករណីមិនអាចអនុវត្តការចុះផ្អាកការផ្គត់ផ្គង់ទឹកបាន ត្រូវស្នើសុំគោលការណ៍ទៅ **ឯកឧត្តមប្រតិភូ** ដើម្បីឱ្យការអនុវត្តបានត្រឹមត្រូវ និងមានតម្លាភាព។ | អនុវត្តបានពេញលេញ | | |

| អនុសាសន៍សវនកម្ម | បានអនុវត្ត/ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
| --- | --- | --- | --- |
| **៣- របាយការណ៍កែសម្រួលទីតាំងនាឡិកា (លើក/រំកិល) មានការស្ទួនគ្នា**<br>មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យ, ផ្ទៀងផ្ទាត់ និងតាមដានឱ្យបានត្រឹមត្រូវ និងច្បាស់លាស់មុននឹងបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍។ | អនុវត្តបានពេញលេញ | | |
| **៤- ការបំពេញឯកសារបង់ប្រាក់លើការងារ លើក/រំកិលនាឡិកាទឹក ជូនអតិថិជន ពុំទាន់មានភាពពេញលេញគ្រប់គ្រាន់**<br>មន្ត្រីទទួលបន្ទុក ត្រូវធ្វើការកត់ត្រាព័ត៌មានឱ្យបានច្បាស់ ដើម្បីឱ្យរបាយ-ការណ៍មានភាពត្រឹមត្រូវ និងពេញលេញមុននឹងចងក្រងរក្សាទុកជាឯកសារ។ | អនុវត្តបានពេញលេញ | | |
| **៥- នាឡិកាខូចត្រូវបានប្តូរថ្មី អនុវត្តខុសពីបែបបទស្តង់ដានីតិវិធីប្រតិបត្តិការ ការគ្រប់គ្រងនាឡិកាទឹក**<br>មន្ត្រីទទួលបន្ទុក ត្រូវយកចិត្តទុកដាក់អនុវត្តការងាររបស់ខ្លួនឱ្យស្របទៅតាមស្តង់ដានីតិវិធីប្រតិបត្តិការ SOP ត្រង់ចំណុច ៤.៣- នាឡិកាខូច " **ក្រោយពេលទទួលព័ត៌មានការិយាល័យទំនាក់ទំនងអតិថិជន ត្រូវចាត់ចែងឱ្យជាងនាឡិកាទៅពិនិត្យ និងដោះដូរនាឡិកាភ្លាមៗមិនឱ្យលើសពីបី (០៣) ម៉ោង ករណីនាឡិកាខូចទឹកមិនចេញ ឬយ៉ាងយូរ បី (០៣) ថ្ងៃការងារ ករណីនាឡិកាខូចតែទឹកនៅចេញ ដោយសហការជាមួយក្រុមគ្រប់គ្រងតំបន់ ឬក្រុមប្រចាំការជួសជុលទឹកធ្លាយ នៃការិយាល័យគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក** " ដែលបានកំណត់ ឬធ្វើបច្ចុប្បន្នភាពទៅលើ SOP ឱ្យស្របទៅនឹងការអនុវត្តន៍ជាក់ស្តែង។ | អនុវត្តបានពេញលេញ | | |
| iii. **ក- មណ្ឌលព័ត៌មានវិទ្យា**<br>**ការិយបរិច្ឆេទ ២០២១** | | | |
| **នីតិវិធីប្រតិបត្តិការការងារ (SOP) ពុំទាន់បានធ្វើបច្ចុប្បន្នភាព**<br>មណ្ឌលព័ត៌មានវិទ្យា ត្រូវធ្វើបច្ចុប្បន្នភាពទៅលើនីតិវិធីប្រតិបត្តិការការងាររបស់ខ្លួនឱ្យមានលក្ខណៈស្របតាមសម័យកាលនៃបច្ចេកវិទ្យា។ | បានធ្វើបច្ចុប្បន្នភាព ដាក់ជូនប្រធានមណ្ឌលព័ត៌មានវិទ្យា គ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០២៤។ | មណ្ឌលព័ត៌មានវិទ្យា ត្រូវពន្លឿនការកែសម្រួល SOP ឱ្យបានកាន់តែឆាប់រហ័ស | ទាប |
| **ខ- អង្គភាពលទ្ធកម្ម**<br>**ការិយបរិច្ឆេទ ២០២១** | | | |
| **១- លិខិតធានាប្រាក់កក់លើការអនុវត្តន៍កិច្ចសន្យា ពុំស្របទៅនឹងការអនុវត្តជាក់ស្តែង ដែលមានរយៈពេលតិចជាងការប្រគល់-ទទួលទំនិញ**<br>អង្គភាពលទ្ធកម្ម ត្រូវពិនិត្យលើសុពលភាពលិខិតធានាប្រាក់កក់ដែលធានាលើការអនុវត្តកិច្ចសន្យាឱ្យបានត្រឹមត្រូវ មុននឹងធ្វើការទូទាត់។ | អនុវត្តបានពេញលេញ | | |
| **២- ការប្រើប្រាស់សម្ភារអនុវត្តពុំទាន់បានត្រឹមត្រូវ ដោយការយកសម្ភារមកប្រើមុនការឯកភាពប្រគល់កិច្ចសន្យាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**<br>អង្គភាពលទ្ធកម្ម ត្រូវសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់លើការបើកសម្ភារយកទៅប្រើប្រាស់ឱ្យត្រឹមត្រូវតាមកិច្ចសន្យា។ | អនុវត្តបានពេញលេញ | | |
| iv. **នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ**<br>**ការិយបរិច្ឆេទ ២០១៥** | | | |
| **ការងារទូទាត់ចំណាយជូននាយកដ្ឋាន/អង្គភាព និងក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួន អនុវត្តយឺត**<br>មន្ត្រីទទួលបន្ទុក ត្រូវអនុវត្តការងារទូទាត់ឱ្យបានទាន់ពេល។ | ដោយសារ<br>- ទំហំការងារច្រើន<br>- មានការខ្វះខាតកម្លាំង | ការិយាល័យ ត្រូវពង្រឹងការងារទូទាត់ឱ្យបានកាន់តែប្រសើរ | ទាប |

| អនុសាសន៍សវនកម្ម | បានអនុវត្ត/ ការឆ្លើយតប | អនុសាសន៍ | ហានិភ័យ |
|---|---|---|---|
| ការិយបរិច្ឆេទ ២០២២ | | | |
| **ការទូទាត់ចំណាយលើការងារដាក់បំពង់ចែកចាយទឹកថ្មី ក្នុងកំណត់ហេតុគណៈកម្មការស្តីពីការចុះពិនិត្យលើការងារជីក-ដាក់បំពង់ ពុំបានបញ្ជាក់ពីគម្រោងបានអនុវត្តរួច និងគម្រោងកំពុងអនុវត្តបន្ត**<br>រាល់គម្រោងដែលបានអនុវត្តមុនលើក ឬទទួលបានគម្រោង មន្ត្រីទទួលបន្ទុកការងារ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការកត់ត្រាលើគម្រោងបានអនុវត្តបញ្ចប់ និងគម្រោងកំពុងអនុវត្តបន្ត ដោយធ្វើជាតារាងរួមភ្ជាប់ជាឧបសម្ព័ន្ធ។ | អនុវត្តបានពេញលេញ | | |

## ខ- លទ្ធផលការងារសវនកម្ម

### i. ក- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម

ក្នុងឆ្នាំ២០២៣ នាយកដ្ឋាន អនុវត្តបាន៖

- ការងារទូទាត់លើការងារជួសជុល និងថែទាំ (ការិ. យន្តសាស្ត្រ និងអគ្គិសនី)ចំនួន ២៥១ សំណើ
- សំណើសុំទូទាត់លើការងារជួសជុលថែទាំ (ការិ. ផលិតកម្ម) ចំនួន ៥៥ សំណើ
- ការពិនិត្យគុណភាពទឹកស្អាត និងទឹកល្អក់តាមបណ្តារោងចក្រផលិតទឹក និងតាមបណ្តាញចែកចាយមានភាពល្អប្រសើរ។

នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយ ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**ការស្នើសុំទូទាត់ជួសជុលប្រព័ន្ធផលិតកម្ម អនុវត្តយឺត**

ក្នុងឆ្នាំ២០២៣ ការងារផ្គត់ផ្គង់ និងទូទាត់ចំណាយរបស់ការិយាល័យយន្តសាស្ត្រ និងអគ្គិសនី មានចំនួន ២៥១ សំណើ។

- សំណើសុំផ្គត់ផ្គង់ មានចំនួន ១៧១ សំណើ
- សំណើសុំទូទាត់ មានចំនួន ៨០ សំណើ

សវនកម្មផ្ទៃក្នុងពិនិត្យឃើញថា បន្ទាប់ពីបានអនុវត្តការងារជួសជុលប្រព័ន្ធផលិតកម្មរួច គម្លាតរយៈពេលនៃការស្នើសុំទូទាត់យឺត មាន ០៧ សំណើ ស្មើនឹង ៨,៧៥ %។

មន្ត្រីទទួលបន្ទុក រៀបចំឯកសារពុំទាន់ស្របតាមបែបបទគណនេយ្យ និងហិរញ្ញវត្ថុ។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងតាមដានទៅលើសំណើបន្ទាប់ពីបានអនុវត្តរួច។

ករណីនេះ នាំឱ្យការរៀបចំឯកសារយឺតយ៉ាវ ដែលនាំឱ្យប៉ះពាល់ដល់ការជួសជុលបន្ទាន់ដទៃផ្សេងៗទៀតលើប្រព័ន្ធផលិតកម្ម និងធ្វើឱ្យការទូទាត់ប្រាក់បុរេប្រទានយឺត។

មន្ត្រីទទួលបន្ទុកការងារ ត្រូវធ្វើការស្នើសុំទូទាត់ចំណាយឱ្យបានទាន់ពេល និងរៀបចំឯកសារឱ្យបានត្រឹមត្រូវតាមបែបបទគណនេយ្យ និងហិរញ្ញវត្ថុ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ ការិយាល័យទទួលយកអនុសាសន៍ណែនាំខាងលើ និងធ្វើការពិនិត្យកែសម្រួលឯកសារទូទាត់ឱ្យបានលឿន និងត្រឹមត្រូវតាមបែបបទគណនេយ្យ និងហិរញ្ញវត្ថុ។**

**ការិយាល័យនឹងចាប់ផ្តើមអនុវត្តបន្ទាប់ពីចេញរបាយការណ៍។**

**សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានរៀបចំបាយការណ៍កែលម្អ នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤។**

## ខ- នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក

ក្នុងឆ្នាំ២០២៣ នាយកដ្ឋាន អនុវត្តបាន៖

| | | | |
|---|---|---|---|
| - ការងាររើបំពង់ | ចំនួន | ២១.០៩៤ | ម៉ែត្រ |
| - ការងាររៀបបំពង់ | ចំនួន | ២៥.២៨១ | ម៉ែត្រ |
| - ការងារបង្ហូរលាងចុងបំពង់ | ចំនួន | ១៩.៣១៣ | ម៉ែត្រ |
| - ការលាងតាមបង្គោលអគ្គីភ័យ | ចំនួន | ៨៣៤ | ម៉ែត្រ |
| - ការជួសជុល និងថែទាំប្រព័ន្ធចែកចាយទឹក | ចំនួន | ២.៩២៣ | កន្លែង |
| - ជួសជុលទឹកធ្លាយមើលឃើញ និងមើលមិនឃើញ | ចំនួន | ៤.៣៨៤ | កន្លែង |

នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### ១- របាយការណ៍ការងាររើ-រៀបបំពង់ អនុវត្តពុំទាន់មានភាពត្រឹមត្រូវ

ក្នុងឆ្នាំ២០២៣ នាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក បានអនុវត្តការងាររើរៀបបំពង់ ចំនួន ៤២ កន្លែង ក្នុងនោះ សវនកម្មពិនិត្យឃើញថាការងាររើ-រៀបបំពង់ អនុវត្តពុំទាន់បានសមស្រប៖

១. ការងាររើបំពង់ ប៉ុន្តែពុំទាន់បានរៀបឡើងវិញ មាន ០៤ កន្លែង ស្មើ ០៩ %

២. ពុំមានរបាយការណ៍រើបំពង់ ប៉ុន្តែមានរបាយការណ៍រៀបបំពង់ មាន ០៥ កន្លែង ស្មើ ១១ %

ប្រការនេះ អនុវត្តពុំទាន់បានសមស្របទៅនឹងស្តង់ដានីតិវិធីប្រតិបត្តិការការងារថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹក SOP ត្រង់ចំណុច **៦. ការងាររើ-រៀបបំពង់ចែកចាយទឹក** វិធីសាស្ត្រនៃការរើ-រៀបបំពង់ ៖ **ផ្ទៀងផ្ទាត់ចំណុចរៀប (ជើងម៉ែត្រ) ឡើងវិញ រួចគូសលម្អិតចុងក្រោយហើយប្រគល់ជូនប្រធានផ្នែក។** ប្រធានផ្នែក ត្រូវចុះពិនិត្យស្ថានភាពបរិក្ខារនៅការដ្ឋានឱ្យបានគ្រប់ជ្រុងជ្រោយ រួចប្រគល់ជូនប្រធានការិយាល័យចុះហត្ថលេខា និងទុកជាឯកសារនៅការិយាល័យ GIS នៃនាយកដ្ឋានផែនការ និងគម្រោង។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យរបាយការណ៍ការងារឱ្យបានត្រឹមត្រូវ។

ករណីនេះ នាំឱ្យការអនុវត្តន៍ការងារពុំមានប្រសិទ្ធភាព។

មន្ត្រីទទួលបន្ទុកការងារ ត្រូវយកចិត្តទុកដាក់៖

- រៀបចំរបាយការណ៍ ដែលបានអនុវត្តឱ្យស្របនឹងបែបបទរដ្ឋបាល។
- រៀបចំគំរូរបាយការណ៍ ឱ្យស្របទៅនឹងការអនុវត្តជាក់ស្តែង។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖**

- **ការងារមួយចំនួន ត្រូវរង់ចាំរហូតដល់ការងារសាងសង់ថ្នល់ ឬលូដាក់រួចរាល់ និងមានទីតាំងត្រឹមត្រូវ ទើបយើងអាចរៀបឡើងវិញបាន។**
- **ទីតាំងរើបំពង់ពុំមានរបាយការណ៍ដោយសារជាការងារដាក់បំពង់ថ្មី ពុំមានគម្រោងរើបំពង់ទេ។**

**ការិយាល័យនឹងកែសម្រួលចំណុចខ្វះខាតនេះឡើងវិញ បន្ទាប់ពីចេញរបាយការណ៍។**

### ២- ការលាងសម្អាតតាមបណ្តាញចូលផ្ទះ ក្នុងទីតាំងតែមួយ ប៉ុន្តែលាងច្រើនដង

ក្នុងឆ្នាំ២០២៣ ការិយាល័យថែទាំប្រព័ន្ធចែកចាយទឹក បានធ្វើការលាងសម្អាតបណ្តាញចូលផ្ទះ ចំនួន ៦៥ កន្លែង ក្នុងនោះសវនករបានពិនិត្យឃើញថា មានចំនួន ០៤ កន្លែង លាងច្រើនដង៖

- លាងបំពង់ ២ ដង ចំនួន ៣ កន្លែង
- លាងបំពង់ ៣ ដង ចំនួន ១ កន្លែង

ប្រការនេះ អនុវត្តពុំទាន់ត្រឹមត្រូវ និងសមស្របតាមការកំណត់ជាក់ស្តែង។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងផ្ទៀងផ្ទាត់ការងារឱ្យបានច្បាស់។

ករណីនេះ នាំឱ្យបរិមាណទឹកអនុញ្ញាតឱ្យប្រើប្រាស់មានការកើនឡើងខ្ពស់។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការបំពេញព័ត៌មានក្នុងរបាយការណ៍អនុវត្តការងារប្រចាំថ្ងៃឱ្យបានច្បាស់។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖**

- **បំពង់ដែលបង្ហូរលាងមានទំហំតូច តម្រូវឱ្យធ្វើការបង្ហូរលាងច្រើនថ្ងៃ និងប្រើរយៈពេលយូរ ដោយសារពុំមានប្រអប់បង្ហូរលាងចុងបំពង់។**
- **ការកត់ត្រាក្នុងរបាយការណ៍បង្ហាញថាបានថ្លាប្រសើរនៅថ្ងៃទី១ ប៉ុន្តែថ្ងៃបន្ទាប់ទឹកមានខ្យាច់កើតឡើងម្តងទៀត តម្រូវឱ្យធ្វើការបង្ហូរលាងឡើងវិញ។**
- **ការកត់ត្រាពុំបានបញ្ជាក់លំអិតក្នុងរបាយការណ៍។**

**ការិយាល័យនឹងកែតម្រូវឡើងវិញបន្ទាប់ពីចេញរបាយការណ៍។**

**សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានរៀបចំរបាយការណ៍កែលម្អ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤។**

## ii. នាយកដ្ឋានអាជីវកម្ម

ក្នុងឆ្នាំ២០២៣ នាយកដ្ឋានអាជីវកម្ម អនុវត្តបាន ដូចជា៖

**១. ការងារតបណ្តាញ ចំនួន ៣០.១១៣ បណ្តាញ**

- ប្រភេទជីវភាព (រ.ទ.ស.ក) ចំនួន ២៤.១៥២ បណ្តាញ
- ប្រភេទជីវភាព (ត្បូងឃ្មុំ) ចំនួន ៧៥៦ បណ្តាញ
- ប្រភេទអាជីវកម្ម (រ.ទ.ស.ក) ចំនួន ៧១២ បណ្តាញ
- ប្រភេទអាជីវកម្ម (ត្បូងឃ្មុំ) ចំនួន ០៣ បណ្តាញ
- បណ្តាញថ្មីតែប្រើលេខកូដចាស់ (ប្តូរទីតាំងនាឡិកា) ចំនួន ៧០៧ បណ្តាញ
- បណ្តាញថ្មីតែប្រើលេខកូដចាស់ (ប្តូរទំហំនាឡិកា) ចំនួន ៧៥ បណ្តាញ

**២. ការងារផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋចំណូលទាប ចំនួន ៣.៧០៨ បណ្តាញ**

**៣. ការងារលើក/រំកិលនាឡិកា ចំនួន ១.០៦៧ នាឡិកា**

នាយកដ្ឋានអាជីវកម្ម អនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### ១- ការរៀបចំឯកសារនាឡិកាទឹកមានអាយុកាលចាប់ពី ១១ ឆ្នាំឡើង ពុំទាន់មានភាពត្រឹមត្រូវ

ក្នុងឆ្នាំ២០២៣ ការិយាល័យទំនាក់ទំនងអតិថិជន បានធ្វើការផ្លាស់ប្តូរនាឡិកាដែលមានអាយុកាលចាប់ពី ១១ ឆ្នាំឡើង ក្នុងរបាយការណ៍មាន៖

- ៥.៩៥៥ នាឡិកា ពុំអាចធ្វើការបែងចែកបានរវាងនាឡិកាដល់អាយុកាលកំណត់, នាឡិកាខូច និងការងារលើក/រំកិលនាឡិកា។
- សវនករពិនិត្យ ៦.០៩៦ នាឡិកា លម្អៀងលើស ១៤១ នាឡិកា

ប្រការនេះ អនុវត្តពុំទាន់បានត្រឹមត្រូវតាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងរៀបចំបែងចែកតាមប្រភេទរបាយការណ៍នីមួយៗឱ្យបានត្រឹមត្រូវ។

ករណីនេះ នាំឱ្យការកត់ត្រារបាយការណ៍ដែលបានអនុវត្ត ពុំមានភាពច្បាស់លាស់ ឬអាចមានស្ទួនគ្នា។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការចងក្រងរបាយការណ៍ (Soft Copy និង Hard Copy) តាមការងារនីមួយៗឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖**

- **នាឡិកា ចំនួន ៥.៩៥៥ គឺជាចំនួនជាក់ស្តែងដែលក្រុមជាងបានចុះទៅដោះដូរតាមគោលការណ៍ ១១ ឆ្នាំឡើង ដែលមានសេចក្តីជូនដំណឹងតាមខណ្ឌនីមួយៗ។**
- **នាឡិកា ចំនួន ១៤១ ធ្វើការដោះដូរ និងបានចាត់ចូលទៅក្នុងប្រភេទតាមសំណើផ្សេងៗ។**

ទទួលយកអនុសាសន៍របស់សវនករ ដោយអនុវត្តចាប់ពីខែមិថុនាទៅ និងកែតម្រូវដោយបញ្ជាក់ពីចំនួនលម្អិតទៅលើរបាយការណ៍ចុះដោះស្រាយតាមសំណើមុន ឬក្រោយ។

**២- ការគ្រប់គ្រងស្តុកសម្ភារអនុវត្តពុំទាន់បានសមស្រប (ដោយមានភាពលម្អៀងលើស)**

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ របាយការណ៍ស្តុកសម្ភារ មានចំនួន ៦៦ មុខ ក្រោយពីបានចុះពិនិត្យជាក់ស្តែងឃើញថាសម្ភារចំនួន ៥៨ មុខ មានភាពត្រឹមត្រូវ និង០៨ មុខ មានភាពលម្អៀងលើស ដូចខាងក្រោម៖

| ល.រ | កូដ | ឈ្មោះសម្ភារ | សមតុល្យចុងគ្រា | | រាប់ជាក់ស្តែង | លម្អៀងលើស | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ឯកត្តា | ចំនួន | | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 = 6 - 5 | |
| 1 | I-00596 | Bend PVC 20x27 | រាយ | 111 | 148 | 37 | |
| 2 | I-00597 | Bend PVC 26x34 | - | 32 | 47 | 15 | |
| 3 | I-00609 | Bend Quick 32 | - | 36 | 38 | 2 | |
| 4 | I-00647 | Coupler Straight Quick 32 | - | 70 | 81 | 11 | |
| 5 | I-00761 | Male Adaptor 50x1.1/2' | - | 9 | 10 | 1 | |
| 6 | I-00803 | Reducing Quick 40x25 | - | 10 | 11 | 1 | |
| 7 | I-00840 | Male Socket PVC 20x27 | - | 39 | 74 | 35 | |
| 8 | I-00854 | Solvent PVC 100g | - | 13 | 46 | 33 | |

ប្រការនេះ អនុវត្តពុំត្រឹមត្រូវលើការបើកសម្ភារយកទៅអនុវត្តប្រចាំថ្ងៃ។

មន្ត្រីទទួលបន្ទុក ពុំបានធ្វើការតាមដាន និងធ្វើបច្ចុប្បន្នភាពសន្និធិស្តុក។

ករណីនេះ នាំឱ្យការគ្រប់គ្រងស្តុក ពុំទាន់មានប្រសិទ្ធភាព។

មន្ត្រីទទួលបន្ទុក ត្រូវខិតខំបង្កើនការផ្ទៀងផ្ទាត់រវាងសម្ភារជាក់ស្តែងជាមួយនឹងបញ្ជីសន្និធិស្តុកជារៀងរាល់ចុងខែនីមួយៗ។ ករណីសម្ភារលើសពីបញ្ជីសន្និធិស្តុកត្រូវបង្វែរចូលទៅក្នុងសន្និធិស្តុកវិញ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ សម្ភារដែលលម្អៀងលើសចំនួន ០៨ មុខ ដោយសារជាងមានសម្ភារដែលអាចប្រើប្រាស់បានយកទៅដាក់ឱ្យអតិថិជន ដោយសារទីតាំងអតិថិជននៅឆ្ងាយ។**

**ទទួលយកអនុសាសន៍របស់សវនករ នឹងបង្វែរសម្ភារចូលក្នុងស្តុកឃ្លាំងធំវិញ នៅខែមិថុនា ឆ្នាំ២០២៤។**

**៣- របាយការណ៍ស្តីពីការផ្អាកការផ្គត់ផ្គង់ទឹក និងភ្ជាប់បណ្តាញឡើងវិញ មានការស្ទួនគ្នា**

ក្នុងឆ្នាំ២០២៣ ការងារផ្អាកការផ្គត់ផ្គង់ទឹក (បិទវ៉ាន) មានចំនួន ១៧.៤៦២ អតិថិជន និងអតិថិជនភ្ជាប់ បណ្តាញឡើងវិញ (បើកបណ្តាញឡើងវិញ) មានចំនួន ៥.២៩៩ អតិថិជន សវនករពិនិត្យឃើញថា៖

- ការផ្អាកការផ្គត់ផ្គង់ទឹក ចំនួន ១០៧ អតិថិជន ការកត់ត្រាក្នុងរបាយការណ៍ស្ទួនគ្នា (ការកំណត់កាលបរិច្ឆេទក្នុងប្រព័ន្ធត្រួតគ្នា)
- ការភ្ជាប់បណ្តាញឡើងវិញ ចំនួន ០៧ អតិថិជន (ការបង់ប្រាក់របស់អតិថិជនស្ទួនគ្នា)

ប្រការនេះ អនុវត្តពុំទាន់មានភាពត្រឹមត្រូវ និងការរៀបចំរបាយការណ៍ពុំមានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងតាមដានរបាយការណ៍អនុវត្តការងារប្រចាំថ្ងៃ។

ករណីនេះ នាំឱ្យការគ្រប់គ្រងឯកសារ ពុំមានភាពច្បាស់លាស់ និងធ្វើឱ្យមានការថ្នាំងថ្នាក់ពីអតិថិជន។

មន្ត្រីទទួលបន្ទុកការងារ ត្រូវ៖

- រៀបចំ និងកំណត់កាលបរិច្ឆេទក្នុងរបាយការណ៍ឱ្យបានត្រឹមត្រូវ
- ពិនិត្យកែសម្រួលនីតិវិធីក្នុងការទទួលប្រាក់ ថ្លៃភ្ជាប់បណ្តាញឡើងវិញពីអតិថិជន និងត្រូវទូទាត់ជូនអតិថិជនវិញក្នុងករណីបង់ស្ទួន ជៀសវាងមានការថ្នាំងថ្នាក់ពីអតិថិជន។ **កម្រិតហានិភ័យ ទាប។**

ការឆ្លើយបំភ្លឺតប ៖

- ករណីផ្អាកការផ្គត់ផ្គង់ទឹកស្អួន ចំនួន ១០៧ អតិថិជន ៖ មន្ត្រីទទួលបន្ទុកមានការភ័ន្តច្រលំ ក្នុងការកំណត់កាលបរិច្ឆេទក្នុងប្រព័ន្ធ
- ការភ្ជាប់បណ្តាញឡើងវិញ មានការបង់ប្រាក់ស្អួន ចំនួន ០៧ អតិថិជន ៖
    - មកពីប្រព័ន្ធ App ដែលកំពុងប្រើប្រាស់មិនបង្ហាញទិន្នន័យអតិថិជនបានបង់ប្រាក់ថ្លៃបើកទឹកភ្លាមៗទេ ទើបបណ្តាលឱ្យមានអតិថិជនមកប្រាក់ ០២ដង/ថ្ងៃ។
    - ទីតាំងដែលបានបង់ប្រាក់ស្អួន មកពីអតិថិជន ឬតំណាងមកបង់ប្រាក់ផ្សេងគ្នា ដោយគាត់មិនបានដឹងថាមានអ្នកមកបង់ប្រាក់ថ្លៃបើកទឹករួចទើបគាត់មកបង់ម្តងទៀត។
    - បច្ចុប្បន្នកំពុងសិក្សារៀបចំធ្វើការកែប្រែដោយមានក្រុមហ៊ុនថ្មី (O One Power) បង្កើត App ថ្មី នៅពេលដែលអតិថិជនបានបង់ប្រាក់ថ្លៃភ្ជាប់បណ្តាញប្រើប្រាស់ទឹកឡើងវិញនឹងបង្ហាញទិន្នន័យភ្លាមៗ និងដាក់ Go Live ក្នុងខែកក្កដា ឆ្នាំ២០២៤។

ទទួលយកអនុសាសន៍របស់សវនករ។

## ៤- របាយការណ៍កែសម្រួលទីតាំងនាឡិកា និងរបាយការណ៍ប្រចាំឆ្នាំ មានភាពលម្អៀង

ក្នុងឆ្នាំ២០២៣ ការងារកែសម្រួលទីតាំងនាឡិកា Hard Copy (លើក/រំកិល) សវនករពិនិត្យឃើញថា៖

- របាយការណ៍អនុវត្តការងារ មានចំនួន ១.០៦៧ នាឡិកា
- របាយការណ៍ប្រចាំឆ្នាំ មានចំនួន ៩៨៥ នាឡិកា
- លម្អៀងលើស មានចំនួន ៨២ នាឡិកា ស្មើនឹង ៨,៣២ %

ប្រការនេះ អនុវត្តពុំទាន់មានភាពត្រឹមត្រូវ និងការរៀបចំរបាយការណ៍ពុំមានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងតាមដានរបាយការណ៍អនុវត្តការងារប្រចាំថ្ងៃ។

ករណីនេះ នាំឱ្យការគ្រប់គ្រងឯកសារ ពុំមានភាពច្បាស់លាស់តាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យ, ផ្ទៀងផ្ទាត់, តាមដានឱ្យបានច្បាស់លាស់ និងបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ មន្ត្រីទទួលបន្ទុក បានអនុវត្តតាមនីតិវិធីលើក/រំកិលនាឡិកា ប៉ុន្តែខ្វះចន្លោះក្នុងការផ្ទៀងផ្ទាត់របាយការណ៍ប្រចាំខែ។**

**ទទួលយកអនុសាសន៍របស់សវនករ ដោយអនុវត្តចាប់ពីខែមិថុនា ឆ្នាំ២០២៤។**

## ៥- ការស្នើសុំប្តូរឈ្មោះអតិថិជនលើវិក្កយបត្រទឹក ពុំមានឯកសារយោងត្រឹមត្រូវ

ក្នុងឆ្នាំ ២០២៣ ការិយាល័យចំណូលមានជ័យ, ឬស្សីកែវ និងសែនសុខ ទទួលបានសំណើសុំប្តូរឈ្មោះពីអតិថិជនចំនួន ៣០៤ អតិថិជន។ ក្នុងនោះ ការិយាល័យចំណូល៖

- មានជ័យ ចំនួន ១៤ អតិថិជន
- ឬស្សីកែវ ចំនួន ១១១ អតិថិជន
- សែនសុខ ចំនួន ១៧៩ អតិថិជន

សវនកម្មផ្ទៃក្នុង ពិនិត្យឃើញថាការភ្ជាប់ឯកសារសំណើសុំប្តូរឈ្មោះអតិថិជន របស់ការិយាល័យចំណូលមានជ័យមានភាពត្រឹមត្រូវ។ ប៉ុន្តែសម្រាប់ការិយាល័យចំណូលឬស្សីកែវ និងការិយាល័យចំណូលសែនសុខ ពុំមានបោះត្រាបញ្ជាក់ពីឃុំ/សង្កាត់ ចំនួន ៨១ អតិថិជន។ ក្នុងនោះ ការិយាល័យចំណូល៖

- ឬស្សីកែវ ចំនួន ៧០ អតិថិជន
- សែនសុខ ចំនួន ១១ អតិថិជន

ប្រការនេះ អនុវត្តពុំទាន់មានភាពត្រឹមត្រូវតាមសំណើសុំប្តូរឈ្មោះ និងប្រើប្រាស់បណ្តាញទឹក " **ឯកសារដែលត្រឹមត្រូវសម្រាប់ប្តូរឈ្មោះបាន ត្រូវថតចម្លងមានបោះត្រាក្រហម**

- អត្តសញ្ញាណបណ្ណម្ចាស់ថ្មី (០១ សន្លឹក)
- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ (០១ សន្លឹក)
- លិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះ ឬប្លង់កាន់កាប់ (០១ សន្លឹក)
- វិក្កយបត្រថ្លៃប្រើប្រាស់ទឹក

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងរៀបចំឯកសារឱ្យបានត្រឹមត្រូវ។

ករណីនេះ នាំឱ្យការអនុវត្តពុំត្រឹមត្រូវទៅតាមស្តង់ដាររបស់អង្គភាពដែលបានកំណត់។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យឯកសារឱ្យបានត្រឹមត្រូវមុននឹងទទួលយកពីអតិថិជន។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ ការិយាល័យចំណូលសែនសុខ និងការិយាល័យចំណូលឫស្សីកែវ ទទួលស្គាល់ការខ្វះខាតលើបែបបទប្តូរឈ្មោះជូនអតិថិជនពិតប្រាកដមែន និងអនុវត្តតាមស្តង់ដារបស់អង្គភាព ចាប់ពីខែមិថុនា ឆ្នាំ២០២៤។ សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានរៀបចំរបាយការណ៍កែលម្អ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៤។**

### iii. ក- មណ្ឌលព័ត៌មានវិទ្យា

ក្នុងឆ្នាំ២០២៣ មណ្ឌលព័ត៌មានវិទ្យា បានអនុវត្តៈ

- ការងារកែតម្រូវទិន្នន័យអតិថិជន ចំនួន ៤២.២៧០ អតិថិជន
- Non- Invoice for Spot Billing ចំនួន ៣៣.៥៧០ អតិថិជន
- ការអនុវត្តចំណាយប្រចាំឆ្នាំ២០២៣ ចំនួន ០៨ ប្រតិបត្តិការ ៖
  - សេវាគាំទ្រ Hardware និង Software មាន ០១ ប្រតិបត្តិការ
  - ចំណាយរដ្ឋបាល (សេវាកម្មទូរគមនាគមន៍ផ្សេងៗ) មាន ០៧ ប្រតិបត្តិការ
    1. WIFI Internet
    2. Firewall Outside Protection Subscription
    3. System Monitoring
    4. Web Hosting
    5. Wireless AP Subscription
    6. SSL Certificate and Installation Service
    7. Internet Connection

មណ្ឌលព័ត៌មានវិទ្យា អនុវត្តការងារបានរលូន និងមានការសហការល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អៈ

#### ១- សៀវភៅចុះលេខលិខិតចេញ-ចូល របស់មណ្ឌលព័ត៌មានវិទ្យាពុំទាន់មានភាពត្រឹមត្រូវ

សៀវភៅចុះលេខលិខិតចេញ-ចូល របស់មណ្ឌលព័ត៌មានវិទ្យា ក្នុងឆ្នាំ២០២៣ បែងចែកជាពីរៈ

- ទាក់ទងនឹងសំណើផ្សេងៗ ចាប់ពីលេខ ០០១ ដល់ ៥៣៤
- សំណើទាក់ទងនឹងការចំណាយ ចាប់ពីលេខ ០០១ ដល់ ១៤៥

ពិនិត្យឃើញថា ៖

- សៀវភៅទាក់ទងនឹងសំណើផ្សេងៗ ការប្រើប្រាស់ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៣
- សំណើទាក់ទងនឹងការចំណាយ ចុះរំលងលេខ (០២៤ ដល់ ០៩៣) ហើយការប្រើប្រាស់ ចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២៣
- សៀវភៅសំណើទាំងពីរប្រើប្រាស់ លេខតែ១ (ស្ទួនគ្នាចាប់ពី០០១ ដល់ ១៤៥)។

ប្រការនេះ អនុវត្តពុំទាន់បានសមស្របក្នុងការគ្រប់គ្រងលេខលិខិតចេញ-ចូល តាមបែបបទរដ្ឋបាល។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការត្រួតពិនិត្យ និងតាមដាន មុននឹងចុះលេខលិខិត។

ករណីនេះ នាំឱ្យការគ្រប់គ្រងលិខិតចេញ-ចូល ពុំមានភាពច្បាស់លាស់។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការបែងចែកសៀវភៅចុះលេខទៅតាមផ្នែកនីមួយៗឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ ជាការខ្វះខាតរបស់និយោជិតអនុវត្តការងារ យើងខ្ញុំនឹងអនុវត្តតាមអនុសាសន៍។ មណ្ឌលព័ត៌មានវិទ្យា នឹងចាប់អនុវត្តក្រោយពេលទទួលបានរបាយការណ៍សវនកម្ម។**

## ២- ការហួសសុពលភាពនៃការប្រើប្រាស់អាជ្ញាប័ណ្ណ និងសេវាកម្មបច្ចេកវិទ្យា សម្រាប់ប្រើប្រាស់រយៈពេល ០១ ឆ្នាំ

ក្នុងឆ្នាំ២០២៣ មណ្ឌលព័ត៌មានវិទ្យា បានលើកផែនការគ្រោងចំណាយលើសេវាគាំទ្រ Hardware, Software និងសេវាកម្មទូរគមនាគមន៍ផ្សេងៗ សម្រាប់ប្រើប្រាស់រយៈពេល ០១ ឆ្នាំ មានចំនួន ០៨ ប្រតិបត្តិការ។ ក្នុងនោះ ពិនិត្យឃើញថាការបន្តការផ្គត់ផ្គង់ ក្រោយថ្ងៃផុតកំណត់ មានចំនួន ០៥ សំណើ៖

| ល.រ | បរិយាយ | ថ្ងៃផុតសុពលភាព | ថ្ងៃស្នើសុំ | រយៈពេលផុតសុពលភាព | ផ្សេងៗ |
|---|---|---|---|---|---|
| 1 | សេវា Internet WIFI | 10/02/23 | 27/03/23 | 45 ថ្ងៃ | |
| 2 | អាជ្ញាប័ណ្ណគ្រប់គ្រងឧបករណ៍ Firewall | 25/02/23 | 06/03/23 | 09 ថ្ងៃ | |
| 3 | អាជ្ញាប័ណ្ណ System Monitoring | 28/02/23 | 20/04/23 | 51 ថ្ងៃ | |
| 4 | សេវាកម្មផ្សព្វផ្សាយគេហទំព័រ និង Email | 01/03/23 | 06/03/23 | 05 ថ្ងៃ | |
| 5 | អាជ្ញាប័ណ្ណគ្រប់គ្រងឧបករណ៍ Wireless Access Point ១៣ គ្រឿង | 28/03/23 | 04/04/23 | 07 ថ្ងៃ | |

ប្រការនេះ អនុវត្តពុំទាន់បានសមស្របដោយការស្នើសុំគោលការណ៍ឯកភាពពី **ឯកឧត្តមប្រតិភូ** ទៅលើការប្រើប្រាស់អាជ្ញាប័ណ្ណ និងសេវាបច្ចេកវិទ្យា ក្រោយថ្ងៃផុតសុពលភាព។

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការត្រួតពិនិត្យ និងតាមដានសុពលភាពការងារឱ្យបានច្បាស់។

ករណីនេះ នាំឱ្យការប្រើប្រាស់បច្ចេកវិទ្យាផ្សេងៗមានភាពអាក់រអួល និងពុំមានសុវត្ថិភាពក្នុងការគ្រប់គ្រងប្រព័ន្ធ Network បានល្អ។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យ និងតាមដានសុពលភាពអាជ្ញាប័ណ្ណ និងប្រព័ន្ធផ្សេងៗឱ្យបានច្បាស់។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ ជាកង្វះខាតរបស់និយោជិតអនុវត្តការងារ យើងខ្ញុំនឹងអនុវត្តតាមអនុសាសន៍។ មណ្ឌលព័ត៌មានវិទ្យានឹងអនុវត្ត ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២៤។**

**សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានរៀបចំរបាយការណ៍កែលម្អ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៥។**

## ខ- អង្គភាពលទ្ធកម្ម

ក្នុងឆ្នាំ២០២៣ អង្គភាពលទ្ធកម្ម បានអនុវត្ត ៤៥ កិច្ចសន្យា ក្នុងនោះ៖

- ដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដបអ) មាន ០៤ កិច្ចសន្យា
- ដេញថ្លៃប្រកួតប្រជែងក្នុងស្រុក (ដបស) មាន ៣៣ កិច្ចសន្យា
- ពិគ្រោះថ្លៃ (ពថ) មាន ០៨ កិច្ចសន្យា

អង្គភាពលទ្ធកម្មអនុវត្តការងារបានរលូន និងមានការសហការគ្នាល្អក្នុងកំឡុងពេលចុះពិនិត្យ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំណុច ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

**ពុំមានកំណត់ហេតុស្តីពីការប្រគល់-ទទួលទំនិញ របស់គណៈកម្មាធិការលទ្ធកម្ម និង កាលបរិច្ឆេទ មុនកំណត់ហេតុការប្រគល់-ទទួលទំនិញ**

ក្នុងឆ្នាំ២០២៣ អង្គភាពលទ្ធកម្ម បានអនុវត្ត ៤៥ កិច្ចសន្យា ក្នុងនោះ៖

- ដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ (ដបអ) មាន ០៤ កិច្ចសន្យា
- ដេញថ្លៃប្រកួតប្រជែងក្នុងស្រុក (ដបស) មាន ៣៣ កិច្ចសន្យា
- ពិគ្រោះថ្លៃ (ពថ) មាន ០៨ កិច្ចសន្យា

ក្នុងនោះ ពិនិត្យឃើញថា៖

- កាលបរិច្ឆេទលើកំណត់ហេតុគណៈកម្មាធិការលទ្ធកម្ម អនុវត្តមុនកាលបរិច្ឆេទកំណត់ហេតុស្តីពីការប្រគល់-ទទួលទំនិញ មាន ០៣ កិច្ចសន្យា។
- ពុំមានកំណត់ហេតុស្តីពីការប្រគល់-ទទួលទំនិញ របស់គណៈកម្មាធិការលទ្ធកម្ម មាន ០៦ កិច្ចសន្យា។

ប្រការនេះ អនុវត្តពុំត្រឹមត្រូវតាមអនុក្រឹត្យលេខ ១៣អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម **ជំពូកទី២ ៖ គណៈកម្មាធិការលទ្ធកម្ម** ត្រង់ **មាត្រាទី៩- អញ្ជើញតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមសង្កេតការណ៍គ្រប់ដំណាក់កាលនៃកិច្ចលទ្ធកម្មសាធារណៈ លើកលែងតែដំណាក់កាលនៃការវាយតម្លៃប្រគល់កិច្ចសន្យា។**

មន្ត្រីទទួលបន្ទុក ខ្វះចន្លោះក្នុងការពិនិត្យ និងរៀបចំឯកសារការប្រគល់-ទទួលឱ្យបានត្រឹមត្រូវ។

ករណីនេះ ធ្វើឱ្យនីតិវិធីនៃការប្រគល់-ទទួលពុំមានប្រសិទ្ធភាព។

មន្ត្រីទទួលបន្ទុក ត្រូវពិនិត្យ និងធ្វើកំណត់ហេតុស្តីពីការប្រគល់-ទទួល ដែលមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានត្រឹមត្រូវដូចមានចែងក្នុងមាត្រាទី៩ ខាងលើ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ អង្គភាពលទ្ធកម្មទទួលយកអនុសាសន៍របស់សវនករ នឹងធ្វើការកែលម្អឱ្យស្របតាមអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ចាប់ពីឆ្នាំ២០២៤ តទៅ។**

**សម្រាប់ចំណុចខ្វះចន្លោះខាងលើ សវនដ្ឋានបានរៀបចំរបាយការណ៍កែលម្អ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៥។**

## iv. នាយកគណនេយ្យ និងហិរញ្ញវត្ថុ

នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ បានធ្វើការគ្រប់គ្រងបញ្ជីការគណនេយ្យ គ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងសន្និធិស្តុកបានល្អប្រសើរ។ ក្នុងកំឡុងពេលចុះពិនិត្យមានការសហការគ្នាល្អ ទន្ទឹមនឹងនោះក៏នៅមានចំណុចខ្វះចន្លោះមួយចំនួន ដែលត្រូវធ្វើការតាមដាន និងកែលម្អ៖

### ១- តារាងស្តង់តម្លៃ មានសុពលភាពតិចជាងការអនុវត្តជាក់ស្តែង

សវនកម្មផ្ទៃក្នុង បានជ្រើសយកការទូទាត់ចំណាយជាប្រាក់ដុល្លារ ($) មកពិនិត្យមានចំនួន ៣៣៧ សំណើ៖

- ឆ្នាំ២០២៣ ចំនួន ២៣០ សំណើ (ខែមករា, ខែតុលា, ខែវិច្ឆិកា និងខែធ្នូ)
- ឆ្នាំ២០២៤ ចំនួន ១០៧ សំណើ (ខែមិថុនា, ខែកក្កដា និងខែសីហា)

ក្នុងនោះ វិក្កយបត្រស្តង់តម្លៃមានសុពលភាពមិនសមាមាត្រនឹងការអនុវត្តន៍ការងារជាក់ស្តែង មាន ០៨ សំណើ៖

- ឆ្នាំ២០២៣ ចំនួន ០១ សំណើ
- ឆ្នាំ២០២៤ ចំនួន ០៧ សំណើ

មន្ត្រីទទួលបន្ទុក ពុំទាន់រៀបចំឯកសារទូទាត់ឱ្យបានសមស្របតាមបែបបទគណនេយ្យ។

ករណីនេះ នាំឱ្យការទូទាត់ពុំមានភាពសមស្រប។

មន្ត្រីទទួលបន្ទុក ត្រូវធ្វើការសហការជាមួយនាយកដ្ឋាន/អង្គភាពពាក់ព័ន្ធ ក្នុងការកែសម្រួលវិក្កយបត្រស្តង់តម្លៃដែលមានសុពលភាពត្រឹមត្រូវតាមការអនុវត្តជាក់ស្តែង។ **កម្រិតហានិភ័យ ទាប។**

ការឆ្លើយបំភ្លឺតប ៖ មន្ត្រីទទួលបន្ទុកតែងតែបានពិនិត្យ និងទំនាក់ទំនងជាមួយនាយកដ្ឋានអនុវត្ត ក៏ដូចក្រុមហ៊ុន/អ្នកផ្គត់ផ្គង់បន្ទាប់ពីពិនិត្យឃើញតារាងស្តង់តម្លៃអស់សុពលភាព ដោយក្រុមហ៊ុន/អ្នកផ្គត់ផ្គង់មួយចំនួនបានកែសម្រួលបន្តសុពលភាពនៃតារាងតម្លៃ ប៉ុន្តែក្រុមហ៊ុន/អ្នកផ្គត់ផ្គង់មួយចំនួនតូចក៏ពុំបានកែសម្រួលដែរ ដោយសារពួកគាត់បានឆ្លើយតប និងរក្សាតម្លៃសម្ភារ/សេវាក្នុងតារាងស្តង់តម្លៃនោះមិនប្រែប្រួលតម្លៃនៅពេលទិញជាក់ស្តែងនោះទេ។

ផ្អែកតាមការអនុវត្តកន្លងមកករណីតារាងស្តង់តម្លៃផុតសុពលភាព ពុំមានប៉ះពាល់តម្លៃពេលទិញជាក់ស្តែងនោះទេ ដោយសារតម្លៃទំនិញក្នុងទីផ្សារក្នុងស្រុកមិនមានការប្រែប្រួលខ្លាំង។ ប៉ុន្តែទោះជាយ៉ាងណាមន្ត្រីទទួលបន្ទុកនឹងកែលម្អឱ្យបានសមស្របតាមអនុសាសន៍។

## ២- ការបញ្ចូលសម្ភារនៅសល់ពីការអនុវត្តន៍គម្រោង ពុំមានភ្ជាប់ប័ណ្ណបញ្ចេញសម្ភារ

ការបញ្ចូលសម្ភារនៅសល់ពីការអនុវត្តន៍គម្រោង ក្នុងឆ្នាំ២០២៣ មានចំនួន ៤៨១ គម្រោង យើងខ្ញុំពិនិត្យឃើញថា មានចំនួន ៤០ គម្រោងពុំមានភ្ជាប់ប័ណ្ណបញ្ចេញសម្ភារ និងរបាយការណ៍អនុវត្តគម្រោងផ្លូវការ ដោយក្នុងនោះមានភ្ជាប់តែ៖

- របាយការណ៍អនុវត្តគម្រោង ( ពុំផ្លូវការ ) មាន ១៤ គម្រោង
- គម្រោងអនុវត្ត (Job Budget & Quotation) ពុំមានភ្ជាប់ប័ណ្ណបញ្ចេញ មាន ២៦ គម្រោង

ប្រការនេះ អនុវត្តពុំទាន់បានសមស្រប ទៅលើការរៀបចំប័ណ្ណបញ្ចូលសម្ភារ។

ករណីនេះ នាំឱ្យមានការបាត់បង់សម្ភារដោយយថាហេតុ។

មន្ត្រីទទួលបន្ទុកការងារខាងលើ ត្រូវធ្វើការសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ក្នុងការភ្ជាប់ឯកសារឱ្យបានត្រឹមត្រូវ។ **កម្រិតហានិភ័យ ទាប។**

**ការឆ្លើយបំភ្លឺតប ៖ នាយកដ្ឋានបានពិនិត្យឃើញ៖**

- **របាយការណ៍អនុវត្តគម្រោង ចំនួន ១៤ គម្រោង ការភ្ជាប់ឯកសារមិនទាន់ផ្លូវការ (ការខ្វះចន្លោះរបស់មន្ត្រីទទួលបន្ទុកដែលពុំបានភ្ជាប់ឯកសារដែលមានហត្ថលេខាត្រឹមត្រូវ) ជាក់ស្តែងរាល់ឯកសារមានរបាយការណ៍អនុវត្តគម្រោងដែលមានចុះហត្ថលេខា**
- **គម្រោងអនុវត្ត (Job Budget & Quotation) ២៦ គម្រោង (ការខ្វះចន្លោះរបស់មន្ត្រីទទួលបន្ទុកពុំបានភ្ជាប់ប័ណ្ណបញ្ចេញសម្ភារ) ជាក់ស្តែងមានបណ្ណបញ្ចេញសម្ភារត្រឹមត្រូវ។**

**យោងលទ្ធផលនេះ នាយកដ្ឋានទទួលយកនូវចំណុចខ្វះខាត ព្រមទាំងកែលម្អឱ្យបានត្រឹមត្រូវបន្ទាប់ពីទទួលបានអនុសាសន៍នេះ។**

## គ- សន្និដ្ឋាន

ការធ្វើសវនកម្មដែលបានធ្វើឡើងខាងលើ បង្ហាញថាដំណើរការនៃប្រតិបត្តិការខាងលើអនុវត្តបានល្អអនុលោមតាមសេចក្តីកំណត់ស្តង់ដាការងារព្រមទាំងបទដ្ឋានគតិយុត្តិនានា។ មន្ត្រី-និយោជិត នៅតាមបណ្តានាយកដ្ឋាន/អង្គភាពបានខិតខំប្រឹងប្រែងសហការអនុវត្តការងារតាមតួនាទី-ភារកិច្ច និងសម្រេចបានលទ្ធផលល្អ។ សវនដ្ឋានមានការឯកភាព និងកែលម្អតាមអនុសាសន៍ណែនាំនូវរាល់ចំណុចខ្វះចន្លោះខាងលើ ព្រមទាំងធ្វើរបាយការណ៍បំភ្លឺតបចំណុចដែលបានកែលម្អ និងពុំទាន់បានធ្វើការកែលម្អក្នុងរយៈពេល **០៣ខែ** បន្ទាប់ពីចេញរបាយការណ៍។

សវនកម្មផ្ទៃក្នុង នឹងធ្វើការតាមដានរាល់អនុសាសន៍ដែលបានពិនិត្យឃើញ នូវបណ្តាចំណុចខ្វះចន្លោះរបស់សវនដ្ឋានក្នុងកំឡុងពេលចុះត្រួតពិនិត្យតាមការកំណត់ក្នុងផែនការប្រចាំឆ្នាំ។

## II. សវនកម្មពុំព្រាងទុក (Surprise Audit)

### ១- ការពិនិត្យសន្និធិស្តុក នៃការិយាល័យបណ្តាញចូលផ្ទះ (ត្រីមាសទី១)

គិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ របាយការណ៍ស្តុក (បំពង់) ដែលមានទំហំ ២៥, ៣២, ៤០, ៥០, ៦៣, ៧៥, ៩០, ១១០, ១៦០ និង២២៥ ក្រោយពីបានពិនិត្យជាក់ស្តែងឃើញថា មានភាពលម្អៀងលើស/ខ្វះ ដូចខាងក្រោម៖

| ល.រ | ក្នុងបញ្ជីគណនេយ្យ | | | | | រាប់ជាក់ស្តែង | ឯកសារសុំខ្ចី (ម) | បំពង់សុំធ្វើ (ម) | ប្រវែងសរុប (ម) | លម្អៀងខ្វះ/លើស |
|---|---|---|---|---|---|---|---|---|---|---|
| | លេខកូដ | បរិយាយ | ទំហំ | ប្រវែង (ម) | សរុប (ម) | | | | | |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10=7+8-9 | 11=10-6 |
| ក- បំពង់លម្អៀង (ខ្វះ) | | | | | | | | | | |
| 1 | I-00780 | Pipe | 63 | 143,855.10 | **144,567.10** | 140,400.00 | 4,090.00 | - | **144,490.00** | **-77.10** |
| | I-03736 | (Shi) Pe | | 712.00 | | | | | | |
| 2 | I-00795 | (L=11.7m) | 90 | 12.00 | **71,781.10** | 68,257.10 | 3,433.80 | - | **71,690.90** | **-90.20** |
| | I-01691 | (L=11.8m) | | 71,455.90 | | | | | | |
| | I-03732 | (Shi) Pe I | | 269.20 | | | | | | |
| | I-03733 | (Shi) Pe II | | 44.00 | | | | | | |
| ខ- បំពង់លម្អៀង (លើស) | | | | | | | | | | |
| 1 | I-00317 | (L=11.8) | 110 | 75,253.50 | **76,124.66** | 73,136.40 | 3,186.00 | 188.80 | **76,133.60** | **8.94** |
| | I-01329 | (L=11.7m) | | 427.16 | | | | | | |
| | I-03727 | (Shi) Pe | | 444.00 | | | | | | |
| 2 | I-00011 | (L=11.7m) | 160 | 11.70 | **65,600.94** | 67,070.00 | 377.60 | 1,734.60 | **65,713.00** | **112.06** |
| | I-01339 | (L=11.8m) | | 65,330.24 | | | | | | |
| | I-03728 | (Shi) Pe | | 259.00 | | | | | | |

និយោជិតទទួលបន្ទុក ពុំបានធ្វើការតាមដាននូវរាល់សម្ភារដែលបានបើក។

ករណីនេះ ធ្វើឱ្យការគ្រប់គ្រង និងតាមដានស្តុកសម្ភារក្នុងប្រព័ន្ធ និងស្តុកជាក់ស្តែង ពុំទាន់មានភាពត្រឹមត្រូវ។

ការិយាល័យ ត្រូវខិតខំបង្កើនការតាមដានស្តុកក្នុងប្រព័ន្ធ ឱ្យបានត្រឹមត្រូវធៀបនឹងស្តុកជាក់ស្តែង។

**ការឆ្លើយបំភ្លឺតប ៖**

- ចំណុច (ក) លម្អៀងខ្វះ ៖ បំពង់ទំហំ ៦៣ មម និងបំពង់ ៩០ មម មកពីការបើកបំពង់របស់ការិយាល័យស្រាវជ្រាវទឹកបាត់បង់ (ជួសជុលទឹកធ្លាយ) នៃនាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក នៅមិនទាន់ធ្វើរបាយការណ៍មកធ្វើប័ណ្ណបញ្ចេញក្នុងប្រព័ន្ធ ដើម្បីដកចំនួនបំពង់ចេញពីបញ្ជីស្តុកលើការងារជួសជុលទឹកធ្លាយ។
- ចំណុច (ខ) លម្អៀងលើស ៖ បំពង់ទំហំ ១១០ មម និងបំពង់ ១៦០ មម មកពីប័ណ្ណដែលបានបើកបំពង់របស់ការិយាល័យបណ្តាញចែកចាយទឹក នៃសាខាសេវាកម្មទឹកស្អាត និងអនាម័យ បានធ្វើប័ណ្ណបើកតាមគម្រោងក្នុងប្រព័ន្ធរួច ប៉ុន្តែគម្រោងដាក់បំពង់មិនទាន់អនុវត្តចប់ ម្យ៉ាងទៀតទីតាំងការដ្ឋានពុំមានកន្លែងរក្សាទុកបំពង់ដែលស្នើសុំបើកទាំងអស់បានទេ ហេតុនេះទើបបើកតាមតម្រូវការប្រើប្រាស់ ដោយផ្ញើបំពង់ក្នុងស្តុកសិន ទើបបណ្តាលឱ្យបំពង់លើសនៅពេលដែលចុះរាប់បំពង់ **(Surprise Audit)**។

ការិយាល័យគណនេយ្យនឹងចាប់ផ្តើមអនុវត្តតាមការកែលម្អរបស់សវនករ បន្ទាប់ពីទទួលបានរបាយការណ៍។

២- ការប្រកាសវិក្កយបត្ររបស់ភ្នាក់ងារអានលេខនាឡិកា និងចែកវិក្កយបត្រ វគ្គ ០៥-០៦/២៤ (ត្រីមាសទី៣)

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ភ្នាក់ងារអានលេខ និងចែកវិក្កយបត្រ ចំនួន ៧៩ រូប បានធ្វើការប្រកាសវិក្កយបត្រទាបជាង ១០០% ស្មើនឹង ២.២៩៣ អតិថិជន។

ក្រោយពីបានធ្វើការពិនិត្យនៅក្នុងប្រព័ន្ធ (Customer Data Management System) នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៤ ឃើញថា៖

- អតិថិជនបន្តប្រើប្រាស់ មាន ៤៨៦ អតិថិជន
- បើកគណនីឡើងវិញ មាន ៨២ អតិថិជន
- លុបគណនី មាន ០១ អតិថិជន (ទីតាំងមួយមានគណនីពីរ)
- ព្យួរគណនី មាន ១.៧២៤ អតិថិជន
  - អតិថិជនស្នើសុំកាត់បណ្តាញ មាន ១២ អតិថិជន
  - ទំនាក់ទំនងអតិថិជនមិនបាន មាន ៣៥ អតិថិជន
  - ទីតាំងគ្មានអ្នកទទួលខុសត្រូវ (នាឡិកាបាត់, ដីឡូត៍ទំនេរកាត់ស្លាពរ) មាន ០៧ អតិថិជន
  - ទីតាំងផ្ទះចាក់សោរចោល មាន ៩៤ អតិថិជន
  - មិនទាន់មានតម្រូវការប្រើប្រាស់ទឹក (ផ្ទះបិទទ្វារចោល, ដីឡូត៍ទុកចោល) មាន ១.០០៧ អតិថិជន
  - ភ្នាក់ងារបង់ជួស (អតិ.ជំពាក់បំណុល ស្មើនឹង ១.៦៣២.០៥០ រៀល) មាន ៤៩៥ អតិថិជន
  - អតិ.ជំពាក់បំណុល (ស្មើនឹង ១១.៨១០.៤០០ រៀល) មាន ៧៤ អតិថិជន

## សន្និដ្ឋាន

ក្នុងអំឡុងពេលធ្វើសវនកម្មពុំព្រាងទុក (Surprise Audit) សវនករពិនិត្យឃើញថា សវនដ្ឋានបានរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងប្រតិបត្តិការបានល្អ។ ក្នុងនោះ ៖

- ការរាប់ស្តុកបំពង់ (PIPE) នៅការិយាល័យបណ្តាញចូលផ្ទះ អនុវត្តពុំទាន់បានសមស្រប ដោយមានភាពលម្អៀងលើស/ខ្វះ។ ទទួលបានលទ្ធផល កម្រិត **B (Priority)**។
- ការប្រកាសវិក្កយបត្រ របស់ភ្នាកងារអានលេខ និងចែកវិក្កយបត្រ តាមការិយាល័យចំណូល
  - ករណីនាឡិកាមិនប្រក្រតី ត្រូវធ្វើការដោះដូរ និងកែតម្រូវទិន្នន័យឱ្យបានទាន់ពេល ដើម្បីអាចចេញវិក្កយបត្រតាមកម្មវិធី។
  - ទីតាំង (ទំនាក់ទំនងអតិថិជនពុំបាន, គ្មានអ្នកទទួលខុសត្រូវ, ទីតាំងផ្ទះចាក់សោរចោល) ការិយាល័យជំនាញ បានធ្វើការចុះបិទទឹក (Disconnect)។
  - អតិថិជនជំពាក់បំណុលស្នើសុំការិយាល័យចំណូល ត្រូវជម្រុញការចុះទារបំណុលឱ្យបានស្របតាមកម្មវិធីប្រមូលប្រាក់ថ្លៃទឹក។

សវនកម្មផ្ទៃក្នុង នឹងពិនិត្យវឌ្ឍនភាពនៃការកែលម្អតាមអនុសាសន៍ជាបន្តទៀត។

## III. ការអានលេខនាឡិកា និងចែកវិក្កយបត្ររបស់ភ្នាក់ងារ វគ្គ ០៩-១០/២៤ តាមការិយាល័យចំណូលនៃនាយកដ្ឋានអាជីវកម្ម (ត្រីមាសទី៤)

អនុសាសន៍ណែនាំរបស់ក្រុមប្រឹក្សាភិបាល ក្នុងកិច្ចប្រជុំលើកទី១២ អាណត្តិទី៨ នាថ្ងៃទី១៩/កញ្ញា/២០២៤ តម្រូវឱ្យសវនកម្មផ្ទៃក្នុង ចុះពិនិត្យលើអានលេខនាឡិកាទឹករបស់ភ្នាក់ងារ វគ្គ០៩-១០/២៤ ជាបានលទ្ធផល៖

| ល.រ | ការិយាល័យចំណូល | ភ្នាក់ងារ | តំបន់ទទួលបន្ទុក | អតិថិជន | ជ្រើសរើស | ពិនិត្យជាក់ស្តែង | ស្ថានភាព |
|---|---|---|---|---|---|---|---|
| 1 | ដូនពេញ | ផេង តាក | 01 02 01...31<br>01 04 01 09 | 2,381 | 108 | 106 | 02 ជាប់សោរ |
| 2 | ច្បារអំពៅ | ណុប សោភ័ន | 07 01...14 | 1,617 | 155 | 150 | 05 ជាប់សោរ |
| 3 | សែនសុខ | រ៉ុម សារ៉េត | 54/79 | 1,197 | 71 | 68 | 03 ជាប់សោរ |
| | | ប៊ិន ចំរើន | 48 50 51 | 1,453 | 51 | 50 | 01 ជាប់សោរ |
| | | វុធ សហចាន់ដារ៉ា | 21...27<br>51...59 | 2,107 | 205 | 187 | 18 ជាប់សោរ |
| សរុប | | | | **8,755** | **590** | **561** | **29 ជាប់សោរ** |

ក្រោយពីបានចុះធ្វើការពិនិត្យឃើញថា៖ ភ្នាក់ងារខាងលើបានធ្វើការអានលេខនាឡិកាបានត្រឹមត្រូវ និងគ្រប់ចំនួន។ ក្នុងនោះដែរសវនកម្មផ្ទៃក្នុងយើងខ្ញុំ បន្តតាមដាន និងចុះពិនិត្យជាក់ស្តែងតាមការិយាល័យចំណូលផ្សេងៗបន្តទៀត។

ថ្ងៃ [illegible] ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២៥
**សវនកម្មផ្ទៃក្នុង**

**សេង គាតារា**

**បានអាន និងឯកភាព**
ថ្ងៃ [illegible] ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២៥
**ជ. គណៈកម្មាធិការសវនកម្ម**
**ប្រធាន**

**ស្រេង សំឌិក**

# ឧបសម្ព័ន្ធ ៣

## របាយការណ៍ហិរញ្ញវត្ថុ
## និង
## របាយការណ៍របស់សវនករឯករាជ្យ

**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៨៣៩ Et/២០១២

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
# (ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ហិរញ្ញវត្ថុ និង
## របាយការណ៍របស់សវនករឯករាជ្យ
## ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៨៣៩ Et/២០១២

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**ព័ត៌មានអំពី រ.ទ.ស.ភ**

| | |
|---|---|
| ក្រុមប្រឹក្សាភិបាល៖ | ឯកឧត្តម ឯក សុនចាន់ (H.E. Ek SonnChan)<br>ឯកឧត្តម ម៉ី វ៉ាន់ (H.E. Mey Vann)<br>ឯកឧត្តម ឡុង ណារ៉ូ (H.E. Long Naro Vann)<br>ឯកឧត្តម ឆាយ វីរៈ (H.E. Chhay Virak)<br>លោក ម៉ា ណូរ៉ាវីន (Mr. Ma Noravin)<br>លោក ណាំ ចន្ទ្រី (Mr. Nam Channtry)<br>លោក ស្រេង សំអិក (Mr. Sreng Samork) |
| ទីស្នាក់ការ៖ | អគារលេខ៤៥ ផ្លូវលេខ១០៦<br>សង្កាត់ស្រះចក ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ធនាគារ៖ | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់<br>គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី<br>គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត<br>ធនាគារ ប្រេដ បែង ខេមបូឌា<br>ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ<br>ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី<br>ធនាគារ កាណាឌីយ៉ា ក.អ<br>ធនាគារ ជីប ម៉ុង ខមមើសល បែង ម.ក<br>ធនាគារ ពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា<br>ធនាគារ ហត្ថា ម.ក<br>ធនាគារ ខេប៊ីប្រាសាក់ ម.ក<br>ធនាគារ មេយបែង (ខេមបូឌា)<br>ធនាគារ ហ្វីលីព ភីអិលស៊ី<br>ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក<br>ធនាគារ ស្ថាបនា ភីអិលស៊ី<br>ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក<br>ធនាគារ វឌ្ឍនៈ<br>រតនាគារជាតិ<br>រតនាគារ រាជធានីភ្នំពេញ<br>រតនាគារ តាខ្មៅ<br>រតនាគារ ត្បូងឃ្មុំ |
| សវនករ៖ | ប៊ី ឌី អូ (ខេមបូឌា) លីមីតធីត |

លេខបញ្ជីពាណិជ្ជកម្មៈ
Co. ០៨៣៩ Et/២០១២

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## មាតិកា


| មាតិកា | ទំព័រ |
| --- | --- |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ - ៥ |
| របាយការណ៍របស់សវនករឯករាជ្យ | ៦ - ១១ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ១២ - ១៣ |
| របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗ | ១៤ |
| របាយការណ៍បម្រែបម្រួលមូលធន | ១៥ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១៦ - ១៧ |
| កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ១៨ - ៦៦ |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយក្នុងការដាក់ជូននូវរបាយការណ៍ ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងការចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងទំនប់ម្លេចក្នុងខេត្តកំពត ព្រមទាំងផ្តល់សេវាផ្សេងៗ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្ម និងសេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាតស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍន៍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សាធារណៈ។

ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ រ.ទ.ស.ភ ក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលនៃប្រតិបត្តិការ

| | ពាន់រៀល |
|---|---|
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ៨៥.០៤២.៩១៣ |

### ភាគលាភ

ភាគលាភដែលបានបង់ និងប្រកាស ក្នុងការិយបរិច្ឆេទមានដូចខាងក្រោម៖

| | ពាន់រៀល |
|---|---|
| សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣៖ | |
| ភាគលាភដំបូង និងចុងក្រោយ ដែលមានតម្លៃ ៣៥០រៀលក្នុងមួយភាគហ៊ុនធម្មតា ត្រូវបានបង់នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ | ៤.៥៦៦.០៩១ |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ទុនបម្រុង និងសំវិធានធន

មានការផ្ទេរទឹកប្រាក់ចំនួន ១២២.០៤៣.៤៩០.៧៥០រៀល ពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមច្បាប់ទូទៅ និងសម្រាប់ការអភិវឌ្ឍន៍ដែលបានអនុម័តក្នុងអំឡុងពេលនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤។

### បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថា មិនមានបំណុលពិបាកទារ និងពុំមានភាពចាំបាច់ដើម្បីធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យឡើយ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានភាពចាំបាច់ ដើម្បីលុបចោលបំណុលពិបាកទារ ឬធ្វើសំវិធានធនសម្រាប់បំណុលជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឡើយ។

### ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ចំណេញ ឬ ខាត និងចំណូលពេញលេញផ្សេងៗ និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារ នៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ រ.ទ.ស.ភ ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឡើយ។

### វិធីសាស្ត្រកំណត់តម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលបានកើតឡើង និងដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំ ឬមានភាពមិនត្រឹមត្រូវដល់វិធីសាស្ត្រកំណត់តម្លៃ ដែលបានអនុវត្តកន្លងមកលើទ្រព្យសកម្ម និងបំណុលរបស់ រ.ទ.ស.ភ ឡើយ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) បន្ទុកណាមួយលើទ្រព្យសកម្មរបស់ រ.ទ.ស.ភ ដែលបានកើតឡើង ដោយសារការដាក់បញ្ចាំសម្រាប់ធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទនេះ ឬ

(២) បំណុលយថាហេតុណាមួយរបស់ រ.ទ.ស.ភ ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទនេះ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗដែលត្រូវបានទាមទារឱ្យសង ឬអាចត្រូវបានទាមទារឱ្យសង ក្នុងអំឡុងពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធភាពរបស់ រ.ទ.ស.ភ ក្នុងការបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួន នៅថ្ងៃកំណត់សងនោះទេ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

### ការផ្លាស់ប្តូរហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនត្រូវបានរៃកញែកក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដែលបណ្តាលឱ្យមានចំនួនទឹកប្រាក់ ដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានការភ័ន្តច្រឡំឡើយ។

### ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ រ.ទ.ស.ភ ក្នុងអំឡុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរ ដែលកើតចេញពីកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ទាំងឡាយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះនៃចុងការិយបរិច្ឆេទ មកទល់នឹងថ្ងៃចេញរបាយការណ៍នេះ ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត ឬមិនប្រក្រតីណាមួយបានកើតឡើង ដែលអាចប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលអាជីវកម្មរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទ ដែលរបាយការណ៍ត្រូវបានធ្វើឡើងឡើយ។

### ដើមទុន

រ.ទ.ស.ភ ពុំបានបោះផ្សាយភាគហ៊ុនណាមួយ ក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

រ.ទ.ស.ភ ពុំមានកិច្ចសន្យាផ្តល់ភាគហ៊ុនមិនទាន់បោះផ្សាយ និងមិនមានភាគហ៊ុនក្រោមកិច្ចសន្យាផ្តល់សិទ្ធិជាភាគហ៊ុនរបស់ រ.ទ.ស.ភ នាចុងការិយបរិច្ឆេទនេះទេ។

### សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលនៅបម្រើការចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយរួមមាន៖

| | |
|---|---|
| ឯកឧត្តម ឯក សុនចាន់ | (តែងតាំងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤) |
| ឯកឧត្តម ស៊ឹម ស៊ីថា | (ចប់អាណត្តិថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤) |
| ឯកឧត្តម ម៉ី វ៉ាន់ | |
| ឯកឧត្តម ឡុង ណារ៉ូ | |
| ឯកឧត្តម ឆាយ វីរៈ | (តែងតាំងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤) |
| ឯកឧត្តម នួន ផារ័ត្ន | (លាឈប់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤) |
| លោក ម៉ា ណូវ៉ាវីន | |
| លោក ណាំ ចន្ទ្រី | |
| លោក ស្រេង សំឌិក | |

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ក្នុងអំឡុង និងចុងការិយបរិច្ឆេទនេះ ពុំមានការរៀបចំណាមួយ ដែលមាន រ.ទ.ស.ភ ជាភាគីមួយ ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយការទិញយកភាគហ៊ុន ឬលិខិតបំណុលពី រ.ទ.ស.ភ ឬពីក្រុមហ៊ុនដទៃមួយទៀតឡើយ។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)**

**អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (ត)**

ចាប់តាំងពីចុងការិយបរិច្ឆេទកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងដោយ រ.ទ.ស.ភ ឬដោយក្រុមហ៊ុនដែលពាក់ព័ន្ធណាមួយ ជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តឡើយ លើកលែងតែសម្រាប់អត្ថប្រយោជន៍ណាមួយដែលអាចត្រូវបានគេចាត់ទុកថាបានកើតឡើងដោយសារប្រតិបត្តិការទាំងនោះ ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

**ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចធ្វើការបញ្ជាក់អះអាងថា របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំឡើង បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិ-ការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) អនុវត្តគោលនយោបាយគណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យបានជាប់លាប់

(ខ) អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាននៃ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ឬ ប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានសមរម្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថា រ.ទ.ស.ភ នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតដែលអាចប៉ាន់ស្មានបាន និង

(ង) ត្រួតពិនិត្យ និងដឹកនាំ រ.ទ.ស.ភ ឱ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចចិត្តជាសារវន្ត ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ រ.ទ.ស.ភ ហើយត្រូវប្រាកដថាសេចក្តីសម្រេចចិត្ត និង/ឬ សេចក្តីណែនាំទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា រ.ទ.ស.ភ បានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

**ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទ**

ព្រឹត្តិការណ៍សំខាន់ៗក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ៣៥ នៃរបាយ-ការណ៍ហិរញ្ញវត្ថុ។

លេខបញ្ជីពាណិជ្ជកម្ម៖
Co. 0៨៣៩ Et/២០១២



**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល (ត)

**សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល**

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់ចាប់ពីទំព័រទី ១២ ដល់ ៦៦ ត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់របស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ។

ចុះហត្ថលេខាតាងនាមក្រុមប្រឹក្សាភិបាល

**ឡុង ណារ៉ូ**
អគ្គនាយក

**ដេង ប៉ូលីដែន**
អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច

**ឯក សុនចាន់**
ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃសុក្រ ១៤រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញថ្ងៃទី២៨ខែមីនាឆ្នាំ២០២៥

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២)**

## សេចក្តីរាយការណ៍សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

**មតិយោបល់**

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងរបាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗ របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ និងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងព័ត៌មានគោលនយោបាយគណនេយ្យសារវន្ត ដែលបានបង្ហាញនៅទំព័រទី ១២ ដល់ ៦៦។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់មកជាមួយនេះ បង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក")។

**មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់**

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.ស.អ.ក")។ ទំនួលខុសត្រូវរបស់យើងខ្ញុំស្របតាមស្តង់ដានេះ ត្រូវបានពណ៌នាបន្ថែមក្នុងកថាខណ្ឌ *ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានភាពគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ។

*ទំនួលខុសត្រូវឯករាជ្យភាព និងក្រមសីលធម៌*

យើងខ្ញុំមានភាពឯករាជ្យពី រ.ទ.ស.ភ ដោយ ស្របតាម *ក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករជំនាញ (រួមទាំងស្តង់ដាឯករាជ្យភាពអន្តរជាតិ)* ("ក្រមសីលធម៌ IESBA") របស់ក្រុមប្រឹក្សាស្តង់ដាសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ រួមជាមួយនឹងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញនូវទំនួលខុសត្រូវខាងសីលធម៌ផ្សេងទៀតរបស់យើង ដោយអនុលោមតាមតម្រូវការនៃក្រមសីលធម៌ទាំងនេះ និងក្រមសីលធម៌ IESBA។

**បញ្ហាសវនកម្មសំខាន់ៗ**

បញ្ហាសវនកម្មសំខាន់ៗ គឺជាបញ្ហាទាំងឡាយណា ដែលមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទនេះ ដោយយោងតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ។ បញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងបរិបទនៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ទាំងមូល ហើយនៅក្នុងការបង្កើតមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ យើងខ្ញុំមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែក ចំពោះបញ្ហាទាំងនេះឡើយ។

BDO (Cambodia) Limited, Certified Public Accountants, a Cambodian limited liability company, is a member of BDO International Limited, a UK company limited by guarantee, and forms part of the international BDO network of independent member firms.

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២) (ត)**

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**(ក) ចំណូលបង្គរពីការលក់ទឹកស្អាត**

ចំណូលបង្គរពីការលក់ទឹកស្អាត ចំនួន ៣៣,២៣៧លានរៀល ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ តំណាងឱ្យតម្លៃនៃការផ្គត់ផ្គង់ទឹកស្អាតទៅអតិថិជននៅចន្លោះនៃកាលបរិច្ឆេទនៃអំនានចុងក្រោយជាមួយនឹងកាលបរិច្ឆេទរបាយការណ៍ ដែលវិក្កយបត្រមិនទាន់បានចេញដោយ រ.ទ.ស.ភ ឱ្យទៅអតិថិជននៅចុងបញ្ចប់ការិយបរិច្ឆេទនៃរបាយការណ៍នោះទេ។ យើងខ្ញុំបានកំណត់ថា នេះជាបញ្ហាសវនកម្ម ដ៏សំខាន់ដោយសារតែពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យ និងការសន្មតសំខាន់ៗរបស់គណៈគ្រប់គ្រងដើម្បីប៉ាន់ប្រមាណការបាត់បង់ទឹក ការប្រើប្រាស់ដែលមិនទាន់ចេញវិក្កយបត្រ និងអត្រាថ្លៃទឹកជាមធ្យមសមស្រប។

***ការឆ្លើយតបសវនកម្ម***

នីតិវិធីសវនកម្មរបស់យើងខ្ញុំរួមមាន៖

- ស្វែងយល់ពីវិធីសាស្ត្រប៉ាន់ស្មានរបស់គណៈគ្រប់គ្រង និងការវាយតម្លៃថាតើវាត្រូវបានអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងសមស្របឬទេ;
- ការធ្វើតេស្តនៃភាពត្រឹមត្រូវគណិតវិទ្យានៃការគណនាប្រាក់ចំណូលបង្គរ;
- ការវាយតម្លៃលើភាពសមហេតុផលនៃធាតុចូលសំខាន់ៗ រួមមាន៖
  - (i) បរិមាណទឹកដែលផលិតក្នុងអំឡុងពេល ដោយស្របតាមរបាយការណ៍ផលិតកម្ម;
  - (ii) ចំណូលទឹកដែលបានចេញវិក្កយបត្រ ដោយការបន្សីទៅនឹងកំណត់ត្រាវិក្កយបត្រ;
  - (iii) ការប៉ាន់ប្រមាណការបាត់បង់ទឹក ដោយពិនិត្យមើលទិន្នន័យប្រវត្តិសាស្ត្រ និងរបាយការណ៍ទឹកបាត់បង់ ("NRW");
  - (iv) អត្រាថ្លៃទឹកជាមធ្យម ដោយពិនិត្យមើលកាលវិភាគដែលបានអនុម័ត និងទម្រង់ប្រើប្រាស់របស់អតិថិជន;
- ប្រៀបធៀបការប៉ាន់ប្រមាណឆ្នាំនេះទៅនឹងវិក្កយបត្របន្តបន្ទាប់ជាក់ស្តែង ដើម្បីវាយតម្លៃ ភាពជឿជាក់នៃដំណើរការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង និង;
- ការចូលរួមជាមួយអ្នកជំនាញផ្នែកព័ត៌មានវិទ្យារបស់យើងខ្ញុំ ដើម្បីវាយតម្លៃភាពជឿជាក់និងសុចរិតភាពនៃប្រព័ន្ធចេញវិក្កយបត្រ និងផលិតទឹកប្រើប្រាស់ ដើម្បីបង្កើតទិន្នន័យមូលដ្ឋានគាំទ្រដល់ការប៉ាន់ប្រមាណចំណូលដែលបានបង្គរ ក៏ដូចជាការវាយតម្លៃភាពគ្រប់គ្រាន់នៃការបង្ហាញពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២) (ត)**

**បញ្ហាសវនកម្មសំខាន់ៗ (ត)**

**(ខ) ការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម**

តម្លៃយោងដុលរបស់គណនីអតិថិជនពាណិជ្ជកម្មរបស់ រ.ទ.ស.ភ មានចំនួន ៧.៥២៣ពាន់លានរៀល ដូចដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

យើងខ្ញុំបានកំណត់ថា នេះគឺជាបញ្ហាសវនកម្មដ៏សំខាន់មួយ ព្រោះវាតម្រូវឱ្យគណៈគ្រប់គ្រងអនុវត្តការវិនិច្ឆ័យសំខាន់ ក្នុងការកំណត់លទ្ធភាពនៃភាពមិនអាចទូទាត់សងរបស់គណនីអតិថិជនពាណិជ្ជកម្ម និងព័ត៌មានដែលមើលទៅមុខដែលសមស្រប។

***ការឆ្លើយតបសវនកម្ម***

នីតិវិធីសវនកម្មរបស់យើងខ្ញុំរួមមាន៖

- គណនាឡើងវិញនូវលទ្ធភាពនៃភាពមិនអាចទូទាត់សង ដោយប្រើប្រាស់នូវទិន្នន័យតាមប្រវត្តិ-សាស្ត្រ និងការកែតម្រូវព័ត៌មានដែលមើលទៅមុខ ដែលត្រូវបានប្រើប្រាស់ដោយ រ.ទ.ស.ភ;
- គណនាឡើងវិញនូវទំនាក់ទំនងមេគុណរវាងសូចនាករម៉ាក្រូសេដ្ឋកិច្ច ដែលត្រូវបានប្រើប្រាស់ដោយ រ.ទ.ស.ភ និងការបាត់បង់តាមប្រវត្តិសាស្ត្រ ដើម្បីកំណត់ភាពសមស្របនៃព័ត៌មានដែលមើលទៅមុខដែលត្រូវបានប្រើប្រាស់ដោយ រ.ទ.ស.ភ;
- សាកសួរទៅកាន់គណៈគ្រប់គ្រង ដើម្បីវាយតម្លៃហេតុផលដែលបង្ហាញពីទំនាក់ទំនងរវាងព័ត៌មានដែលមើលទៅមុខ និងការបាត់បង់ឥណទានរំពឹងទុក; និង
- បានវាយតម្លៃព្រឹត្តិការណ៍ការបាត់បង់ជាក់ស្តែងជាបន្តបន្ទាប់ រហូតដល់ចុងបញ្ចប់នៃរយៈពេលរាយការណ៍សម្រាប់របស់ខ្លួន។ ទំនាក់ទំនងជាមួយសូចនាករនៃការកើនឡើងយ៉ាងខ្លាំងនៃហានិភ័យឥណទានដែលបានអនុវត្តដោយគណៈគ្រប់គ្រង។

**ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកម្មខាងលើ**

ក្រុមប្រឹក្សាភិបាលរបស់ រ.ទ.ស.ភ មានទំនួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយ-ការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ និងរបាយការណ៍សវនកម្មខាងលើរបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ មិនរួមបញ្ចូលព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនផ្តល់នូវទម្រង់សន្និដ្ឋានជាបែបផែនាណាមួយឡើយ។

ទាក់ទងនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអាននូវព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗមានភាពមិនសមស្របជាសារវន្ត ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឬក៏ចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីសវនកម្ម ឬបើមិនដូច្នោះទេ លេចឡើងមានកំហុសឆ្គងជាសារវន្ត។

ផ្អែកលើកិច្ចការដែលយើងខ្ញុំបានអនុវត្ត ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំតម្រូវឱ្យរាយការណ៍នូវហេតុការណ៍ទាំងនោះ។ យើងខ្ញុំពុំមានអ្វីដើម្បីរាយការណ៍ក្នុងករណីនេះទេ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២) (ត)**

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញនូវទិដ្ឋភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏ទទួលខុសត្រូវក្នុងការរក្សានូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសំខាន់ៗ ដែលក្រុមប្រឹក្សាភិបាលកំណត់ថា មានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឱ្យជៀសផុតពីកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាលជាអ្នកទទួលការខុសត្រូវ ក្នុងការវាយតម្លៃទៅលើលទ្ធភាពបន្តប្រតិបត្តិការរបស់ រ.ទ.ស.ភ ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយធ្វើការលាតត្រដាង ប្រសិនជាមាននូវកត្តាដែលពាក់ព័ន្ធនឹងនិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយប្រើប្រាស់នូវមូលដ្ឋានគណនេយ្យបែប អនិរន្តរភាព លុះត្រាតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយ រ.ទ.ស.ភ ឬបញ្ឈប់ប្រតិបត្តិការ ឬមិនមានជម្រើសប្រាកដណាមួយ ប៉ុន្តែត្រូវតែធ្វើដូច្នេះ។

## ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផល ថាតើរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ និងចេញនូវរបាយការណ៍សវនកម្មដែលរួមមាន មតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងយ៉ាងសមហេតុផល គឺជាអំណះអំណាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនបានធានាថាការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា តែងតែរកឃើញនូវកំហុសឆ្គងជាសារវន្តពេលដែលវាកើតមានឡើងនោះទេ។ កំហុសឆ្គងអាចកើតឡើងពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ត្រូវបានចាត់ទុកជាសារវន្ត ប្រសិនបើជាលក្ខណៈមួយៗ ឬជាលក្ខណៈរួមផ្តុំ អាចមានឥទ្ធិពលលើការសម្រេចចិត្តសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់លើមូលដ្ឋាននៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃលើហានិភ័យកំហុសឆ្គងជាសារវន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ថាតើវាបណ្តាលមកពីការក្លែងបន្លំ ឬការភ័ន្តច្រឡំ ហើយធ្វើការរៀបចំ និងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបាននូវភស្តុតាងសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យដើម្បីជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។ ហានិភ័យនៃការមិនបានរកឃើញនូវកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ គឺខ្ពស់ជាងហានិភ័យដែលបណ្តាលមកពីការភ័ន្តច្រឡំ ដោយសារតែការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិតគ្នា ការក្លែងបន្លំ ការលុបចោលដោយចេតនា ការបកស្រាយខុស ឬក៏ការបំពានលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់ពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងសវនកម្ម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមស្ថានភាព ប៉ុន្តែមិនមែនក្នុងគោលបំណងបញ្ចេញមតិយោបល់ពីប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ រ.ទ.ស.ភ នោះឡើយ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២) (ត)**

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ (ត)**

ជាផ្នែកមួយនៃសវនកម្មដែលអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដោយវិជ្ជាជីវៈ និងរក្សានូវការសង្ស័យដោយវិជ្ជាជីវៈនៅក្នុងសវនកម្មទាំងមូល។ យើងខ្ញុំក៏បាន៖ (ត)

- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានអនុវត្ត និងភាពសមហេតុផលនៃប៉ាន់ស្មានគណនេយ្យ និងលាតត្រដាងដែលពាក់ព័ន្ធ ដែលបានរៀបចំដោយក្រុមប្រឹក្សាភិបាល។
- ធ្វើសេចក្តីសន្និដ្ឋានលើភាពសមស្របនៃមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ដែលប្រើប្រាស់ដោយគណៈគ្រប់គ្រង និងផ្អែកលើភស្តុតាងដែលទទួលបាន ថាតើមានភាពមិនប្រាកដប្រជាកើតឡើងជាសារវន្ត ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចប៉ះពាល់ដល់លទ្ធភាពបន្តប្រតិបត្តិការរបស់ខ្លួនដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តមួយកើតឡើង យើងខ្ញុំត្រូវបានតម្រូវឱ្យទាញការយកចិត្តទុកដាក់ក្នុងរបាយការណ៍សវនកម្ម និងការលាតត្រដាងនៅក្នុងរបាយ-ការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ឬក៏កែប្រែមតិយោបល់របស់យើងខ្ញុំ ប្រសិនបើការកំណត់ទាំងនោះមិនគ្រប់គ្រាន់។ សេចក្តីសន្និដ្ឋានយើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលទទួលបាន រហូតដល់ថ្ងៃចេញរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណាព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចនឹងបង្កឱ្យ រ.ទ.ស.ភ បញ្ឈប់នូវនិរន្តរភាពនៃដំណើរការអាជីវកម្ម។
- វាយតម្លៃលើបទបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ រួមទាំងការលាតត្រដាង ថាតើរបាយការណ៍ហិរញ្ញវត្ថុ រ.ទ.ស.ភ តំណាងឱ្យប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងៗ ក្នុងរបៀបរបបមួយដែលសម្រេចបាននូវការបង្ហាញត្រឹមត្រូវ។

ក្នុងចំណោមចំណុចពាក់ព័ន្ធផ្សេងៗ យើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាភិបាលអំពីផែនការវិសាលភាពការងារ និងពេលវេលានៃសវនកម្ម និងចំណុចសំខាន់ៗដែលបានរកឃើញ រួមមានកង្វះខាតសំខាន់ៗនៅក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញនៅក្នុងអំឡុងសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំផ្តល់ជូនក្រុមប្រឹក្សាភិបាលផងដែរ នូវសេចក្តីថ្លែងការណ៍មួយ ដែលយើងបានអនុលោមទៅតាមតម្រូវការនៃក្រមសីលធម៌ពាក់ព័ន្ធផ្សេងៗ ដែលទាក់ទិននឹងឯករាជ្យភាព និងធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សានូវទំនាក់ទំនងទាំងអស់ និងបញ្ហាផ្សេងៗទៀតដែលអាចមានឥទ្ធិពលលើឯករាជ្យភាពរបស់យើងខ្ញុំ ហើយប្រសិនបើមានសកម្មភាពនានាត្រូវបានចាត់វិធានការដើម្បីលុបបំបាត់ការគម្រាមកំហែង ឬការការពារដែលបានអនុវត្ត។

អំពីបញ្ហាដែលយើងខ្ញុំបានទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាល យើងខ្ញុំបានកំណត់ថា បញ្ហាទាំងនោះ គឺមានសារៈសំខាន់បំផុតនៅក្នុងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទនេះ ដូច្នេះហើយវា គឺជាបញ្ហាសវនកម្មសំខាន់ៗ។ យើងខ្ញុំនឹងពណ៌នាបញ្ហាទាំងនោះនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លុះត្រាតែមានច្បាប់ ឬបញ្ញត្តិ រារាំងក្នុងការបង្ហាញជាសាធារណៈអំពីបញ្ហាទាំងនោះ ឬក៏ក្នុងកាលៈទេសៈដ៏កម្រមួយ យើងខ្ញុំកំណត់ថាបញ្ហានេះមិនគួរបង្ហាញនៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារតែផលវិបាកជាអវិជ្ជមានពីការបង្ហាញនោះ អាចនឹងមានផលប៉ះពាល់ដល់អត្ថប្រយោជន៍សាធារណៈ។

**របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគហ៊ុនិករបស់**
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**
**(លេខ Co. ០៨៣៩ Et/២០១២) (ត)**

**បញ្ហាដទៃ**

របាយការណ៍នេះត្រូវបានធ្វើឡើងតែចំពោះភាគហ៊ុនិករបស់ រ.ទ.ស.ភ ប៉ុណ្ណោះ។ យើងមិនទទួលខុសត្រូវចំពោះបុគ្គលណាម្នាក់ចំពោះខ្លឹមសារនៃរបាយការណ៍នេះទេ។

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន មួយផ្សេងទៀតដែលជាគណនេយ្យករជំនាញសាធារណៈ ដែលមានរបាយការណ៍ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ បានបញ្ចេញមតិយោបល់ពិត និងត្រឹមត្រូវលើរបាយការណ៍ទាំងនោះ។

សម្រាប់ និងជំនួសឱ្យ
**ប៊ី ឌី អូ (ខេមបូឌា) លីមីធីត**

សុង ស្រីរដ្ឋា
*គណនេយ្យករជំនាញ*

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
រាជធានីភ្នំពេញថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ៣១ ធ្នូ ២០២៤ ពាន់រៀល | ៣១ ធ្នូ ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | ១ មករា ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ | ៥ | ២.៩៣៩.៦៦៤.៤២៦ | ២.៤៩៤.៥០១.៧១៤ | ២.២០៣.០៤១.៩១៤ |
| ទ្រព្យសកម្មអរូបី | ៦ | ៩.០៨០.៥០៧ | ១០.៤៦៣.០៧៤ | ១២.០៨៩.៥៨៧ |
| | | ២.៩៤៨.៧៤៤.៩៣៣ | ២.៥០៤.៩៦៤.៧៨៨ | ២.២១៥.១៣១.៥០១ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | |
| សន្និធិ | ៧ | ១៤៤.២៣៥.៧៧០ | ៣១៨.៧៤៦.៥៩២ | ១៥២.៧៣៧.០៧៨ |
| គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ | ៨ | ២៧.៥៣៧.៩២៧ | ១៧.៦៦៤.០៨៦ | ២៥.៣៧៧.១៧០ |
| កិច្ចសន្យាទ្រព្យសកម្ម | ៩ | ៣៧.៥៨៦.១៩០ | ៣៨.៦២៨.៤៧៧ | ៣៨.៩២៥.៤៦៧ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ១០ | ៣.៨៩៤.៥៨៩ | ៧.៩៥៦.៦៥១ | ៧.៩៥៦.៦៥១ |
| ការវិនិយោគរយៈពេលខ្លី | ១១ | ៩៤.៩៦១.៣៦០ | ១២៧.៣១៦.០០៣ | ១២៦.១១៨.៤១៦ |
| ទ្រព្យសកម្មពន្ធចរន្ត | | ៣.៧៩៧.៨៤៦ | - | - |
| សមតុល្យសាច់ប្រាក់ និងធនាគារ | ១២ | ១៨.៤០៦.៦៦៦ | ២៣.០៨៨.៥៧០ | ៦១.១៥៨.៩១៥ |
| | | ៣៣០.៤២០.៣៤៨ | ៥៣៣.៤០០.៣៨៩ | ៤០៨.២៧៣.៦៩៧ |
| **ទ្រព្យសកម្មសរុប** | | ៣.២៧៩.១៦៥.២៨១ | ៣.០៣៨.៣៦៥.១៧៧ | ២.៦២៣.៤០៥.១៩៨ |
| **មូលធន និងបំណុល** | | | | |
| **មូលធន** | | | | |
| ដើមទុន | ១៣ | ៦២០.៧៥៩.១០៧ | ៦២០.៧៥៩.១០៧ | ៦២០.៧៥៩.១០៧ |
| ទុនបម្រុង | ១៤ | ៧១៣.២៣២.៦០៣ | ៥៩១.១៩២.៦៦៦ | ៥៤៣.២៦៨.០៧៥ |
| ចំណេញរក្សាទុក | | ៣១.០៨០.៩០៣ | ៧២.៦៤៤.០១៨ | ៥២.២២៦.១៩៥ |
| | | ១.៣៦៥.០៧២.៦១៣ | ១.២៨៤.៥៩៥.៧៩១ | ១.២១៦.២៥៣.៣៧៧ |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

**របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**
**នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (ត)**

| | កំណត់សម្គាល់ | ៣១ ធ្នូ ២០២៤ ពាន់រៀល | ៣១ ធ្នូ ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) | ១ មករា ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|---|
| **បំណុល** | | | | |
| **បំណុលរយៈពេលវែង** | | | | |
| ប្រាក់កម្ចី | ១៥ | ៤៤៣.៧២៧.០៩៩ | ៤៥៧.៨១៨.៧៣៥ | ៩៨៦.៨៩៥.៧១៧ |
| ជំនួយពន្យារពីរដ្ឋាភិបាល និង ជំនួយផ្សេងៗ | ១៦ | ៧២.៦២៥.៩៦១ | ៧៨.១៦២.៧៤៦ | ៦៩.២៣៨.៤៧៧ |
| បំណុលពន្ធពន្យារ | ១៧ | ១០៥.១៤៦.៨៦១ | ៩១.៩៩៤.៣២១ | ៧៧.០១៦.៧១៦ |
| គណនីត្រូវបង់ផ្សេងៗ | ១៨ | ៨៨.៩៥០.៥៦៦ | ៨២.៩០៣.៧៣២ | ៧៦.៨០១.៧០៥ |
| | | ៧១០.៤៥០.៤៨៧ | ៧០៦.៨៧៩.៥៣៤ | ១.២០៩.៩៥២.៦១៥ |
| **បំណុលរយៈពេលខ្លី** | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៨ | ២១៣.២២៤.២២៥ | ១៦៩.៧៤៣.៦៤០ | ១៤៩.៨៩០.១៩៥ |
| ប្រាក់កម្ចី | ១៥ | ៩៨៦.៨៩២.២៨៣ | ៨៦២.៧៨៣.៣៥០ | ២៣.៩៩៩.១៥៨ |
| កិច្ចសន្យាបំណុល | ៩ | ៣.៥២៥.៦៧៣ | ៤.២៥៤.១៣៨ | ៤.៤៥៦.៧៥៦ |
| បំណុលពន្ធចរន្ត | | - | ១០.១០៨.៧២៤ | ១៩.៧៥៣.១៤៧ |
| | | ១.២០៣.៦៤២.១៨១ | ១.០៤៦.៨៨៩.៨៥២ | ១៩៧.៥៩៩.២០៦ |
| **បំណុលសរុប** | | ១.៩១៤.០៩២.៦៦៨ | ១.៧៥៣.៧៦៩.៣៨៦ | ១.៤០៧.១៥១.៨២១ |
| **មូលធន និងបំណុលសរុប** | | ៣.២៧៩.១៦៥.២៨១ | ៣.០៣៨.៣៦៥.១៧៧ | ២.៦២៣.៤០៥.១៩៨ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍ចំណេញ ឬ ខាត និងចំណូលពេញលេញផ្សេងៗ
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|
| **ចំណូល៖** | | | |
| ចំណូលពីការលក់ | ១៩ | ៣១៧.៧៧៨.៩៩៦ | ២៩៧.៤១៦.១៩១ |
| កម្រៃពីការសាងសង់ | ២០ | ១១.៣៩២.១១២ | ១៤.៨៥៤.៥៣៩ |
| ចំណូលផ្សេងៗ | ២១ | ១៨.៥២៦.៦៧០ | ២១.១៣៨.១៥០ |
| | | ៣៤៧.៦៩៧.៧៧៨ | ៣៣៣.៤០៨.៨៣០ |
| **ចំណាយ៖** | | | |
| ចំណាយរំលស់ទ្រព្យសកម្មរូបី និងអរូបី | | (៥៩.៥១៥.៩១៤) | (៦១.៩៧៨.១៣៤) |
| ចំណាយថ្លៃភ្លើង | | (៤៨.៦៥៣.០៦៣) | (៤២.២៩១.៤៤៦) |
| ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | ២២ | (៨៥.៥៥២.៥១០) | (៨០.២៩២.៤៣៨) |
| ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត | ២៣ | (១៨.៩៧៦.៥៩០) | (១៥.៨៧៥.៣១៣) |
| ចំណាយវត្ថុធាតុដើមសម្រាប់តភ្ជាប់បណ្ដាញ | ២៤ | (៦.២៩៣.២៧៧) | (៤.៨១៦.៥១៤) |
| ចំណាយជួសជុល និងថែទាំ | | (១៤.៦៦៦.៧៣២) | (១១.៦៥១.០៥៨) |
| ចំណាយសេវាសាងសង់ | | (៨.៩៦១.៥៩៦) | (៩.៧៣១.៥១៨) |
| ការប្រែប្រួលបំនៃការថយចុះតម្លៃលើឥណទានផ្ដល់ឱ្យបុគ្គលិក | ១០ | ២៦០.៨៧៤ | - |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (១៤.១៣៦.៣៩៩) | (១៥.១៩៥.៤៣៧) |
| ខាតពីការបកប្រែរូបិយប័ណ្ណបរទេស - សុទ្ធ | ២៥ | (២.១៩៦.១២១) | (៥.៨៥៦.៩១៩) |
| | | (២៥៨.៦៩១.៣២៨) | (២៤៧.៦៤៨.៧៧៧) |
| ចំណេញប្រតិបត្តិការ | | ៨៩.០០៦.៤៥០ | ៨៥.៧៦០.០៥៣ |
| ចំណូលហិរញ្ញវត្ថុ | ២៦ | ៥៧.១៦៩.៣៨៧ | ៣៩.០៣៨.៥៩១ |
| ចំណាយហិរញ្ញវត្ថុ | ២៦ | (៣៩.០០១.៤៧៦) | (២៥.៨៦០.៥៩៧) |
| ចំណេញមុនបង់ពន្ធ | | ១០៧.១៧៤.៣៦១ | ៩៨.៩៣៨.០៤៧ |
| ចំណាយពន្ធ | ២៧ | (២២.១៣១.៤៤៨) | (២៦.២៩០.៤៧៥) |
| ចំណេញក្នុងការិយបរិច្ឆេទ | | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ |
| ចំណូលពេញលេញផ្សេងៗសរុបបន្ទាប់ពីគិតពន្ធរួច | | - | - |
| ចំណូលពេញលេញសរុបក្នុងការិយបរិច្ឆេទ | | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ |

ចំណេញក្នុងមួយភាគហ៊ុន (បង្ហាញជាប្រាក់រៀល) ដែលជាកម្មសិទ្ធិរបស់ភាគហ៊ុនិករបស់ រ.ទ.ស.ភ ក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់មានដូចខាងក្រោម៖

| | កំណត់សម្គាល់ | ២០២៤ | ២០២៣ |
|---|---|---|---|
| ក្នុងមួយភាគហ៊ុនគោល | ២៨ | ៩៧៧,៨១ | ៨៣៥,២៩ |
| ក្នុងមួយភាគហ៊ុនថយចុះ | ២៨ | ៩៧៧,៨១ | ៨៣៥,២៩ |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ដើមទុន ពាន់រៀល | ទុនបម្រុង ពាន់រៀល | ចំណេញរក្សាទុក ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** ដូចដែលបានរាយការណ៍ពីមុន | | ៦២០.៧៥៩.១០៧ | ៥៤៣.២៦៨.០៧៥ | ១០៨.១៨៥.៨៦៥ | ១.២៧២.២១៣.០៤៧ |
| ការធ្វើនិយ័តកម្មឆ្នាំមុន | ៣៧ | - | - | (៥៥.៩៥៩.៦៧០) | (៥៥.៩៥៩.៦៧០) |
| **សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ កំណត់ឡើងវិញ** | | ៦២០.៧៥៩.១០៧ | ៥៤៣.២៦៨.០៧៥ | ៥២.២២៦.១៩៥ | ១.២១៦.២៥៣.៣៧៧ |
| ចំណេញក្នុងការិយបរិច្ឆេទតំណាងឱ្យចំណូលពេញលេញសរុប៖ | | | | | |
| - ដូចដែលបានរាយការណ៍ពីមុន | | - | - | ១២៦.៦០៩.៥៨២ | ១២៦.៦០៩.៥៨២ |
| - ការធ្វើនិយ័តកម្មឆ្នាំមុន | ៣៧ | - | - | (៥៣.៩៦២.០១០) | (៥៣.៩៦២.០១០) |
| កំណត់ឡើងវិញ | | - | - | ៧២.៦៤៧.៥៧២ | ៧២.៦៤៧.៥៧២ |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន** | | | | | |
| ការផ្ទេរទៅទុនបម្រុង៖ | | | | | |
| - ដូចដែលបានរាយការណ៍ពីមុន | ១៤ | - | ១០៣.៨៨០.៧០៧ | (១០៣.៨៨០.៧០៧) | - |
| - ការធ្វើនិយ័តកម្មឆ្នាំមុន | ៣៧ | - | (៥៥.៩៥៦.១១៦) | ៥៥.៩៥៦.១១៦ | - |
| ភាគលាភ | ២៩ | - | - | (៤.៣០៥.១៥៨) | (៤.៣០៥.១៥៨) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ៤៧.៩២៤.៥៩១ | (៥២.២២៩.៧៤៩) | (៤.៣០៥.១៥៨) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣/ ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ កំណត់ឡើងវិញ** | | **៦២០.៧៥៩.១០៧** | **៥៩១.១៩២.៦៦៦** | **៧២.៦៤៤.០១៨** | **១.២៨៤.៥៩៥.៧៩១** |
| ចំណេញក្នុងការិយបរិច្ឆេទតំណាងឱ្យចំណូលពេញលេញសរុប | | - | - | ៨៥.០៤២.៩១៣ | ៨៥.០៤២.៩១៣ |
| **ប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន** | | | | | |
| ការផ្ទេរទៅទុនបម្រុង | ១៤ | - | ១២២.០៤៣.៤៩១ | (១២២.០៤៣.៤៩១) | - |
| ភាគលាភ | ២៩ | - | - | (៤.៥៦៦.០៩១) | (៤.៥៦៦.០៩១) |
| សរុបប្រតិបត្តិការជាមួយម្ចាស់ភាគហ៊ុន | | - | ១២២.០៤៣.៤៩១ | (១២៦.៦០៩.៥៨២) | (៤.៥៦៦.០៩១) |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | **៦២០.៧៥៩.១០៧** | **៧១៣.២៣៦.១៥៧** | **៣១.០៧៧.៣៤៩** | **១.៣៦៥.០៧២.៦១៣** |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

| | កំណត់សម្គាល់ | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | |
| ចំណេញមុនបង់ពន្ធ | | ១០៧.១៧៤.៣៦១ | ៩៨.៩៣៨.០៤៧ |
| និយ័តកម្ម៖ | | | |
| រំលស់ទ្រព្យសកម្មអរូបី | ៦ | ១.១៥៧.១៥៥ | ១.៨៥៦.៤៥០ |
| រំលស់ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៦ | (២.០០៩.៩០៨) | (២.០០៩.៩០៨) |
| រំលស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៥៨.១០៧.៨៧៣ | ៦០.១១៥.៣៦៩ |
| ចំណូលហិរញ្ញវត្ថុ | ២៦ | (៥៧.១៦៩.៣៨៧) | (៣៩.០៣៨.៥៩១) |
| ចំណាយហិរញ្ញវត្ថុ | ២៦ | ៣៩.០០១.៤៧៦ | ២៥.៨៦០.៥៩៧ |
| ការលុបចេញពីបញ្ជីនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៣៦៥.៩០៧ | ១.៦២៨.៤៥៥ |
| ការលុបចេញពីបញ្ជីនៃទ្រព្យសកម្មអរូបី | ៦ | ២៥០.៨៨៦ | ៦.៣១៥ |
| ការប្រែប្រួលបង់នៃការថយចុះតម្លៃលើឥណទានផ្តល់ឱ្យបុគ្គលិក | ១០ | (២៦០.៨៧៤) | - |
| ចំណេញប្រតិបត្តិការមុនបម្រែបម្រួលដើមទុនបង្វិល | | ១៤៦.៦១៧.៤៨៩ | ១៤៧.៣៥៦.៧៣៤ |
| បម្រែបម្រួលដើមទុនបង្វិល៖ | | | |
| សន្និធិ | | ១៣០.០២៣.៤៥២ | (២៣៨.១៥២.៩៣៨) |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | | (១៥.០៨៤.១៦០) | ៨.១៤០.៣៥០ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | | (១៤.៧៤៦.៨៣៣) | ១២.៧៧២.៣៨៣ |
| កិច្ចសន្យាទ្រព្យសកម្ម | | ១.០៤២.២៨៧ | (៣.៧០៣.០១០) |
| កិច្ចសន្យាបំណុល | | (៧២៨.៤៦៥) | (២០២.៦១៨) |
| សាច់ប្រាក់បានមកពី/(ប្រើក្នុង)ប្រតិបត្តិការ | | ២៤៧.១២៣.៧៧០ | (៧៣.៧៨៩.០៩៩) |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (១៩.០៨៧.៦៣២) | (២០.៩៥៧.២៩៣) |
| សាច់ប្រាក់សុទ្ធបានមកពី/(ប្រើក្នុង)សកម្មភាពប្រតិបត្តិការ | | ២២៨.០៣៦.១៣៨ | (៩៤.៧៤៦.៣៩២) |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (៣៨៩.៨៩៦.៨៥៤) | (២៥៦.២២៦.២៣២) |
| ការទិញទ្រព្យសកម្មអរូបី | ៦ | (២៥.៤៧៤) | (២៣៦.២៥២) |
| ការប្រាក់បានទទួល | | ៨.០២៥.៩៧៧ | ៦.៣១០.៤៩១ |
| ការដកប្រាក់/(ការដាក់ប្រាក់)នៃទុនវិនិយោគរយៈពេលខ្លី | | ៣២.៣៥៤.៦៤៣ | (១.១៩៧.៥៨៧) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | | (៣៤៩.៥៤១.៧០៨) | (២៥១.៣៤៩.៥៨០) |

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**របាយការណ៍លំហូរសាច់ប្រាក់**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (ត)**

| | កំណត់សម្គាល់ | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|---|
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | |
| ភាគលាភបានបង់ | | (៤.៥៦៦.០៩១) | (៤.៣០៥.១៥៨) |
| សាច់ប្រាក់បានមកពីប្រាក់កម្ចី | | ១៥៥.៩១១.៥៩៨ | ៣៩១.៩៨៧.៥៣៧ |
| ការប្រាក់បានបង់ | | (១៩.២៣២.៥៦៣) | (១៥.១១១.៤៧៥) |
| ការបង់សងប្រាក់កម្ចី | | (២០.០៨៥.៣៣៧) | (២១.៤៧៩.៤៥៤) |
| ប្រាក់ជំនួយទទួលបានពីរដ្ឋាភិបាល | ១៦ | ៤៧៣.១២៣ | ៦.៩៣៨.១៧៧ |
| ប្រាក់ទទួលបានពីការទូទាត់តណ្ហាទានផ្ដល់ឱ្យបុគ្គលិក | | ៤.៣២២.៩៣៦ | - |
| សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពហិរញ្ញប្បទាន | | ១១៦.៨២៣.៦៦៦ | ៣០៨.០២៥.៦២៧ |
| **តំហយសុទ្ធសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ១២ | (៤.៦៨១.៨០៤) | (៣៨.០៧០.៣៤៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ** | | ២៣.០៨៨.៤៧០ | ៦១.១៥៨.៨១៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ** | | ១៨.៤០៦.៦៦៦ | ២៣.០៨៨.៤៧០ |

***ការផ្ទៀងផ្ទាត់នៃបំណុលដែលបានមកពីសកម្មភាពហិរញ្ញប្បទាន***

| | ប្រាក់កម្ចី (កំណត់សម្គាល់លេខ ១៥) គិតជាពាន់រៀល |
|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | **១.០០៩.៩៩៤.៨៧៥** |
| លំហូរសាច់ប្រាក់ | ៣២០.៥០៨.០៧៩ |
| លំហូរមិនមែនសាច់ប្រាក់៖ | |
| - ផលប៉ះពាល់នៃអត្រាប្តូរប្រាក់បរទេស | (៩.៩៦៧.៩៥៥) |
| - ការប្រាក់បង្គរ | ៦៧.០៨៦ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | **១.៣២០.៦០២.០៨៥** |
| លំហូរសាច់ប្រាក់ | ១៣៥.៨២៦.២៦១ |
| លំហូរមិនមែនសាច់ប្រាក់ | |
| - ផលប៉ះពាល់នៃអត្រាប្តូរប្រាក់បរទេស | (២៥.៩៧៥.៤៤២) |
| - ការប្រាក់បង្គរ | ១៦៦.៤៧៨ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **១.៤៣០.៦១៩.៣៨២** |

*កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុមួយនេះ។*

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**(ចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា)**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤**

## ១. ព័ត៌មានអំពី រ.ទ.ស.ភ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ហៅកាត់ថា ("រ.ទ.ស.ភ") ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេសរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ("ក.ឧ.វ.ប.ន") និងស្ថិតក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("ក.ស.ហ.វ") ហើយមានការិយាល័យកណ្តាលនៅរាជធានីភ្នំពេញ។ រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មថាជាសហគ្រាសសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច និងមានលេខចុះបញ្ជី Co.០៨៣៩ Et/២០១២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២។

ការិយាល័យដែលបានចុះបញ្ជីរបស់ រ.ទ.ស.ភ គឺនៅអគារលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់រៀលដែលជារូបិយវត្ថុដែល រ.ទ.ស.ភ កំពុងប្រើប្រាស់ផងដែរ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តឱ្យចេញផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

## ២. សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ រ.ទ.ស.ភ គឺការផលិត និងការចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ និងតំបន់ក្បែរដែលរួមមានក្រុងតាខ្មៅ ខេត្តត្បូងឃ្មុំ និងទំនប់ម្តេចក្នុងខេត្តកំពត ព្រមទាំងផ្តល់សេវាផ្សេងៗ។ កម្មវត្ថុអាជីវកម្មរបស់ រ.ទ.ស.ភ គឺ៖

- វិនិយោគ កសាង ពង្រីក ដំណើរការ ជួសជុល និងថែទាំមធ្យោបាយសម្រាប់ផលិត និងប្រព័ន្ធចែកចាយទឹកស្អាត
- គ្រប់គ្រងបរិក្ខារដើម្បីបង្កើនផលិតកម្ម និងសេវាកម្ម និងធានាគុណភាពទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់
- ដំណើរការអាជីវកម្ម សេវាកម្ម និងភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹកស្អាតស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យា ពាណិជ្ជកម្ម និងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍ក្នុងស្រុក និងក្រៅប្រទេស ដើម្បីពង្រីក និងអភិវឌ្ឍន៍ រ.ទ.ស.ភ ទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង
- ធានាឱ្យបាននូវចីរភាពដំណើរការផលិតកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សាធារណៈ។

គ្មានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាពចម្បងរបស់ រ.ទ.ស.ភ ក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

## ៣. មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ដែលចេញផ្សាយដោយនិយ័តករគណនេយ្យ និងសវនកម្ម ("ន.គ.ស") នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤. គោលការណ៍គណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យដែលបានអនុវត្តគឺ ស្របតាមការិយបរិច្ឆេទមុន លើកលែងតែផលប៉ះពាល់នៃការអនុវត្តវិសោធនកម្មថ្មីចំពោះ ស.រ.ហ.អ.ក ប្រសិនបើមាន ក្នុងអំឡុងការិយបរិច្ឆេទនេះ។ ស.រ.ហ.អ.ក ថ្មីដែលត្រូវបានអនុវត្ត នៅក្នុងអំឡុងការិយបរិច្ឆេទត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់លេខ ៣៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

របាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រសន្មតថ្លៃដើម លើកលែងនូវអ្វីដែលបានបញ្ជាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

# ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | ដីធ្លី ពាន់រៀល | អគារ ពាន់រៀល | គ្រឿងយន្ត ពាន់រៀល | បំពង់បង្ហូរទឹក ពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍ ពាន់រៀល | គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ ពាន់រៀល | បរិក្ខារអគ្គិសនី ពាន់រៀល | យានយន្ត ពាន់រៀល | រ៉ាន និងឧបករណ៍ប្រើប្រាស់ផ្សេងៗ ពាន់រៀល | នាឡិកាទឹក ពាន់រៀល | ការតភ្ជាប់បណ្តាញចូលផ្ទះ ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| *ថ្លៃដើម* | | | | | | | | | | | | | |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ១៧៦.៥៧៦.១៥៥ | ៤១៥.៩៨៦.៨៧០ | ១៣៧.៤៩៨.៨២៩ | ៧២៤.១១៦.៨៣២ | ៣.១២៣.៧០០ | ២៨.២៤៩.៥៦១ | ១៦៤.៦៧១.៥៩០ | ៤៩.៩៣៥.៦៨០ | ៤៥.៤៣៩.២៨៨ | ១៣.៥៨០.២៨៦ | ៣០.៣៩៤.០៣៣ | ១.០១៥.៨៨៨.៤០៦ | ២.៨០៥.៤៦១.២៣០ |
| ការទិញបន្ថែម | - | ៨៨.៥២៥ | ៣៦៨.៦៩០ | - | - | ១.៧៨៩.១៧៥ | ១.៣៣៤.៨២២ | ៧.៧៧៥.៣៥៧ | ៤៣០.២១៤ | - | - | ២៦៩.៧៥០.៩៩៣ | ២៨១.៥៣៧.៧៧៦ |
| ការផ្ទេរពីសន្និធិ | - | - | ៣.២៨១.៥៣៣ | ៤.៣៨៥ | ១៤៤.៦៣៣ | ៥៦.៨៤៩ | ១.២៦១.៤៣០ | ១១.០៨៨ | ២.៤៨៧.០៥៨ | ៥៤.៩៧៤ | - | ៦៤.៨៤១.៤៧៥ | ៧២.១៤៣.៤២៥ |
| ការផ្ទេរ | ២៣.៥៣៥.១៥៣ | ១.៥៩៣.៩៧៥ | ៧៨.៥៦៧ | ៦៧.៩២៧.០៣០ | - | - | ៨៦៤.៧៥៧ | ៣.៥០៥.៣១១ | ៤៥២.៩៣៣ | ៨៤៨.៥២១ | ៦.៥៣៧.៦១៦ | (១០៥.៣៤៣.៨៦៣) | - |
| ការលុបចេញពីបញ្ជី | - | (៤៤៨.០៩២) | (១.២៧៦.៩៩៧) | - | (៥៧.៦៦២) | (៨០២.៨១៩) | (៧២៧.៤៥៤) | (៦០៧.៤៧០) | (១.១៣១.៣១៤) | (៣.៧៤១) | - | (១.១៨៣.៧៨៥) | (៦.២៣៩.៣៣៤) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដូចដែលបានរាយការណ៍ពីមុន | ២០០.១១១.៣០៨ | ៤១៧.២២១.២៧៨ | ១៣៩.៩៥០.៦២២ | ៧៩២.០៤៨.២៤៧ | ៣.២១០.៦៧១ | ២៩.២៩២.៧៦៦ | ១៦៧.៤០៥.១៤៥ | ៦០.៦១៩.៩៦៦ | ៤៧.៦៧៨.១៧៩ | ១៤.៤៨០.០៤០ | ៣៦.៩៣១.៦៤៩ | ១.២៤៣.៩៥៣.២២៦ | ៣.១៥២.៩០៣.០៩៧ |
| ការធ្វើនិយ័តកម្មឆ្នាំមុន (កំណត់សម្គាល់លេខ ៣៧) | - | - | - | - | - | - | - | - | - | - | - | (៤៧៧.៥៧៦) | (៤៧៧.៥៧៦) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ កំណត់ឡើងវិញ | ២០០.១១១.៣០៨ | ៤១៧.២២១.២៧៨ | ១៣៩.៩៥០.៦២២ | ៧៩២.០៤៨.២៤៧ | ៣.២១០.៦៧១ | ២៩.២៩២.៧៦៦ | ១៦៧.៤០៥.១៤៥ | ៦០.៦១៩.៩៦៦ | ៤៧.៦៧៨.១៧៩ | ១៤.៤៨០.០៤០ | ៣៦.៩៣១.៦៤៩ | ១.២៤៣.៤៧៥.៦៥០ | ៣.១៥២.៤២៥.៥២ |
| ការទិញបន្ថែម | - | ២៣.១៧៩ | ១២០.២៤៥ | - | - | ២.០៧១.៩៥២ | ២១២.៤១១ | ១.៤៥៣.០៥២ | ១៧៥.៩៤០ | - | - | ៤៥៥.០៩២.៣៤៣ | ៤៥៩.១៤៩.១២ |
| ការផ្ទេរពីសន្និធិ | - | - | ២.៥១៤.២៧៩ | - | ២៧៧.១៥៧ | - | ២.៣៥២.២៤៧ | ៤.១០០.១១២ | ២.០៦៩.៦១៣ | ៨០៦.១៤៩ | ១០.៤៥៤.៧២០ | ២១.៩១៣.០៥៣ | ៤៤.៤៨៧.៣៣ |
| ការផ្ទេរ | - | ១.០០១.៦០២ | - | ៣០.៧៣៩.៣១១ | - | - | ២០៩.៧៤១ | - | ៥១៤.៩៣៥ | ៧៤១.០៥៦ | - | (៣៣.២០៦.៦៤៥) | |
| ការលុបចេញពីបញ្ជី | - | (៧៣.០០៩) | (៦៦២.៤៣៥) | - | - | (១.៥២៣.៣០៦) | (១.៧៦៩.២៧៤) | - | (៦១៨.៨៨៤) | - | - | - | (៤.៦៤៦.៩០ |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ២០០.១១១.៣០៨ | ៤១៨.១៧៣.០៥០ | ១៤១.៩២២.៧១១ | ៨២២.៧៨៧.៥៥៨ | ៣.៤៨៧.៨២៨ | ២៩.៨៤១.៤១២ | ១៦៨.៤១០.៣២០ | ៦៦.១៧៣.១៣០ | ៤៩.៨១៩.៧៨៣ | ១៦.០២៧.២៤៥ | ៤៧.៣៨៦.៣៦៩ | ១.៦៨៧.២៧៤.៣៩១ | ៣.៦៥១.៤១៥.១០ |

លេខបញ្ជីពាណិជ្ជកម្ម៖
Co. ០៨៣៩ Et/២០១២



## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

| | ដីធ្លី ពាន់រៀល | អគារ ពាន់រៀល | គ្រឿងយន្ត ពាន់រៀល | បំពង់បង្ហូរទឹក ពាន់រៀល | បរិក្ខារមន្ទីរពិសោធន៍ ពាន់រៀល | គ្រឿងសង្ហារឹម និង បរិក្ខារការិយាល័យ ពាន់រៀល | បរិក្ខារអគ្គិសនី ពាន់រៀល | យានយន្ត ពាន់រៀល | ពិន និង ឧបករណ៍ប្រើប្រាស់ផ្សេងៗ ពាន់រៀល | នាឡិកាទឹក ពាន់រៀល | ការតភ្ជាប់បណ្ដាញចូលផ្ទះ ពាន់រៀល | ការងារកំពុងដំណើរការ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| *រំលស់បង្គរ* | | | | | | | | | | | | | |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | - | ៩៣.៧៩៥.៧៧១ | ៧២.៦៦២.៦៥៧ | ២២៨.៦៣៦.២៤៥ | ១.១៩៤.៤៩៩ | ១៩.២២១.៥៥៥ | ១០៧.៣៨៥.៩៩៥ | ៤១.៦៩៩.៨០៨ | ២២.១៩០.៩៣៥ | ៩.៥១៧.២៩៣ | ៦.១១៤.៩៥៩ | - | ៦០២.៤១៩.៣១៧ |
| រំលស់ក្នុងឆ្នាំ | - | ៨.៩០៧.៣០៥ | ៧.២៨៨.៨០៤ | ២០.៤៧៩.២៨០ | ៣៦៤.៧១១ | ២.៥៧១.០១៩ | ៨.២៤០.៨០៥ | ៣.៧២៤.៤៥៣ | ៤.២៦៨.៧៦៦ | ១.៤៨៧.៨២៨ | ២.៧៨២.៣៩៨ | - | ៦០.១១៥.៣៦៩ |
| ការលុបចេញពីបញ្ជី | - | (១១០.២៣១) | (១.២២៣.៨០៤) | - | (៥៦.១៣៧) | (៧៨០.៣៦២) | (៧២៧.៤៥៤) | (៦០៧.៤៧០) | (១.១០១.៦៨០) | (៣.៧៤១) | - | - | (៤.៦១០.៨៧៩) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | - | ១០២.៥៩២.៨៤៥ | ៧៨.៧២៧.៦៥៧ | ២៤៩.១១៥.៥២៥ | ១.៥០៣.០៧៣ | ២១.០១២.២១២ | ១១៤.៨៩៨.៩៤៦ | ៤៤.៨១៦.៧៩១ | ២៥.៣៥៨.០២១ | ១១.០០១.៣៨០ | ៨.៨៩៧.៣៥៧ | - | ៦៥៧.៩២៣.៨០៧ |
| រំលស់ក្នុងឆ្នាំ | - | ៩.០២៨.០៦៣ | ៦.៥៦១.២២៤ | ១៧.៧៣៩.៧២៩ | ៣៩៣.១២៧ | ២.៤៦៣.៧៤៧ | ៨.៤៥៦.១៦០ | ៤.២១១.០៣៧ | ៤.៣៣៨.៥៩៥ | ១.៣៨៩.៣០៧ | ៣.៥២៦.៨៨៤ | - | ៥៨.១០៧.៨៧៣ |
| ការលុបចេញពីបញ្ជី | - | (៣៦.៨៧៦) | (៥៩៥.៦៦៥) | - | - | (១.៨៩២.៦៤៦) | (១.៥៣៦.៩៣០) | - | (៦១៨.៨៨៤) | - | - | - | (៤.២៨១.០០១) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | - | ១១១.៥៨៤.០៣២ | ៨៤.៦៩៣.២១៦ | ២៦៦.៨៥៥.២៥៤ | ១.៨៩៦.២០០ | ២១.៩៨៣.៣១៣ | ១២១.៨១៨.១៧៦ | ៤៩.០២៧.៨២៨ | ២៩.០៧៧.៧៣២ | ១២.៣៩០.៦៨៧ | ១២.៤២៤.២៤១ | - | ៧១១.៧៥០.៦៧៩ |
| *តម្លៃយោង* | | | | | | | | | | | | | |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ២០០.១១១.៣០៨ | ៣០៦.៥៨៩.០១៨ | ៥៧.២២៩.៤៩៥ | ៥៥៥.៩៣២.៣០៤ | ១.៥៩១.៦២៨ | ៧.៨៥៨.០៩៩ | ៤៦.៥៩២.១៤៤ | ១៧.១៤៥.៣០២ | ២០.៧៤២.០៥១ | ៣.៦៣៦.៥៥៨ | ៣៤.៩៦២.១២៨ | ១.៦៨៧.២៧៤.៣៩១ | ២.៩៣៩.៦៦៤.៤២៦ |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ២០០.១១១.៣០៨ | ៣១៤.៦២៨.៤៣៣ | ៦១.២២២.៩៦៥ | ៥៤២.៩៣២.៧២២ | ១.៧០៧.៥៩៨ | ៨.២៨០.៥៥៤ | ៥២.៥០៦.១៩៩ | ១៥.៨០៣.១៧៥ | ២២.៣២០.១៥៨ | ៣.៤៧៨.៦៦០ | ២៨.០៣៤.២៩២ | ១.២៤៣.៤៧៥.៦៥០ | ២.៤៩៤.៥០១.៧១៤ |

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

(ក) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ ត្រូវបានកត់ត្រាដំបូងតាមថ្លៃដើម។ ក្រោយការទទួលស្គាល់ដំបូង ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង់បង្គរពីការថយចុះតម្លៃផ្សេងៗ។

រំលស់ត្រូវបានគណនាដើម្បីជម្រះថ្លៃដើមនៃទ្រព្យសកម្មឱ្យនៅត្រឹមតម្លៃសំណល់របស់ខ្លួន តាមមូលដ្ឋានរំលស់ថេរ លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាន។ អាយុកាលរំលស់មានដូចខាងក្រោម៖

| | |
|---|---|
| អគារ | ៣០ ទៅ ៥០ឆ្នាំ |
| គ្រឿងយន្ត | ៣ ទៅ ២០ឆ្នាំ |
| បំពង់បង្ហូរទឹក | ៦ ទៅ ៥០ឆ្នាំ |
| បរិក្ខារ មន្ទីរពិសោធន៍ | ៦ ទៅ ៧ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារការិយាល័យ | ២ ទៅ ៧ឆ្នាំ |
| បរិក្ខារអគ្គិសនី | ២ ទៅ ២០ឆ្នាំ |
| យានយន្ត | ២ ទៅ ៧ឆ្នាំ |
| វ៉ាន និងឧបករណ៍ប្រើប្រាស់ផ្សេងៗ | ៣ ទៅ ១៥ឆ្នាំ |
| នាឡិកាទឹក | ៥ ទៅ ២០ឆ្នាំ |
| ការតភ្ជាប់បណ្តាញចូលផ្ទះ | ១២ឆ្នាំ |

ដីធ្លីមានអាយុកាលមិនកំណត់ និងមិនត្រូវបានធ្វើរំលស់ទេ។

ការសាងសង់កំពុងដំណើរការបង្ហាញ អំពីការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតថ្មី ការពង្រីកបណ្តាញបញ្ជូន និងចែកចាយ និងការជួសជុលឡើងវិញ។ ការសាងសង់កំពុងដំណើរការ មិនត្រូវបានគេធ្វើរំលស់ រហូតដល់ពេលដែលទ្រព្យសកម្មទាំងនោះសាងសង់រួចរាល់សម្រាប់ប្រើប្រាស់។

(ខ) នៅក្នុងអំឡុងការិយបរិច្ឆេទ រ.ទ.ស.ភ បានទូទាត់ប្រាក់ក្នុងការទិញ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---:|---:|
| ការទិញបន្ថែម | ៤៥៩.១៤៩.១២២ | ២៨១.៩៩៤.៧៩៩ |
| ការកើនឡើងក្នុងទឹកប្រាក់ត្រូវសងទៅអ្នកផ្គត់ផ្គង់ | (៦៤.២៧៤.២៥២) | (១៤.១១៧.៧៣៥) |
| មូលធនកម្មការប្រាក់លើទ្រព្យសកម្មមានលក្ខណៈគ្រប់គ្រាន់ | (៤.៩៧៨.០១៦) | (១១.៦៥០.៨៣២) |
| សាច់ប្រាក់ទូទាត់លើការទិញ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៣៨៩.៨៩៦.៨៥៤ | ២៥៦.២២៦.២៣២ |

## ៦. ទ្រព្យសកម្មអរូបី

| | ពាន់រៀល |
|---|---|
| ***ថ្លៃដើម*** | |
| **សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២៣** | ២៦.៧៥២.៨៧០ |
| ការទិញបន្ថែម | ២៣៦.២៥២ |
| ការលុបចេញពីបញ្ជី | (៦.៣១៥) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ២៦.៩៨២.៨០៧ |
| ការទិញបន្ថែម | ២៥.៤៧៤ |
| ការលុបចេញពីបញ្ជី | (២៥០.៨៨៦) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ២៦.៧៥៧.៣៩៥ |
| ***រំលស់បង្គរ*** | |
| **សមតុល្យថ្ងៃទី១ ខែមករាឆ្នាំ២០២៣** | ១៤.៦៦៣.២៨៣ |
| រំលស់ក្នុងឆ្នាំ | ១.៨៥៦.៤៥០ |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | ១៦.៥១៩.៧៣៣ |
| រំលស់ក្នុងឆ្នាំ | ១.១៥៧.១៥៥ |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ១៧.៦៧៦.៨៨៨ |
| ***តម្លៃយោង*** | |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២៤** | ៩.០៨០.៥០៧ |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ១០.៤៦៣.០៧៤ |

(ក) ទ្រព្យសកម្មអរូបីត្រូវបានវាស់វែងដំបូងតាមថ្លៃដើម។ ក្រោយការទទួលស្គាល់ដំបូង ទ្រព្យសកម្មអរូបីត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការថយចុះតម្លៃបង្គរប្រសិនបើមាន។

(ខ) ទ្រព្យសកម្មអរូបី រួមមានសូហ្វវែរគណនេយ្យ និងកម្មវិធីបណ្ដាញ ត្រូវបានធ្វើរំលស់ទៅលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានចំនួន ៧ ឆ្នាំដោយប្រើមូលដ្ឋានរំលស់ថេរ។

## ៧. សន្និធិ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| **ថ្លៃដើម** | | |
| បំពង់ចែកចាយទឹក និងបរិក្ខារភ្ជាប់ | ១០៨.៩៧២.៣៩២ | ២៣៦.៣៦៩.៧៨០ |
| នាឡិកាទឹក | ១០.២៤៤.៣៩៣ | ៧.៤២១.១៥៩ |
| គ្រឿងបន្លាស់ និងឧបករណ៍ផ្សេងៗ | ១១.៦៣១.១២០ | ៨.៨០៤.២៨២ |
| សារធាតុគីមី | ២.១៣៤.៤០៩ | ២.៥៤២.០៦០ |
| ធុងស្តុកទឹក និងកញ្ចប់ផ្សេងៗ | ១០០.២១៦ | ១០០.២១៦ |
| សន្និធិកំពុងបញ្ជូនមក(*) | ៧៣៣.៤៩៦ | ៤៨.៩៣៣.៨៥៣ |
| វត្ថុធាតុដើមផ្សេងៗ | ១០.៤១៩.៧៨៤ | ១៤.៥៧៥.២៤២ |
| | ១៤៤.២៣៥.៧៧០ | ៣១៨.៧៤៦.៥៩២ |

*សន្និធិកំពុងបញ្ជូនមក គឺបំពង់ទីប ដែលបានមកដល់កំពង់ផែនៃប្រទេសកម្ពុជា។

(ក) ថ្លៃដើមសន្និធិ ត្រូវបានកំណត់ដោយប្រើប្រាស់មូលដ្ឋានតម្លៃមធ្យមទម្ងន់ និងត្រូវបានកត់ត្រាតាមតម្លៃទាបជាងរវាងតម្លៃដើម និងតម្លៃសុទ្ធដែលទទួលបាន។

(ខ) ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ រ.ទ.ស.ភ បានទទួលស្គាល់ចំណាយចំនួន ២៥,២៧ពាន់លានរៀល (២០២៣៖ ២០,៦៩ពាន់លានរៀល)។

## ៨. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| **គណនីអតិថិជនពាណិជ្ជកម្ម** | | |
| គណនីត្រូវទទួលពីអ្នកប្រើប្រាស់តាមផ្ទះ | ៨៥៤.៨៩៧ | ២.៤២៩.៣៨១ |
| គណនីត្រូវទទួលពីអ្នកប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម | ១.២៧០.៣០០ | ១.៦៧៣.៦៩៦ |
| គណនីត្រូវទទួលពីគ្រឹះស្ថានសាធារណៈ | ៥.៣៤២.៥១៦ | ៤.៤៧៦.៧៣៤ |
| គណនីត្រូវទទួលពីអ្នកចែកចាយទឹកស្អាត | ៦០.០៩៦ | ២២១.៥០៨ |
| ដក៖ ខាតបង់ពីការថយចុះតម្លៃ (អ្នកប្រើប្រាស់តាមផ្ទះ) | (៥.៥៥៣) | (៥.៥៥៣) |
| | ៧.៥២២.២៥៦ | ៨.៧៩៥.៧៦៦ |
| **គណនីត្រូវទទួលផ្សេងៗ** | | |
| ការប្រាក់ត្រូវទទួល | ១.៣២៣.៦៦៣ | ២.៧៣៦.១៤៦ |
| គណនីត្រូវទទួលផ្សេងៗ | ៦.៣៩៩.៩៨៦ | ៥.៤៩១.៩០៧ |
| | ៧.៧២៣.៦៤៩ | ៨.២២៨.០៥៣ |
| **គណនីត្រូវទទួលសរុប** | ១៥.២៤៥.៩០៥ | ១៧.០២៣.៨១៩ |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ១២.២៩២.០២២ | ៦៤០.២៧៧ |
| | ២៧.៥៣៧.៩២៧ | ១៧.៦៦៤.០៩៦ |

## ៨. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ (ត)

(ក) គណនីត្រូវទទួលសុបត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) គណនីអតិថិជនពាណិជ្ជកម្ម គឺជាគណនីមិនមានការប្រាក់ ហើយរយៈពេលនៃការកំណត់សងដែលផ្តល់ដោយ រ.ទ.ស.ភ ទៅអតិថិជនដែលជាអ្នកប្រើប្រាស់តាមផ្ទះ មានរយៈពេលមួយខែ (២០២៣៖ មួយខែ) ហើយសម្រាប់ស្ថាប័នរដ្ឋាភិបាលមានរយៈពេលមួយឆ្នាំ (២០២៣៖ មួយឆ្នាំ)។

(គ) អតិថិជនដែលជាគ្រឹះស្ថានសាធារណៈ គឺទាក់ទងទៅនឹងថ្លៃទឹកត្រូវបានទទួលបានពីស្ថាប័នរដ្ឋាភិបាល ដែលស្ថាប័នទាំងនោះពុំមានប្រវត្តិមិនសងប្រាក់សម្រាប់ពេលថ្មីៗនេះទេ។

(ឃ) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់គណនីត្រូវទទួល មានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| រៀលខ្មែរ | ១៥.៩៨០.១៥៦ | ១៧.០២៣.៨១៩ |
| ដុល្លារអាមេរិក | ១១.៥៥៧.៧៧១ | ៦៤០.២៧៧ |
| | ២៧.៥៣៧.៩២៧ | ១៧.៦៦៤.០៩៦ |

(ង) ចំពោះការថយចុះតម្លៃនៃគណនីអតិថិជនពាណិជ្ជកម្ម និងកិច្ចសន្យាទ្រព្យសកម្ម ដែលមិនមានសមាសធាតុហិរញ្ញប្បទានគួរឱ្យកត់ សម្គាល់ រ.ទ.ស.ភ បានអនុវត្តវិធីសាស្ត្រសាមញ្ញ (Simplified approach) នៃ ស.រ.ហ.អ.ក ៩ ដើម្បីវាស់វែងការខាតបង់ឥណទានរំពឹងទុក ដោយប្រើប្រាស់សំវិធានធននៃការខាតបង់ឥណទានរំពឹងទុកសរុបសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម និងកិច្ចសន្យាទ្រព្យសកម្ម។ ដើម្បីវាស់វែងការខាតបង់ឥណទានរំពឹងទុកដែលផ្អែកលើមូលដ្ឋាន រួមទូទៅគណនីអតិថិជនពាណិជ្ជកម្ម និងកិច្ចសន្យាទ្រព្យសកម្ម ត្រូវបានចាប់ជាក្រុមដោយផ្អែកលើ ហានិភ័យឥណទាន និងអាយុកាលប្រហាក់ប្រហែលគ្នា។ អត្រាខាតបង់ដែលរំពឹងទុក គឺបានផ្អែកលើបទពិសោធន៍នៃការខាតបង់ឥណទានរបស់ រ.ទ.ស.ភ។ ប្រវត្តិនៃអត្រាខាតបង់ គឺត្រូវបានកែតម្រូវសម្រាប់ពេលបច្ចុប្បន្ន និងព័ត៌មានដែលមើលទៅមុខដោយផ្អែកលើកត្តាម៉ាក្រូសេដ្ឋកិច្ចដែលប៉ះពាល់ដល់អតិថិជនរបស់ រ.ទ.ស.ភ ។

គណៈគ្រប់គ្រង បានអនុវត្តការវិនិច្ឆ័យយ៉ាងសំខាន់ក្នុងការកំណត់ប្រូបាប៊ីលីតេនៃភាពមិនអាចទូទាត់សងរបស់គណនីអតិថិជនពាណិជ្ជកម្ម និងព័ត៌មានដែលមើលទៅមុខបានសមរម្យ។

នៅចុងបញ្ចប់នៃរយៈពេលរាយការណ៍នីមួយៗ ការប្រឈមហានិភ័យឥណទាន និងការផ្តោតអារម្មណ៍ទាក់ទងនឹងគណនីអតិថិជនពាណិជ្ជកម្មរបស់ រ.ទ.ស.ភ ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ការប៉ះពាល់អតិបរមា | ៧.៥២២.២៥៦ | ៨.៧៩៥.៧៦៦ |
| ទ្រព្យធានាដែលមាន (ប្រាក់កក់ពីអតិថិជន) | (៧.៥២២.២៥៦) | (៨.៧៩៥.៧៦៦) |
| ការប្រឈមសុទ្ធទៅនឹងហានិភ័យឥណទាន | - | - |

ក្នុងអំឡុងការិយបរិច្ឆេទ រ.ទ.ស.ភ ពុំបានចរចារឡើងវិញអំពីលក្ខខណ្ឌនៃគណនីអតិថិជនពាណិជ្ជកម្មទេ។

## ៨. គណនីអតិថិជនពាណិជ្ជកម្ម និង គណនីត្រូវទទួលផ្សេងៗ (ត)

(ច) បម្រែបម្រួលសំវិធានធនលើការថយចុះតម្លៃសម្រាប់គណនីអតិថិជនមានដូចខាងក្រោម៖

| | សំវិធានធន ជាក់លាក់ ពាន់រៀល | សំវិធានធន សរុប ពាន់រៀល |
|---|---|---|
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣/ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | ៥.៥៥៣ | ៥.៥៥៣ |
| គិតបន្ថែមសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុ | - | - |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣/ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | ៥.៥៥៣ | ៥.៥៥៣ |

សំវិធានធនជាក់លាក់សំដៅទៅលើ កូនបំណុលដែលបានកំណត់ជាលក្ខណៈបុគ្គលដែលជួបការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងច្រើនហើយបានខកខានមិនបានបង់ការទូទាត់ ដែលនឹងត្រូវធ្វើសំវិធានធននៅចុងការិយបរិច្ឆេទ។

(ឆ) ការថយចុះតម្លៃសម្រាប់គណនីត្រូវទទួលផ្សេងៗ និងឥណទានផ្តល់ឱ្យបុគ្គលិក ត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទូទៅ (General approach) របស់ ស.រ.ហ.អ.ក ៩ ដោយប្រើប្រាស់គំរូនៃការខាតបង់ឥណទានរំពឹងទុកដែលមើលទៅមុខ (Forward looking expected credit loss model)។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់ដើម្បីកំណត់ចំនួនទឹកប្រាក់នៃការថយចុះតម្លៃ ដោយផ្អែកថាតើ មានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងហានិភ័យ ឥណទានដែរចាប់តាំងពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុឬទេ ។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុទាំងឡាយ ដែលហានិភ័យឥណទានមិនបានកើនឡើងខ្លាំងចាប់តាំងពីការទទួលស្គាល់ដំបូង នោះការខាតបង់ឥណទានរំពឹងទុកក្នុងរយៈពេល ១២ខែ រួមជាមួយចំណូលការប្រាក់ដុលត្រូវបានទទួលស្គាល់។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលហានិភ័យឥណទានបានកើនឡើងគួរឱ្យកត់សម្គាល់នោះ ការខាតបង់ឥណទានដែលរំពឹងទុកសរុប (Lifetime expected credit loss) រួមជាមួយចំណូលការប្រាក់ដុលត្រូវបានទទួលស្គាល់។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានកំណត់ជាឥណទានមានការថយចុះតម្លៃ ការខាតបង់ឥណទានដែលរំពឹងទុកសរុប រួមជាមួយចំណូលការប្រាក់លើមូលដ្ឋានសុទ្ធ ត្រូវបានទទួលស្គាល់។

## ៩. កិច្ចសន្យាទ្រព្យសកម្ម/(បំណុល)

| | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល (កំណត់ឡើងវិញ) |
|---|---|---|
| **កិច្ចសន្យាទ្រព្យសកម្ម** | | |
| គណនីត្រូវទទួលពីសេវាសាងសង់ | ៤.៣៩៨.៥៦៤ | ៧.៦២៤.៣៣៩ |
| ចំណូលបង្ករពីការលក់ទឹកស្អាត | ៣៣.១៨៧.៦២៦ | ៣១.០០៤.១៣៨ |
| | ៣៧.៥៨៦.១៩០ | ៣៨.៦២៨.៤៧៧ |
| **កិច្ចសន្យាបំណុល** | | |
| ចំណូលពន្យារ | (៥.២៧៨) | (៥.២៧៨) |
| ចំណូលមិនទាន់ទទួលស្គាល់ | (៣.៥២០.៣៩៥) | (៤.២៤៨.៨៦០) |
| | (៣.៥២៥.៦៧៣) | (៤.២៥៤.១៣៨) |
| | ៣៤.០៦០.៥១៧ | ៣៤.៣៧៤.៣៣៩ |

## ៩. កិច្ចសន្យាទ្រព្យសកម្ម/(បំណុល) (ត)

(ក) គណនីត្រូវទទួលពីសេវាកម្មសាងសង់ និងចំណូលពន្យារ

គណនីត្រូវទទួលពីសេវាកម្មសាងសង់ និងចំណូលពន្យារតំណាងឱ្យភាពខុសគ្នានៃពេលវេលាក្នុងការទទួលស្គាល់ប្រាក់ចំណូល និងវិក្កយបត្រសំខាន់ៗ។ វិក័យបត្រសំខាន់ៗត្រូវបានរៀបចំឡើង និង/ឬចរចារជាមួយអតិថិជនដើម្បីឆ្លុះបញ្ចាំងពីការបញ្ចប់នៃកិច្ចសន្យាជាក់ស្តែង។

គណនីត្រូវទទួលពីសេវាកម្មសាងសង់ ត្រូវបានផ្ទេរទៅឱ្យគណនីត្រូវទទួលនៅពេលដែលសិទ្ធិទទួលបានផលប្រយោជន៍សេដ្ឋកិច្ចដោយគ្មានលក្ខខណ្ឌ។ ជាធម្មតាវាកើតឡើងនៅពេលដែល រ.ទ.ស.ភ ចេញវិក្កយបត្រជូនអតិថិជន។ កិច្ចសន្យាបំណុល ត្រូវបានទទួលស្គាល់ជាចំណូលនៅពេលកាតព្វកិច្ចនៃការអនុវត្តត្រូវបានបំពេញ។

ចំណូលពន្យារ គឺតំណាងឱ្យប្រាក់ដែលទទួលបានមុន សម្រាប់សេវាកម្មសាងសង់ដែលទាក់ទងនឹងការពង្រីកប្រព័ន្ធចែកចាយទឹកទៅកាន់អ្នកចែកចាយទឹកនៅតាមបណ្តាខេត្តផ្សេងៗ។ ចំណូលពន្យារត្រូវបានទទួលស្គាល់ជាចំណូលនៅពេលកាតព្វកិច្ចត្រូវបានបំពេញ។

(ខ) ចំណូលបង្ករពីការលក់ទឹកស្អាត

ចំណូលបង្ករពីការលក់ទឹកស្អាតតំណាងឱ្យទឹកដែលបានផ្គត់ផ្គង់ទៅដល់អតិថិជន ប៉ុន្តែមិនទាន់បានចេញវិក្កយបត្រនៅចុងឆ្នាំ។ កិច្ចសន្យាទ្រព្យសកម្មទាំងនេះត្រូវបានផ្ទេរទៅឱ្យគណនីត្រូវទទួលនៅពេលដែលសិទ្ធិទទួលបានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចឥតលក្ខខណ្ឌ ដែលកើតឡើងនៅពេលដែល រ.ទ.ស.ភ ចេញវិក្កយបត្រ។

(គ) បម្រែបម្រួលជាសារវន្តនៃសមតុល្យកិច្ចសន្យា

| | គណនីត្រូវទទួលពី សេវាសាងសង់ ពាន់រៀល | ចំណូលបង្ករពីការ លក់ទឹកស្អាត ពាន់រៀល | ចំណូល មិនទាន់ទទួលស្គាល់ ពាន់រៀល |
|---|---|---|---|
| **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ (កំណត់ឡើងវិញ)** | ៣.៥៣៣.៨៩៧ | ២៨.៥០៧.៣៥៤ | ៤.៤៥១.៤៧៨ |
| ការកើនឡើងដោយសារការទទួលស្គាល់ថ្លៃសេវាសំណង់មិនទាន់ចេញវិក្កយបត្រ/ការលក់ទឹកស្អាតដល់អតិថិជន | ១៤.៨៥៥.៥៣៩ | ៣១០.១០៤.៧១៧ | - |
| ការចេញវិក្កយបត្រ | (១០.៧៦៤.០៩៧) | (៣០៧.៦០៧.៩៣៣) | (២០២.៦១៨) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (កំណត់ឡើងវិញ)** | ៧.៦២៤.៣៣៩ | ៣១.០០៤.១៣៨ | ៤.២៤៨.៨៦០ |
| ការកើនឡើងដោយសារការទទួលស្គាល់ថ្លៃសេវាសំណង់មិនទាន់ចេញវិក្កយបត្រ/ការលក់ទឹកស្អាតដល់អតិថិជន | ១១.៣៩២.១១២ | ៣០២.១៧២.៩២៣ | ១.៣៣១.១៩២ |
| ការចេញវិក្កយបត្រ | (១៤.៦១៧.៨៨៧) | (២៩៩.៩៨៩.៤៣៥) | (២.០៥៩.៦៥៧) |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ៤.៣៩៨.៥៦៤ | ៣៣.១៨៧.៦២៦ | ៣.៥២០.៣៩៥ |

## ៩. កិច្ចសន្យាទ្រព្យសកម្ម/(បំណុល) (ត)

(ឃ) តម្លៃនៃកិច្ចសន្យាមិនទាន់ត្រូវបានទទួលស្គាល់ជាចំណូល

ប្រាក់ចំណូលដែលត្រូវបានគេរំពឹងថានឹងត្រូវទទួលស្គាល់នៅពេលអនាគត ទាក់ទងទៅនឹងកាតព្វកិច្ចនៃការអនុវត្តដែលមិនទាន់បានបំពេញ (ឬបានបំពេញខ្លះ) នៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នេះមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | - | ៣.៥២០.៣៩៥ | ៣.៥២០.៣៩៥ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៤.២៤៨.៨៦០ | - | ៤.២៤៨.៨៦០ |

(ង) រ.ទ.ស.ភ បានអនុវត្ត ស.រ.ហ.អ.ក ៩ វិធីសាស្ត្រសាមញ្ញ (Simplified approach) ក្នុងការវាស់វែងការខាតបង់ឥណទានរំពឹងទុក ដោយប្រើសំវិធានធនឥណទានបាត់បង់រយៈពេលវែងដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

(ច) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់កិច្ចសន្យាទ្រព្យសកម្ម និងកិច្ចសន្យាបំណុលមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| **កិច្ចសន្យាទ្រព្យសកម្ម** | | |
| រៀលខ្មែរ | ៣៣.១៨៧.៦២៦ | ៣១.០០៤.១៣៨ |
| ដុល្លារអាមេរិក | ៤.៣៩៨.៥៦៤ | ៧.៦២៤.៣៣៩ |
| | ៣៧.៥៨៦.១៩០ | ៣៨.៦២៨.៤៧៧ |
| **កិច្ចសន្យាបំណុល** | | |
| រៀលខ្មែរ | ៥.២៧៨ | ៥.២៧៨ |
| ដុល្លារអាមេរិក | ៣.៥២០.៣៩៥ | ៤.២៤៨.៨៦០ |
| | ៣.៥២៥.៦៧៣ | ៤.២៥៤.១៣៨ |

## ១០. ឥណទានផ្តល់ឱ្យបុគ្គលិក

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ទឹកប្រាក់ត្រូវទទួលពីបុគ្គលិក | ៣.៨៩៤.៥៨៩ | ៨.២១៧.៥២៥ |
| ដក៖ ការថយចុះតម្លៃលើឥណទានផ្តល់ឱ្យបុគ្គលិក | - | (២៦០.៨៧៤) |
| | ៣.៨៩៤.៥៨៩ | ៧.៩៥៦.៦៥១ |

(ក) ឥណទានផ្តល់ឱ្យបុគ្គលិកត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់។

## ១០. ឥណទានផ្តល់ឱ្យបុគ្គលិក (ត)

(ខ) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តភាគហ៊ុនដែលនឹងបោះផ្សាយលក់ចំនួន ១០% បម្រុងសម្រាប់បុគ្គលិករបស់ រ.ទ.ស.ភ។ កាលបរិច្ឆេទបែងចែកចំនួនភាគហ៊ុនជូនបុគ្គលិកនីមួយៗ ត្រូវបានកំណត់នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ដែលត្រូវបានចាត់ទុកថាជាការបរិច្ឆេទផ្តល់គម្រោងភាគហ៊ុនរបស់បុគ្គលិក។ ទឹកប្រាក់ឥណទានសរុបមានចំនួន ៨.២១៨លានរៀល ត្រូវបានផ្តល់ឱ្យខ្ចីនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២។ រ.ទ.ស.ភ ផ្តល់ឥណទានដល់បុគ្គលិក និងមន្ត្រីជាន់ខ្ពស់ដើម្បីទិញភាគហ៊ុនទាំងនេះក្នុងរយៈពេលបីឆ្នាំដោយមិនគិតការប្រាក់។ នៅថ្ងៃកំណត់ឥណទាននេះត្រូវសងវិញទាំងស្រុងជូន រ.ទ.ស.ភ។ យោងតាមកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ បុគ្គលិកទាំងអស់ត្រូវបានអនុញ្ញាតឱ្យជួញដូរភាគហ៊ុនរបស់ខ្លួនបាន នៅពេលដែលឥណទាននេះបានទូទាត់សងរួចរាល់។ រ.ទ.ស.ភ បានបង្កើតគណនីបណ្តោះអាសន្ននៅប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីកាន់កាប់មូលបត្រកម្មសិទ្ធិរបស់អភិបាល និងមន្ត្រី-និយោជិតចំនួន ៥២៩ រូបសរុបជាភាគហ៊ុនចំនួន ១.៣០៤.៣៩៦ ភាគហ៊ុន ដូចមានចែងក្នុងវិញ្ញាបនបត្របញ្ញើមូលបត្រលេខ ១៨៥/១២ ចេញដោយផ្សារមូលបត្រកម្ពុជា ("ផ.ម.ក")។

នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ រ.ទ.ស.ភ បានដាក់សំណើរទៅនិយ័តករមូលបត្រកម្ពុជា ("ន.ម.ក") សម្រាប់ការអនុម័តលើការផ្ទេរកម្មសិទ្ធិភាគហ៊ុនដែលកាន់កាប់បច្ចុប្បន្ននៅក្រោមឈ្មោះរបស់ រ.ទ.ស.ភ ទៅកាន់មន្ត្រីជាន់ខ្ពស់ និងបុគ្គលិកចំនួន ៣៩៦ រូប។ ការអនុញ្ញាតការផ្ទេរកម្មសិទ្ធិនេះ គឺចាំបាច់សម្រាប់ រ.ទ.ស.ភ ដើម្បីបន្តជំហានបន្ទាប់ជាមួយ ផ.ម.ក។ អភិបាល និងមន្ត្រី-និយោជិតចំនួន ១៣៣ រូប ដែលមានភាគហ៊ុនសរុបចំនួន ៤៩៨.៨៣៩ ភាគហ៊ុន គឺជានិវត្តជន ស្លាប់ ឬមិនអាចទាក់ទងបាន ដោយរក្សានៅក្រោមគណនីបណ្តោះអាសន្ន ដើម្បីរង់ចាំដំណោះស្រាយ។ ន.ម.ក បានអនុម័តតាមសំណើរបស់ រ.ទ.ស.ភ តាមរយៈលិខិតជាផ្លូវការចេញនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤។

នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៤ នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សបានប្រកាសជាផ្លូវការដល់អភិបាល និងមន្ត្រី-និយោជិតដែលពាក់ព័ន្ធ អំពីការទូទាត់ប្រាក់កម្ចីដែលនឹងត្រូវធ្វើឡើង តាមរយៈការទូទាត់ជាមួយប្រាក់បៀវត្សរ៍ ដែលនឹងចាប់ផ្តើមពីខែមិថុនា ឆ្នាំ២០២៤ តទៅ។

យោងតាមលិខិតយល់ព្រមពី ន.ម.ក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ រ.ទ.ស.ភ បានដាក់សំណើទៅកាន់ ផ.ម.ក ដើម្បីផ្ទេរគណនីជួញដូរទៅបុគ្គលិករបស់ខ្លួន។ ក្នុងនោះមានតែមន្ត្រី និយោជិត ៣៩០រូប ប៉ុណ្ណោះដែលមានសិទ្ធិទទួលបានការផ្ទេរនេះ ចំណែកចំនួន ៦ រូបដែលនៅសល់ ដែលកាន់កាប់ភាគហ៊ុនសរុបចំនួន ១៨.៤៨៧ បដិសេធមិនព្រមទូទាត់ តាមរយៈការទូទាត់ជាមួយប្រាក់បៀវត្សរ៍ ចូលនិវត្តន៍ ឬស្លាប់។

នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ រ.ទ.ស.ភ បានបញ្ចប់ការអនុវត្តនីតិវិធីផ្ទៃក្នុង ក្នុងការផ្ទេរភាគហ៊ុនចំនួន ៧៨៧.០៤៣ ពីគណនីបណ្តោះអាសន្នទៅកាន់គណនីជួញដូររបស់អភិបាល និងមន្ត្រី-និយោជិតចំនួន ៣៩០ រូប។

(គ) រ.ទ.ស.ភ បានអនុវត្តវិធីសាស្ត្រទូទៅ (General approach) របស់ ស.រ.ហ.អ.ក ៩ ដើម្បីវាស់វែងការខាតបង់នៃឥណទានរំពឹងទុក ដោយប្រើគំរូនៃការខាតបង់នៃឥណទានដែលរំពឹងទុកដែលមើលទៅមុខ (Forward looking expected credit loss model) ដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ ៨ នៃរបាយការណ៍ហិរញ្ញវត្ថុ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ តម្លៃភាគហ៊ុនបានកើនឡើង ហើយគណៈគ្រប់គ្រងបានសម្រេចចិត្តធ្វើការប្រែត្រឡប់នៃការថយចុះតម្លៃដែលមានតម្លៃប្រហែល ២៦១ លានរៀល (២០២៣៖ គ្មាន) នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ១០. ឥណទានផ្តល់ឱ្យបុគ្គលិក (ត)

(ឃ) នៅចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍នីមួយៗ ហានិភ័យឥណទាន និងការផ្តោតអារម្មណ៍ទាក់ទងនឹងឥណទានផ្តល់ឱ្យបុគ្គលិករបស់ រ.ទ.ស.ភ ត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០១២៣<br>ពាន់រៀល |
|---|---|---|
| ការប៉ះពាល់អតិបរមា | ៣.៨៩៤.៥៨៩ | ៧.៩៥៦.៦៥១ |
| ទ្រព្យធានាដែលមាន | (៣.៨៩៤.៥៨៩) | (៧.៩៥៦.៦៥១) |
| ផលប៉ះពាល់សុទ្ធចំពោះហានិភ័យឥណទាន | - | - |

(ង) បម្រែបម្រួលសំវិធានធនលើការថយចុះតម្លៃនៃឥណទានផ្តល់ឱ្យបុគ្គលិកមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ២៦០.៨៧៤ | ២៦០.៨៧៤ |
| ការប្រែត្រលប់នៃការថយចុះតម្លៃ | (២៦០.៨៧៤) | - |
| នាថ្ងៃទី៣១ ខែធ្នូ | - | ២៦០.៨៧៤ |

## ១១. ការវិនិយោគរយៈពេលខ្លី

(ក) ការវិនិយោគរយៈពេលខ្លី ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) ការវិនិយោគរយៈពេលខ្លី រួមមានប្រាក់បញ្ញើដែលមានទឹកប្រាក់ចំនួន ៩៤,៩ពាន់លានរៀល (២០២៣៖ ១២៧,៣ពាន់លានរៀល) បង្កើតឡើងជាពិសេសសម្រាប់គោលបំណងនៃការទទួលការប្រាក់ និងសម្រាប់វិធានការប្រុងប្រយ័ត្ន និងសកម្មភាពបាន់ស្មាន។

(គ) ការវិនិយោគរយៈពេលខ្លី គឺជាប្រាក់បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់រយៈពេលប្រាំបួនខែ ទៅដប់ពីរខែ (២០២៣៖ ប្រាំបួនខែ ទៅដប់ពីរខែ) និងទទួលបានការប្រាក់ពី ៣,៥០% ទៅ ៥,២៥% (២០២៣៖ ៣,៥០% ទៅ ៦,៧៥%) ក្នុងមួយឆ្នាំ។

(ឃ) អត្រាការប្រាក់មធ្យមទម្ងន់ដែលមានប្រសិទ្ធភាព នៃការដាក់ប្រាក់បញ្ញើជាមួយធនាគារមានអាជ្ញាបណ្ណរបស់ រ.ទ.ស.ភ នៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នីមួយៗមានដូចខាងក្រោម៖

| | អត្រាការប្រាក់មធ្យមទម្ងន់ ដែលមានប្រសិទ្ធភាពប្រចាំឆ្នាំ<br>% | នៅក្នុងអំឡុងពេល ១ឆ្នាំ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | |
| អត្រាថេរ | ៤,៥៧ | ៩៤.៩៦១.៣៦០ | ៩៤.៩៦១.៣៦០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | |
| អត្រាថេរ | ៦,០២ | ១២៧.៣១៦.០០៣ | ១២៧.៣១៦.០០៣ |

## ១១. ការវិនិយោគរយៈពេលខ្លី (ត)

(ង) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់ការវិនិយោគរយៈពេលខ្លីមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ខ្មែររៀល | ៣០.០០០.០០០ | ៣៥.០០០.០០០ |
| ដុល្លារអាមេរិក | ៦៤.៩៦១.៣៦០ | ៩២.៣១៦.០០៣ |
| | ៩៤.៩៦១.៣៦០ | ១២៧.៣១៦.០០៣ |

## ១២. សមតុល្យសាច់ប្រាក់ និងធនាគារ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| សាច់ប្រាក់ក្នុងដៃ | ១៩៦.៨២០ | ៣៣៥.០៧១ |
| សាច់ប្រាក់នៅធនាគារ | ១៨.២០៩.៨៤៦ | ២២.៧៥៣.៤៩៩ |
| | ១៨.៤០៦.៦៦៦ | ២៣.០៨៨.៥៧០ |

(ក) សមតុល្យសាច់ប្រាក់ និងធនាគារ ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់សមតុល្យសាច់ប្រាក់ និងធនាគារមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ខ្មែររៀល | ១៧.០៣៣.៣៧៩ | ១៨.៩១៩.៩៩០ |
| ដុល្លារអាមេរិក | ១.៣៧៣.២៨៧ | ៤.១៦៨.៥៨០ |
| | ១៨.៤០៦.៦៦៦ | ២៣.០៨៨.៥៧០ |

(គ) អត្រាការប្រាក់មធ្យមទម្ងន់ដែលមានប្រសិទ្ធភាព នៃការដាក់ប្រាក់បញ្ញើជាមួយធនាគារមានអាជ្ញាបណ្ណរបស់ រ.ទ.ស.ភ នៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នីមួយៗមានដូចខាងក្រោម៖

| | ២០២៤<br>% | ២០២៣<br>% |
|---|---|---|
| អត្រាថេរ | ១,៦៥ | ១,៥០ |

## ១៣. ដើមទុន

| | ភាគហ៊ុនធម្មតា ចំនួន | ភាគហ៊ុនធម្មតា ពាន់រៀល | ភាគហ៊ុនប្រភេទ "ក" ចំនួន | ភាគហ៊ុនប្រភេទ "ក" ពាន់រៀល | បុព្វលាភភាគហ៊ុន ពាន់រៀល | ទុនបម្រុង ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|---|---|
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៣៩១.១០១.៩៤២ | ៣៩១.១០០.៩៤២ | ៦៣.១៥៣.១៧៨ | ៧៩.៥៣១.៨២៥ | ៦២០.៧៥៩.១០៧ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៣ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ | ៣៩១.១០០.៩៤២ | ៣៩១.១០០.៩៤២ | ៦៣.១៥៣.១៧៨ | ៧៩.៥៣១.៨២៥ | ៦២០.៧៥៩.១០៧ |

(ក) នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យបំបែកដើមទុនដែលមានទាំងអស់ចំនួន ៤៦៥.០២៨.០០០រៀល ទៅជាភាគហ៊ុនធម្មតាចំនួន ៧៣.៩២៧.១៨៧ ភាគហ៊ុន និងភាគហ៊ុនប្រភេទ (ក) ចំនួន ៣៩១.១០០.៩៤២ភាគហ៊ុន ដែលក្នុងមួយហ៊ុន មានតម្លៃចារឹក ១.០០០រៀល។ ភាគហ៊ុនប្រភេទ (ក) មិនបានទទួលការប្រាក់ ឬភាគលាភទេ ហើយមានសិទ្ធិ និងលក្ខខណ្ឌដូចមានលម្អិតនៅក្នុងមាត្រា ១២.២ នៃលក្ខន្តិកៈចុះនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២។

(ខ) នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ រ.ទ.ស.ភ បានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជាដោយជោគជ័យ។ រ.ទ.ស.ភ គឺជាក្រុមហ៊ុនដំបូងគេក្នុងផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនធម្មតាសរុបចំនួន ៨៦.៩៧៣.១៦២ ភាគហ៊ុន ដែលក្នុងមួយហ៊ុនមានតម្លៃចារឹក ១.០០០រៀល។ ថ្លៃដើមក្នុងការចេញផ្សាយភាគហ៊ុនថ្មី ចំនួន ១៣.០៤៥.៩៧៥ភាគហ៊ុន មានទឹកប្រាក់ចំនួន ៦.០០០លានរៀល ត្រូវបានកាត់កងជាមួយនឹងបុព្វលាភភាគហ៊ុន។

(ខ) រាល់ភាគហ៊ុនដែលបានចេញផ្សាយទាំងអស់ត្រូវបានបង់ប្រាក់រួចរាល់ទាំងស្រុង។ សេចក្តីលម្អិតអំពីភាគហ៊ុនធម្មតាមានដូចខាងក្រោម៖

| ភាគហ៊ុនិក | ចំនួនភាគហ៊ុន | % |
|---|---|---|
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ៧៣.៩២៧.១៨៧ | ៨៥% |
| ភាគហ៊ុនិកដទៃទៀត | ១២.៥៤៧.១៣៦ | ១៤% |
| គម្រោងភាគហ៊ុនរបស់បុគ្គលិក* | ៤៩៨.៨៣៩ | ១% |
| | ៨៦.៩៧៣.១៦២ | ១០០% |

* យោងតាមកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ បុគ្គលិកទាំងអស់ត្រូវបានអនុញ្ញាតឱ្យជួញដូរភាគហ៊ុនរបស់ខ្លួនបាន នៅពេលដែលពួកគេសងឥណទានរួចរាល់។

(គ) នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ ក.ស.ហ.វ បានបង្កើនដើមទុនរបស់ខ្លួននៅ រ.ទ.ស.ភ ដោយបណ្តាក់ទុនបន្ថែមតាមរយៈទ្រព្យសកម្ម បំណុល និងមូលធន សម្រាប់ប្រតិបត្តិការរោងចក្រផលិតទឹកស្អាតខេត្តត្បូងឃ្មុំ ហៅកាត់ថា ("គម្រោងខេត្តត្បូងឃ្មុំ ") ទៅឱ្យ រ.ទ.ស.ភ ដែលមានទឹកប្រាក់សរុបចំនួន ៧៨.០៨៨.៦០៤.០០០រៀល ដោយពុំមានការបោះផ្សាយភាគហ៊ុនបន្ថែមរបស់ រ.ទ.ស.ភ ទេ។

## ១៤. ទុនបម្រុង

| | ទុនបម្រុង ដើមទុន ពាន់រៀល | ទុនបម្រុង តាមច្បាប់ ពាន់រៀល | ទុនបម្រុង ទូទៅ ពាន់រៀល | ទុនបម្រុង សម្រាប់ការអភិវឌ្ឍ ពាន់រៀល | សរុប ពាន់រៀល |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ដូចដែលបានរាយការណ៍ពីមុន** | ១.៦៤៨.៤៣៥ | ៣៨.៥៨១.៦៧១ | ៣៨.៥៨១.៦៧១ | ៤៦៤.៤៥៦.២៩៨ | ៥៤៣.២៦៨.០៧៥ |
| ផ្ទេរពី/(ទៅ)ប្រាក់ចំណេញរក្សាទុក៖ | | | | | |
| - ដូចដែលបានរាយការណ៍ពីមុន | - | ៥.៤០៩.២៩៤ | ៥.៤០៩.២៩៤ | ៩៣.០៦២.១១៩ | ១០៣.៨៨០.៧០៧ |
| - ការធ្វើនិយ័តកម្មឆ្នាំមុន (កំណត់សម្គាល់លេខ ៣៧) | - | - | - | (៥៥.៩៥៦.១១៦) | (៥៥.៩៥៦.១១៦) |
| កំណត់ឡើងវិញ | - | ៥.៤០៩.២៩៤ | ៥.៤០៩.២៩៤ | ៣៧.១០៦.០០៣ | ៤៧.៩២៤.៥៩១ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣/ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ (កំណត់ឡើងវិញ)** | ១.៦៤៨.៤៣៥ | ៤៣.៩៩០.៩៦៥ | ៤៣.៩៩០.៩៦៥ | ៥០១.៥៦២.៣០១ | ៥៩១.១៩២.៦៦៦ |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុក | - | ៦.៣៣០.៤៧៩ | ៦.៣៣០.៤៧៩ | ១០៩.៣៨២.៥៣៣ | ១២២.០៤៣.៤៩១ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | ១.៦៤៨.៤៣៥ | ៥០.៣២១.៤៤៤ | ៥០.៣២១.៤៤៤ | ៦១០.៩៤៤.៨៣៤ | ៧១៣.២៣៦.១៥៧ |

(ក) យោងតាមលក្ខន្តិកៈរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩ ត្រង់មាត្រា ២៩ បានចែងថាប្រាក់ចំណេញរបស់ រ.ទ.ស.ភ បន្ទាប់ពីការកាត់កងនឹងការខាតយោងពីឆ្នាំមុន (ប្រសិនបើមាន) អាចត្រូវប្រើប្រាស់ដូចខាងក្រោម៖

- សម្រាប់ថ្លែងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត
- សម្រាប់ទុនបម្រុងតាមច្បាប់ ៥%
- សម្រាប់ទុនបម្រុងសេរី ៥%
- សមតុល្យនៅសល់សម្រាប់ទុនបម្រុងសម្រាប់ការអភិវឌ្ឍសហគ្រាស។

(ខ) ដោយចូលជាធរមានពីការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានយល់ព្រមតាមសំណើរពី រ.ទ.ស.ភ តាមរយៈលិខិតលេខ ២២៥៤ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ ដែលបានស្នើសុំបែងចែកប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួនចំនួន ១០% ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក៏ប៉ុន្តែចាប់ពីឆ្នាំ២០១២ទៅ បន្ទាប់ពី រ.ទ.ស.ភ បានចុះបញ្ជីរួចហើយការបែងចែកភាគលាភនឹងត្រូវអនុវត្តតាមលក្ខន្តិកៈថ្មីរបស់ រ.ទ.ស.ភ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២។

**១៤. ទុនបម្រុង (ត)**

(ខ) ការបែងចែកភាគលាភមានដូចខាងក្រោម៖

គោលការណ៍ក្នុងការបែងចែកភាគលាភបានកំណត់តាមលក្ខខណ្ឌនៃការបែងចែកប្រាក់ចំណេញ ដូចខាងក្រោម៖

១. ការទូទាត់ការខាតក្នុងឆ្នាំកន្លងទៅ

២. បន្ទាប់ពីបានទូទាត់ការខាតក្នុងឆ្នាំកន្លងទៅរួច ប្រសិនបើនៅមានប្រាក់ចំណេញ នោះប្រាក់ចំណេញនោះត្រូវបែងចែកដូចខាងក្រោម៖

i. ថ្លែងសរសើរដល់ថ្នាក់ដឹកនាំ និងនិយោជិត តាមលក្ខខណ្ឌដូចខាងក្រោម៖

- ផ្តល់ជូននូវប្រាក់បៀវត្ស ១ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធចាប់ពី ៥% ទៅ ១០%នៃចំណាយប្រតិបត្តិការ។
- ផ្តល់ជូននូវប្រាក់បៀវត្ស ២ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធចាប់ពី ១០% ទៅ ២០%នៃចំណាយប្រតិបត្តិការ។
- ផ្តល់ជូននូវប្រាក់បៀវត្ស ៣ខែចំពោះបុគ្គលិកទាំងអស់ ប្រសិនបើមានប្រាក់ចំណេញសុទ្ធច្រើនជាង២០% នៃចំណាយប្រតិបត្តិការ។

ii. ២% សម្រាប់ប្រាក់សោធននិវត្តន៍ និងអសមត្ថភាពវិជ្ជាជីវៈ

iii. ៥% សម្រាប់ទុនបម្រុងតាមច្បាប់

iv. ៥% សម្រាប់ទុនបម្រុងសេរី

v. ៥% សម្រាប់មូលនិធិសង្គម ដែលនឹងត្រូវកត់ត្រាជាចំណាយក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង

៣. ចំនួនទឹកប្រាក់ដែលនៅសល់បន្ទាប់ពីការបែកចែកខាងលើនេះត្រូវបន្តបែងចែកដូចខាងក្រោម៖

i. បម្រុងសម្រាប់ការវិនិយោគពេលអនាគត (ប្រាក់ចំណេញរក្សាទុក) ដែលទឹកប្រាក់នេះត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល

ii. ទឹកប្រាក់នៅសល់ ពីទុនបម្រុងសម្រាប់ការវិនិយោគ ត្រូវបែងចែកជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ៨៥% និង១៥%ទៀតជូនវិនិយោគិនសាធារណៈ។

(គ) ការប្រើប្រាស់គណនីបម្រុងសម្រាប់បង់សកម្មភាពសង្គម គឺអនុលោមតាមលិខិតលេខ២៨៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០។ សកម្មភាពសង្គមនេះទាក់ទងនឹងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ក្រុមយោធានៅតាមបណ្តាខេត្តមួយចំនួន។ សកម្មភាពត្រូវបានបន្តរហូតដល់ឆ្នាំ២០១១ ដោយយោងតាមលិខិតរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់ លេខ២២១០ សហវ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១។

(ឃ) ក្នុងអំឡុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ មានការផ្ទេរឡើងវិញនូវទឹកប្រាក់ចំនួន ៥៥,៩៦៥ ពាន់លានរៀលដែលត្រូវបានធ្វើឡើងពីការផ្ទេរទុនបម្រុងសម្រាប់ការវិនិយោគ ទៅប្រាក់ចំណេញរក្សាទុក។ ការផ្ទេរនេះបង្ហាញពី ការកែប្រែនៅក្នុងការប៉ាន់ស្មាន នៃចំណូលបង្គរពីការលក់ទឹកស្អាតដែលបានទទួលពីស្គាល់មុន។

ការផ្ទេរឡើងវិញនេះ ត្រូវបានកត់ត្រាតាមរយៈមូលធន និងមិនមានផលប៉ះពាល់ទៅដល់ប្រាក់ចំណេញ ឬការខាតសម្រាប់ការិយបរិច្ឆេទនេះទេ។

## ១៥. ប្រាក់កម្ចី

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| **រយៈពេលវែង** | | |
| ក.ស.ហ.រ - ទីភ្នាក់ងារសហប្រតិបត្តិការ អន្តរជាតិជប៉ុន (“JICA”) | ២៧.៧៤៨.៩១០ | ៣២.៩០៥.២២១ |
| ក.ស.ហ.រ - ធនាគារអភិវឌ្ឍន៍អាស៊ី (“ADB”) | ២៤.៨៣០.០២៩ | ២៨.១៨១.១៧៨ |
| ធនាគារវិនិយោគអឺរ៉ុប (“EIB”) | ៣៩១.១៤៨.១៥៩ | ៣៩៦.៧៣២.៣៣៦ |
| | ៤៤៣.៧២៧.០៩៩ | ៤៥៧.៨១៨.៧៣៥ |
| **ប្រាក់កម្ចីរយៈពេលខ្លី** | | |
| ក.ស.ហ.រ - JICA | ១.២៣៤.១៦៣ | ១.៤០៦.២៣៧ |
| ក.ស.ហ.រ - ADB | ២.២៦៧.៩៩០ | ២.៣៧៧.២៥១ |
| AFD - ឥណទានលេខ ១១២១ 0១F | ៨.៤២៥.៨៧៨ | ១៨.២៦០.៥១៤ |
| AFD - ឥណទានលេខ ១១៧៤ 0១P | ១៤៥.៦៦១.៤៥៣ | ១៤៨.១៤០.២៣១ |
| AFD - ឥណទានលេខ ១១៧៦ 0១S | ៣៣៧.១៩៨.៦៥៧ | ៣៣៤.៤០០.៦០៦ |
| AFD - ឥណទានលេខ ១២៤៤ 0១M | ៤១១.៩៨២.៨៥៨ | ៣៤៨.៩៦៨.២៦៤ |
| AFD - ឥណទានលេខ ១២៧៣ 0១P | ៧២.០៤៣.៦៤៦ | - |
| ធនាគារវិនិយោគអឺរ៉ុប (“EIB”) | ៨.០៧៧.៦៣៩ | ១១០.១៥៤ |
| | ៩៨៦.៨៩២.២៨៣ | ៨៦២.៧៨៣.៣៥០ |
| **ប្រាក់កម្ចីសរុប** | | |
| ក.ស.ហ.រ - JICA | ២៨.៩៨៣.០៧៣ | ៣៤.៣១១.៤៥៨ |
| ក.ស.ហ.រ - ADB | ២៧.០៩៨.០១៩ | ៣០.៥៥៨.៤២៩ |
| AFD - ឥណទានលេខ ១១២១ 0១ F | ៨.៤២៥.៨៧៨ | ២៧.៣៨០.៦០៧ |
| AFD - ឥណទានលេខ ១១៧៤ 0១P | ១៤៥.៦៦១.៤៥៣ | ១៤៨.១៤០.២៣១ |
| AFD - ឥណទានលេខ ១១៧៦ 0១S | ៣៣៧.១៩៨.៦៥៧ | ៣៣៤.៤០០.៦០៦ |
| AFD - ឥណទានលេខ ១២៤៤ 0១M | ៤១១.៩៨២.៨៥៨ | ៣៤៨.៩៦៨.២៦៤ |
| AFD - ឥណទានលេខ ១២៧៣ 0១P | ៧២.០៤៣.៦៤៦ | - |
| ធនាគារវិនិយោគអឺរ៉ុប (“EIB”) | ៣៩៩.២២៥.៧៩៨ | ៣៩៦.៨៤២.៤៩០ |
| | ១.៤៣០.៦១៩.៣៨២ | ១.៣២០.៦០២.០៨៥ |

(ក) ប្រាក់កម្ចី ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) ក.ស.ហ.រ - JICA

យោងតាមកិច្ចព្រមព្រៀងប្រាក់កម្ចីបន្ទាប់បន្សំចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ រ.ទ.ស.ភ ត្រូវបានផ្តល់ប្រាក់កម្ចី ជាអតិបរមាចំនួន ៣.៥១៣.០០០.០០០យ៉េន ពី ក.ស.ហ.រ ។

គោលបំណងនៃប្រាក់កម្ចីនេះ គឺដើម្បីផ្តល់ហិរញ្ញប្បទានដល់ការរចនា និងការសាងសង់រោងចក្រទឹកស្អាត និងការបញ្ជូនទឹកស្អាត នៅនិរោធ (កញ្ចប់ថវិការង ខ)។

## ១៥. ប្រាក់កម្ចី (ត)

(ខ) ក.ស.ហ.រ - JICA (ត)

អត្រាការប្រាក់ប្រចាំឆ្នាំគឺ ០,៦៦% (២០២៣៖ ០,៦៦%) ក្នុងមួយឆ្នាំ។

កម្ចីនេះនឹងត្រូវបានបង់រំលស់ជា ២៨ដំណាក់កាលប្រចាំឆមាស ចាប់ផ្តើមពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៤ និងបញ្ចប់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកប្រាក់ និងការសងប្រាក់។

ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងប្រាក់កម្ចីបន្ទាប់បន្សំលេខ CP-P (MoEF - JICA) ចុះនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ប្រាក់កម្ចីនេះត្រូវបានចារឹកតម្លៃជាប្រាក់យ៉េនជប៉ុន ("JPY") ហើយ រ.ទ.ស.ភ នឹងត្រូវបង់សងត្រលប់ទៅវិញនូវប្រាក់ដើម និងការប្រាក់ជារូបិយប័ណ្ណក្នុងស្រុក ក្នុងអត្រាប្តូរប្រាក់ដែល ក.ស.ហ.រ បង់ជូនទៅឱ្យ JICA។ អត្រាការប្រាក់ប្រចាំឆ្នាំត្រូវបានកែប្រែពី ៧,៥០% ទៅ ០,៦៦% ក្នុងមួយឆ្នាំ។ កាលកំណត់ឥណទានត្រូវបានពន្យារពីរយៈពេល ១២ឆ្នាំ ទៅ ៤០ឆ្នាំ ដែលប្រាក់កម្ចីនេះត្រូវបញ្ចប់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០៤៩ ។

(គ) ក.ស.ហ.រ - ADB

យោងតាមកិច្ចព្រមព្រៀងប្រាក់កម្ចីបន្ទាប់បន្សំចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ៣៨.២៩៩.៩៣៧.៥០០រៀល (SDR៩.៦០៥.០០០) ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ឥណទានដែលផ្តល់នេះក្នុងគោលបំណងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យទឹកស្អាតនៅតាមខេត្ត និងជុំវិញទីក្រុង។

អត្រាការប្រាក់ប្រចាំឆ្នាំគឺ ១,៦៥% (២០២៣៖ ១,៦៥%) ក្នុងមួយឆ្នាំ។

កម្ចីនេះត្រូវបានបង់រំលស់ប្រចាំឆមាស នៅរៀងរាល់ថ្ងៃទី១៥ ខែមករា និងថ្ងៃទី១៥ ខែកក្កដា នៃឆ្នាំនីមួយៗ ដោយចាប់ផ្តើមពីឆ្នាំ២០១២តទៅ។ ហានិភ័យការប្តូររូបិយប័ណ្ណកើតពីការប្រែប្រួលរវាងតម្លៃរូបិយប័ណ្ណនៃឥណទាន និងរូបិយប័ណ្ណប្រើប្រាស់ចំពោះការសងប្រាក់របស់ រ.ទ.ស.ភ (ប្រាក់រៀល) នឹងត្រូវបានធានាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អត្រាប្តូរប្រាក់រៀល (រៀល/SDR) ត្រូវបានកំណត់នៅថ្ងៃចុះកិច្ចសន្យា។

ការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងប្រាក់កម្ចីបន្ទាប់បន្សំលេខ ១៤៦៨ - CAM (MoEF - ADB) ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៩ ប្រាក់កម្ចីនេះត្រូវចារឹកតម្លៃជា Special Drawing Right ("SDR") ហើយ រ.ទ.ស.ភ នឹងត្រូវបង់សងត្រលប់ទៅវិញនូវប្រាក់ដើម និងការប្រាក់ជារូបិយប័ណ្ណក្នុងស្រុក ក្នុងអត្រាប្តូរប្រាក់ដែល ក.ស.ហ.រ បង់ជូនទៅឱ្យធនាគារអភិវឌ្ឍន៍អាស៊ី។ អត្រាការប្រាក់ប្រចាំឆ្នាំត្រូវបានកែប្រែពី ៦,៥០% ទៅ ១,៦៥% ក្នុងមួយឆ្នាំ។ ប្រាក់កម្ចីនេះត្រូវបង់រំលស់ ប្រចាំឆមាស នៅរៀងរាល់ថ្ងៃទី១ ខែមេសា និងថ្ងៃទី១ ខែតុលា នៃឆ្នាំនីមួយៗដោយចាប់ផ្តើមពីឆ្នាំ២០១៩ នេះតទៅ។

(ឃ) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ ០១F

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១១២១ ០១F ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៣ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទាន អតិបរមាចំនួន ៣០.០០០.០០០ អឺរ៉ូពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មីទី២នៅសង្កាត់និរោធ និងបន្ថែមប្រព័ន្ធបញ្ជូន រួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

អត្រាការប្រាក់ គឺអត្រា EURIBOR ៦ខែ ដក ០,៥៩%ក្នុងមួយឆ្នាំ (កំណត់ត្រឹម ៥,១៩% ក្នុងមួយឆ្នាំ ហើយអត្រាការប្រាក់អប្បបរមា គឺ០,២៥% ក្នុងមួយឆ្នាំ)។

**១៥. ប្រាក់កម្ចី (ត)**

(ឃ) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១២១ 01F (ត)

កម្ចីនេះត្រូវបានបង់រំលស់ជា ២៤ដំណាក់កាលប្រចាំឆមាស ដោយរួមបញ្ចូលរយៈពេលអនុគ្រោះ ៤ឆ្នាំ។ ការបង់សងត្រឡប់ត្រូវចាប់ផ្តើមពីខែមករា ឆ្នាំ២០១៨ តទៅ។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងជាប្រាក់អឺរ៉ូ ទាំងការដកការប្រាក់ និងការសងប្រាក់។

(ង) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៤ 01P

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១១៧៤ 01P ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ៤៧.១០០.០០០ដុល្លារអាមេរិក ដែលស្មើនឹង ៣០.០០០.០០០អឺរ៉ូ ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មី នៅរោងចក្រផលិតទឹកចំការមននិងបន្ថែមប្រព័ន្ធបញ្ជូនរួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

អត្រាការប្រាក់ជាសកល (អត្រាប្រសិទ្ធភាពជាសកល) ដែលអនុវត្តចំពោះឥណទានអាចត្រូវបានវាយតម្លៃក្នុងអត្រាប្រចាំឆ្នាំ ១,១៦% លើមូលដ្ឋាននៃ ៣៦៥ ថ្ងៃ និងការប្រាក់រយៈពេល ៦ខែ ដែលកំណត់ត្រឹម ១,១៤% ក្នុងមួយឆ្នាំបូក ០,៦៥% ដែលត្រូវបង់ទៅ ក.ស.ហ.វ និង ជាមួយអត្រាអប្បបរមា ០,២៥% ក្នុងមួយឆ្នាំ។

កម្ចីនេះត្រូវបានបង់រំលស់ជា ២៦ដំណាក់កាលប្រចាំឆមាស ដោយរួមបញ្ចូលរយៈពេលអនុគ្រោះ ៧ឆ្នាំ។ ការបង់សងត្រឡប់ត្រូវចាប់ផ្តើមពីខែមករា ឆ្នាំ២០២៥ តទៅ។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងជាប្រាក់ដុល្លារ ទាំងការដកការប្រាក់ និងការសងប្រាក់។

(ច) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១១៧៦ 01S

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១១៧៦ 01S ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ៨៥.០០០.០០០ដុល្លារអាមេរិក ដែលស្មើនឹង ៧៧.៣០០.០០០អឺរ៉ូ ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មី នៅរោងចក្រផលិតទឹកបាក់ខែង និងបន្ថែមប្រព័ន្ធបញ្ជូនរួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

អត្រាការប្រាក់ប្រចាំឆ្នាំ គឺផ្អែកលើអត្រាយោងថេរ ដែលកែតម្រូវសម្រាប់ការប្រែប្រួលនៃអត្រាសន្ទស្សន៍រវាងកាលបរិច្ឆេទចុះហត្ថលេខា និងកាលបរិច្ឆេទកំណត់អត្រាការប្រាក់ ដូចដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងឥណទាន។ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១៩ ដែលជាថ្ងៃដកប្រាក់កម្ចី មានអត្រាថេរ ១,២២% ក្នុងមួយឆ្នាំ។ អត្រាសន្ទស្សន៍នៅកាលបរិច្ឆេទចុះហត្ថលេខាគឺ ០,៦៨% ក្នុងមួយឆ្នាំ ខណៈដែលអត្រាសន្ទស្សន៍នៅលើកាលបរិច្ឆេទកំណត់អត្រា (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩) គឺ ០,១១% ក្នុងមួយឆ្នាំ។ ជាហេតុនាំឱ្យមាននិយ័តកម្មធ្លាក់ចុះទៅអត្រា ០,៦៧% ដែលនាំឱ្យមានអត្រាការប្រាក់ថេរដែលបានកំណត់គឺ ០,៥៥% ក្នុងមួយឆ្នាំ។ យោងតាមកិច្ចព្រមព្រៀងឥណទានរវាង ក.ស.ហ.វ និង រ.ទ.ស.ភ មានការគិតការប្រាក់បន្ថែមចំនួន ០,៣៥% ក្នុងមួយឆ្នាំត្រូវបានអនុវត្តដោយ ក.ស.ហ.វ ទៅ រ.ទ.ស.ភ លើសមតុល្យឥណទានដែលបានទទួល។ ការប្រាក់ត្រូវបង់ប្រចាំឆមាស នៅរៀងរាល់ថ្ងៃទី១៥ ខែមិថុនា និងថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗផ្អែកលើសមតុល្យឥណទានដែលនៅសល់ និងចំនួនថ្ងៃនៅក្នុងរយៈពេលការប្រាក់លើមូលដ្ឋាននៃ ៣៦០ ថ្ងៃ។

កម្ចីនេះត្រូវបានបង់រំលស់ជា ២៦ដំណាក់កាលប្រចាំឆមាស ដោយរួមបញ្ចូលរយៈពេលអនុគ្រោះ ៧ឆ្នាំ។ ការបង់សងត្រឡប់ត្រូវចាប់ផ្តើមពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៦ និងបញ្ចប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០៣៨ ។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

## ១៥. ប្រាក់កម្ចី (ត)

(ឆ) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១២៤៤ ០១M

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១២៤៤ ០១M ចុះថ្ងៃទី១៤ ខែវិច្ឆកា ឆ្នាំ២០២០ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ១០១.៤០០.០០០ដុល្លារអាមេរិក ដែលស្មើនឹង ១០០.០០០.០០០អឺរ៉ូ ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មី នៅរោងចក្រផលិតទឹកបាក់ខែង ២ និងបន្ថែមប្រព័ន្ធបញ្ជូនរួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

អត្រាការប្រាក់ប្រចាំឆ្នាំ គឺផ្អែកលើអត្រាយោងថេរ ដែលបានកែតម្រូវសម្រាប់ការប្រែប្រួលនៃអត្រាសន្ទស្សន៍ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខារហូតដល់កាលបរិច្ឆេទកំណត់អត្រាការប្រាក់។ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលជាថ្ងៃដកប្រាក់កម្ចី មានអត្រាថេរ ០,៤៨% ក្នុងមួយឆ្នាំ ហើយអត្រាសន្ទស្សន៍ ០,០៨% ក្នុងមួយឆ្នាំ ដែលនាំឱ្យមានអត្រាការប្រាក់ថេរដែលអាចអនុវត្តបាន ០,៥៥% ក្នុងមួយឆ្នាំ។ យោងតាមកិច្ចព្រមព្រៀងឥណទានរវាង ក.ស.ហ.វ និង រ.ទ.ស.ភ មានការគិតការប្រាក់បន្ថែមចំនួន ០,៣៥% ក្នុងមួយឆ្នាំត្រូវបានអនុវត្តដោយ ក.ស.ហ.វ ទៅ រ.ទ.ស.ភ លើសមតុល្យឥណទានដែលបានទទួល។ ការប្រាក់ត្រូវបង់ប្រចាំឆមាស នៅរៀងរាល់ថ្ងៃទី១៥ ខែមិថុនា និងថ្ងៃទី១៥ ខែធ្នូ នៃឆ្នាំនីមួយៗផ្អែកលើសមតុល្យឥណទានដែលនៅសល់ និងចំនួនថ្ងៃនៅក្នុងរយៈពេលការប្រាក់លើមូលដ្ឋាននៃ ៣៦០ ថ្ងៃ។

កម្ចីនេះត្រូវបានបង់រំលស់ជា ២៦ដំណាក់កាលប្រចាំឆមាស ដោយរួមបញ្ចូលរយៈពេលអនុគ្រោះ៧ ឆ្នាំ។ ការបង់សងប្រាក់ដើមត្រូវចាប់ផ្តើមពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៧ និងបញ្ចប់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០៣៩។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិកទាំងការដកការប្រាក់ និងការសងប្រាក់។

ថ្លៃសេវាកិច្ចសន្យាត្រូវបង់ទៅឱ្យ ក.ស.ហ.វ ក្រោមកិច្ចព្រមព្រៀងផ្តល់ឥណទាន ហើយត្រូវបានគិតប្រាក់តែលើផ្នែកដែលមិនទាន់បានប្រើប្រាស់នៃឥណទាន។ ថ្លៃសេវាទាំងនេះចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំទីពីរបន្ទាប់ពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងអត្រា ០,២៥% ក្នុងមួយឆ្នាំ។ ចាប់ពីឆ្នាំទីបី អត្រាកើនឡើងដល់ ០,៣៥% ក្នុងមួយឆ្នាំ។ ថ្លៃសេវាត្រូវបានគណនាលើមូលដ្ឋានប្រចាំថ្ងៃ ដោយផ្អែកលើសមតុល្យឥណទានដែលនៅសល់ ហើយត្រូវបង់នៅថ្ងៃជាក់លាក់។ សម្រាប់គោលបំណងនៃការគណនានេះ សមតុល្យដែលមិនបានបង់ រួមបញ្ចូលនូវចំនួនទឹកប្រាក់ដែលបានស្នើរសុំ ប៉ុន្តែមិនទាន់អនុញ្ញាតិពីម្ចាស់ឥណទាន។

(ជ) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១២៧៣ ០១P

យោងតាមកិច្ចព្រមព្រៀងឥណទានលេខ CKH ១២៧៣ ០១P ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ២០០.០០០.០០០អឺរ៉ូ ពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង។

កិច្ចព្រមព្រៀងឥណទាននេះមានចំនួន២ភាគគឺ ភាគ ក និងភាគ ខ។ ភាគ ក តំណាងឱ្យចិតសិបភាគរយ (៧០%) នៃចំនួនឥណទានសរុបចារឹកតម្លៃជាអឺរ៉ូ ហើយភាគ ខ តំណាងឱ្យសាមសិបភាគរយ (៣០%) នៃចំនួនឥណទានសរុបចារឹកតម្លៃជាប្រាក់អឺរ៉ូ។

ទឹកប្រាក់ក្នុងកិច្ចព្រមព្រៀងឥណទាន ដែលបានអនុម័តនីមួយៗអាចត្រូវបានផ្តល់ទៅឱ្យ រ.ទ.ស.ភ ក្នុងការដកប្រាក់មួយ ឬច្រើនដងក្នុងអំឡុងពេលដែលអាចអនុវត្តបាន ដែលអនុញ្ញាតឱ្យដកអតិបរមាចំនួនសាមសិបដង (៣០) ក្នុងមួយឥណទាន។ ឥណទានភាគ ក ត្រូវដកយកប្រើប្រាស់អស់ទើបអាចស្នើ ឬប្រើប្រាស់ឥណទានភាគ ខ បាន។ ចំនួនអប្បបរមានៃការដកប្រាក់នីមួយៗត្រូវបានកំណត់នៅ ៣០០.០០០ អឺរ៉ូសម្រាប់ភាគ ក ឬសមតុល្យដែលនៅសល់ប្រសិនបើមានតិចជាងចំនួននេះ។ សម្រាប់ភាគ ខ ប្រសិនបើអ្នកខ្ចីជ្រើសរើស អត្រាការប្រាក់អថេរនោះ ការដកប្រាក់អប្បបរមាគឺ ៣០០.០០០អឺរ៉ូ ឬសមតុល្យដែលនៅសល់ប្រសិនបើទាបជាង។ ប្រសិនបើ រ.ទ.ស.ភ ជ្រើសរើសអត្រាការប្រាក់ថេរសម្រាប់ភាគ ខ នោះការដកអប្បបរមាកើនឡើងដល់ ៣.០០០.០០០អឺរ៉ូ ឬសមតុល្យដែលមានប្រសិនបើតិចជាង។ លក្ខខណ្ឌទាំងនេះត្រូវបានចែងដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឥណទាន។

## ១៥. ប្រាក់កម្ចី (ត)

(ផ) ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង - ឥណទានលេខ ១២៧៣ ០១P (ត)

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មី នៅរោងចក្រផលិតទឹកចាក់ខែង ៣ និងបន្ថែមប្រព័ន្ធបញ្ជូនរួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

អត្រាការប្រាក់ ដែលអាចអនុវត្តបានចំពោះ ភាគ ក គឺ ១,១០% ក្នុងមួយឆ្នាំ ខណៈដែលអត្រាការប្រាក់សម្រាប់ភាគ ខ គឺ ១,០០%ក្នុងមួយឆ្នាំ។ អត្រាទាំងនេះជាកម្មវត្ថុនៃការបញ្ជាក់ចុងក្រោយ ហើយអាចប្រែប្រួលនៅពេលកំណត់អត្រាការប្រាក់។

កម្ចីនេះត្រូវបានបង់រំលស់ជា ២៦ដំណាក់កាលប្រចាំឆមាស ដោយរួមបញ្ចូលរយៈពេលអនុគ្រោះ ៧ឆ្នាំ។ ប្រតិបត្តិការនេះត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

(ឈ) ធនាគារវិនិយោគអឺរ៉ុប (“EIB”)

យោងតាមកិច្ចព្រមព្រៀងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩ រវាងរាជរដ្ឋាភិបាលកម្ពុជា (“RGC”) (តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ជាមួយធនាគារវិនិយោគអឺរ៉ុប (“EIB”) និងបន្តចុះកិច្ចព្រមព្រៀងចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩ រវាង RGC និង រ.ទ.ស.ភ ដែល រ.ទ.ស.ភ បានផ្តល់ជំនួយឥណទានអតិបរមាមិនលើសចំនួន ១០០.០០០.០០០ដុល្លារអាមេរិក។

ឥណទានដែលផ្តល់នេះ ក្នុងគោលបំណងការសាងសង់រោងចក្រផលិតទឹកស្អាតថ្មី នៅរោងចក្រផលិតទឹកចាក់ខែង និងបន្ថែមប្រព័ន្ធបញ្ជូនរួមទាំងធ្វើឱ្យប្រព័ន្ធចែកចាយកាន់តែមានភាពប្រសើរឡើង។

ឥណទាននេះរួមមានប្រាក់ដើមចំនួនប្រាំមួយដូចខាងក្រោម៖

(១) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ១០.០០០.០០០ដុល្លារអាមេរិក ដែលស្មើនឹង ៨.៤២៨.១៥០អឺរ៉ូពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៩១០១៦ ភាគ ១ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០។ ឥណទានមានអត្រាការប្រាក់ថេរ ០,២៥៨% ក្នុងមួយឆ្នាំ។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាស ដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ និងបញ្ចប់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០៤៥។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

(២) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ២២.៤០០.០០០ដុល្លារអាមេរិក ដែលស្មើនឹង ១៩.០៤៥.៩៩៩អឺរ៉ូពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៩១០១៦ ភាគ ២ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១។ ឥណទានមានអត្រាការប្រាក់ថេរ ០,៤៨៥% ក្នុងមួយឆ្នាំ។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាសដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៦ និងបញ្ចប់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០៤៦។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

(៣) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ១៣.០០០.០០០ដុល្លារអាមេរិកពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៩១០១៦ ភាគ ៣ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។ ឥណទានមានអត្រាការប្រាក់អថេរលើមូលដ្ឋាន LIBOR រយៈពេល ៦ ខែបូកនឹងគម្លាតនៃ ៣៩,៤ ពិន្ទុមូលដ្ឋាន (“ព.ម”) នាំឱ្យមានអត្រាការប្រាក់ចំនួន ២,០៩% សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ និង អត្រាការប្រាក់ជាសកល (អត្រាប្រសិទ្ធភាពជាសកល) ដែលអនុវត្តចំពោះឥណទានអាចត្រូវបានវាយតម្លៃក្នុងអត្រាប្រចាំឆ្នាំ ៤,១៨% លើមូលដ្ឋាននៃ ៣៦០ ថ្ងៃ និងប្រចាំឆមាសសម្រាប់ការប្រាក់។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាសដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៧ និងបញ្ចប់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០៤៧។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

**១៥. ប្រាក់កម្ចី (ត)**

(ឈ) ធនាគារវិនិយោគអឺរ៉ុប ("EIB") (ត)

ឥណទាននេះរួមមានប្រាក់ដើមចំនួនប្រាំមួយដូចខាងក្រោម៖ (ត)

(៤) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ១៤.៦០០.០០០ដុល្លារអាមេរិកពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៩១០១៦ ភាគ ៤ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣។ ឥណទានមានអត្រាការប្រាក់អថេរលើមូលដ្ឋាន LIBOR រយៈពេល ៦ ខែបូកនឹងគម្លាតនៃ ៣២,១ ពិន្ទុមូលដ្ឋាន ("ព.ម") នាំឱ្យមានអត្រាការប្រាក់ចំនួន ២,០៩% សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ និង អត្រាការប្រាក់ជាសកល (អត្រាប្រសិទ្ធភាពជាសកល) ដែលអនុវត្តចំពោះឥណទានអាចត្រូវបានវាយតម្លៃក្នុងអត្រាប្រចាំឆ្នាំ ៤,៩៩% លើមូលដ្ឋាននៃ ៣៦០ ថ្ងៃ និងប្រចាំឆមាសសម្រាប់ការប្រាក់។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាសដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៨ និងបញ្ចប់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០៤៧។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

(៥) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ២៦.០០០.០០០ដុល្លារអាមេរិកពី EIB ស្មើនឹង ២៣.៨៤០.០៨៨អឺរ៉ូពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៨៩០០៨ ភាគ ១ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣។ ឥណឥទានមានអត្រាការប្រាក់ថេរ ០,៦១៥% ក្នុងមួយឆ្នាំ។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាស ដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៥ និងបញ្ចប់ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០៤៤។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់អឺរ៉ូ ទាំងការដកការប្រាក់ និងការសងប្រាក់។

(៦) រ.ទ.ស.ភ ត្រូវបានផ្តល់ជំនួយឥណទានអតិបរមាចំនួន ១៤.០០០.០០០ដុល្លារអាមេរិកពី EIB ស្មើនឹង ១១.៧៩៩.៤១០អឺរ៉ូពី EIB ក្រោមកិច្ចព្រមព្រៀងឥណទានលេខ FIN.៨៩០០៨ ភាគ ២ ជាមួយនឹងកាលបរិច្ឆេទដកប្រាក់ដែលបានគ្រោងទុកនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២០។ ឥណទានមានអត្រាការប្រាក់ថេរ ០,២៦% ក្នុងមួយឆ្នាំ។ ប្រាក់ដើមត្រូវសងជាប្រចាំឆមាស ដោយចាប់ផ្តើមដំបូងនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ និងបញ្ចប់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០៤៥។ ប្រតិបត្តិការទាំងអស់ត្រូវបានធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ទាំងការដកការប្រាក់ និងការសងប្រាក់។

អត្រាការប្រាក់ដែលបានអនុវត្តលើសមតុល្យដែលនៅសល់នៃភាគឥណទាននីមួយៗ គឺជាអត្រាថេរ ឬអថេរដែលគិតដោយ EIB ទៅ ក.ស.ហ.វ បូកបន្ថែម ០,៣៥% ក្នុងមួយឆ្នាំដែលគិតដោយ ក.ស.ហ.វ ទៅកាន់ រ.ទ.ស.ភ ។ ការប្រាក់នឹងត្រូវបានគិតចាប់ពីថ្ងៃដកប្រាក់ លើមូលដ្ឋាននៃ ៣៦០ ថ្ងៃដោយប្រើវិធីអត្រាថេរ (៣០ថ្ងៃក្នុង១ ខែ) ឬវិធីសាស្ត្រអត្រាអថេរ (ថ្ងៃពិតប្រាកដដែលបានកន្លងផុតទៅ)។ ការប្រាក់ត្រូវបង់ជាប្រចាំឆមាសនៅថ្ងៃទី១៥ ខែមិថុនា និងថ្ងៃ១៥ ខែធ្នូ ជារៀងរាល់ឆ្នាំ។

ប្រាក់ដើមត្រូវសងជាប្រចាំឆមាសនៅថ្ងៃដូចគ្នានេះ ដោយចាប់ផ្តើមដំបូងមិនលឿនជាង ៣០ ថ្ងៃ និងមិនលើសពីប្រាំឆ្នាំគិតចាប់ពីកាលបរិច្ឆេទទូទាត់ដែលបានគ្រោងទុក ហើយការសងចុងក្រោយកើតឡើងមិនលឿនជាង ៤ ឆ្នាំ និងមិនលើសពី ២៥ ឆ្នាំគិតចាប់ពីកាលបរិច្ឆេទទូទាត់ដែលបានគ្រោងទុក។ ប្រតិបត្តិការសងប្រាក់ដើម ការប្រាក់ និងសេវាផ្សេងៗ ត្រូវបានធ្វើឡើងទៅ ក.ស.ហ.វ ជារូបិយប័ណ្ណទៅតាមភាគនៃឥណទាននីមួយៗ។

## ១៥. ប្រាក់កម្ចី (ត)

(ញ) តម្លៃសមស្របនៃប្រាក់កម្ចីរបស់ រ.ទ.ស.ភ ត្រូវបានចាត់ថ្នាក់នៅក្នុងកម្រិត ៣ នៃឋានានុក្រមតម្លៃសមស្រប។ មិនមានការផ្លាស់ប្តូរកម្រិតនៅក្នុងឋានានុក្រមក្នុងអំឡុងការិយបរិច្ឆេទទេ។

បច្ចេកទេសវាយតម្លៃដែលបានប្រើ និងធាតុចូលសំខាន់ៗក្នុងការវាយតម្លៃលើប្រាក់កម្ចីដែលបានវាស់វែងនៅកម្រិតទី៣ ត្រូវបានពិពណ៌នាដូចខាងក្រោម៖

| **បំណុលហិរញ្ញវត្ថុ** | **បច្ចេកទេសវាយតំលៃបានប្រើ** | **ធាតុចូលដែលមិនអាចសង្កេតបានយ៉ាងសំខាន់** | **អន្តរទំនាក់ទំនងរវាងធាតុចូលដែលមិនអាចសង្កេតបានសំខាន់ៗ និងតម្លៃសមស្រប** |
|---|---|---|---|
| ប្រាក់កម្ចី | វិធីសាស្ត្រអប្បហារ លំហូរសាច់ប្រាក់ | អត្រាអប្បហារ | អត្រាអប្បហារកាន់តែខ្ពស់ តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុនឹងកាន់តែទាប |

(ដ) ប្រាក់កម្ចី ដែលមិនត្រូវបានរាយការណ៍តាមតម្លៃសមស្រប និងតម្លៃយោងដែលមិនប្រហាក់ប្រហែលទៅនឹងតម្លៃសមស្របមានដូចខាងក្រោម៖

| | **២០២៤** | | **២០២៣** | |
|---|---|---|---|---|
| | **តម្លៃយោង** | **តម្លៃសមស្រប** | **តម្លៃយោង** | **តម្លៃសមស្រប** |
| | **ពាន់រៀល** | **ពាន់រៀល** | **ពាន់រៀល** | **ពាន់រៀល** |
| ប្រាក់កម្ចីដែលមានអត្រាថេរ | ១.៣២៥.២០២.១៥១ | ១.២៣០.៧៤៩.៤១៥ | ១.២២០.៩៥៨.១៨២ | ១.១០១.៧៥៩.៨៥៣ |

តម្លៃសមស្របរបស់ប្រាក់កម្ចី ត្រូវបានប៉ាន់ស្មានដោយវិធីសាស្ត្រអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត ដោយប្រើប្រាស់នូវអត្រាទីផ្សារបច្ចុប្បន្នដែលអាចរកបានសម្រាប់ រ.ទ.ស.ភ សម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ស្រដៀងគ្នា។

(ឋ) តម្លៃយោងនៃប្រាក់កម្ចី គឺជាការប៉ាន់ប្រមាណសមហេតុផលនៃតម្លៃសមស្រប ទាំងដោយសារលក្ខណៈរយៈពេលខ្លីរបស់ពួកគេ ឬជាឧបករណ៍អត្រាអថេរដែលត្រូវបានកំណត់តម្លៃឡើងវិញទៅនឹងអត្រាការប្រាក់ទីផ្សារនៅ ឬជិតចុងបញ្ចប់នៃការិយបរិច្ឆេទរាយការណ៍។

(ឌ) តារាងខាងក្រោមនេះបង្ហាញពីតម្លៃយោង អត្រាការប្រាក់ប្រសិទ្ធភាពជាមធ្យមទម្ងន់នៅចុងបញ្ចប់នៃរយៈពេលរបាយការណ៍នីមួយៗ និងកាលកំណត់ដែលនៅសល់នៃកម្ចីរបស់ រ.ទ.ស.ភ ដែលត្រូវប្រឈមនឹងហានិភ័យអត្រាការប្រាក់៖

| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | **អត្រាការប្រាក់ប្រសិទ្ធភាពប្រចាំឆ្នាំជាមធ្យមទម្ងន់ %** | **នៅក្នុងរយៈពេល ពេល១ឆ្នាំ ពាន់រៀល** | **ពី១ឆ្នាំ ទៅ ២ឆ្នាំ ពាន់រៀល** | **ពី២ឆ្នាំ ទៅ ៥ឆ្នាំ ពាន់រៀល** | **លើសពី៥ឆ្នាំ ពាន់រៀល** | **សរុប ពាន់រៀល** |
|---|---|---|---|---|---|---|
| អត្រាថេរ | ០,៩៩ | ៩៨៦.៨៩២.២៨៣ | ១៥.៧៤៣.៨៧៩ | ៥៤.០៣០.៤៣៥ | ២៦៨.៥៣៥.៥៥៤ | ១.៣២៥.២០២.១៥១ |
| អត្រាអថេរ | ៦,៤៤ | - | - | ១១.៨៤៩.៨៤៨ | ៩៣.៥៦៧.៣៨៣ | ១០៥.៤១៧.២៣១ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | |
| អត្រាថេរ | ០,៩៨ | ៨៦២.៧៨៣.៣៥០ | ១១.៣៦៧.៩២១ | ៥៦.៨៧៤.៦៣៣ | ២៨៩.៩៣២.២៧៨ | ១.២២០.៩៥៨.១៨២ |
| អត្រាថេរ | ៦,០៩ | - | - | ១.៣២៧.៦២៥ | ៩៨.៣១៦.២៧៨ | ៩៩.៦៤៣.៩០៣ |

## ១៥. ប្រាក់កម្ចី (ត)

(ឈ) តារាងខាងក្រោមសង្ខេបទម្រង់កាលកំណត់នៃការខ្ចីប្រាក់របស់ រ.ទ.ស.ភ នៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ ដោយផ្អែកទៅលើកាតព្វកិច្ចទូទាត់សងដែលមិនបានធ្វើអប្បហារតាមកិច្ចសន្យាដូចខាងក្រោម៖

| | តាមតម្រូវការ ឬក្នុងរយៈពេលមួយឆ្នាំ<br>ពាន់រៀល | ពីមួយទៅប្រាំឆ្នាំ<br>ពាន់រៀល | លើសពីប្រាំឆ្នាំ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤** | | | | |
| កម្ចី | ១.០៥៨.១៧៣.៨៩៣ | ៩១.៦៧១.១៨៦ | ៣៧៩.៨៥៩.៧៨៦ | ១.៥២៩.៧០៤.៨៦៥ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | |
| កម្ចី | ៩២៥.២៣៧.៦៧៨ | ៧៦.៩៩៦.១៧៩ | ៤១២.៣១៥.១៥៨ | ១.៤១៤.៥៤៩.០១៥ |

(ញ) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់ប្រាក់កម្ចីមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ដុល្លារអាមេរិក | ១.៣៦៦.១១២.៤១២ | ១.២២៨.៣៥១.៥៩១ |
| អឺរ៉ូ | ៨.៤២៥.៨៧៨ | ២៧.៣៨០.៦០៧ |
| Special Drawing Right | ២៧.០៩៨.០១៩ | ៣០.៥៥៨.៤២៩ |
| យ៉េនជប៉ុន | ២៨.៩៨៣.០៧៣ | ៣៤.៣១១.៤៥៨ |
| | ១.៤៣០.៦១៩.៣៨២ | ១.៣២០.៦០២.០៨៥ |

(ដ) ការរំលោភបំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចី

ប្រាក់កម្ចីរយៈពេលវែងរបស់ រ.ទ.ស.ភ ពី AfD ដែលមានការប្រាក់ពី ០,២៥% ទៅ ៦,០៩% (២០២៣៖ ០,២៥% ទៅ ១,៨០%) នឹងត្រូវបង់សងចាប់ពី ១ ដល់ ២៤ ឆ្នាំ (២០២៣៖ ១ ដល់ ២៥ ឆ្នាំ)។ ប្រាក់កម្ចីទាំងនេះមានកម្មវត្ថុក្នុងកិច្ចព្រមព្រៀង ដែលរួមមានកម្រិតអានុភាពអតិបរិមា ដែលប្រសិនបើមានការរំលោភបំពាន អាចបណ្តាលឱ្យមានការផ្អាក ឬលុបចោលសិទ្ធិ ដើម្បីស្នើសុំការទូទាត់បន្ថែមនៃចំនួនប្រាកម្ចីដែលមិនទាន់បានដក និងតម្រូវការនៃសមតុល្យដែលនៅសល់ ប្រសិនបើការបំពានលើកិច្ចព្រមព្រៀងប្រាក់កម្ចីនោះមាន លក្ខណៈជាសារវន្តពី ក.ស.ហ.វ និង/ឬ AfD ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ រ.ទ.ស.ភ បានហួសពីកម្រិតអានុភាពអតិបរមា។ រ.ទ.ស.ភ បានទទួលការលើកលែងពី AfD នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។ អាស្រ័យហេតុនេះ ប្រាក់កម្ចីត្រូវបានចាត់ថ្នាក់ប្រាក់កម្ចីរយៈពេលខ្លី ដូចការិយបរិច្ឆេទរាយការណ៍ទាំងនោះ។ រ.ទ.ស.ភ បន្តតាមដានការអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងរក្សាទំនាក់ទំនងយ៉ាងសកម្មជាមួយម្ចាស់ឥណទានដែលពាក់ព័ន្ធ ដើម្បីគ្រប់គ្រងការរំលោភបំពានដែលអាចកើតមាន។

## ១៦. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ

| | ជំនួយពីសហភាពអឺរ៉ុប<br>ពាន់រៀល | ជំនួយរដ្ឋាភិបាល<br>ពាន់រៀល | ជំនួយរបស់ JICA<br>ពាន់រៀល | ជំនួយផ្សេងៗ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|---|
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ៥៤.៤៣៦.១៩៩ | ១០.១៩១.៥២៧ | ៣.៩៧២.៥០២ | ៦៣៨.២៤៩ | ៦៩.២៣៨.៤៧៧ |
| ការបន្ថែម | - | ៦.១៥៧.៨០០ | - | ៧៧៦.៣៧៧ | ៦.៩៣៤.១៧៧ |
| រំលស់ | - | (១.៨៥៣.០០៦) | (១៣៤.០៦៩) | (២២.៨៣៣) | (២.០០៩.៩០៨) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៥៤.៤៣៦.១៩៩ | ១៤.៤៩៦.៣២១ | ៣.៨៣៨.៤៣៣ | ១.៣៩១.៧៩៣ | ៧៤.១៦២.៧៤៦ |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ | ៥៤.៤៣៦.១៩៩ | ១៤.៤៩៦.៣២១ | ៣.៨៣៨.៤៣៣ | ១.៣៩១.៧៩៣ | ៧៤.១៦២.៧៤៦ |
| ការបន្ថែម | - | - | - | ៤៧៣.១២៣ | ៤៧៣.១២៣ |
| រំលស់ | - | (១.៨៥៣.០០៦) | (១៣២.៥០៧) | (២៤.៣៩៥) | (២.០០៩.៩០៨) |
| សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | ៥៤.៤៣៦.១៩៩ | ១២.៦៤៣.៣១៥ | ៣.៧០៥.៩២៦ | ១.៨៤០.៥២១ | ៧២.៦២៥.៩៦១ |

រំលស់លើជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ ត្រូវបានកត់ត្រាជាចំណូលផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗ។

(ក) ជំនួយពីសហភាពអឺរ៉ុប

ជំនួយពីសហភាពអឺរ៉ុប គឺជំនួយលើការទិញសម្ភារៈសម្រាប់គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ចំនួន ១២.៧០០.០០០អឺរ៉ូ ក្នុងទម្រង់ជាជំនួយវិនិយោគដែលធ្វើឡើងតាមរយៈថវិកាទូទៅរបស់សហភាពអឺរ៉ុប។

(ខ) ជំនួយពីរាជរដ្ឋាភិបាល

ជំនួយពីរាជរដ្ឋាភិបាល កើតមកពីការចំណេញលើលម្អៀងនៃអត្រាថេរ ដែលបានប្រើដើម្បីប្តូរប្រាក់ (រៀល/SDR) ក្រោមកិច្ចព្រមព្រៀងឥណទានបន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រ.ទ.ស.ភ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៧ ដែលមានទឹកប្រាក់សរុបចំនួន ៩.៦៩៥.០០០SDR ពីធនាគារអភិវឌ្ឍន៍អាស៊ី។ រ.ទ.ស.ភ បានសម្រេចរក្សាទុកចំណេញពីការប្តូរប្រាក់ នេះក្នុងបញ្ជីរបស់ រ.ទ.ស.ភ ថាជាជំនួយ (ដោយសារមិនមានតម្រូវការឱ្យបង្វិលប្រាក់ចំណេញនេះទៅវិញទេ) ហើយប្រាក់ចំណេញនេះនឹងត្រូវរំលស់ដោយផ្អែក លើគោលការណ៍ដូចគ្នានឹងជំនួយពន្យារផ្សេងៗដែរ។

(គ) ជំនួយពី JICA

ជំនួយពី JICA គឺជំនួយលើគម្រោងអនុវត្តថាមពលស្អាត ដោយប្រព័ន្ធប្រតិបត្តិការអគ្គីសនីតាមប្រព័ន្ធសូឡា។

ជំនួយបន្ថែម គឺជាទឹកប្រាក់ដែលទទួលបានពីកញ្ចប់ថវិកាទូទៅរបស់រដ្ឋាភិបាលជប៉ុនដែលមានចំនួន ១.៤៩៤.៦២៤ដុល្លារអាមេរិក ឬស្មើនឹង ៦.១៥៧.៨០០.០០០រៀល។ គោលបំណងនៃជំនួយគឺដើម្បីផ្តល់មូលនិធិដល់គម្រោងផលិតទឹកស្អាតបឹងធំ ដើម្បីកែលម្អសេវាផ្គត់ផ្គង់ទឹកស្អាតនៅភូមិភាគនិរតីនៃរាជធានីភ្នំពេញ។

## ១៦. ជំនួយពន្យារពីរដ្ឋាភិបាល និងជំនួយផ្សេងៗ (ត)

(ឃ) ជំនួយផ្សេងៗ

ជំនួយផ្សេងៗគឺជាការឧបត្ថម្ភទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារពីទីស្នាក់ការសហប្រតិបត្តិការអន្តរជាតិរបស់ Associate International des Maires Francophones (AIMF) ក្រុមហ៊ុន KUBOTA Construction Co.. Ltd និងរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ។

ជំនួយបន្ថែម តំណាងឱ្យចំនួនទឹកប្រាក់ដែលទទួលបានពីរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េចំនួន ៨០.០០០ដុល្លារអាមេរិក ឬស្មើនឹង ៣២២.០០០.០០០រៀល និងជំនួយទូទៅដែលមានចំនួន ១៥១.១២៣.៤០៧រៀល។

## ១៧. បំណុលពន្ធពន្យារ

សមាសធាតុ និងបម្រែបម្រួល(បំណុល)/ទ្រព្យសកម្មពន្ធពន្យារមានដូចខាងក្រោម៖

| | នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ ពាន់រៀល | កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ ឬខាត (កំណត់សម្គាល់ ២៧) ពាន់រៀល | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ពាន់រៀល |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (៨៧.០០៦.២២៩) | (៧.១៩៧.៩៣៣) | (៩៤.២០៤.១៦២) |
| ចំណូលបង្ករ | (៧.៧២៥.៦៩៥) | ២០៨.៤៥៧ | (៧.៥១៧.២៣៨) |
| សំវិធានធនលើសន្និធិហួសសម័យ | ៨៥០.៨២៨ | (១៤៥.៦៩៣) | ៧០៥.១៣៥ |
| សំវិធានធនសម្រាប់បំណុលជាប់សង្ស័យ | ១០.០៨១ | - | ១០.០៨១ |
| អត្ថប្រយោជន៍បុគ្គលិក | ៥៣.២៨៥ | - | ៥៣.២៨៥ |
| ចំណូលពន្យារ | (៩៤៣.៨៧០) | (៥.២៦១.៦១៧) | (៦.២០៥.៤៨៧) |
| ការបកប្រែរូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | ២.៧៦៧.២៧៩ | (៧៥៥.៧៥៤) | ២.០១១.៥២៥ |
| | (៩១.៩៩៤.៣២១) | (១៣.១៥២.៥៤០) | (១០៥.១៤៦.៨៦១) |

| | នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ ពាន់រៀល | កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ ឬខាត (កំណត់សម្គាល់ ២៧) ពាន់រៀល | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ពាន់រៀល |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (៨០.៤៦៦.៥១៨) | (៦.៥៣៩.៧១១) | (៨៧.០០៦.២២៩) |
| ចំណូលបង្ករ | - | (៧.៧២៥.៦៩៥) | (៧.៧២៥.៦៩៥) |
| សំវិធានធនលើសន្និធិហួសសម័យ | - | ៨៥០.៨២៨ | ៨៥០.៨២៨ |
| សំវិធានធនសម្រាប់បំណុលជាប់សង្ស័យ | ១០.០៨១ | - | ១០.០៨១ |
| អត្ថប្រយោជន៍បុគ្គលិក | ៥៣.២៨៥ | - | ៥៣.២៨៥ |
| ចំណូលពន្យារ | ៣០៦.៩២៦ | (១.២៥០.៧៩៦) | (៩៤៣.៨៧០) |
| ការបកប្រែរូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | ៣.០៧៩.៥១០ | (៣១២.២៣១) | ២.៧៦៧.២៧៩ |
| | (៧៧.០១៦.៧១៦) | (១៤.៩៧៧.៦០៥) | (៩១.៩៩៤.៣២១) |

## ១៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| **គណនីត្រូវបង់ផ្សេងៗ - រយៈពេលវែង** | | |
| ប្រាក់កក់ថ្លៃទឹកត្រូវបង្វិលសងវិញ | ៨៨.៩៥០.៥៦៦ | ៨២.៩០៣.៧៣២ |
| **គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម - រយៈពេលខ្លី** | | |
| ភាគីទីបី | ១២៦.១៥៧.៨១៤ | ៨៣.៨៥៦.៦៧៧ |
| **គណនីត្រូវបង់ផ្សេងៗ - រយៈពេលខ្លី** | | |
| បង្គរប្រាក់លើកទឹកចិត្តបុគ្គលិក | ១១.៩៥០.៧៦៤ | ១១.៥០៥.១៩១ |
| ទឹកប្រាក់ជំពាក់សាលារាជធានីភ្នំពេញ | ៦៤.៦៤២.៧៦៨ | ៥៦.២២៥.៩៤៧ |
| ទឹកប្រាក់ជំពាក់ទៅបុគ្គលិក | ៧៣១.៥១៦ | ៤.៥១០.២៨៦ |
| ប្រាក់ធានាប្រតិបត្តិការ | ៦៧.២៩២ | ៦៧.៣៥៦ |
| ពន្ធត្រូវបង់ផ្សេងៗ | ៧៥.១៨៤ | ៩៧២.៨៤៨ |
| គណនីត្រូវបង់ផ្សេងៗ | ៩.៥៩៨.៨៨៧ | ១២.៦០៥.៣៣៥ |
| | ៨៧.០៦៦.៤១១ | ៨៥.៨៨៦.៩៦៣ |
| | ២១៣.២២៤.២២៥ | ១៦៩.៧៤៣.៦៤០ |
| | ៣០២.១៧៤.៧៩១ | ២៥២.៦៤៧.៣៧២ |

(ក) គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ ត្រូវបានចាត់ថ្នាក់ជាបំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។

(ខ) គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម គឺជាគណនីមិនមានការប្រាក់ និងលក្ខខណ្ឌឥណទានពាណិជ្ជកម្មធម្មតា ដែលផ្តល់ជូន រ.ទ.ស.ភ ចាប់ពីមួយខែ ដល់បីខែ (២០២៣៖ មួយខែដល់បីខែ)។

(គ) ប្រាក់កក់ថ្លៃទឹកត្រូវបង្វិលសងវិញត្រូវបានប្រមូលពីអតិថិជន ដែលមានមូលដ្ឋានផ្អែកលើទំហំនៃនាឡិកាទឹកមុនពេលតភ្ជាប់ ហើយត្រូវបានកត់ត្រាទុកនូវទឹកប្រាក់ដែលទទួលបាននោះជាប្រាក់កក់ថ្លៃទឹកត្រូវបង្វិលសងវិញដែលស្ថិតនៅក្រោមបំណុលរយៈពេលវែង។

(ឃ) ទឹកប្រាក់ជំពាក់ទៅបុគ្គលិក គឺតំណាងឱ្យទឹកប្រាក់ទាំងអស់ដែលត្រូវទូទាត់ទៅឱ្យបុគ្គលិកដែលកើតឡើងមកពីការបញ្ចប់គម្រោងប្រាក់សោធននិវត្តន៍របស់ រ.ទ.ស.ភ ដែលមានប្រសិទ្ធភាពនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (“MoLVT”) បានចេញផ្សាយប្រកាសលេខ ៤៤៣ ស្តីពីការទូទាត់ប្រាក់បំណាច់អតីតភាពការងារ និងបន្ទាប់មក ក៏បានកែតម្រូវដោយសេចក្តីណែនាំលេខ ០៤២/១៩ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

## ១៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ (ត)

(ឃ) ប្រកាសនេះ តម្រូវអោយនិយោជកទាំងអស់ ក្រៅពីវិស័យវាយនភណ្ឌ និងកាត់ដេរ ធ្វើការទូទាត់ប្រាក់បំណាច់អតីតភាពការងារដល់និយោជិតរបស់ខ្លួនដូចខាងក្រោម៖

- ប្រាក់អតីតភាពការងារថ្មីក្នុងឆ្នាំ៖ ចាប់ពីឆ្នាំ២០១៩ តទៅចំនួនទឹកប្រាក់ស្មើនឹង ១៥ថ្ងៃនៃប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងទៀតក្នុងមួយឆ្នាំ។
- ការអនុវត្តត្រឡប់ក្រោយ (ប្រាក់រំលឹកអតីតភាពការងារ)៖ ចាប់ពីឆ្នាំ២០២២ តទៅចំនួនទឹកប្រាក់ស្មើនឹង ៦ថ្ងៃនៃប្រាក់បៀវត្សរ៍សុទ្ធក្នុងមួយឆ្នាំ។ សំវិធានធនលើប្រាក់រំលឹកអតីតភាពការងារត្រូវបានគណនាមិនលើសឱ្យ ពីចំនួនអតិបរមាស្មើនឹង ៦ខែនៃប្រាក់បៀវត្សរ៍សុទ្ធរបស់និយោជិត (អាស្រ័យលើរយៈពេលបម្រើការងាររបស់និយោជិត) ដែលមានអតីតភាពការងារមុនឆ្នាំ ២០១៩។

ការទូទាត់នឹងត្រូវបានធ្វើឡើងពីរដងក្នុងមួយឆ្នាំ គឺនៅក្នុងខែមិថុនា និងខែធ្នូ។ និយោជិតពុំមានសិទ្ធិទទួលបានប្រាក់បំណាច់រំលឹកអតីតភាពការងារនៅសល់ ដែលមិនទាន់បានទូទាត់នោះទេ ប្រសិនបើគាត់លាលែងពីការងារ។

យោងតាមប្រកាសលេខ ០១៨/២០ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ ចេញផ្សាយដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការពន្យារការទូទាត់ប្រាក់រំលឹកអតីតភាពការងារដែលមានមុនឆ្នាំ ២០១៩ និងពន្យារការទូទាត់ប្រាក់បំណាច់អតីតភាពការងារក្នុងឆ្នាំ២០២០។

ប្រកាសនេះ ត្រូវបានពន្យារពេលក្នុងការអនុវត្តរហូតដល់ឆ្នាំ២០២១។

ប្រាក់រំលឹកអតីតភាពការងារបង្គរសម្រាប់បុគ្គលិកដែលមានអតីតភាពការងារមុនឆ្នាំ២០១៩ ត្រូវបានទូទាត់ជាមួយនឹងឥណទានឱ្យបុគ្គលិក (ដូចដែលបានលាតត្រដាងក្នុងកំណត់សម្គាល់លេខ ១០ នៃរបាយការណ៍ហិរញ្ញវត្ថុ) ដោយចំនួនដែលនៅសល់ ត្រូវបានគ្រប់គ្រង និងទូទាត់ស្របតាមការបញ្ចប់គម្រោងប្រាក់សោធននិវត្តន៍ និងអតីតភាពការងារ។

ខាងក្រោមនេះជាបម្រែបម្រួលទឹកប្រាក់ជំពាក់ទៅបុគ្គលិក៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ៤.៥១០.២៨៦ | ៦.០៧១.៤៣៧ |
| សំវិធានធនក្នុងអំឡុងការិយបរិច្ឆេទ | ៤.៤៥១.១៩១ | ៣.៦៩៦.៧៦៥ |
| ការទូទាត់អតីតភាពការងារជាមួយឥណទានផ្តល់ឱ្យបុគ្គលិក | (៣.៧៦០.៥៦៨ | - |
| ការទូទាត់បានធ្វើឡើងក្នុងអំឡុងការិយបរិច្ឆេទ | (៤.៤៦៩.៣៩៣ | (៥.២៥៧.៩១៦) |
| | ៧៣១.៥១៦ | ៤.៥១០.២៨៦ |

## ១៨. គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ (ត)

(ង) ទម្រង់នៃការប្រឈមនៃរូបិយប័ណ្ណរបស់គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗមានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| រៀលខ្មែរ | ១៣៨.០២៨.០៩៩ | ១៥១.៩៥២.៨៨៨ |
| ដុល្លារអាមេរិក | ១៤៩.៣២៨.៩៣៦ | ៦០.៨៩៣.៦៣៦ |
| អឺរ៉ូ | ១៤.៨១៧.៧៥៦ | ៣៩.៨០០.៨៤៨ |
| | ៣០២.១៧៤.៧៩១ | ២៥២.៦៤៧.៣៧២ |

(ច) តារាងដូចខាងក្រោមសង្ខេបទម្រង់កាលកំណត់នៃគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗរបស់ រ.ទ.ស.ភ នៅចុងការិយបរិច្ឆេទរបាយការណ៍នីមួយៗ ដោយផ្អែកលើកាតព្វកិច្ចទូទាត់សងដែលមិនបានធ្វើអប្បហារតាមកិច្ចសន្យាដូចខាងក្រោម៖

| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ | តាមតម្រូវការ ឬ ក្នុងរយៈពេល ១ឆ្នាំ<br>ពាន់រៀល | ពី ១ឆ្នាំទៅ ៥ឆ្នាំ<br>ពាន់រៀល | លើសពី ៥ឆ្នាំ<br>ពាន់រៀល | សរុប<br>ពាន់រៀល |
|---|---|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ២១៣.២២៤.២២៥ | - | ៨៨.៩៥០.៥៦៦ | ៣០២.១៧៤.៧៩១ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៦៩.៧៤៣.៦៤០ | - | ៨២.៩០៣.៧៣២ | ២៥២.៦៤៧.៣៧២ |

## ១៩. ចំណូលពីការលក់

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ការលក់ទឹកស្អាត៖ | | |
| - អ្នកប្រើប្រាស់តាមផ្ទះ | ១១០.៦២០.៣២០ | ១០៥.១៥៦.០៣២ |
| - អ្នកប្រើប្រាស់ជាលក្ខណៈអាជីវកម្ម | ១៦០.១២៨.៣៦៧ | ១៤៥.៨៧៤.៨១២ |
| - គ្រឹះស្ថានសាធារណៈ | ២២.១២៣.៩៧៨ | ២០.៦៥៧.៨២៤ |
| - អាជ្ញាធររដ្ឋស្វយ័តនានា | ៩៣០.២៩២ | ៩២៨.៤១៦ |
| - អ្នកចែកចាយទឹកស្អាត | ៩.៩១០.៥៨៧ | ៩.៦៧៩.៨៩៥ |
| បង្គត់ភាពខុសគ្នាលើប្រាក់ចំណូលពីការលក់ទឹកស្អាត | ៧៤.៣៥៩ | ៦៩.៣៦៨ |
| - ដក៖ ការលុបចោលវិក្កយបត្រ | (១.៦១៤.៩៨០) | (៨៣៣.៣៩៩) |
| | ៣០២.១៧២.៩២៣ | ២៨១.៥៣២.៩៤៨ |
| ចំណូលបានពីការតភ្ជាប់បណ្តាញ | ១០.៨៣៦.៣៤៣ | ១១.៣១៤.៥២៦ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ៤.៦២៥.១០៦ | ៤.៣៤៣.២៧៥ |
| ការលក់គ្រឿងបន្លាស់ និងនាឡិកាទឹក | ១៤៤.៦២៤ | ២២៥.៣៩២ |
| | ៣១៧.៧៧៨.៩៩៦ | ២៩៧.៤១៦.១៤១ |

(ក) ការលក់ទឹកស្អាត

ចំណូលដែលទទួលបានពីការលក់ទឹកស្អាតត្រូវបានទទួលស្គាល់នៅចំណុចពេលមួយដែលទឹកត្រូវបានផ្គត់ផ្គង់ដោយ រ.ទ.ស.ភ និងត្រូវបានប្រើប្រាស់ដោយអតិថិជន។

(ខ) ចំណូលបានពីការតភ្ជាប់បណ្តាញ

ចំណូលបានពីការតភ្ជាប់បណ្តាញ ត្រូវបានទទួលស្គាល់ចំណុចពេលមួយដែលការតភ្ជាប់ បណ្តាញត្រូវបានធ្វើរួចរាល់។

(គ) ចំណូលការផ្លាស់ប្តូរនាឡិកាទឹក

ចំណូលការផ្លាស់ប្តូរនាឡិកាទឹក រ.ទ.ស.ភ ត្រូវបានទទួលស្គាល់ចំណុចពេលមួយដែល រ.ទ.ស.ភ ធ្វើការចេញវិក្កយបត្រដោយគិតថ្លៃ ៥០រៀល ក្នុង១ម៉ែត្រគូបក្នុងមួយខែនៃទំហំនាឡិកា។

## ២០. កម្រៃពីសេវាសាងសង់

ថ្លៃឈ្នួលសេវាកម្មសាងសង់បង្ហាញពី ថ្លៃឈ្នួលនៃសេវាកម្មសំណង់ដែលមានទាក់ទងនឹងការពង្រីកប្រព័ន្ធចែកចាយទឹកទៅកាន់អ្នកចែកចាយទឹកនៅតាមបណ្តាខេត្តនានា។

ចំណូលពីកិច្ចសន្យាសាងសង់ ត្រូវបានវាស់វែងតាមតម្លៃប្រតិបត្តិការថេរដែលបានយល់ព្រមក្រោមកិច្ចព្រមព្រៀង។

## ២០. ការប្រែប្រួលសេវាសាខសចំ (ត)

ប្រាក់ចំណូលត្រូវបានទទួលស្គាល់ នៅពេលការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានផ្ទេរទៅឱ្យអតិថិជនហើយវាទំនងជាថា រ.ទ.ស.ភ នឹងប្រមូលការតបស្នងដែលខ្លួននឹងត្រូវបានផ្តល់ជាថ្នូរនឹងទ្រព្យសម្បត្តិដែលនឹងត្រូវផ្ទេរជូនអតិថិជន។ អាស្រ័យលើលក្ខខណ្ឌនៃកិច្ចសន្យា និងច្បាប់ដែលអនុវត្តចំពោះការគ្រប់គ្រងកិច្ចសន្យាទ្រព្យសម្បត្តិអាចផ្ទេរទៅតាមពេលវេលា ឬនៅពេលណាមួយ។ ការគ្រប់គ្រងនៃទ្រព្យសម្បត្តិ គឺត្រូវបានផ្ទេរជាដំណាក់ៗប្រសិនបើការអនុវត្តន៍របស់ រ.ទ.ស.ភ មិនទាន់បានបង្កើតទ្រព្យសកម្ម ហើយ រ.ទ.ស.ភ មានសិទ្ធិទូទាត់សម្រាប់ការអនុវត្តដែលបានបំពេញរហូតដល់សព្វថ្ងៃ។

ប្រសិនបើការគ្រប់គ្រងការផ្ទេរទ្រព្យសកម្មក្នុងរយៈពេលមួយ ប្រាក់ចំណូលត្រូវបានទទួលស្គាល់ក្នុងអំឡុងពេលនៃកិច្ចសន្យាដោយប្រើវិធីសាស្ត្រធាតុចូល ដោយយោងទៅដំណាក់កាលឆ្ពោះទៅរកភាពពេញលេញនៃកាតព្វកិច្ចដែលបានអនុវត្តនោះ។ បើមិនដូច្នោះទេប្រាក់ចំណូលត្រូវបានទទួលស្គាល់នៅចំណុចមួយនៅពេលដែលអតិថិជនទទួលបានការត្រួតពិនិត្យទ្រព្យសម្បត្តិ។

ការវិនិច្ឆ័យសំខាន់ៗ ត្រូវបានទាមទារនៅក្នុងការកំណត់កាតព្វកិច្ចប្រតិបត្តិការ ការបែងចែកតម្លៃ និងការចំណាយលើការដាក់បញ្ចូលវិធីសាស្ត្រធាតុចូលដើម្បីទទួលស្គាល់ប្រាក់ចំណូលតាមពេលវេលា។

រ.ទ.ស.ភ កំណត់នូវកាតព្វកិច្ចអនុវត្ត ដែលមានលក្ខណៈខុសៗគ្នា និងជាសម្ភារដែលជាការវិនិច្ឆ័យនៅក្នុងបរិបទនៃកិច្ចសន្យា។ តម្លៃប្រតិបត្តិការត្រូវបានកំណត់ដោយផ្អែកទៅលើប្រាក់ចំណេញដែលបានប៉ាន់ប្រមាណមុននឹងបែងចែកទៅកាតព្វកិច្ចអនុវត្តដែលបានកំណត់។ រ.ទ.ស.ភ ក៏បានប៉ាន់ប្រមាណនូវតម្លៃកិច្ចសន្យាសរុបក្នុងការអនុវត្តវិធីសាស្ត្រធាតុចូលដើម្បីទទួលបានប្រាក់ចំណូលតាមពេលវេលា។

## ២១. ចំណូលផ្សេងៗ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ជំនួយពីរាជរដ្ឋាភិបាល និងជំនួយផ្សេងៗ | ២.០០៩.៩០៨ | ២.០០៩.៩០៨ |
| ការលក់គ្រឿងបន្លាស់ និងនាឡិកាទឹក | ១០.៨២៧.២៧២ | ១៥.៤១៤.៦៧៦ |
| ចំណូលពីការដាកពិន័យ | ១.៦៦៦.៤១៨ | ២៨០.៧០១ |
| ចំណូលផ្សេងៗ | ៤.០២៣.០៧២ | ៣.៤៣២.៨៦៥ |
| | ១៨.៥២៦.៦៧០ | ២១.១៣៨.១៥០ |

## ២២. ចំណាយប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្សបុគ្គលិក | ៤៣.១៦៤.៥៣៨ | ៤០.៨៣៥.៣៥៧ |
| ប្រាក់លើកទឹកចិត្ត | ១២.៥២១.៥១២ | ១១.៩៤១.៧៥៥ |
| ប្រាក់រង្វាន់ | ១១.៤៣៧.៥៥៩ | ១០.៧១៦.០១៧ |
| ការទូទាត់អតីតភាពការងារ | ១.០៧៨.៦២៤ | ១.១១៧.៨៨៩ |
| ប្រាក់ឈ្នួលសម្រាប់អ្នកម៉ៅការ | ២.២០៣.៣២៩ | ១.៤៦៥.៦២១ |
| ចំណាយផ្សេងៗទាក់ទងនឹងបុគ្គលិក | ១៥.១៤៦.៩៤៨ | ១៤.២១៥.៧៩៩ |
| | ៨៥.៥៥២.៥១០ | ៨០.២៩២.៤៣៨ |

## ២៣. ចំណាយវត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ក្លរ (Chlorine) | ៥.៦១៥.៨៧១ | ៤.៨៨៦.០៦៦ |
| ប៉ូលី អាលុយមីញ៉ូម ក្លរីដ (Poly Aluminium Chloride) | ៩.២៩១.២៦៧ | ៨.៨២០.៧៣៥ |
| អំបិល (Salt) | ១.២៣៥.៥៧៧ | ១.២៥៥.៤៣២ |
| កំបោរ (Lime) | ២.១០១.៦៨៥ | ៤៣២.៤០៤ |
| វត្ថុធាតុដើមផ្សេងទៀត | ៧៣២.៥៩០ | ៨៨០.៦៧៦ |
| | ១៨.៩៧៦.៥៩០ | ១៥.៨៧៥.៣១៣ |

## ២៤. ចំណាយវត្ថុធាតុដើមសម្រាប់ការតភ្ជាប់បណ្តាញ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល |
|---|---|---|
| ចំណាយលើការប្តូរនាឡិកាទឹក | ៥.៦៨៤.៩៥០ | ៤.២២៥.៩៥០ |
| ថ្លៃដើមបំពង់ | ១៤.៨៨៧ | ២៦.៥០១ |
| ថ្លៃដើមផ្សេងៗ | ៥៩៣.៨៤០ | ៥៦៤.០៦៣ |
| | ៦.២៩៣.២៧៧ | ៤.៨១៦.៥១៤ |

## ២៥. (ចំណេញ)/ខាតពីការបកប្រែរូបិយប័ណ្ណបរទេស - សុទ្ធ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ចំណេញពីការបកប្រែរូបិយប័ណ្ណបរទេស | (៧.៦៧៥.១៣៩) | (៤.៦៩៩.៤៨៦) |
| ខាតពីការបកប្រែរូបិយប័ណ្ណបរទេស | ៩.៨៧១.២៦០ | ១០.៥៥៦.៣៦៥ |
| | ២.១៩៦.១២១ | ៥.៨៥៦.៨១៩ |

## ២៦. ចំណូល/(ចំណាយ) ការប្រាក់

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ចំណូលការប្រាក់៖ | | |
| - ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារ (ក) | ៦.៦១៣.៤៩៤ | ៦.៧៣៧.៧៦៧ |
| - ចំណេញពីការបកប្រែរូបិយប័ណ្ណបរទេសរបស់ប្រាក់កម្ចី | ៥០.៥៥៥.៨៩៣ | ៣២.៣០០.៨២៤ |
| | ៥៧.១៦៩.៣៨៧ | ៣៩.០៣៨.៥៩១ |
| ចំណាយការប្រាក់៖ | | |
| - ចំណាយការប្រាក់លើប្រាក់កម្ចី (ខ) | (១៩.៣៩៩.០៩១) | (១៥.១៧៨.៥៦០) |
| - ខាតសុទ្ធពីការបកប្រែរូបិយប័ណ្ណបរទេសរបស់ប្រាក់កម្ចី | (២៤.៥៨០.៤៥១) | (២២.៣៣២.៨៦៩) |
| - មូលធនកម្មការប្រាក់លើទ្រព្យសកម្មមានលក្ខណៈគ្រប់គ្រាន់ | ៤.៩៧៨.០១៦ | ១១.៦៥០.៨៣២ |
| | (៣៩.០០១.៤៧៦) | (២៥.៨៦០.៥៩៧) |
| ចំណូលការប្រាក់ - សុទ្ធ | ១៨.១៦៧.៩១១ | ១៣.១៧៧.៩៩៤ |

(ក) ចំណូលការប្រាក់ គឺជាចំណូលពីគណនីប្រាក់បញ្ញើសន្សំ និងប្រាក់បញ្ញើផ្សេងៗដែលនៅក្នុងធនាគារក្នុងស្រុកក្នុងគ្រា។

(ខ) ចំណាយការប្រាក់ គឺជាចំណាយការប្រាក់ទៅលើប្រាក់កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង និងប្រាក់កម្ចីដែលទទួលបានបន្តពី ក.ស.ហ.វ ដែលត្រូវទទួលបានការឧបត្ថម្ភតាមរយៈកម្ចីដែលទទួលបានពី ADB EIB និង JICA។

## ២៧. ចំណាយពន្ធ

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ចំណាយពន្ធលើប្រាក់ចំណេញ៖ | | |
| ឆ្នាំចរន្ត | ៨.៩៧៨.៩០៨ | ១១.៣១២.៨៧០ |
| ចំណាយពន្ធពន្យារ (កំណត់សម្គាល់លេខ ១៧)៖ | | |
| ភាពខុសគ្នាបណ្ដោះអាសន្ន | ១៣.១៥២.៥៤០ | ៩.៤៦០.៧០៦ |
| សំវិធានធនខ្វះក្នុងការិយបរិច្ឆេទមុន | - | ៥.៥១៦.៨៩៩ |
| | ១៣.១៥២.៥៤០ | ១៤.៩៧៧.៦០៥ |
| ចំណាយពន្ធសរុប | ២២.១៣១.៤៤៨ | ២៦.២៩០.៤៧៥ |

ផ្អែកលើច្បាប់ស្ដីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា រ.ទ.ស.ភ មានកាតព្វកិច្ចក្នុងការបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា ២០% (២០២៣៖ ២០%) លើប្រាក់ចំណេញជាប់ពន្ធ ឬពន្ធអប្បបរមាក្នុងអត្រា ១% (២០២៣៖ ១%) នៃចំណូលសរុប មួយណាមានតម្លៃច្រើនជាង។

## ២៧. ចំណាយពន្ធ (ត)

តួលេខក្នុងការសម្របសម្រួលរវាងចំណាយពន្ធ និងផលគុណនៃប្រាក់ចំណេញគណនេយ្យនឹងអត្រាពន្ធដាររបស់ រ.ទ.ស.ភ មានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | ១០៧.១៧៤.៣៦១ | ៩៨.៩៣៨.០៤៧ |
| ពន្ធគណនាតាមអត្រាពន្ធស្របច្បាប់នៅកម្ពុជា ២០% (២០២៣៖ ២០%) | ២១.៤៣៤.៨៧២ | ១៩.៧៨៧.៦០៩ |
| ឥទ្ធិពលពន្ធដារទៅលើ៖ | | |
| ចំណាយដែលមិនអាចកាត់កង | ៦៩៦.៥៧៦ | ៩៨៥.៩៦៧ |
| | ២២.១៣១.៤៤៨ | ២០.៧៧៣.៥៧៦ |
| សំវិធានធនខ្វះលើពន្ធពន្យារក្នុងការិយបរិច្ឆេទមុន | - | ៥.៥១៦.៨៩៩ |
| ចំណាយពន្ធសរុប | ២២.១៣១.៤៤៨ | ២៦.២៩០.៤៧៥ |

## ២៨. ចំណេញក្នុងមួយភាគហ៊ុន

(ក) ចំណេញក្នុងមួយភាគហ៊ុនគោល

ចំណេញក្នុងមួយភាគហ៊ុនគោល ត្រូវបានគណនាដោយយកប្រាក់ចំណេញរបស់ភាគហ៊ុនិក របស់ រ.ទ.ស.ភ ចែកនឹងចំនួនភាគហ៊ុនមធ្យមទម្ងន់ដែលបានបោះផ្សាយក្នុងការិយបរិច្ឆេទ។

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ប្រាក់ចំណេញជាកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុនធម្មតា | ៨៥.០៤២.៩១៣ | ៧២.៦៤៧.៥៧២ |
| ចំនួនភាគហ៊ុនមធ្យមទម្ងន់ | ៨៦.៩៧៣.១៦២ | ៨៦.៩៧៣.១៦២ |
| ចំណេញក្នុងមួយភាគហ៊ុនគោល | ៩៧៧,៨១ | ៨៣៥,២៩ |
| ចំណេញក្នុងមួយភាគហ៊ុនថយចុះ | ៩៧៧,៨១ | ៨៣៥,២៩ |

(ខ) ចំណេញក្នុងមួយភាគហ៊ុនថយចុះ

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ត្រូវបានគណនាដោយកែប្រែចំនួនមធ្យមនៃភាគហ៊ុនធម្មតាដែលមាន ដោយសន្មតថាមានការផ្ទេរភាគហ៊ុនដែលមានសក្តានុពលទាំងអស់ទៅជាភាគហ៊ុនធម្មតា។

សម្រាប់ការិយបរិច្ឆេទបញ្ចប់នេះ រ.ទ.ស.ភ មិនមានភាគហ៊ុនដែលមានសក្តានុពលអាចផ្ទេរទៅជាភាគហ៊ុនធម្មតានោះទេ។ ដូចនេះចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញក្នុងមួយភាគហ៊ុនគោល។

## ២៩. ភាគលាភ

| | ២០២៤ | | ២០២៣ | |
|---|---|---|---|---|
| | ភាគលាភក្នុងមួយហ៊ុន រៀល | ចំនួនទឹកប្រាក់នៃភាគលាភ ពាន់រៀល | ភាគលាភក្នុងមួយហ៊ុន រៀល | ចំនួនទឹកប្រាក់នៃភាគលាភ ពាន់រៀល |
| ការប្រកាសភាគលាភលើកដំបូង និងលើកចុងក្រោយ | ៣៥០ | ៤.៥៦៦.០៩១ | ៣៣០ | ៤.៣០៥.១៥៨ |

នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤ ក្រុមប្រឹក្សាភិបាលបានស្នើ និងអនុម័តភាគលាភសម្រាប់ការិយបរិច្ឆេទបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលមានតម្លៃ ៣៥០រៀលក្នុងមួយភាគហ៊ុន ដែលគិតជាទឹកប្រាក់សរុបចំនួន ៤.៥៦៦.០៩១.៣៥០រៀលជូនភាគហ៊ុនិក។

## ៣០. ការលាតត្រដាងពីភាគីពាក់ព័ន្ធ

(ក) ភាគីមួយត្រូវបានចាត់ទុកថាជាសម្ព័ន្ធញាតិជាមួយរ.ទ.ស.ភ ប្រសិនបើភាគីនោះមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោល ឬមានឥទ្ធិពលសំខាន់លើភាគីមួយនោះក្នុងការសម្រេចចិត្តហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬបញ្ច្រាសមកវិញ ឬបើ រ.ទ.ស.ភ និងភាគីនោះស្ថិតក្រោមការគ្រប់គ្រងតែមួយ ឬស្ថិតក្រោមឥទ្ធិពលសំខាន់រួម។ ភាគីពាក់ព័ន្ធ អាចជារូបវន្ត ឬនីតិបុគ្គល។

គណៈគ្រប់គ្រងសំខាន់ៗ របស់ រ.ទ.ស.ភ រួមមានបុគ្គលទាំងឡាយណា (រួមបញ្ចូលទាំងអភិបាល រ.ទ.ស.ភ) ដែលមានសិទ្ធិអំណាច និងទំនួលខុសត្រូវក្នុងការគ្រោង ដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ រ.ទ.ស.ភ ដោយផ្ទាល់ ឬដោយប្រយោល។

(ខ) រ.ទ.ស.ភ មានប្រតិបត្តិការជាមួយនឹងភាគីពាក់ព័ន្ធក្នុងការិយបរិច្ឆេទនេះដូចខាងក្រោម៖

| | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល |
|---|---|---|
| ក្រុមហ៊ុនក្រោមការគ្រប់គ្រងតែមួយ | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | | |
| ការប្រាក់លើប្រាក់កម្ចីដែលបានបង់ | ១៩.៣៩៦.៦៥៥ | ១៥.១៧៨.៥៦០ |

សមតុល្យជាមួយភាគីពាក់ព័ន្ធ នៅចុងរយៈពេលរាយការណ៍ត្រូវបានលាតត្រដាង នៅក្នុងកំណត់សម្គាល់លេខ ១៥ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធព័ណ៌នាខាងលើត្រូវបានធ្វើឡើងតាមលក្ខណៈពាណិជ្ជកម្មធម្មតា។

(គ) អត្ថប្រយោជន៍គណៈគ្រប់គ្រងសំខាន់ៗ សម្រាប់ការិយបរិច្ឆេទនេះមានដូចខាងក្រោម៖

| | ២០២៤ ពាន់រៀល | ២០២៣ ពាន់រៀល |
|---|---|---|
| ប្រាក់បៀវត្ស និងការចំណាយផ្សេងៗ | ២.៤៥៨.៤២២ | ២.៣៩៨.២៩៩ |

## ៣១. ចំណាយជាប់កិច្ចសន្យា

នៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ រ.ទ.ស.ភ បានជាប់កិច្ចសន្យាក្នុងការចំណាយមូលធនកម្មទៅលើទ្រព្យសកម្មខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ២៨៣.០៥៧.៨៨១ | ៣៧.២៤០.១៣៧ |
| សេវាផ្តល់ការប្រឹក្សាយោបល់ | ២.៦៦៩.៧៩៤ | ៩.៧៦២.៨៧៧ |
| ការទិញបំពង់ដែកស្វិត បរិក្ខារភ្ជាប់ និងបរិក្ខារផ្សេងៗ | ១.០៥៤.១៧៦ | ២៦.៩៥០.៥៤៦ |
| | ២៨៦.៧៨១.៨៥១ | ៧៣.៩៥៣.៥៦០ |

## ៣២. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ

(ក) ការគ្រប់គ្រងមូលធន

គោលបំណងចម្បងរបស់ រ.ទ.ស.ភ ក្នុងការគ្រប់គ្រងមូលធន គឺដើម្បីធានាឱ្យបានថា រ.ទ.ស.ភ អាចបន្តប្រតិបត្តិការរបស់ខ្លួន ដោយឈរលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម ហើយស្របពេលជាមួយគ្នានេះធ្វើឱ្យមានកំណើនផលលាភដល់ភាគហ៊ុនិក តាមរយៈការបង្កើនប្រសិទ្ធភាពអនុបាតបំណុល និងមូលធន។ ពុំមានការផ្លាស់ប្តូរយុទ្ធសាស្ត្រទូទៅរបស់ រ.ទ.ស.ភ តាំងពីការិយបរិច្ឆេទមុនទេ។

រ.ទ.ស.ភ បានគ្រប់គ្រងរចនាសម្ព័ន្ធមូលធន និងធ្វើនិយ័តកម្មលើរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃលក្ខខណ្ឌសេដ្ឋកិច្ច។ ដើម្បីរក្សា ឬធ្វើនិយ័តកម្មលើរចនាសម្ព័ន្ធមូលធន រ.ទ.ស.ភ អាចធ្វើ និយ័តកម្មលើការទូទាត់ភាគលាភទៅឱ្យភាគហ៊ុនិក ការបង្វិលភាគហ៊ុនទៅឱ្យភាគហ៊ុនិក ឬការបោះផ្សាយភាគហ៊ុនថ្មី។ ពុំមានការប្រែប្រួលលើគោលបំណងគោលនយោបាយ ឬដំណើរការផ្សេងៗទេ នៅក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

រ.ទ.ស.ភ ឃ្លាំមើល និងរក្សាកម្រិតប្រុងប្រយ័ត្នរបស់បំណុលសរុប និងដើម្បីឱ្យបាននូវអនុលោមភាពតម្រូវការមូលធនដែលដាក់ដោយផ្នែកខាងក្រៅ។

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

គោលបំណងនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ គឺដើម្បីបង្កើនប្រសិទ្ធភាពតម្លៃសម្រាប់ភាគហ៊ុនិក ហើយទន្ទឹមគ្នានេះក៏ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងដោយសារការប្រែប្រួលនៃទីផ្សារហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់គោលបំណងនេះ និងគោលការណ៍មូលដ្ឋាននៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ។ ហេតុនេះគណៈគ្រប់គ្រងបង្កើតគោលការណ៍លម្អិតដូចជាកម្រិតសិទ្ធិអំណាច ទំនួលខុសត្រូវលើការត្រួតពិនិត្យ ការកំណត់ និងវាស់វែងអត្តសញ្ញាណហានិភ័យ និងដែនកំណត់នៃការប្រឈមដោយអនុលោមតាមគោលបំណង និងគោលការណ៍មូលដ្ឋានដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

រ.ទ.ស.ភ ប្រឈមជាចម្បងទៅនឹងហានិភ័យរូបិយប័ណ្ណបរទេស ហានិភ័យអត្រាការប្រាក់ហានិភ័យឥណទាន ព្រមទាំងហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់។ ព័ត៌មានស្តីពីការគ្រប់គ្រងការប្រឈមដែលពាក់ព័ន្ធមានដូចខាងក្រោម៖

## ៣២. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(១) ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេស គឺហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុ ដែលអាចនឹងមានការផ្លាស់ប្តូរដោយការប្រែប្រួលអត្រាប្តូរប្រាក់បរទេស។ ប្រឈមមុខនឹងហានិភ័យនៃការផ្លាស់ប្តូរអត្រាប្តូរប្រាក់បរទេសរបស់ រ.ទ.ស.ភ ពាក់ព័ន្ធជាចម្បងនឹងសកម្មភាពប្រតិបត្តិការរបស់ រ.ទ.ស.ភ (នៅពេលសាច់ប្រាក់ និងសមមូលសាច់ប្រាក់ ការវិនិយោគរយៈពេលខ្លី ការទិញ និងកម្ចីត្រូវបានចារឹកតម្លៃជារូបិយប័ណ្ណបរទេស)។

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យរបស់ រ.ទ.ស.ភ ដែលមានទឹកប្រាក់មិនមែនជារូបិយប័ណ្ណមុខងារ មានដូចខាងក្រោម៖

| | ២០២៤<br>ពាន់រៀល | ២០២៣<br>ពាន់រៀល<br>(កំណត់ឡើងវិញ) |
|---|---|---|
| <u>ការវិនិយោគរយៈពេលខ្លី</u> | | |
| ដុល្លារអាមេរិក | ៦៤.៩៦១.៣៦០ | ៩២.៣១៦.០០៣ |
| <u>សមតុល្យសាច់ប្រាក់ និងធនាគារ</u> | | |
| ដុល្លារអាមេរិក | ១.៣៧៣.២៨៧ | ៤.១៦៨.៥៨០ |
| <u>គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ</u> | | |
| ដុល្លារអាមេរិក | ១១.៥៥៧.៧៧១ | ៦៤០.២៧៧ |
| <u>កិច្ចសន្យាទ្រព្យសកម្ម</u> | | |
| ដុល្លារអាមេរិក | ៤.៣៩៨.៥៦៤ | ៧.៦២៤.៣៣៩ |
| <u>កិច្ចសន្យាបំណុល</u> | | |
| ដុល្លារអាមេរិក | ៣.៥២០.៣៩៥ | ៤.២៤៨.៨៦០ |
| <u>ប្រាក់កម្ចី</u> | | |
| ដុល្លារអាមេរិក | ១.៣៦៦.១១២.៤១២ | ១.២២៨.៣៥១.៥៩១ |
| អឺរ៉ូ | ៨.៤២៥.៨៧៨ | ២៧.៣៨០.៦០៧ |
| Special Drawing Right | ២៧.០៩៨.០១៩ | ៣០.៥៥៨.៤២៩ |
| យ៉េនជប៉ុន | ២៨.៩៨៣.០៧៣ | ៣៤.៣១១.៤៥៨ |
| <u>គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ</u> | | |
| ដុល្លារអាមេរិក | ១៤៩.៣២៨.៩៣៦ | ៦០.៨៩៣.៦៣៦ |
| អឺរ៉ូ | ១៤.៨១៧.៧៥៦ | ៣៩.៨០០.៨៤៨ |

## ៣២. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(១) ហានិភ័យរូបិយប័ណ្ណបរទេស (ត)

តារាងខាងក្រោមនេះបង្ហាញអំពីការវិភាគភាពងាយរងផលប៉ះពាល់របស់ រ.ទ.ស.ភ ទៅនឹងការប្រែប្រួល ដែលអាចកើតមានឡើងទៅលើអត្រាប្តូរប្រាក់ដុល្លារអាមេរិក អឺរ៉ូ SDR និងយ៉េនជប៉ុន ធៀបទៅនឹងរូបិយប័ណ្ណមុខងាររនៃ រ.ទ.ស.ភ ជាមួយកត្តាអថេរផ្សេងៗទៀតនៅដដែលៈ

| | | ២០២៤ | ២០២៣ |
|---|---|---|---|
| **ប្រាក់ចំណេញក្រោយដកពន្ធ** | | **ពាន់រៀល** | **ពាន់រៀល** |
| ដុល្លារ/រៀល | - កើនឡើង ៣% (២០២៣៖ ៣%) | (៣១.១៩៤.៦៦៦) | (២៧.១៦៤.៨០៨) |
| | - ចុះខ្សោយ ៣% (២០២៣៖ ៣%) | ៣១.១៩៤.៦៦៦ | ២៧.១៦៤.៨០៨ |
| អឺរ៉ូ/រៀល | - កើនឡើង ៣% (២០២៣៖ ៣%) | (២០២.២២១) | (៦៥៧.១៣៥) |
| | - ចុះខ្សោយ ៣% (២០២៣៖ ៣%) | ២០២.២២១ | ៦៥៧.១៣៥ |
| SDR/រៀល | - កើនឡើង ៣% (២០២៣៖ ៣%) | (៦៥០.៣៥២) | (៧៣៣.៤០២) |
| | - ចុះខ្សោយ ៣% (២០២៣៖ ៣%) | ៦៥០.៣៥២ | ៧៣៣.៤០២ |
| យ៉េនជប៉ុន/រៀល | - កើនឡើង ៣% (២០២៣៖ ៣%) | (៦៩៥.៥៩៤) | (៨២៣.៤៧៥) |
| | - ចុះខ្សោយ ៣% (២០២៣៖ ៣%) | ៦៩៥.៥៩៤ | ៨២៣.៤៧៥ |

(២) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតរបស់ឧបករណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ អាចនឹងផ្លាស់ប្តូរដោយសារតែការប្រែប្រួលរបស់អត្រាការប្រាក់ទីផ្សារ។

ការប្រឈមរបស់ រ.ទ.ស.ភ ទៅនឹងហានិភ័យអត្រាការប្រាក់ កើតឡើងជាចម្បងចេញពីឥណទាន និងប្រាក់កម្ចី។ រ.ទ.ស.ភ គ្រប់គ្រងការប្រឈមអត្រាការប្រាក់របស់ខ្លួន ដោយឃ្លាំមើលយ៉ាងយកចិត្តទុកលើទីផ្សារបំណុល នៅពេលដែលចាំបាច់ រក្សាឱ្យបានការលាយគ្នាប្រកបដោយភាពប្រុងប្រយ័ត្នរវាង កម្ចីមានអត្រាថេរ និងប្រែប្រួល។ រ.ទ.ស.ភ ពុំបានប្រើប្រាស់ ឧបករណ៍ហិរញ្ញវត្ថុ និស្សន្ទដើម្បីទប់ស្កាត់កាតព្វកិច្ចបំណុលណាមួយនោះ។

<u>ការវិភាគភាពងាយរងផលប៉ះពាល់នៃហានិភ័យអត្រាការប្រាក់</u>

តារាងខាងក្រោមបង្ហាញពីការវិភាគលើភាពងាយរងផលប៉ះពាល់របស់ រ.ទ.ស.ភ ប្រសិនបើអត្រាការប្រាក់នៅចុងកាលបរិច្ឆេទរាយការណ៍ ប្រែប្រួល ០,១% និងកត្តាអថេរផ្សេងទៀតនៅដដែលៈ

| | ២០២៤ | ២០២៣ |
|---|---|---|
| | **ពាន់រៀល** | **ពាន់រៀល** |
| **ប្រាក់ចំណេញក្រោយដកពន្ធ** | | |
| - កំណើន ០,១% (២០២៣:០,១%) | (១៨១.៦៨៦) | (២០០.៦២០) |
| - តំហយ ០,១% (២០២៣៖០,១%) | ១៨១.៦៨៦ | ២០០.៦២០ |

## ៣២. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(២) ហានិភ័យអត្រាការប្រាក់ (ត)

ភាពងាយរងផលប៉ះពាល់នៃអត្រាការប្រាក់ក្នុងឆ្នាំ២០២៤ ខ្ពស់ជាងឆ្នាំ២០២៣ ដោយសារតែកំណើននៃមូលធនកម្មការប្រាក់នៅក្នុងការិយបរិច្ឆេទ។ ការប៉ាន់ស្មាននៃបម្រែបម្រួលជាភាគរយលើការវិភាគ ភាពងាយរងផលប៉ះពាល់នៃអត្រាការប្រាក់ គឺផ្អែកលើបរិស្ថានទីផ្សារបច្ចុប្បន្នដែលអាចធ្វើវិភាគបាន។

(៣) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាការខាតបង់ផ្នែកហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ ដោយសមភាគីនៃឧបករណ៍ហិរញ្ញវត្ថុមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងកិច្ចសន្យា។ ជាចម្បង រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានដោយសារការលក់ហើយទូទាត់តាមក្រោយ។ តាមគោលការណ៍របស់ រ.ទ.ស.ភ ត្រូវឃ្លាំមើលជាប្រចាំទៅលើស្ថានភាពហិរញ្ញវត្ថុរបស់សមភាគីទាំងនោះ ដើម្បីធានាថា រ.ទ.ស.ភ ប្រឈមនឹងហានិភ័យឥណទានតិចតួចបំផុត។

ការប្រឈមចម្បងរបស់ រ.ទ.ស.ភ ចំពោះហានិភ័យឥណទាន កើតឡើងតាមរយៈគណនីអតិថិជនពាណិជ្ជកម្មអតិថិជនរបស់ខ្លួន។ រ.ទ.ស.ភ គ្រប់គ្រងហានិភ័យឥណទានលើការលក់ដោយធានាថាអតិថិជនរបស់ខ្លួនមានជំហរហិរញ្ញវត្ថុ និងប្រវត្តិឥណទានល្អ។

រ.ទ.ស.ភ កំណត់ទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចទូទាត់បាន នៅពេលដែលការទូទាត់តាមកិច្ចសន្យាហួសពេលកំណត់ ហើយនៅពេលដែលព័ត៌មានផ្ទៃក្នុង ឬ ខាងក្រៅបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុមិនអាចប្រមូលមកវិញបាន។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានលុបចោលនៅពេលដែលគ្មានការរំពឹងទុកសមហេតុផលកស្តីពីស្តារលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជនពាណិជ្ជកម្ម រ.ទ.ស.ភ តម្រូវឱ្យមានប្រាក់កក់មុនពេលមានការតភ្ជាប់ទឹកត្រូវបានធ្វើឡើង។ ចំពោះនាយកដ្ឋានរបស់រដ្ឋាភិបាល រ.ទ.ស.ភ មិនតម្រូវឱ្យមានប្រាក់កក់ឡើយដោយ រ.ទ.ស.ភ ជឿជាក់ថាអាចប្រមូលពីនាយកដ្ឋានទាំងនេះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ប្រភពនៃហិរញ្ញវត្ថុសំរាប់នាយកដ្ឋានទាំងនេះ) ដែលជាអ្នកគ្រប់គ្រងហិរញ្ញវត្ថុ និង ភាគហ៊ុនិកនៃ រ.ទ.ស.ភ។

គោលនយោបាយនៃការកាត់ប្រាក់កក់ គឺអនុវត្តទៅតាមអតិថិជនដែលមិនទាន់បានទូទាត់បំណុលរបស់ពួកគេទៅតាមលក្ខខណ្ឌឥណទាន។

ដើម្បីកាត់បន្ថយហានិភ័យលើសាច់ប្រាក់នៅក្នុងធនាគារ និងការវិនិយោគរយៈពេលខ្លី (ប្រាក់បញ្ញើកាលកំណត់របស់ធនាគារ) រ.ទ.ស.ភ បានបែងចែកប្រាក់បញ្ញើរបស់វាទៅតាមធនាគារខុសៗគ្នាដោយប្រើប្រាស់ធនាគារក្នុងស្រុកធំៗ និងមានឈ្មោះល្បីមួយចំនួនដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

<u>ការប្រឈមចំពោះហានិភ័យឥណទាន និងទម្រង់នៃការប្រមូលផ្តុំហានិភ័យឥណទាន</u>

ការប្រឈមអតិបរមាទៅនឹងហានិភ័យឥណទានរបស់ រ.ទ.ស.ភ តំណាងដោយតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុនីមួយៗ។

នៅចុងការិយបរិច្ឆេទរាយការណ៍:

(១) ប្រមាណ ១០% (២០២៣៖ ២៨%) គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗរបស់ រ.ទ.ស.ភ គឺជំពាក់ដោយអតិថិជនជាអ្នកប្រើប្រាស់តាមផ្ទះ។

(២) ប្រមាណ ១៧% (២០២៣៖ ១៩%) គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗរបស់ រ.ទ.ស.ភ គឺជំពាក់ដោយអតិថិជនជាលក្ខណៈអាជីវកម្ម។

## ៣២. ការគ្រប់គ្រងមូលធន និងហានិភ័យហិរញ្ញវត្ថុ (ត)

(ខ) ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

(៣) ហានិភ័យឥណទាន (ត)

<u>ការប្រឈមចំពោះហានិភ័យឥណទាន និងទម្រង់នៃការប្រមូលផ្តុំហានិភ័យឥណទាន</u> (ត)

នៅចុងការិយបរិច្ឆេទរាយការណ៍៖ (ត)

(៣) ប្រមាណ ៧១% (២០២៣៖ ៥១%) គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗរបស់ រ.ទ.ស.ភ គឺជំពាក់ដោយអតិថិជនគ្រឹះស្ថានសាធារណៈ។

(៤) ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់

ហានិភ័យសាច់ប្រាក់ងាយស្រួល និងលំហូរសាច់ប្រាក់ កើតឡើងពីការគ្រប់គ្រងរបស់ រ.ទ.ស.ភ ទៅលើមូលធនបង្វិល។ វាគឺជាហានិភ័យមួយ ដែល រ.ទ.ស.ភ នឹងជួបប្រទះផលលំបាកក្នុងការបំពេញនូវកាតព្វកិច្ចហិរញ្ញវត្ថុនៅពេលដែលដល់កាលកំណត់ត្រូវសង។

រ.ទ.ស.ភ គ្រប់គ្រងលំហូរសាច់ប្រាក់ពីប្រតិបត្តិការ និងភាពមានស្រាប់នៃមូលនិធិយ៉ាងសកម្ម ដើម្បីធានាបាននូវរាល់តម្រូវការប្រតិបត្តិការ វិនិយោគ និងហិរញ្ញប្បទាន។ នៅក្នុងយុទ្ធសាស្ត្រនៃការគ្រប់គ្រងហានិភ័យសាច់ប្រាក់ងាយស្រួល រ.ទ.ស.ភ រក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលគ្រប់គ្រាន់សម្រាប់គាំទ្រដល់សកម្មភាព ប្រតិបត្តិការរបស់ រ.ទ.ស.ភ។

## ៣៣. ព័ត៌មានតាមផ្នែក

រ.ទ.ស.ភ ផ្គត់ផ្គង់ទឹកទៅដល់ក្រុមគ្រួសារ ដែលមានទីលំនៅនៅទីក្រុងភ្នំពេញ និងតាមបណ្តាទីតាំងនានាដែលនៅជុំវិញទីក្រុង។ ដើម្បីទ្រទ្រង់អាជីវកម្មចែកចាយទឹកប្រើប្រាស់ រ.ទ.ស.ភ ត្រូវតែផ្គត់ផ្គង់នូវបណ្តាញ ទឹកធ្វើជាសេវាកម្មទ្រទ្រង់។ ប្រាក់ចំណូលបានមកពីការតភ្ជាប់ទឹក (សេវាកម្មទ្រទ្រង់សម្រាប់ការផ្គត់ផ្គង់ទឹកប្រើប្រាស់) មានចំនួនតិចជាង ៣% (២០២៣៖ ៤%) នៃប្រាក់ចំណូលសរុបខណៈពេលដែលចំណូលដែលបានមកពីការផ្គត់ផ្គង់ទឹកប្រើប្រាស់មានចំនួន ៩៧% (២០១៩៖ ៩៦%) នៃប្រាក់ចំណូលសរុបរបស់ រ.ទ.ស.ភ។

រ.ទ.ស.ភ មានផ្នែកមួយនៃរបាយការណ៍ដែលមានឈ្មោះថាការផ្គត់ផ្គង់ទឹកប្រើប្រាស់។ ប្រធានផ្នែកប្រតិបត្តិការបានធ្វើការសម្រេចចិត្ត (ក្រុមខាងផ្នែកគ្រប់គ្រង) ពិនិត្យឡើងវិញនូវរបាយការណ៍គ្រប់គ្រងផ្នែកខាងក្នុងដែលរាយការណ៍អំពីការបំពេញមុខងាររបស់ចម្រៀកនៃការផ្គត់ផ្គង់ទឹកប្រើប្រាស់ជាទាំងមូល ដើម្បីវាយតម្លៃការបំពេញមុខងារ និងបែងចែកធនធាន។ ប្រធានផ្នែកប្រតិបត្តិធ្វើការត្រួតពិនិត្យលើការបំពេញមុខងារលើផ្នែកនៃរបាយការណ៍ដោយវាស់វែងលើប្រាក់ចំណេញដុល ប្រាក់ចំណេញមុនពេលកាត់ពន្ធ និងប្រាក់ចំណេញក្រោយពេលកាត់ពន្ធដោយប្រៀបធៀបជាមួយកាលបរិច្ឆេទឆ្នាំមុន។

## ៣៤. យថាភាពនៃពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងប្រទេសកម្ពុជា គឺមានភាពថ្មី និងត្រូវបានកំណត់លក្ខណៈដោយប្រភេទពន្ធជាច្រើន និងជានិច្ចកាល មានការផ្លាស់ប្តូរនៃបទបញ្ញត្តិ ដែលជាធម្មតាមានលក្ខណៈមិនសូវជាក់លាក់ មានភាពផ្ទុយគ្នា និងប្រែប្រួលទៅតាមការបកស្រាយ។ ជានិច្ចកាល ការបកស្រាយផ្សេងៗគ្នាកើតមានក្នុងចំណោម អាជ្ញាធរពន្ធ និងយុត្តាធិការជាច្រើន។ ពន្ធត្រូវបានត្រួតពិនិត្យឡើងវិញ និងស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួនដែលទទួលការអនុញ្ញាតដោយច្បាប់ក្នុងការដាក់ការផាកពិន័យធ្ងន់ធ្ងរ ការដាក់ទណ្ឌកម្ម និងការប្រាក់។ ការពិតទាំងនេះប្រហែលជាអាចបង្កើតហានិភ័យនៃពន្ធនៅក្នុងប្រទេសកម្ពុជាខ្លាំងជាងនៅប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាបំណុលពន្ធត្រូវបានកត់ត្រាយ៉ាងគ្រប់គ្រាន់ដោយផ្អែកលើការបកស្រាយបទបញ្ញត្តិពន្ធរបស់ខ្លួន។ ប៉ុន្តែអាជ្ញាធរដែលពាក់ព័ន្ធអាចមានការបកស្រាយផ្សេងគ្នា ហើយឥទ្ធិពលជាសារវន្តរបស់វាអាចមានសារៈសំខាន់ខ្លាំង។

## ៣៥. ព្រឹត្តិការណ៍សំខាន់ៗក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ រ.ទ.ស.ភ និង ក្រុមហ៊ុន VINCI Construction Grands Projects បាន ចុះកិច្ចព្រមព្រៀងលើការសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងដំណាក់កាលទី៣ ដែលមានសមត្ថភាព ផលិតទឹកបាន១៩៥.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ។ កិច្ចសន្យាសាងសង់នេះមានទឹកប្រាក់ចំនួន ១០៣លានដុល្លារ អាមេរិក ដែលបានពីផ្តល់កម្ចីហិរញ្ញប្បទានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់មូលនិធិដោយដៃគូអភិវឌ្ឍន៍ បារាំងចំនួន ៦១លានដុល្លារអាមេរិក និងមូលធនរបស់ រ.ទ.ស.ភ ចំនួន ៤២លានដុល្លារអាមេរិក។ ការសាងសង់ បានចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០២៤ និងបញ្ចប់នៅត្រីមាសទី៣ ឆ្នាំ២០២៧ ។

## ៣៦. តួលេខប្រៀបធៀប

តួលេខប្រៀបធៀបមួយចំនួនត្រូវបានគេធ្វើចំណាត់ថ្នាក់ឡើងវិញ ដើម្បីឱ្យស្របទៅនឹងការបង្ហាញក្នុងគ្រា បច្ចុប្បន្ន។

| | កំណត់ឡើងវិញ<br>ពាន់រៀល | ដូចដែលបាន<br>រាយការណ៍ពីមុន<br>ពាន់រៀល |
|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | |
| **បំណុលរយៈពេលវែង** | | |
| កម្ចី | ៤៥៧.៨១៨.៧៣៥ | ១.២៩៦.៩២៤.៦៨៤ |
| **បំណុលរយៈពេលខ្លី** | | |
| កម្ចី | ៨៦២.៧៨៣.៣៥០ | ២៣.៦៧៧.៤០១ |
| **របាយការណ៍លំហូរសាច់ប្រាក់** | | |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ | (៩៤.៧៤៦.៣៩២) | (៨២.៦៥៦.៣០២) |
| សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ | (២៥១.៣៤៩.៥៨០) | (២៦៥.៩៦៨.៥៤២) |

ការចាត់ថ្នាក់ឡើងវិញពីកម្ចីរយៈពេលវែងទៅកម្ចីរយៈពេលខ្លីចំនួន ៨៣៩.១០៥.៩៤៧.៩០៥រៀល។

## ៣៧. និយ័តកម្មក្នុងការិយបរិច្ឆេទមុន

តួលេខប្រៀបធៀបមួយចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលបានត្រូវកំណត់ឡើងវិញនៅក្នុងទិដ្ឋភាពនៃការកែតម្រូវឆ្នាំមុន៖

(ក) ការទទួលស្គាល់លើសនៃចំណូលបង្គរពីការលក់ទឹកស្អាតចំនួន ៥៧.៧១៨.២៧៨.២២៤រៀល។
(ខ) ការទទួលស្គាល់លើសនៃគណនីត្រូវទទួលពីសេវាសាងសង់ចំនួន ១.៨១១.០៧៧.៦៥២រៀល។
(គ) ការចាត់ថ្នាក់ឡើងវិញពីគណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗទៅទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារចំនួន ៩៣៤.៥៩៨.៥៨៩រៀល។
(ឃ) ការចាត់ថ្នាក់ឡើងវិញពីសមតុល្យសាច់ប្រាក់ និងធនាគារ ទៅទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារចំនួន ៤៥៧.០២១.៩០៨រៀល។
(ង) ការចាត់ថ្នាក់ឡើងវិញពីចំណេញ/(ខាត)ពីការបកប្រែរូបិយប័ណ្ណបរទេស - សុទ្ធ ទៅចំណូល/(ចំណាយ) ហិរញ្ញវត្ថុចំនួន ៣២.៣០០.៨២៥.០០០រៀល និង២២.៣៣២.៨៦៧.០០០រៀល រៀងៗគ្នា។
(ច) ការចាត់ថ្នាក់ឡើងវិញពីគណនីត្រូវបង់ផ្សេងៗទៅ សមតុល្យសាច់ប្រាក់ និងធនាគារចំនួន ៥.២៤២.២៨៦.០២១រៀល។

## ៣៧. និយ័តកម្មក្នុងការិយបរិច្ឆេទមុន

តួរលេខប្រៀបធៀបមួយចំនួននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ រ.ទ.ស.ភ សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ដែលបានត្រូវកំណត់ឡើងវិញនៅក្នុងទិដ្ឋភាពនៃការកែតម្រូវឆ្នាំមុន៖ (ត)

(ឆ) ការផ្ទៀងផ្ទាត់ពីការខុសគ្នានៃសមតុល្យធនាគារស្ថិតក្រោមសមតុល្យសាច់ប្រាក់ និងធនាគារ ចំនួន ២.១៨៦.០៨៤.៤០៩រៀល។

(ជ) ការផ្ទេរពីទុនបម្រុងតាមច្បាប់ទៅប្រាក់ចំណេញរក្សាទុកចំនួន ៥៥.៩៥៦.១១៦.០៤៨រៀល។

(ញ) ការចាត់ថ្នាក់ខុស និងការបង្វែត្រឡប់មកវិញមិនត្រឹមត្រូវនៃប្រាក់ជានាពីធនាគារ ដែលអាចទទួលបាន និងការខកខាននៃការកត់ត្រាលម្អៀងនៃការប្តូរប្រាក់បរទេសចំនួន ២.៨៨៧.៧៦៩.៣១៦រៀល។

(ដ) ការទទួលស្គាល់លើសនៃបំណុលពន្ធចរន្ត និងសំវិធានធនខ្វះនៃបំណុលពន្ធពន្យារ ចំនួន ១០.៦១៩.៩៤៨.៥៣៨រៀល និង ១០.០៤៧.៤៦២.៩៥៥រៀល រៀងៗគ្នា។

ផលប៉ះពាល់នៃការកែតម្រូវកំហុសដែលបានរៀបរាប់ខាងលើមានដូចខាងក្រោម៖

(ក) ការផ្ទៀងផ្ទាត់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

| | ដូចដែលបានរាយការណ៍ពីមុន ពាន់រៀល | ការធ្វើនិយ័តកម្មឆ្នាំមុន ពាន់រៀល | កំណត់ឡើងវិញ ពាន់រៀល |
|---|---|---|---|
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ៣២.៧០៧.៤១៦ | (៧.៣៣០.២៤៦) | ២៥.៣៧៧.១៧០ |
| កិច្ចសន្យាទ្រព្យសកម្ម | ៩២.៧៦៨.៣៧៤ | (៥៧.៨៤២.៩០៧) | ៣៤.៩២៥.៤៦៧ |
| សមតុល្យសាច់ប្រាក់ និងធនាគារ | ៥៦.៧១៦.៤៣៩ | ៤.៤៤២.៤៧៦ | ៦១.១៥៨.៩១៥ |
| ចំណេញរក្សាទុក | ១០៨.១៨៥.៨៦៥ | (៥៥.៩៥៩.៦៧០) | ៥២.២២៦.១៩៥ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ - រយៈពេលខ្លី | ១៥៤.៦៦១.១៥២ | (៤.៧៧១.០០៧) | ១៤៩.៨៩០.១៤៥ |

(ខ) ការផ្ទៀងផ្ទាត់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដូចដែលបានរាយការណ៍ពីមុន ពាន់រៀល | ការធ្វើនិយ័តកម្មឆ្នាំមុន ពាន់រៀល | កំណត់ឡើងវិញ ពាន់រៀល |
|---|---|---|---|
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ២.៤៩៤.៩៧៩.២៩០ | (៤៧៧.៥៧៦) | ២.៤៩៤.៥០១.៧១៤ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ | ២៧.៩៨០.២៣៦ | (១០.៣១៦.១៤០) | ១៧.៦៦៤.០៩៦ |
| កិច្ចសន្យាទ្រព្យសកម្ម | ១៥៥.៥០១.២៥៥ | (១១៦.៨៧២.៧៧៨) | ៣៨.៦២៨.៤៧៧ |
| សមតុល្យសាច់ប្រាក់ និងធនាគារ | ១៦.១១៧.២២២ | ៦.៩៧១.៣៤៨ | ២៣.០៨៨.៥៧០ |
| ទុនបម្រុង | ៦៤៧.១៤៨.៧៨២ | (៥៥.៩៥៦.១១៦) | ៥៩១.១៩២.៦៦៦ |
| ចំណេញរក្សាទុក | ១២៦.៦០៩.៥៨២ | (៥៣.៩៦២.០១០) | ៧២.៦៤៧.៥៧២ |
| បំណុលពន្ធពន្យារ | ៨១.៩៤៦.៨៥៨ | ១០.០៤៧.៤៦៣ | ៩១.៩៩៤.៣២១ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីត្រូវបង់ផ្សេងៗ | ១៧៩.៩៤៤.៦២១ | (១០.២០០.៩៨១) | ១៦៩.៧៤៣.៦៤០ |
| បំណុលពន្ធចរន្ត | ២០.៧២៨.៦៧២ | (១០.៦១៩.៩៤៨) | ១០.១០៨.៧២៤ |

## ៣៧. និយ័តកម្មក្នុងការិយបរិច្ឆេទមុន (ត)

ផលប៉ះពាល់នៃការកែតម្រូវកំហុសដែលបានរៀបរាប់ខាងលើមានដូចខាងក្រោម៖ (ត)

(គ) ការផ្ទៀងផ្ទាត់របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដូចដែលបានរាយការណ៍ពីមុន ពាន់រៀល | ការធ្វើនិយ័តកម្មឆ្នាំមុន ពាន់រៀល | កំណត់ឡើងវិញ ពាន់រៀល |
|---|---|---|---|
| ចំណូល | ៣៤៩.៦៤០.០៧៣ | (៥២.២២៣.៩៣២) | ២៩៧.៤១៦.១៤១ |
| កម្រៃពីការសាងសង់ | ១៦.៦៦៥.៦១៧ | (១.៨១១.០៧៨) | ១៤.៨៥៤.៥៣៩ |
| ចំណេញពីការបកប្រែរូបិយប័ណ្ណបរទេស - សុទ្ធ | ៤.១១១.០៣៩ | (៤.១១១.០៣៩) | - |
| ចំណូលផ្សេងៗ | ២១.៦៣៧.៦៣៦ | (៤៩៩.៤៨៦) | ២១.១៣៨.១៥០ |
| ខាតពីការបកប្រែរូបិយប័ណ្ណបរទេស - សុទ្ធ | - | (៥.៨៥៦.៩១៩) | (៥.៨៥៦.៩១៩) |
| ចំណូលហិរញ្ញវត្ថុ | ៦.៧៣៧.៧៦៦ | ៣២.៣០០.៨២៥ | ៣៩.០៣៨.៥៩១ |
| ចំណាយហិរញ្ញវត្ថុ | (៣.៥២៧.៧៣០) | (២២.៣៣២.៨៦៧) | (២៥.៨៦០.៥៩៧) |
| ចំណាយពន្ធ | (២៦.៨៦២.៩៦១) | ៥៧២.៤៨៦ | (២៦.២៩០.៤៧៥) |

## ៣៨. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី

### ៣៨.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន

រ.ទ.ស.ភ បានអនុវត្តនូវវិសោធនកម្មដូចខាងក្រោម ក្នុងអំឡុងការិយបរិច្ឆេទនេះ។

| | ថ្ងៃចូលជាធរមាន |
|---|---|
| *ការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់* (វិសោធនកម្មលើ ស.គ.អ.ក ៧ *របាយការណ៍លំហូរសាច់ប្រាក់* និង ស.រ.ហ.អ.ក ៧ *ឧបករណ៍ហិរញ្ញវត្ថុ៖ ការលាតត្រដាងព័ត៌មាន*) | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ *បំណុលភតិសន្យាក្នុងការលក់ និងការជួលត្រឡប់* | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.គ.អ.ក ១ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬ បំណុលរយៈពេលវែង* | ១ មករា ២០២៤ |
| វិសោធនកម្មលើ ស.គ.អ.ក ១ *បំណុលរយៈពេលវែងជាមួយការព្រមព្រៀងជាផ្លូវការ* | ១ មករា ២០២៤ |

*ការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់* (វិសោធនកម្មលើ ស.គ.អ.ក ៧ *របាយការណ៍លំហូរសាច់ប្រាក់* និង ស.រ.ហ.អ.ក ៧ *ឧបករណ៍ហិរញ្ញវត្ថុ៖ ការលាតត្រដាងព័ត៌មាន*)

វិសោធនកម្មទាំងនេះណែនាំការលាតត្រដាងថ្មីទាក់ទងនឹងការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់ ដែលជួយអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃផលប៉ះពាល់នៃការរៀបចំទាំងនេះលើបំណុល លំហូរសាច់ប្រាក់ និងការប្រឈមទៅនឹងហានិភ័យសាច់ប្រាក់ងាយស្រួលរបស់អង្គភាព។

## ៣៨. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៨.១ ការអនុវត្តនូវ ស.រ.ហ.អ.ក ថ្មី ក្នុងការិយបរិច្ឆេទបច្ចុប្បន្ន (ត)

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ *បំណុលភតិសន្យាក្នុងការលក់ និងការជួលត្រឡប់មកវិញ*</u>

វិសោធនកម្មនេះតម្រូវឱ្យអ្នកលក់-ភតិកៈ ធ្វើការវាស់វែងជាបន្តបន្ទាប់នូវបំណុលភតិសន្យាដែលកើតចេញពីការជួលត្រឡប់មកវិញតាមរបៀបដែលវាមិនទទួលស្គាល់ចំនួននៃប្រាក់ចំណេញ ឬខាតណាមួយដែលទាក់ទងនឹងសិទ្ធិក្នុងការប្រើប្រាស់ដែលបានរក្សាទុក។ តម្រូវការថ្មីមិនរារាំងអ្នកលក់-ភតិកៈពីការទទួលស្គាល់ប្រាក់ចំណេញ ឬខាតណាមួយដែលទាក់ទងនឹងការបញ្ចប់ការជួលមួយផ្នែក ឬពេញលេញនោះទេ។

<u>វិសោធនកម្មលើ ស.គ.អ.ក ១ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬ បំណុលរយៈពេលវែង*</u>

ស.គ.អ.ក. ១ *ការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* ត្រូវបានកែប្រែទៅ៖

- បញ្ជាក់ថាការចាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង ផ្អែកលើសិទ្ធិដែលមាននៅចុងការិយបរិច្ឆេទនៃរបាយការណ៍
- បញ្ជាក់ថាការចាត់ថ្នាក់មិនត្រូវបានរងផលប៉ះពាល់ដោយការរំពឹងទុក ថាតើអង្គភាពមួយនឹងអនុវត្តសិទ្ធិរបស់ខ្លួនដើម្បីធ្វើការពន្យារក្នុងការទូទាត់បំណុល
- ពន្យល់ថាសិទ្ធិកើតមានឡើង ប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្តនៅចុងការិយបរិច្ឆេទនៃរបាយការណ៍ និង
- ណែនាំឱ្យបានស្គាល់និយមន័យនៃ "ការទូទាត់" ដើម្បីធ្វើឱ្យច្បាស់ថាការទូទាត់សំដៅទៅលើការផ្ទេរទៅសមភាគីនូវសាច់ប្រាក់ ឧបករណ៍មូលធន ទ្រព្យសកម្ម ឬសេវាកម្មផ្សេងៗ។

<u>វិសោធនកម្មលើ ស.គ.អ.ក ១ *បំណុលរយៈពេលវែងជាមួយការព្រមព្រៀងជាផ្លូវការ*</u>

ការធ្វើវិសោធនកម្មកែប្រែតម្រូវការដែលបានណែនាំដោយ *ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយៈពេលវែង* អំពីរបៀបដែលក្រុមហ៊ុនចាត់ថ្នាក់បំណុល និងបំណុលហិរញ្ញវត្ថុផ្សេងទៀតថាជារយៈពេលខ្លី ឬរយៈពេលវែងក្នុងកាលៈទេសៈពិសេស៖ មានតែការព្រមព្រៀងជាផ្លូវការដែលក្រុមហ៊ុនតម្រូវឱ្យអនុវត្ត ឬមុនពេលកាលបរិច្ឆេទរាយការណ៍ប៉ះពាល់ដល់ចំណាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬរយៈពេលវែង។ លើសពីនេះក្រុមហ៊ុនមួយត្រូវលាតត្រដាងព័ត៌មាននៅក្នុងកំណត់សម្គាល់ ដែលអាចឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុយល់អំពីហានិភ័យ ដែលបំណុលរយៈពេលវែងជាមួយការព្រមព្រៀងជាផ្លូវការអាចនឹងត្រូវសងវិញក្នុងរយៈពេលដប់ពីរខែ។

## ៣៨. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៨.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥

ខាងក្រោមនេះគឺជាវិសោធនកម្ម និងស្តង់ដាគណនេយ្យ ដែលបានចេញផ្សាយរួច ប៉ុន្តែ រ.ទ.ស.ក ពុំទាន់បានអនុវត្ត៖

| | ថ្ងៃចូលជាធរមាន |
|---|---|
| វិសោធនកម្មលើ ស.គ.អ.ក ២១ *កង្វះលទ្ធភាពផ្លាស់ប្តូរ* | ១ មករា ២០២៥ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៧ និង ស.រ.ហ.អ.ក ៩ *ការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ* | ១ មករា ២០២៦ |
| ការកែលម្អប្រចាំឆ្នាំលើស្តង់ដាគណនេយ្យ *ស.រ.ហ.អ.ក - ភាគ១១* | ១ មករា ២០២៦ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ និង ស.រ.ហ.អ.ក ៧ *កិច្ចសន្យាដែលយោងទៅលើថាមពលអគ្គិសនីដែលពឹងផ្អែកលើធម្មជាតិ* | ១ មករា ២០២៦ |
| ស.រ.ហ.អ.ក ១៨ *ការបង្ហាញ និងការលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុ* | ១ មករា ២០២៧ |
| ស.រ.ហ.អ.ក ១៩ *ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្មានការទទួលខុសត្រូវសាធារណៈ៖ ការលាតត្រដាង* | ១ មករា ២០២៧ |
| វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និង ស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យរវាងសហគ្រិន និងញ្ញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរួមទុន* | ពន្យារ |

រ.ទ.ស.ក កំពុងវិភាគលើផលប៉ះពាល់ក្នុងការអនុវត្តវិសោធនកម្ម និងស្តង់ដាគណនេយ្យ ដោយហេតុថា ក្រុមប្រឹក្សាភិបាលពុំទាន់មានជំហរ ដើម្បីសន្និដ្ឋានលើផលប៉ះពាល់ដែលអាចមានទៅលើលទ្ធផល និងស្ថានភាពហិរញ្ញវត្ថុរបស់ រ.ទ.ស.ក នៅឡើយទេ។

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តវិសោធនកម្ម និងស្តង់ដាគណនេយ្យមានដូចខាងក្រោម៖

<u>វិសោធនកម្មលើ ស.គ.អ.ក ២១ *កង្វះលទ្ធភាពផ្លាស់ប្តូរ*</u>

វិសោធនកម្មលើ ស.គ.អ.ក ២១ *កង្វះលទ្ធភាពផ្លាស់ប្តូរ* ត្រូវបានធ្វើវិសោធនកម្មទៅ៖

- បញ្ជាក់នៅពេលដែលរូបិយប័ណ្ណអាចប្តូរទៅជារូបិយប័ណ្ណផ្សេងទៀត ហើយនៅពេលដែលវាមិនមែនរូបិយប័ណ្ណអាចផ្លាស់ប្តូរបាននៅពេលដែលអង្គភាពមួយអាចផ្លាស់ប្តូររូបិយប័ណ្ណនោះ ទៅជារូបិយប័ណ្ណផ្សេងទៀតតាមរយៈទីផ្សារ ឬយន្តការផ្លាស់ប្តូរ ដែលបង្កើតសិទ្ធិ និងកាតព្វកិច្ចដែលអាចអនុវត្តបានដោយគ្មានការពន្យារពេលហួសហេតុនៅកាលបរិច្ឆេទវាស់វែង និងសម្រាប់គោលបំណងជាក់លាក់រូបិយប័ណ្ណ គឺមិនអាចប្តូរទៅជារូបិយប័ណ្ណផ្សេងទៀត ប្រសិនបើអង្គភាពណាមួយអាចទទួលបានត្រឹមតែចំនួនមិនសំខាន់រូបិយប័ណ្ណផ្សេងទៀត។
- បញ្ជាក់អំពីរបៀប ដែលអង្គភាពកំណត់អត្រាប្តូរប្រាក់ដែលត្រូវអនុវត្តនៅពេលដែលរូបិយប័ណ្ណមិនមែនអាចផ្លាស់ប្តូរបាននៅពេលដែលរូបិយប័ណ្ណមិនអាចផ្លាស់ប្តូរបាននៅកាលបរិច្ឆេទវាស់វែង អង្គភាពមួយប៉ាន់ប្រមាណអត្រាប្តូរប្រាក់កន្លែងជាអត្រាដែលនឹងអនុវត្តចំពោះប្រតិបត្តិការ ដែលមានសណ្តាប់ធ្នាប់រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទវាស់វែង ហើយដែលនឹងឆ្លុះបញ្ចាំងយ៉ាងស្មោះត្រង់ស្ថានភាពសេដ្ឋកិច្ចដែលកំពុងរីកចម្រើន។
- តម្រូវឱ្យមានការលាតត្រដាងព័ត៌មានបន្ថែម នៅពេលដែលរូបិយប័ណ្ណមិនអាចប្តូរបាន ពេលណារូបិយប័ណ្ណមិនអាចផ្លាស់ប្តូរបាន អង្គភាពត្រូវបង្ហាញព័ត៌មានដែលអាចឱ្យអ្នកប្រើប្រាស់ប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដើម្បីវាយតម្លៃថា ការខ្វះខាតនៃការផ្លាស់ប្តូររូបិយវត្ថុប៉ះពាល់ដល់ ឬ យ៉ាងណារំពឹងថានឹងមានផលប៉ះពាល់ ដំណើរការហិរញ្ញវត្ថុ ស្ថានភាពហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់។

## ៣៨. ការអនុវត្តនូវស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៨.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តវិសោធនកម្ម និងស្តង់ដាគណនេយ្យមានដូចខាងក្រោម៖ (ត)

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៧ និង ស.រ.ហ.អ.ក ៩ *ការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ*</u>

វិសោធនកម្មបញ្ជាក់ពី៖

- តម្រូវការទាក់ទងនឹងកាលបរិច្ឆេទនៃការទទួលស្គាល់ និងការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ដោយមានករណីលើកលែងសម្រាប់ការឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុដែលបានទូទាត់តាមរយៈការផ្ទេរអេឡិចត្រូនិក។
- តម្រូវការសម្រាប់ការវាយតម្លៃលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ដោយមានការណែនាំបន្ថែមលើការវាយតម្លៃនៃលក្ខណៈជាប់ពាក់ព័ន្ធ។
- លក្ខណៈនៃប្រាក់កម្ចីដែលមិនមានជំនួយ និងឧបករណ៍ភ្ជាប់តាមកិច្ចសន្យា។

វិសោធនកម្មនេះក៏ណែនាំអំពីតម្រូវការលាតត្រដាងព័ត៌មានបន្ថែម សម្រាប់ឧបករណ៍មូលធនដែលត្រូវបានចាត់ថ្នាក់ជា តម្លៃសមស្របតាមចំណូលពេញលេញ ("FVOCI") និងសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានលក្ខណៈពាក់ព័ន្ធ។

<u>ការកែលម្អប្រចាំឆ្នាំលើស្តង់ដាគណនេយ្យ *ស.រ.ហ.អ.ក - ភាគ១១*</u>

ការកែលម្អប្រចាំឆ្នាំធ្វើវិសោធនកម្មលើស្តង់ដាដូចខាងក្រោម៖

- គណនេយ្យទប់ស្កាត់ហានិភ័យដោយការអនុវត្តលើកដំបូង (វិសោធនកម្មលើ ស.រ.ហ.អ.ក ១ ការអនុវត្តលើកដំបូងរបស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ)
- ការលាតត្រដាងពីភាពខុសគ្នាពន្យាររវាងតម្លៃសមស្រប និងតម្លៃប្រតិបត្តិការ (វិសោធនកម្មលើការណែនាំសម្រាប់ការអនុវត្ត ស.រ.ហ.អ.ក ៧)
- ចំណេញ ឬខាតលើការឈប់ទទួលស្គាល់ (វិសោធនកម្មលើ ស.រ.ហ.អ.ក ៧)
- ការណែនាំ និងការលាតត្រដាងព័ត៌មានហានិភ័យឥណទាន (វិសោធនកម្មលើការណែនាំសម្រាប់ការអនុវត្ត ស.រ.ហ.អ.ក ៧)
- ការឈប់ទទួលស្គាល់នៃបំណុលភតិសន្យា (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩)
- តម្លៃប្រតិបត្តិការ (វិសោធនកម្មលើ ស.រ.ហ.អ.ក ៩)
- ការកំណត់ "ភ្នាក់ងារពិត" (វិសោធនកម្មលើ ស.រ.ហ.អ.ក ១0) និង
- វិធីសាស្ត្រថ្លៃដើម (វិសោធនកម្មលើ ស.គ.អ.ក ៧)។

<u>វិសោធនកម្មលើ ស.រ.ហ.អ.ក ៩ និង ស.រ.ហ.អ.ក ៧ *កិច្ចសន្យាដែលយោងទៅលើថាមពលអគ្គិសនីដែលពឹងផ្អែកលើធម្មជាតិ*</u>

វិសោធនកម្មរួមមាន៖

- ការបញ្ជាក់អំពីការអនុវត្តតម្រូវការ "ការប្រើប្រាស់ដោយខ្លួនឯង"
- ការអនុញ្ញាតឱ្យមានគណនេយ្យទប់ស្កាត់ហានិភ័យ ប្រសិនបើកិច្ចសន្យាទាំងនេះត្រូវបានប្រើជាឧបករណ៍ទប់ស្កាត់ហានិភ័យ និង
- ការបន្ថែមតម្រូវការលាតត្រដាងថ្មី ដើម្បីឱ្យវិនិយោគិនយល់អំពីឥទ្ធិពលនៃកិច្ចសន្យាទាំងនេះលើលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន

## ៣៨. ការអនុវត្តនូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៨.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ (ត)

ផលប៉ះពាល់ដែលអាចកើតមានពីការអនុវត្តវិសោធនកម្ម និងស្តង់ដាគណនេយ្យមានដូចខាងក្រោម៖ (ត)

<u>ស.រ.ហ.អ.ក ១៨ ការបង្ហាញ និងការលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុ</u>

ស.រ.ហ.អ.ក ១៨ នឹងត្រូវជំនួស ស.គ.អ.ក ១ *ការលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុ* ដែលជាប្រភពចម្បងក្នុងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុស្របតាមតម្រូវការរបស់ស្តង់ដាគណនេយ្យអន្តរជាតិ។

ខាងក្រោមនេះ គឺជាការសង្ខេបនៃការផ្លាស់ប្តូរដ៏សំខាន់បំផុតដែលណែនាំដោយ ស.រ.ហ.អ.ក ១៨៖

- តម្រូវការតាមប្រភេទ និងសរុបរងនៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាត៖ ធាតុនៃចំណូល និងចំណាយនឹងត្រូវបានចាត់ទុកជាប្រតិបត្តិការ ហិរញ្ញប្បទាន វិនិយោគ ពន្ធលើប្រាក់ចំណូល ឬ ប្រភេទប្រតិបត្តិ មិនបន្ត។ ការចាត់ថ្នាក់នេះនឹងអាស្រ័យលើការរួមបញ្ចូលគ្នានៃការវាយតម្លៃនៃសកម្មភាពអាជីវកម្មចម្បងរបស់អង្គភាព និងជម្រើសគោលនយោបាយគណនេយ្យមួយជាក់លាក់
- តម្រូវការសរុបរងរបាយការណ៍ប្រាក់ចំណេញ ឬខាត៖ ផ្តែកលើការអនុវត្តរបស់អង្គភាពនៃតម្រូវការចាត់ថ្នាក់ដូចបានរៀបរាប់ក្នុងលេខ ១ ហើយសរុបរងជាក់លាក់តម្រូវឱ្យបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដូចជាចំណេញប្រតិបត្តិការ។ ចំណេញប្រតិបត្តិការសរុបរងឥឡូវនេះត្រូវបានកំណត់នៅក្នុង ស.រ.ហ.អ.ក ១៨។
- ការដាក់ស្លាក ការប្រមូលផ្តុំ និងការបំបែកការប្រមូលផ្តុំ៖ តម្រូវការពង្រីកសម្រាប់ការដាក់ស្លាក ការប្រមូលផ្តុំ និងការបំបែកការប្រមូលផ្តុំនៃព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ
- ការផ្លាស់ប្តូរវិសាលភាពតូចចង្អៀតចំពោះរបាយការណ៍លំហូរសាច់ប្រាក់៖ ការកែសម្រួលតម្រូវការរបាយការណ៍លំហូរសាច់ប្រាក់នឹងត្រូវបានបង្ហាញ រួមទាំងការចាត់ថ្នាក់នៃលំហូរសាច់ប្រាក់របស់ការប្រាក់ និង ភាគលាភ និង
- វិធានការអនុវត្តដែលកំណត់ដោយគណៈគ្រប់គ្រង៖ តម្រូវការសម្រាប់អង្គភាពជាក់លាក់ ដើម្បីរួមបញ្ចូល "វិធានការអនុវត្តដែលកំណត់ដោយគណៈគ្រប់គ្រង" (ឧទាហរណ៍៖ វិធានការអនុវត្តជំនួស "វិធានការមិនមែន GAAP") ក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ជាមួយនឹងការបន្សុំទៅនឹងសរុបរងអនុលោមតាម ស.រ.ហ.អ.ក ដែលនៅជិតបំផុត។ ឧទាហរណ៍ "ការកែតម្រូវនៃចំណេញ ឬខាត" បន្សុំទៅនឹងប្រាក់ចំណេញ ឬខាត។

<u>ស.រ.ហ.អ.ក ១៩ *ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលគ្មានការទទួលខុសត្រូវសាធារណៈ៖ ការលាតត្រដាង*</u>

ស.រ.ហ.អ.ក ១៩ អនុញ្ញាតឱ្យក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានសិទ្ធិអនុវត្ត ស្តង់ដាគណនេយ្យ ស.រ.ហ.អ.ក ជាមួយនឹងការកាត់បន្ថយការលាតត្រដាង ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធអាចជ្រើសរើសដើម្បីអនុវត្ត ស.រ.ហ.អ.ក ១៩ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម របាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ឬរបាយការណ៍ហិរញ្ញវត្ថុតែមួយដែលបានផ្តល់ឱ្យនៅកាលបរិច្ឆេទរាយការណ៍៖

- វាមិនមានទំនួលខុសត្រូវសាធារណៈទេ និង
- ក្រុមហ៊ុនមេរបស់ខ្លួនរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម ដែលមានសម្រាប់ការប្រើប្រាស់ជាសាធារណៈក្រោមស្តង់ដាគណនេយ្យ ស.រ.ហ.អ.ក ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលអនុវត្ត ស.រ.ហ.អ.ក ១៩ តម្រូវឱ្យបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ច្បាស់លាស់ និងមិនបានរក្សាទុករបស់ខ្លួនអំពីការអនុលោមតាមស្តង់ដាគណនេយ្យ ស.រ.ហ.អ.ក ដែល ស.រ.ហ.អ.ក ១៩ ត្រូវបានអនុម័ត។

## ៣៨. ការអនុវត្តនូវស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ហ.អ.ក") ថ្មី (ត)

### ៣៨.២ ស.រ.ហ.អ.ក ថ្មីដែលបានចេញផ្សាយ ប៉ុន្តែនឹងចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ពី ឬបន្ទាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ (ត)

វិសោធនកម្មលើ ស.រ.ហ.អ.ក ១០ និងស.គ.អ.ក ២៨ *ការលក់ ឬការចែកចាយនៃទ្រព្យ រវាងសហគ្រិន និង ញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន*

ការធ្វើវិសោធនកម្មនេះបញ្ជាក់ពីវិសាលភាពនៃការចំណេញ ឬខាតដែលត្រូវទទួលស្គាល់ នៅពេលដែលអង្គភាពលក់ ឬដាក់ទុនជាទ្រព្យសម្បត្តិទៅញាតិសម្ព័ន្ធ ឬក្រុមហ៊ុនរួមទុន។ នៅពេលប្រតិបត្តិការទាក់ទងទៅនឹងអាជីវកម្ម ចំណេញ ឬខាតត្រូវបានទទួលស្គាល់ទាំងស្រុង នៅពេលដែលប្រតិបត្តិការពាក់ព័ន្ធនឹងទ្រព្យសកម្មដែលមិនរួមចំណែកក្នុងអាជីវកម្ម ចំណេញ ឬខាតត្រូវបានទទួលស្គាល់តែចំពោះផលប្រយោជន៍របស់វិនិយោគិនដែលមិនពាក់ព័ន្ធនឹងក្រុមហ៊ុនរួមទុន ឬញាតិសម្ព័ន្ធ។

# ឧបសម្ព័ន្ធ ៤

## លទ្ធផលពិនិត្យគុណភាពទឹក
## ពីរោងចក្រផលិតទឹកស្អាតបាក់ខែង

TEST REPORT 7191347954-CHM25-PN

# TEST REPORT: 7191347954-CHM25-PN

Date: 22 JAN 2025

Tel: +65 6973 6164

Client's Ref:

Email: na.pi@tuvsud.com

**Note:** This report is issued subject to the Testing and Certification Regulations of the TÜV SÜD Group and the General Terms and Conditions of Business of TÜV SÜD PSB Pte Ltd. In addition, this report is governed by the terms set out within this report.

**SUBJECT**

Analysis of Drinking Water Sample

**CLIENT**

Phnom Penh Water Supply Authority (PPWSA)
#45, Street 106, Phnom Penh 12202
Cambodia

Attention: Keo Heng

**DATE OF SAMPLE SUBMISSION / TESTING**

20 Dec 2024 / 20 Dec 2024 to 21 Jan 2025

**DESCRIPTION OF SAMPLE**

One water sample was received and labelled as "Drinking Water"

PSB Singapore

## METHOD OF TEST

1. APHA-AWWA-WEF 24th Edition 2022 - Standard Methods for the Examination of Water and Wastewater.
2. USEPA Method 508 Determination of Chlorinated Pesticides in Water by Gas Chromatography Electron Capture Detector (GC/ECD).
3. USEPA Method 515 Determination of Chlorinated Acids in Drinking Water by Liquid-Liquid Extraction, Derivitization, and GC/ECD.
4. EPA 8260D: Volatile Organic Compounds by Gas Chromatography Mass Spectrometry (GC/MS).
5. EPA 8270E: Semi-Volatile Organic Compounds by GC/MS.
6. USEPA Method 551.1 Determination of Chlorination Disinfection Byproducts, Chlorinated Solvents, and Halogenated Pesticides/Herbicides in Drinking Water by Liquid-Liquid Extraction and GC/ECD.
7. USEPA Method 552.2 Determination of Haloacetic Acids and Dalapon in Drinking Water by Liquid-Liquid Extraction, Derivatization and GC/ECD.
8. Determination of EDTA and NTA by Solid Phase Extraction, Derivatization and GC/MS.
9. Determination of Bromate by Derivatization and GC/MS.
10. Determination of Inorganic Anions in Drinking Water by Ion Chromatography (IC).

**The below tests were sub-contracted to the partner laboratory:**

11. NF EN ISO 10704 : 2019 Water quality - Gross Alpha and Gross Beta Activity.
12. Determination of Malathion by Liquid-Liquid Extraction and GC/MS.
13. High Performance Liquid Chromatography with Tandem Mass Spectrometry (LC/MS/MS) for:
    - Acrylamide
    - Aldicarb Sulfoxide and Aldicarb Sulfone
    - Carbofuran
    - Chlorotoluron
    - Microcystin-LR
    - Microcystins (Total)
    - Isoproturon
    - N-Nitrosodimethylamine (NDMA)
    - Dichlorvos
    - Atrazine and its chloro-s-triazine metabolites
    - Bentazone
    - Diquat
    - Glyphosate and Aminomethylphosphonic acid (AMPA)

PSB Singapore

## RESULTS

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| **Microbiological Parameter** | | | | |
| Escherichia coli | cfu/100mL | < 1 | 1 | < 1 |
| | | | | |
| **Physical Parameters** | | | | |
| Color | Hazen | Not detected | 2.5 | - |
| Conductivity at 25ºC | µS/cm | 283 | - | - |
| Odour | | Unobjectionable | - | - |
| pH @ 25°C | | 7.8 | - | - |
| Total Dissolved Solids | mg/L | 170 | 1 | - |
| Turbidity | NTU | 0.1 | 0.1 | - |
| | | | | |
| **Radiological Parameters** | | | | |
| Gross Alpha | Bq/L | Not detected | 0.03 | 0.5 |
| Gross Beta | Bq/L | 0.12 | 0.05 | 1 |
| | | | | |
| **Chemical Parameters** | | | | |
| Acrylamide | mg/L | Not detected | 0.0005 | 0.0005 |
| Alachlor | mg/L | Not detected | 0.001 | 0.02 |
| Aldicarb Sulfoxide and Aldicarb Sulfone | mg/L | Not detected | 0.01 | 0.01 |
| Aldrin & Dieldrin | mg/L | Not detected | 0.00003 | 0.00003 |
| Antimony | mg/L | Not detected | 0.001 | 0.02 |
| Arsenic | mg/L | Not detected | 0.001 | 0.01 |
| Atrazine and its chloro-s-triazine metabolites | mg/L | Not detected | 0.005 | 0.1 |
| Aluminium | mg/L | 0.08 | 0.001 | - |
| Barium | mg/L | 0.03 | 0.001 | 1.3 |
| Bentazone | mg/L | Not detected | 0.001 | - |
| Benzene | mg/L | Not detected | 0.001 | 0.01 |
| Benzo (a) pyrene | mg/L | Not detected | 0.0001 | 0.0007 |
| Boron | mg/L | 0.02 | 0.001 | 2.4 |
| Bromate | mg/L | Not detected | 0.01 | 0.01 |
| Bromodichloromethane | mg/L | Not detected | 0.001 | 0.06 |
| Bromoform | mg/L | Not detected | 0.001 | 0.1 |
| Cadmium | mg/L | Not detected | 0.001 | 0.003 |
| Calcium | mg/L | 19.9 | 0.001 | - |
| Carbofuran | mg/L | Not detected | 0.005 | 0.007 |
| Carbon Tetrachloride | mg/L | Not detected | 0.001 | 0.004 |
| Chlorate | mg/L | Not detected | 0.2 | 0.7 |
| Chlordane (total isomers) | mg/L | Not detected | 0.0001 | 0.0002 |
| Chlorine (Free) | mg/L | 0.5 | 0.01 | 5 |
| Chlorite | mg/L | Not detected | 0.2 | 0.7 |
| Chloroform | mg/L | Not detected | 0.001 | 0.3 |
| Chlorotoluron | mg/L | Not detected | 0.01 | 0.03 |
| Chlorpyrifos | mg/L | Not detected | 0.001 | 0.03 |
| Chromium (in all forms as a total) | mg/L | Not detected | 0.01 | 0.05 |
| Copper | mg/L | Not detected | 0.01 | 2 |

**RESULTS** (Continued)

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Cyanazine | mg/L | Not detected | 0.0001 | 0.0006 |
| Cyanide | mg/L | Not detected | 0.01 | - |
| Cyanogen chloride (as cyanide) | mg/L | Not detected | 0.01 | - |
| Chloride | mg/L | 36.0 | 0.1 | - |
| 2,4-D (2,4-dichlorophenoxyacetic acid) in free acid form | mg/L | Not detected | 0.01 | 0.03 |
| 2,4-DB [2,4-Dichlorophenoxy) butyric acid] | mg/L | Not detected | 0.01 | 0.09 |
| DDT & Metabolites | mg/L | Not detected | 0.0001 | 0.001 |
| Di(2-Ethylhexyl) phthalate | mg/L | Not detected | 0.001 | 0.008 |
| 1,2-Dibromo-3-chloropropane (DBCP) | mg/L | Not detected | 0.001 | 0.001 |
| Dibromoacetonitrile | mg/L | Not detected | 0.001 | 0.07 |
| Dibromochloromethane | mg/L | Not detected | 0.001 | 0.1 |
| 1,2-Dibromoethane (Ethylene Dibromide) 1,2- | mg/L | Not detected | 0.0001 | 0.0004 |
| Dichloroacetate | mg/L | Not detected | 0.01 | 0.05 |
| Dichloroacetonitrile | mg/L | Not detected | 0.01 | 0.02 |
| Dichlorobenzene, 1,2- | mg/L | Not detected | 0.001 | 1 |
| Dichlorobenzene, 1,4- | mg/L | Not detected | 0.001 | 0.3 |
| Dichloroethane, 1,2- | mg/L | Not detected | 0.001 | 0.03 |
| Dichloroethene (cis & trans), 1,2- | mg/L | Not detected | 0.001 | 0.05 |
| Dichloromethane | mg/L | Not detected | 0.001 | 0.02 |
| Dichloropropane, 1,2- | mg/L | Not detected | 0.001 | 0.04 |
| Dichloropropene, 1,3- | mg/L | Not detected | 0.001 | 0.02 |
| Dichlorvos | mg/L | Not detected | 0.1 | - |
| Dicofol | mg/L | Not detected | 0.1 | - |
| Dichlorprop | mg/L | Not detected | 0.01 | 0.1 |
| Dimethoate | mg/L | Not detected | 0.001 | 0.006 |
| Dioxane, 1,4- | mg/L | Not detected | 0.01 | 0.05 |
| Diquat | mg/L | Not detected | 0.001 | - |
| Endrin | mg/L | Not detected | 0.0001 | 0.0006 |
| Epichlorohydrin | mg/L | Not detected | 0.0001 | 0.0004 |
| Ethylbenzene | mg/L | Not detected | 0.001 | 0.3 |
| Edetic acid (EDTA-Ethylene Diamine Tetraacetic Acid) in free acid form | mg/L | Not detected | 0.1 | 0.6 |
| Fenoprop (2,4,5-TP; 2,4,5-trichlorophenoxy propionic acid) | mg/L | Not detected | 0.003 | 0.009 |
| Fluoride | mg/L | Not detected | 0.1 | 1.5 |
| Glyphosate and Aminomethylphosphonic acid (AMPA) | mg/L | Not detected | 0.001 | - |
| Hexachlorobutadiene (HCBD) | mg/L | Not detected | 0.0001 | 0.0006 |
| Hydroxyatrazine | mg/L | Not detected | 0.01 | 0.2 |
| Isoproturon | mg/L | Not detected | 0.005 | 0.009 |
| Iron | mg/L | Not detected | 0.02 | - |
| Lead | mg/L | Not detected | 0.001 | 0.01 |
| Lindane | mg/L | Not detected | 0.0001 | 0.002 |
| Malathion | mg/L | Not detected | 0.001 | - |
| MCPA (4-Chloro-2-methylphenoxyacetic acid) | mg/L | Not detected | 0.003 | - |
| Mecoprop (MCPP; [2(2-methyl-chlorophenoxy) propionicacid] | mg/L | Not detected | 0.003 | 0.01 |
| Mercury, in inorganic form | mg/L | Not detected | 0.001 | 0.006 |
| Methoxychlor | mg/L | Not detected | 0.001 | 0.02 |
| Metolachlor | mg/L | Not detected | 0.01 | 0.01 |
| Microcystin-LR | mg/L | Not detected | 0.001 | - |

**RESULTS** (Continued)

| Test Parameter | | Drinking Water | Detection Limit | *WHO Guideline Value |
|---|---|---|---|---|
| Microcystins (Total) | mg/L | Not detected | 0.001 | 0.001 |
| Molinate | mg/L | Not detected | 0.001 | 0.006 |
| Monochloramine | mg/L | 0.1 | 0.1 | 3 |
| Monochloroacetic acid (chloroacetic acid) | mg/L | Not detected | 0.01 | 0.02 |
| Manganese | mg/L | Not detected | 0.01 | 0.08 |
| Magnesium | mg/L | 9.98 | 0.001 | - |
| Molybdenum | mg/L | Not detected | 0.02 | - |
| Nickel | mg/L | Not detected | 0.02 | 0.07 |
| Nitrate (as N) | mg/L | 0.3 | 0.02 | 11 |
| Nitrilotriacetic acid (NTA) | mg/L | Not detected | 0.1 | 0.2 |
| Nitrite (as N) | mg/L | Not detected | 0.03 | 0.9 |
| Nitrate plus nitrite combined | units | 0.027 | 0.009 | 1 |
| Nitrisodimethylamine (NDMA) | mg/L | Not detected | 0.0001 | 0.0001 |
| Pendimethalin | mg/L | Not detected | 0.001 | 0.02 |
| Pentachlorophenol (PCP) | mg/L | Not detected | 0.001 | 0.009 |
| Perchlorate | mg/L | Not detected | 0.04 | 0.07 |
| Permethrin, where used as a larvicide for public health purposes | mg/L | Not detected | 0.04 | - |
| Pyriproxyfen | mg/L | Not detected | 0.04 | - |
| Selenium | mg/L | Not detected | 0.001 | 0.04 |
| Simazine | mg/L | Not detected | 0.001 | 0.002 |
| Sodium dichloroisocyanurate | mg/L | Not detected | 0.1 (as cyanuric acid) | 50 (40 as cyanuric acid) |
| Styrene | mg/L | Not detected | 0.001 | 0.02 |
| Sulfate as $SO_4^{2-}$ | mg/L | 13.4 | 0.1 | - |
| Silica (as $SiO_2$) | mg/L | 11.9 | 0.002 | - |
| Sodium | mg/L | 12.6 | 0.001 | - |
| Terbuthylazine (TBA) | mg/L | Not detected | 0.001 | 0.007 |
| Tetrachloroethene | mg/L | Not detected | 0.001 | 0.1 |
| Toluene | mg/L | Not detected | 0.001 | 0.7 |
| Trichloroethene | mg/L | Not detected | 0.001 | 0.008 |
| Trichlorophenol, 2,4,6- | mg/L | Not detected | 0.001 | 0.2 |
| 2,4,5-T (2,4,5-Trichlorophenoxyacetic acid) | mg/L | Not detected | 0.003 | 0.009 |
| Trichloroacetate | mg/L | Not detected | 0.01 | 0.2 |
| Trifluralin | mg/L | Not detected | 0.001 | 0.02 |
| Total Trihalomethanes Ratio[#] | unit | Not detected | 0.04 | < 1 |
| Total Organic Carbon (TOC) | mg/L | Not detected | 1.0 | - |
| Total Alkalinity (as $CaCO_3$) | mg/L | 64.5 | 1.0 | - |
| Total Hardness as ($CaCO_3$) | mg/L | 90.7 | 0.007 | - |
| Total Phosphorus (as P) | mg/L | Not detected | 0.1 | - |
| Uranium | mg/L | Not detected | 0.001 | 0.03 |
| Vinyl Chloride | mg/L | Not detected | 0.0001 | 0.0003 |
| Xylenes | mg/L | Not detected | 0.001 | 0.5 |

Note:
1. *Specification is based on WHO Guidelines for Drinking-Water Quality (2022) 4th Edition.
2. #The sum of the ratio of the concentration of each to its respective guideline value should not exceed 1.

PSB Singapore

**REMARKS**

The parameters tested for the water sample complied with WHO Guidelines for Drinking-Water Quality (2022) 4th Edition.

TÜV SÜD

**THAI GIA BACH**
CHEMIST

**DR. PI NA**
PRODUCT MANAGER
ENVIRONMENTAL MONITORING
CHEMICAL CENTRE

PSB Singapore

Please note that this Report is issued under the following terms :

1. This report applies to the sample of the specific product/equipment given at the time of its testing/calibration. The results are not used to indicate or imply that they are applicable to other similar items. In addition, such results must not be used to indicate or imply that TÜV SÜD PSB approves, recommends or endorses the manufacturer, supplier or user of such product/equipment, or that TÜV SÜD PSB in any way "guarantees" the later performance of the product/equipment. Unless otherwise stated in this report, no tests were conducted to determine long term effects of using the specific product/equipment.

2. The sample/s mentioned in this report is/are submitted/supplied/manufactured by the Client. TÜV SÜD PSB therefore assumes no responsibility for the accuracy of information on the brand name, model number, origin of manufacture, consignment or any information supplied.

3. Nothing in this report shall be interpreted to mean that TÜV SÜD PSB has verified or ascertained any endorsement or marks from any other testing authority or bodies that may be found on that sample.

4. This report shall not be reproduced wholly or in parts and no reference shall be made by the Client to TÜV SÜD PSB or to the report or results furnished by TÜV SÜD PSB in any advertisements or sales promotion.

5. Unless otherwise stated, the tests were carried out in TÜV SÜD PSB Pte Ltd, 15 International Business Park Singapore 609937.

6. The tests carried out by TÜV SÜD PSB and this report are subject to TÜV SÜD PSB's General Terms and Conditions of Business and the Testing and Certification Regulations of the TÜV SÜD Group.

Effective 01 January 2021

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)**

-----------------------------------------------------------------

: + ៨៥៥(២៣) ៦៣៥ ០៨ ០៨

: ir@ppwsa.com.kh

: WWW.PPWSA.COM.KH

-----------------------------------------------------------------

អគារលេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

# ឧបសម្ព័ន្ធ ៥

## ទិសដៅអាជីវកម្មប្រចាំឆ្នាំ ២០២៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ទិសដៅអាជីវកម្មឆ្នាំ២០២៥







រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

ខែឧសភា ឆ្នាំ២០២៥

# មាតិកា

## ទិសដៅអាជីវកម្ម ឆ្នាំ២០២៥

### ផ្នែក ក: ផែនការដំណើរការសហគ្រាស


១. ផែនការផលិតទឹកស្អាត ... 2

២. ផែនការសេវាអតិថិជន ... 4

៣. ផែនការហិរញ្ញវត្ថុ ... 8

៤. ផែនការធនធានមនុស្ស ... 9


### ផ្នែក ខ: ផែនការវិនិយោគ


៥. ផែនការវិនិយោគ ... 20

ក. ពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹក និងចែកចាយទឹក ... 20

ខ. ឧបករណ៍ទ្រទ្រង់គម្រោង ... 22

គ. ផែនការសំណង់ស៊ីវិល ... 26

ឃ. បំណែងចែកប្រភពថវិកាវិនិយោគ ឆ្នាំ២០២៥ ... 26

# សេចក្តីផ្តើម

ផែនការឆ្នាំ ២០២៥ របស់ **រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** (**រ.ទ.ស.ភ**) គឺត្រូវបានកសាងឡើងក្នុង គោលបំណង ដើម្បីកំណត់ទិសដៅចម្បងៗសម្រាប់កម្មវត្ថុអាជីវកម្ម ដែលត្រូវសម្រេចឱ្យបានដោយអនុវត្តតាមសកម្មភាព ដែលមានចែងដូចខាងក្រោម៖

ក. វិនិយោគ កសាង ពង្រីក ដំណើរការ និងជួសជុលថែរក្សា មធ្យោបាយសម្រាប់ប្រព្រឹត្តកម្មទឹកស្អាតប្រព័ន្ធបណ្តាញផ្គត់ផ្គង់ទឹកស្អាត និងប្រព័ន្ធតាមដាននិងវិភាគគុណភាពទឹកស្អាត។

ខ. ប្រើប្រាស់នូវគ្រប់វិធានការ ក្នុងការបង្កើនប្រសិទ្ធភាពនៃប្រព្រឹត្តកម្មទឹកស្អាតទាំងបរិមាណ និងគុណភាព ក៏ដូចជាប្រសិទ្ធភាពនៃការផ្តល់សេវាកម្ម ដើម្បីឱ្យការផ្គត់ផ្គង់ទឹកស្អាត ឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពអាជីវកម្ម-សេវាកម្ម និងឧស្សាហកម្មផ្សេងៗ។

គ. ធ្វើអាជីវកម្ម ផ្តល់សេវាកម្ម និងអនុវត្តការងារផ្សេងៗទៀត ដែលទាក់ទងនឹងវិស័យទឹកស្អាត និងអនាម័យ នៅក្នុង ឬក្រៅប្រទេស តបតាមការសម្រេចរបស់ **ក្រុមប្រឹក្សាភិបាល** ឬ **ឯកឧត្តមប្រតិភូ** និងដោយអនុលោមតាមច្បាប់។

ឃ. ធ្វើសហប្រតិបត្តិការលើផ្នែកបច្ចេកទេស ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ជាមួយដៃគូអភិវឌ្ឍន៍ក្នុង និងក្រៅប្រទេស ដើម្បីអភិវឌ្ឍ **រ.ទ.ស.ភ** ឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ង. ធានាឱ្យបាននូវចីរភាពនៃដំណើរការប្រព្រឹត្តកម្ម អាជីវកម្ម និងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយផលប្រយោជន៍សង្គម។

# ផ្នែក ក ផែនការដំណើរការសហគ្រាស

គោលបំណងចម្បងរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) គឺជានាឱ្យបាននូវការផ្គត់ផ្គង់ទឹកស្អាត២៤ម៉ោង ក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ (លើកលែងករណីដាច់ចរន្តអគ្គិសនី) ជាមួយនឹងសម្ពាធគ្រប់គ្រាន់ និងតម្លៃមួយសមស្រប ជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ រួមបញ្ចូលទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ព្រមទាំងតំបន់សេវាផ្គត់ផ្គង់ទឹកស្អាតរបស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតម្លេច និងត្បូងឃ្មុំ ដោយមិនមើលរំលងប្រជាពលរដ្ឋដែលមានចំណូលទាបនោះឡើយ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ រ.ទ.ស.ភ បានរៀបចំកសាងផែនការនៃដំណើរការសហគ្រាស សម្រាប់ឆ្នាំ២០២៥ ដោយផ្អែកលើរបាយការណ៍លទ្ធផលជាក់ស្តែង ៨ខែ បូកប៉ាន់ស្មាន ៤ខែ ក្នុងឆ្នាំ២០២៤ ដែលត្រូវបានបែងចែកជាផែនការសំខាន់ៗដូចខាងក្រោម៖

## ១. ផែនការផលិតកម្មទឹកស្អាត

នាឆ្នាំ២០២៥ ខាងមុខ រ.ទ.ស.ភ នឹងមានរោងចក្រផលិតទឹកស្អាតចំនួន៩ ដែលមានសមត្ថភាពផលិតទឹកស្អាតសរុបចំនួនប្រមាណ ១.០៣០.០០០ ម៉ែត្រគូបក្នុងមួយថ្ងៃ ដូចមានបង្ហាញខាងក្រោម៖

- រោងចក្រភូមិព្រែក ១៥០.០០០ ម³/ថ្ងៃ
- រោងចក្រជ្រោយចង្វារ ១៣០.០០០ ម³/ថ្ងៃ
- រោងចក្រចំការមន ៥២.០០០ ម³/ថ្ងៃ
- រោងចក្រនិរោធជំហានទី (១+២) ២៦០.០០០ ម³/ថ្ងៃ
- រោងចក្របាក់ខែងជំហានទី១ ១៩៥.០០០ ម³/ថ្ងៃ
- រោងចក្របាក់ខែងជំហានទី២ ១៩៥.០០០ ម³/ថ្ងៃ
- រោងចក្របឹងធំ ៦.០០០ ម³/ថ្ងៃ
- រោងចក្រតាខ្មៅ ៣០.០០០ ម³/ថ្ងៃ
- រោងចក្រម្លេច ២.០០០ ម³/ថ្ងៃ
- រោងចក្រត្បូងឃ្មុំ ១០.០០០ ម³/ថ្ងៃ

នាឆ្នាំ២០២៥ ខាងមុខ ដើម្បីជានាឱ្យការផ្គត់ផ្គង់ទឹកស្អាតឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់របស់ប្រជាពលរដ្ឋទាំងនៅតំបន់សេវាមានស្រាប់ និងតំបន់សេវាថ្មី រ.ទ.ស.ភ បានរៀបចំផែនការផលិតទឹកស្អាត ដើម្បីធ្វើការផ្គត់ផ្គង់ប្រចាំឆ្នាំ ចំនួន ៣១៨.២១៩.១០៨ម³ ដែលជាមធ្យមស្មើនឹងប្រមាណ ៨៧៧.០០៧ម³/ថ្ងៃ ។ បរិមាណទឹកផលិតប្រចាំឆ្នាំ នៅឆ្នាំ ២០២៥ ខាងមុខ គ្រោងនឹងមានបរិមាណប្រហាក់ប្រហែលនឹងបរិមាណទឹកផលិតប្រចាំឆ្នាំ២០២៤ ។ ក្នុងនោះផងដែរ រ.ទ.ស.ភ គ្រោងនឹងដាក់ឱ្យដំណើរការ នូវរោងចក្រផលិតទឹកស្អាតតាខ្មៅ សមត្ថភាពផលិតទឹកស្អាត ៣០.០០០ម³/ថ្ងៃ

ដែលគ្រោងដាក់ដំណើរការនៅត្រីមាសទី២ ឆ្នាំ២០២៥ ដែលនឹងជួយផ្គត់ផ្គង់ទឹកបន្ថែមទៅកាន់តំបន់សេវាក្នុងទីប្រជុំជនតាខ្មៅ និងតំបន់សេវានៅជុំវិញផងដែរ។

ចំពោះផែនការផលិតទឹកស្អាតសរុបក្នុងឆ្នាំ២០២៥ គឺមានអត្រាចំនួន ៨៥% ធៀបនឹងសមត្ថភាពផលិតទឹកស្អាតសរុបរបស់រោងចក្រទាំង៩។ តាមរយៈការវាយតម្លៃទៅលើអត្រានេះ រោងចក្រទាំង៩ របស់ រ.ទ.ស.ភ នឹងមានសមត្ថភាពផលិតទឹកស្អាតពេញលេញ ដើម្បីផ្គត់ផ្គង់ជូនដល់ប្រជាពលរដ្ឋបានគ្រប់គ្រាន់នៅឆ្នាំ ២០២៥ ខាងមុខនេះ។ ក្នុងនោះផងដែរ រ.ទ.ស.ភ ក៏នឹងរំពឹងថាមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការធានាការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ នៅឆ្នាំបន្ទាប់ទៀត ផងដែរ។

ផែនការចាត់ចែងដំណើរការផលិតទឹកស្អាតរបស់រោងចក្រផលិតទឹកស្អាតទាំង៩ របស់ រ.ទ.ស.ភ មានបង្ហាញក្នុងតារាងដូចខាងក្រោម៖

| រោងចក្រ ផលិតទឹកស្អាត | ផែនការផលិតកម្មទឹកស្អាត ក្នុងឆ្នាំ2025 (ម៉ែត្រគូប) | | | | | |
|---|---|---|---|---|---|---|
| | លទ្ធផលប៉ាន់ស្មានឆ្នាំ2024 | ផែនការឆ្នាំ2025 | កំណើន ធៀប2024 | ផែនការ ផលិតកម្មមធ្យម ប្រចាំថ្ងៃ | សមត្ថភាព ផលិតមធ្យម ប្រចាំថ្ងៃ | ប្រសិទ្ធភាព ដំណើរការ រោងចក្រ |
| | (1) | (2) | (2/1) | (3) | (4) | (3/4) |
| ភូមិព្រៃក | 58,877,255 | 53,837,500 | 91% | 147,500 | 150,000 | 98% |
| ជ្រោយចង្វារ | 44,529,999 | 36,500,000 | 82% | 100,000 | 130,000 | 77% |
| ចំការមន | 19,118,976 | 18,250,000 | 95% | 50,000 | 52,000 | 96% |
| និរោធ | 96,993,230 | 94,900,000 | 98% | 260,000 | 260,000 | 100% |
| បាក់ខែងដំហានទី1+2 | 100,231,829 | 101,580,500 | 101% | 278,303 | 390,000 | 71% |
| បឹងធំ | 549,000 | 2,190,000 | - | 6,000 | 6,000 | 100% |
| តាខ្មៅ | | 9,792,000 | - | 32,000 | 30,000 | 107% |
| ម្លេច | 553,427 | 522,500 | 94% | 1,432 | 2,000 | 72% |
| ត្បូងឃ្មុំ | 591,982 | 577,500 | 98% | 1,772 | 10,000 | 18% |
| **សរុប** | **321,445,698** | **318,150,000** | **99%** | **877,007** | **1,030,000** | **85%** |

## អត្រាបរិមាណផលិតកម្មទឹកស្អាតរបស់រោងចក្រទាំងប្រាំបួន




ចំពោះការរៀបចំផែនការ ក្នុងការកំណត់បរិមាណវត្ថុធាតុដើមសម្រាប់ផលិតកម្មទឹកស្អាត គឺផ្អែកលើទិន្នន័យប្រើប្រាស់ជាក់ស្តែងក្នុងឆ្នាំ២០២២ ឆ្នាំ២០២៣ និងឆ្នាំ២០២៤ ដោយគោរពយ៉ាងខ្ជាប់ខ្ជួនទៅនឹងបទដ្ឋាននៃប្រតិបត្តិការផលិតកម្មទឹកស្អាត និងគុណភាពទឹក ដើម្បីធានាឱ្យបាននូវគុណភាពទឹកស្អាត គ្មានមេរោគ ដែលស្របតាមស្តង់ដារទឹកផឹកថ្នាក់ជាតិ និងស្តង់ដារគុណភាពទឹកផឹករបស់អង្គការសុខភាពពិភពលោក។

### ផែនការប្រើប្រាស់វត្ថុធាតុដើម និងថាមពលអគ្គិសនី សម្រាប់ផលិតកម្មទឹកស្អាតឆ្នាំ២០២៥ មានដូចខាងក្រោម៖

| បរិយាយ | ផែនការប្រើប្រាស់វត្ថុធាតុដើម សម្រាប់ឆ្នាំ2025 | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ភូមិព្រែក | ជ្រោយចង្វារ | ចំការមន | និរោធ | បាក់ខែង ជំហាន ទី1+2 | បឹងធំ | តាខ្មៅ | ម្លេច | ត្បូងឃ្មុំ | សរុប |
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | (1+2+3+4+5+6+7+8+9) |
| PAC | គ.ក្រ | 704,165 | 279,383 | 233,192 | 1,042,478 | 969,434 | 95,070 | | 7,141 | 18,340 | 3,349,202 |
| | ក្រ.ម$^3$ | 13.08 | 7.65 | 12.78 | 10.99 | 9.54 | 43.41 | | 13.67 | 31.76 | 10.53 |
| ក្លរ៉ូរាវ | គ.ក្រ | - | 52,155 | 79,153 | - | 382,610 | - | | - | - | 513,918 |
| | ក្រ.ម$^3$ | - | 1.43 | 4.34 | | 3.77 | | | | | 2.34 |

| បរិយាយ | ផែនការប្រើប្រាស់វត្ថុធាតុដើម សម្រាប់ឆ្នាំ2025 | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ភូមិព្រែក | ជ្រោយចង្វារ | ចំការមន | និរោធ | បាក់ខែង ជំហាន ទី1+2 | បឹងធំ | តាខ្មៅ | ម្លេច | ត្បូងឃ្មុំ | សរុប |
| | | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | (1+2+3+4+5+6+7+8+9) |
| កំបោរ | គ.ក្រ | 323,173 | 128,200 | 77,600 | 403,520 | 355,863 | 14,262 | | - | - | 1,302,617 |
| | ក្រ.ម$^3$ | **6.00** | **3.51** | **4.25** | **4.25** | **3.50** | **6.51** | | | | **4.11** |
| ភ្ល័រឧស្ម័ន | គ.ក្រ | 207,547 | 66,308 | - | 327,996 | - | - | | - | - | 601,851 |
| | ក្រ.ម$^3$ | **3.86** | **1.82** | | **3.46** | | | | | | **3.25** |
| ភ្ល័រម្សៅ | គ.ក្រ | - | - | - | - | - | 25,176 | | 4,488 | 5,802 | 35,465 |
| | ក្រ.ម$^3$ | | | | | | **11.50** | | **8.59** | **10.05** | **10.78** |
| អគ្គិសនី | គ.វ៉.ម៉ | 15,612,875 | 10,367,552 | 4,562,500 | 28,470,000 | 30,270,989 | 657,000 | | 147,868 | 219,450 | 90,308,233 |
| | វ៉.ម៉./ម | **290** | **284** | **250** | **300** | **298** | **300** | | **283** | **380** | **293** |
| អគ្គិសនី រដ្ឋបាល | គ.វ៉.ម៉ | 790,900 | - | - | - | - | | | - | 31,550 | 822,450 |

ឯកតាប្រើប្រាស់វត្ថុធាតុដើម ដែលបានអនុវត្តក្នុងឆ្នាំ២០២៤ និងផែនការក្នុងឆ្នាំ២០២៥៖

| បរិយាយ | ឯកតាប្រើប្រាស់វត្ថុធាតុដើម | | |
|---|---|---|---|
| | លទ្ធផលប៉ាន់ស្មានឆ្នាំ2024 | ផែនការឆ្នាំ2025 | បម្រែបម្រួល |
| | (1) | (2) | (2)-(1) |
| PAC ( គ.ក ) | 3,974,570 | 3,349,202 | **-1.83 ក្រ.ម$^3$** |
| ក្រ.ម$^3$ | **12.36** | **10.53** | |
| ក្លររាវ ( គ.ក ) | 435,391 | 513,918 | **0.1 ក្រ.ម$^3$** |
| ក្រ.ម$^3$ | **2.24** | **2.34** | |
| កំបោរ ( គ.ក ) | 913,631 | 1,302,617 | **-2.07 ក្រ.ម$^3$** |

| | | | |
|---|---|---|---|
| ក្រ.ម3 | 6.18 | 4.11 | |
| ក្លរ៍ឧស្ម័ន (គ.ក) | 521,086 | 601,851 | 0.65 ក្រ.ម3 |
| ក្រ.ម3 | 2.6 | 3.25 | |
| ក្លរ៍ម្សៅ (គ.ក) | 64,213 | 35,465 | 6.29 ក្រ.ម3 |
| ក្រ.ម3 | 4.49 | 10.78 | |
| អគ្គិសនី (គ.វ.ម៉) | 88,891,803 | 90,308,233 | 5.87 វ.ម៉/ម3 |
| វ.ម៉/ម3 | 277 | 292.87 | |

- បរិមាណប្រើប្រាស់ PAC គ្រោងនឹងថយចុះប្រមាណ ១,៨៣ក្រាម/ម៣ បើធៀបទៅនឹងការប្រើប្រាស់ ឆ្នាំ២០២៤ ដោយសារនៅឆ្នាំ ២០២៥ ខាងមុខ គុណភាពទឹកអាចនឹងបន្តប្រែប្រួល ដែលបណ្តាលមកពី បម្រែបម្រួលកម្ពស់ទឹក ពីមួយឆ្នាំទៅមួយឆ្នាំ។

- បរិមាណប្រើប្រាស់ក្លរ៍រាវគ្រោងនឹងកើនឡើងប្រមាណ ០,១ក្រាម/ម៣ បើធៀបនឹងការប្រើប្រាស់ឆ្នាំ២០២៤។

- បរិមាណប្រើប្រាស់កំបោរ គ្រោងនឹងថយចុះប្រមាណ ២,០៧ក្រាម/ម៣ បើធៀបនឹងការប្រើប្រាស់ ក្នុងឆ្នាំ ២០២៤ ដោយសារក្នុងឆ្នាំ២០២៥ ខាងមុខ រោងចក្រចំនួន៧ ដូចជាភូមិព្រៃក ជ្រោយចង្វារ ចំការមន និរោធ បាក់ខែង និងបឹងធំ គ្រោងនឹងប្រើប្រាស់កំបោរ នៅពេលដែលមានបម្រែបម្រួល pH ទៅតាមរដូវ និងតម្រូវការដាក់ស្តែងតែប៉ុណ្ណោះ។

- បរិមាណប្រើប្រាស់ក្លរ៍ឧស្ម័ន នឹងមានការកើនឡើងប្រមាណ ០,៦៥ក្រាម/ម៣ ដោយសារការជួយបំពេញ បន្ថែមទៅលើការប្រើប្រាស់ក្លរ៍រាវ នៅក្នុងរោងចក្រភូមិព្រៃក ជ្រោយចង្វារ និងនិរោធ។

- បរិមាណប្រើប្រាស់ក្លរ៍ម្សៅ នឹងមានការកើនឡើងប្រមាណ ៦,២៩ក្រាម/ម៣ ដោយសាររោងចក្រផលិតទឹកស្អាតបឹងធំ នឹងចាប់ផ្តើមដំណើរការពេញសមត្ថភាព នាឆ្នាំ២០២៥ ខាងមុខ។

- បរិមាណប្រើប្រាស់ថាមពលអគ្គិសនីនឹងមានការកើនឡើងប្រមាណ ៥,៨៧វ.ម៉/ម៣ ធៀបនឹងឆ្នាំ២០២៤ ដោយសារនៅក្នុងឆ្នាំ២០២៥ រ.ទ.ស.ភ បានដាក់ឱ្យដំណើរការពេញសមត្ថភាពរបស់រោងចក្រផលិតទឹកស្អាតបឹងធំ។

## ២. ផែនការសេវាអតិថិជន

នៅក្នុងឆ្នាំ២០២៥ រោងចក្រផលិតទឹកស្អាតទាំងប្រាំបួន នឹងត្រូវដំណើរការពេញសមត្ថភាព (ភូមិព្រៃក, ជ្រោយចង្វារ, ចំការមន, និរោធ ,បាក់ខែងជំហានទី១ និងទី២, បឹងធំ, តាខ្មៅ, ម្លេច និងត្បូងឃ្មុំ) ដែលផ្តល់លទ្ធភាពឱ្យ រ.ទ.ស.ភ ដើម្បីធ្វើការពង្រីក ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតបន្ថែមនៅតំបន់ជាយក្រុង និងបំពេញតំបន់តាមច្រកក្នុងផ្ទៃសេវា។ ការពង្រីក ផ្ទៃសេវានេះត្រូវបានផ្តល់អាទិភាពទៅតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចទៅលើការអភិវឌ្ឍលំនៅដ្ឋាន និងឧស្សាហកម្មនានា ដោយមិនមើលរំលងតំបន់រស់នៅ របស់ប្រជាពលរដ្ឋដែលមានចំណូលទាប។

## ២.១ ផែនការតបណ្តាញចូលផ្ទះ

យោងតាមលទ្ធផលនៃការធ្វើអង្កេត តម្រូវការប្រើប្រាស់ទឹកស្អាតលើទីតាំងដែលគ្រោងពង្រីកតំបន់សេវា សម្រាប់ឆ្នាំ២០២៥ រ.ទ.ស.ភ បានរៀបចំផែនការតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋចំនួន ៣០.០០០គ្រួសារ (រាជធានីភ្នំពេញ និងតាខ្មៅ) ដែលក្នុងនោះប្រភេទអតិថិជនជីវភាពមានចំនួន ២៤.៦៥៨គ្រួសារ អតិថិជនអាជីវកម្មមានចំនួន ២.៣៤២គ្រួសារ និងអតិថិជនចំណូលទាបមានចំនួន ៣.០០០គ្រួសារ។ លទ្ធផលនៃការធ្វើអង្កេតមានលម្អិតជូនក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះទីតាំង | ចំនួនគ្រួសារអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | ចំនួន | ភាគរយ | |
| **I. គម្រោងដាក់បំពង់ថ្មីជាយក្រុង ឆ្នាំ 2025** | | **21,807** | **18,205** | **1,164** | **83%** | **2,438** | **11%** | |
| **ក/ខណ្ឌកំបូល** | | | | | | | | |
| **ក.1** | **សង្កាត់ភ្លើងឆេះរទេះ** | | | | | | | |
| 1 | ភូមិត្រាញ់តាប៉ាញ់ | 127 | 58 | 19 | 61% | 50 | 39% | 03ឃ្លាំង |
| 2 | ភូមិភ្លើងឆេះរទេះលិច | 353 | 295 | 15 | 88% | 43 | 12% | 04ឃ្លាំង |
| 3 | ភូមិភ្លើងឆេះរទេះកើត | 259 | 192 | 16 | 80% | 51 | 20% | 10ឃ្លាំង |
| 4 | ភូមិគោកខ្សាច់ | 272 | 221 | 12 | 86% | 39 | 14% | 01ឃ្លាំង |
| 5 | ភូមិទួលគី | 356 | 290 | 21 | 87% | 45 | 13% | 05ឃ្លាំង |
| 6 | ភូមិកប់ត្នក | 335 | 273 | 15 | 86% | 47 | 14% | |
| 7 | ភូមិព្រៃរងៀង | 294 | 222 | 26 | 84% | 46 | 16% | 6ឃ្លាំង |
| **ក.2** | **សង្កាត់ស្នោរ** | | | | | | | |
| 8 | ភូមិរំដួលត្បូង | 99 | 53 | 4 | 58% | 42 | 42% | 02ឃ្លាំង |
| 9 | ភូមិរំដួលជើង | 122 | 61 | 11 | 59% | 50 | 41% | 03ឃ្លាំង |
| 10 | ភូមិព្រៃកាយ | 55 | 31 | 2 | 60% | 22 | 40% | |
| 11 | ភូមិតាអិន | 211 | 149 | 13 | 77% | 49 | 23% | 02ឃ្លាំង |
| 12 | ភូមិតាពូង | 97 | 67 | 12 | 81% | 18 | 19% | 04ឃ្លាំង |
| 13 | ភូមិស្នោរលិច | 179 | 123 | 7 | 73% | 49 | 27% | 02ឃ្លាំង |

| ល.រ | ឈ្មោះទីតាំង | ចំនួនគ្រួសារ អតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | ចំនួន | ភាគរយ | |
| 14 | ភូមិស្មោរកើត | 161 | 99 | 4 | 64% | 58 | 36% | |
| 15 | ភូមិសាក់ប្រយុទ្ធ | 58 | 40 | 1 | 71% | 17 | 29% | |
| 16 | ភូមិអង្គជ័យ | 94 | 41 | 9 | 53% | 44 | 47% | 02ឃ្លាំង |
| 17 | ភូមិទួលលៀប | 184 | 113 | 6 | 65% | 65 | 35% | |
| **ក.3** | **សង្កាត់កំបូល** | | | | | | | |
| 18 | ភូមិជំទាវម៉ៅ | 86 | 57 | 2 | 69% | 27 | 31% | |
| 19 | ភូមិកប់អំពិស | 85 | 63 | 4 | 79% | 18 | 21% | |
| 20 | ភូមិអង្គបឹងចក | 75 | 44 | 7 | 68% | 24 | 32% | |
| 21 | ភូមិលិចវត្ត | 114 | 48 | 12 | 53% | 54 | 47% | 03ឃ្លាំង |
| 22 | ភូមិតានួន | 248 | 176 | 24 | 81% | 48 | 19% | 06ឃ្លាំង |
| 23 | ភូមិស្នួលខ្ពស់ | 212 | 161 | 13 | 82% | 38 | 18% | 04ឃ្លាំង |
| 24 | ភូមិអំពិល | 85 | 50 | 2 | 61% | 33 | 39% | 02ឃ្លាំង |
| 25 | ភូមិគ្រឹប | 147 | 102 | 8 | 75% | 37 | 25% | 01ឃ្លាំង |
| 26 | ភូមិសាឡុង | 279 | 221 | 4 | 81% | 54 | 19% | |
| **ក.4** | **សង្កាត់ឪឡោក** | | | | | | | |
| 27 | ភូមិត្រពាំងពោធិ | 119 | 78 | 7 | 71% | 34 | 29% | |
| 28 | ភូមិសាមគ្គីប្រយុទ្ធ | 13 | 9 | 0 | 69% | 4 | 31% | |
| 29 | ភូមិជ័យជំនះ | 32 | 24 | 1 | 78% | 7 | 22% | |
| 30 | ភូមិត្រពាំងអារក្ស | 223 | 173 | 21 | 87% | 29 | 13% | 04ឃ្លាំង |
| 31 | ភូមិបឹងកំបោរ | 37 | 24 | 1 | 68% | 12 | 32% | |
| 32 | ភូមិថ្ម | 45 | 29 | 4 | 73% | 12 | 27% | |
| 33 | ភូមិបឹងគ្រើស | 117 | 79 | 11 | 77% | 27 | 23% | 02ឃ្លាំង |

| ល.រ | ឈ្មោះទីតាំង | ចំនួនគ្រួសារអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | ចំនួន | ភាគរយ | |
| 34 | ភូមិដូនវត្ត | 127 | 87 | 6 | 73% | 34 | 27% | |
| 35 | ភូមិពង្រ | 78 | 55 | 1 | 72% | 22 | 28% | |
| **ក.5** | **សង្កាត់បឹងធំ** | | | | | | | |
| 36 | ភូមិព្រៃតាកែ | 140 | 96 | 11 | 76% | 33 | 24% | |
| 37 | ភូមិត្រពាំងក្រសាំង | 107 | 55 | 8 | 59% | 44 | 41% | 04ឃ្លាំង |
| 38 | ភូមិចំបក់ពណ្ណរាយ | 94 | 51 | 6 | 61% | 37 | 39% | |
| 39 | ភូមិទួលស្វាយ | 108 | 75 | 3 | 72% | 30 | 28% | |
| **ខ/ខណ្ឌដង្កោ** | | | | | | | | |
| **ខ.1** | **សង្កាត់ពងទឹក** | | | | | | | |
| 40 | ភូមិស្រញ៉ រ | 272 | 220 | 18 | 88% | 34 | 13% | 06ឃ្លាំង |
| 41 | ភូមិឃ្លះសណ្ដាយ | 220 | 166 | 7 | 79% | 47 | 21% | |
| **ខ.2** | **សង្កាត់ស្ពានថ្ម** | | | | | | | |
| 42 | ភូមិស្ពានថ្ម | 130 | 94 | 4 | 75% | 32 | 25% | |
| 43 | ភូមិម៉ឺនត្រា | 443 | 389 | 9 | 90% | 45 | 10% | 02ឃ្លាំង |
| 44 | ភូមិអញ្ចាញ | 155 | 116 | 5 | 78% | 34 | 22% | |
| 45 | ភូមិគោកឪឡឹក | 272 | 219 | 8 | 83% | 45 | 17% | |
| 46 | ភូមិព្រែកជ្រៃ | 144 | 93 | 17 | 76% | 34 | 24% | 12ឃ្លាំង |
| 47 | ភូមិដូង | 62 | 39 | 2 | 66% | 21 | 34% | |
| 48 | ភូមិហា | 114 | 72 | 4 | 67% | 38 | 33% | |
| 49 | ភូមិស្វាយមានលក្ខណ៍ | 82 | 58 | 6 | 78% | 18 | 22% | |
| **ខ.3** | **សង្កាត់ព្រែកកំពឹស** | | | | | | | |
| 50 | ភូមិក្រាំងស្វាយ (ត្បូង) | 6,800 | 6,298 | 467 | 99% | 35 | 1% | 20ឃ្លាំង |

| ល.រ | ឈ្មោះទីតាំង | ចំនួនគ្រួសារអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | ចំនួន | ភាគរយ | |
| 51 | ភូមិក្រាំងស្វាយ | 924 | 858 | 24 | 95% | 42 | 5% | 08ឃ្លាំង |
| 52 | ភូមិព្រៃកកំពឹស | 399 | 351 | 12 | 91% | 36 | 9% | |
| **ខ.4** | **សង្កាត់សាក់សំពៅ** | | | | | | | |
| 53 | ភូមិពោធិ៍រលំ | | | | | | | |
| 54 | ភូមិខ្វិត | | | | | | | |
| 55 | ភូមិក្រាំង | 600 | 457 | 22 | 80% | 121 | 20% | |
| 56 | ភូមិតាផូ | | | | | | | |
| 57 | ភូមិកំរៀង | | | | | | | |
| **ខ.5** | **សង្កាត់រលួស** | | | | | | | |
| 58 | ភូមិកណ្ដាល | 3,200 | 3,016 | 129 | 98% | 55 | 2% | 12ឃ្លាំង |
| **គ/ខណ្ឌព្រែកព្នៅ** | | | | | | | | |
| **គ.1** | **សង្កាត់ពង្សាំង** | | | | | | | |
| 59 | ភូមិចុងថ្នល់ | 176 | 143 | 4 | 84% | 29 | 16% | 01ឃ្លាំង |
| 60 | ភូមិបឹងខ្នំ | 216 | 175 | 7 | 84% | 34 | 16% | |
| 61 | ភូមិកន្លែងគល់ | 185 | 146 | 5 | 82% | 34 | 18% | 02ឃ្លាំង |
| 62 | ភូមិចំបក់ធំ | 85 | 62 | 1 | 74% | 22 | 26% | 04ឃ្លាំង |
| 63 | ភូមិត្រពាំងថ្លាន់ | 126 | 77 | 11 | 70% | 38 | 30% | |
| 64 | ភូមិត្រពាំងស្គន់ | 36 | 21 | 3 | 67% | 12 | 33% | 02ឃ្លាំង |
| 65 | ភូមិត្នោតខ្ពស់ | 222 | 181 | 4 | 83% | 37 | 17% | |
| 66 | ភូមិតាស្គរ | 85 | 57 | 2 | 69% | 26 | 31% | |
| 67 | ភូមិព្រៃស្នួល | 102 | 58 | 5 | 62% | 39 | 38% | |
| 68 | ភូមិទួល | 174 | 135 | 7 | 82% | 32 | 18% | |

| ល.រ | ឈ្មោះទីតាំង | ចំនួនគ្រួសារអតិថិជន | អតិថិជន | | | អតិថិជនចំណូលទាប | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | | ជីវភាព | អាជីវកម្ម | ភាគរយ | ចំនួន | ភាគរយ | |
| 69 | ភូមិទួលពង្សាំង | 129 | 88 | 9 | 75% | 32 | 25% | |
| ឃ/ក្រុងតាខ្មៅ | | | | | | | | |
| ឃ.1 | សង្កាត់កំពង់សំណាញ់ | | | | | | | |
| 70 | ភូមិព្រែករាំង | 407 | 351 | 17 | 90% | 39 | 10% | 06ឃ្លាំង |
| 71 | ភូមិអាចម៍កុក | 220 | 180 | 6 | 85% | 34 | 15% | 02ឃ្លាំង |
| **II. គម្រោងបំពេញផ្ទៃសេវាឆ្នាំ2025** | | **8,193** | **6,453** | **1,178** | **93%** | **562** | **7%** | **សំណង់** |
| 1 | 04ខណ្ឌក្នុងក្រុង ( D1,D2,D3,D4) | 100 | 71 | 10 | 81% | 19 | 19% | |
| 2 | ខណ្ឌឬស្សីកែវ | 750 | 547 | 116 | 88% | 87 | 12% | **400** |
| 3 | ខណ្ឌមានជ័យ | 450 | 380 | 38 | 93% | 32 | 7% | **200** |
| 4 | ខណ្ឌដង្កោ | 723 | 629 | 32 | 91% | 62 | 9% | **500** |
| 5 | ខណ្ឌពោធិសែនជ័យ | 1,400 | 1,122 | 213 | 95% | 65 | 5% | **1,100** |
| 6 | ខណ្ឌសែនសុខ | 700 | 518 | 116 | 91% | 66 | 9% | **400** |
| 7 | ខណ្ឌជ្រោយចង្វារ | 1,300 | 1,013 | 226 | 95% | 61 | 5% | **1,000** |
| 8 | ខណ្ឌច្បារអំពៅ | 1,200 | 926 | 214 | 95% | 60 | 5% | **880** |
| 9 | ខណ្ឌព្រែកព្នៅ | 1,200 | 945 | 189 | 95% | 66 | 6% | **1,100** |
| 10 | ក្រុងតាខ្មៅ | 370 | 302 | 24 | 88% | 44 | 12% | **220** |
| សរុប | | **30,000** | **24,658** | **2,342** | **90%** | **3,000** | **10.00%** | **5,800** |

## ២.២ ផែនការដោះដូរនាឡិកា

នាឆ្នាំ ២០២៥ ខាងមុខ រ.ទ.ស.ភ មានផែនការដោះដូរនាឡិកា ដែលមានទំហំចាប់ពី ១៥ ដល់ ៣០០មម សរុបចំនួន ៣៥.៩១៨ នាឡិកា។ ក្នុងនោះផងដែរ ផែនការសកម្មភាព ក្នុងការអនុវត្តការងារផ្លាស់ប្តូរនាឡិកា ចាប់ពីត្រីមាស១ ដល់ត្រីមាស៤ ឆ្នាំ២០២៥ ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ទំហំនាឡិកា | ឯកតា | ផែនការឆ្នាំ2025 | ផែនការ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | ត្រីមាសទី1/2025 | ត្រីមាសទី2/2025 | ត្រីមាសទី3/2025 | ត្រីមាសទី4/2025 | |
| ក | ខ | គ | ឃ | 1 | 2 | 3 | 4 | 5 | |
| 1 | ផ្លាស់ប្តូរនាឡិកា | 15 | គ្រឿង | **35,000** | 8,750 | 8,750 | 8,750 | 8,750 | ដោះដូរនាឡិកាអាយុកាល 11ឆ្នាំឡើងមានចំនួន 30,000 គ្រឿង |
| 2 | ផ្លាស់ប្តូរនាឡិកា | 20 | - | **350** | 88 | 88 | 87 | 87 | |
| 3 | ផ្លាស់ប្តូរនាឡិកា | 25 | - | **300** | 75 | 75 | 75 | 75 | |
| 4 | ផ្លាស់ប្តូរនាឡិកា | 40 | - | **170** | 43 | 43 | 42 | 42 | |
| 5 | ផ្លាស់ប្តូរនាឡិកា | 80 | - | **66** | 17 | 17 | 16 | 16 | សម្រាប់ផ្លាស់ប្តូរពីនាឡិកាមេហ្គានិចមកអេឡិចត្រូម៉ាញ៉េទិច |
| 6 | ផ្លាស់ប្តូរនាឡិកា | 100 | - | **24** | 6 | 6 | 6 | 6 | |
| 7 | ផ្លាស់ប្តូរនាឡិកា | 150 | - | **5** | 1 | 1 | 2 | 1 | |
| 8 | ផ្លាស់ប្តូរនាឡិកា | 200 | - | **1** | 0 | 1 | 0 | 0 | |
| 9 | ផ្លាស់ប្តូរនាឡិកា | 250 | - | **1** | 0 | 1 | 0 | 0 | |
| 10 | ផ្លាស់ប្តូរនាឡិកា | 300 | - | **1** | 0 | 1 | 0 | 0 | |
| | សរុប | | | **35,918** | **8,980** | **8,983** | **8,978** | **8,977** | |

## ២.៣ ផែនការអាជីវកម្ម

### ២.៣.១ ការងារអាជីវកម្មស្នាក់ការកណ្តាល (រាជធានីភ្នំពេញ និងក្រុងតាខ្មៅ)

ក្រោយពីដាក់ដំណើរការរោងចក្រផលិតទឹកស្អាតបាក់ខែងដំណាក់កាលទី១ និងទី២ នៅក្នុងឆ្នាំ២០២៤ និងផែនការដំណើរការនូវរោងចក្រផលិតទឹកស្អាតតាខ្មៅ នាឆ្នាំ២០២៥ ខាងមុខ រ.ទ.ស.ភ បាននឹងកំពុងអនុវត្តការងារដាក់បំពង់មេនាំទឹក និងបំពង់ចែកចាយទឹក ដើម្បីបញ្ជូន និងចែកចាយទឹកស្អាតជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់សេវាកម្មក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ ជាពិសេសតំបន់ជាយក្រុងឱ្យទទួលបានសម្ពាធទឹកគ្រប់គ្រាន់ សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។

នាឆ្នាំ២០២៥ ខាងមុខ រ.ទ.ស.ភ គ្រោងនឹងពង្រីកអាជីវកម្ម នៅទូទាំងតំបន់សេវា និងជាពិសេសតំបន់សេវាកម្មដែលគ្រោងនឹងពង្រីកតាមរយៈផែនការតបណ្តាញអតិថិជនថ្មីចំនួន ៣០.០០០បណ្តាញ ដោយអនុវត្តទៅតាមកម្មវិធីការងារដាក់បំពង់មេ និងបំពង់ចែកចាយទឹកស្អាត ក្នុងឆ្នាំ២០២៥។

តាមរយៈការចុះអង្កេតចំនួនអតិថិជននៅក្នុងតំបន់ផ្ទៃសេវា ជាពិសេសតំបន់ដែលគ្រោងពង្រីកបណ្តាញបំពង់ចែកចាយទឹកស្អាត ជាលទ្ធផលបណ្តាញអតិថិជនប្រភេទអាជីវកម្មដែលប្រើប្រាស់ទឹកក្នុងបរិមាណច្រើនមានចំនួន ២.៣៤២ទីតាំង

និងភាគច្រើនជាប្រភេទជីវភាពធម្មតា និងសំណង់ផ្ទះល្វែង។ ផ្អែកលើលទ្ធផលចុះអង្កេត និងសន្ទស្សន៍តាមបណ្តាឆ្នាំកន្លងមក ជាពិសេសសូចនាករប៉ាន់ស្មាននៃឆ្នាំ២០២៤ រ.ទ.ស.ភ សន្និដ្ឋានថានៅក្នុងឆ្នាំ២០២៥ខាងមុខ អតិថិជនសរុបនឹងកើនឡើងដល់ ៥២៧.៥៥០បណ្តាញ (បណ្តាញមិនប្រើប្រាស់ទឹកនឹងមានចំនួនប្រមាណ ៣៦.០០០បណ្តាញ) ដែលបរិមាណប្រើប្រាស់ទឹកជាមធ្យមក្នុងមួយបណ្តាញក្នុងមួយខែនឹងមានចំនួនប្រមាណ ៤៣ម៣/បណ្តាញ/ខែ និងថ្លៃលក់ទឹកមធ្យមនឹងស្មើនឹងប្រមាណ ១.៣៥០រៀល/ម៣។

ដូច្នេះ បរិមាណទឹកលក់សរុបនឹងមានចំនួនប្រមាណ ២៥៣.៦៣៩.៨០០ម៣ ដែលគ្រោងនឹងទទួលបានចំណូលពីថ្លៃលក់ទឹកសរុបចំនួនប្រមាណ ៣៤២.៤១៣.៧៣០.០០០រៀល។ ក្នុងនោះផងដែរ អត្រាទឹកគ្មានចំណូលសម្រាប់ ឆ្នាំ ២០២៥ ត្រូវបានកំណត់ថាគ្រោងនឹងថយនៅត្រឹមប្រមាណ ២០% ដែលនឹងតម្រូវឱ្យបរិមាណផលិតកម្មទឹកស្អាត ស្មើ នឹងប្រមាណ ៣១៧.០៥០.០០០ម៣។

សន្ទស្សន៍អាជីវកម្មសំខាន់ៗ៖

| បរិយាយ | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|---|---|---|
| បរិមាណទឹក/បណ្តាញ/ខែ (ម³) | 44.08 | 44.88 | 44.96 | 42.58 | 41.16 | 41.35 | 46.57 | 42.45 | 43 |
| ថ្លៃទឹកលក់ជាមធ្យម(៛/ម³) | 1,017 | 1,001 | 999.32 | 1,350 | 1,311 | 1308.99 | 1,333.72 | 1,337.18 | 1,350 |

តារាងផែនការអាជីវកម្មនៅតំបន់សេវាក្នុងរាជធានីភ្នំពេញ និងក្រុងតាខ្មៅ សម្រាប់ឆ្នាំ២០២៥ មានដូចខាងក្រោម៖

| បរិយាយ | ឯកតា | លទ្ធផលប៉ាន់ស្មានឆ្នាំ២០២៤ (1) | ផែនការឆ្នាំ២០២៥ (2) | អត្រា% (2/1) |
|---|---|---|---|---|
| 1-តបណ្តាញចូលផ្ទះ | បណ្តាញ | 30,000 | 30,000 | **100%** |
| 2-ចំនួនអតិថិជនចុងគ្រា | អតិថិជន | 497,300 | 527,550 | **106%** |
| 3-ទឹកប្រើប្រាស់/បណ្តាញ/ខែ | ម³ | 42.45 | 43 | **101%** |
| 4-បរិមាណទឹកលក់ | ម³ | 231,985,142 | 253,639,800 | **109%** |
| 5-បរិមាណទឹកផលិត | ម³ | 320,300,289 | 317,050,000 | **99%** |
| 6-អត្រាធ្វើបរិមាណទឹកលក់ | % | 72.43 | 80 | **110%** |
| 7-ថ្លៃទឹកប្រកាសលក់ | រៀល | 310,206,801,815 | 342,413,730,000 | **110%** |
| 8-អត្រាទារប្រាក់ថ្លៃទឹក | % | 99.9 | 99.9 | **100%** |
| 9-ថ្លៃទឹកលក់ជាមធ្យម | រៀល/ម³ | 1,337.18 | 1,350.00 | **101%** |

### ២.៣.២ ការងារអាជីវកម្មខេត្តត្បូងឃ្មុំ

ក្រៅពីផែនការពង្រីកអាជីវកម្មនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ សម្រាប់ឆ្នាំ២០២៥ ខាងមុខ រ.ទ.ស.ភ គ្រោងនឹងផលិតទឹកស្អាតនៅរោងចក្រត្បូងឃ្មុំចំនួនប្រមាណ ៦៤៦.៦០៨ម$^{៣}$ ដោយបរិមាណទឹកលក់គ្រោងនឹងលក់បានប្រមាណ ៥៨៧.៨២៥ម$^{៣}$ ជាមួយនឹងការប៉ាន់ស្មានអត្រាទឹកគ្មានចំណូលប្រមាណ ១០%។ ផ្អែកលើស្ថានភាពអាជីវកម្មជាក់ស្តែងបច្ចុប្បន្ន ថ្លៃលក់ទឹកជាមធ្យមក្នុងឆ្នាំ២០២៥ គ្រោងនឹងទទួលបានដូចទៅនឹងឆ្នាំ២០២៤ ដែលស្មើនឹង ២.០០០ រៀល/ម$^{៣}$ ដោយក្នុងនោះ ចំណូលថ្លៃលក់ទឹក គ្រោងនឹងទទួលបានចំនួនប្រមាណ ១.១៧៥.៦៥០.០០០រៀល។

### ២.៣.៣ ការងារអាជីវកម្មម្លេច

ចំពោះផែនការក្នុងឆ្នាំ២០២៥ សម្រាប់អាជីវកម្មនៅរោងចក្រផលិតទឹកស្អាតម្លេច រ.ទ.ស.ភ គ្រោងនឹងផលិតទឹកស្អាតប្រមាណ ៥២២.៥០០ម$^{៣}$ ដោយបរិមាណទឹកលក់គ្រោងនឹងលក់បានប្រមាណ ៤៩៦.៣៧៥ម$^{៣}$ ជាមួយអត្រាទឹកគ្មានចំណូលប្រមាណ ៥%។ ក្នុងនោះផងដែរ ថ្លៃលក់ទឹកជាមធ្យមក្នុងឆ្នាំ ២០២៥ គ្រោងនឹងទទួលបានដូចទៅនឹងឆ្នាំ២០២៤ ដែលស្មើនឹង ១.៧៥០រៀល/ម$^{៣}$ ដោយចំណូលថ្លៃលក់ទឹក គ្រោងនឹងទទួលបានចំនួនប្រមាណ ៨៦៨.៦៥៦.២៥០រៀល។

## ៣. ផែនការហិរញ្ញវត្ថុ

ដើម្បីសម្រេចបាននូវគោលបំណងនេះ រ.ទ.ស.ភ បានកសាងផែនការដំណើរការសហគ្រាសសម្រាប់ឆ្នាំ២០២៥ ដោយផ្អែកលើរបាយការណ៍លទ្ធផលជាក់ស្តែង៨ខែ បូកប៉ាន់ស្មាន៤ខែ ឆ្នាំ២០២៤ មានដូចខាងក្រោម៖

**តារាងផែនការគណនីលទ្ធផល សម្រាប់ឆ្នាំ២០២៥**

| បរិយាយ | លទ្ធផលប៉ាន់ស្មាន ឆ្នាំ ២០២៤ | ផែនការឆ្នាំ ២០២៥ | អត្រា (%) |
|---|---|---|---|
| ក. ចំណូល | (1) | (2) | (2)/(1) |
| 1-ចំណូលថ្លៃទឹក | 312,144,312,700 | 344,458,036,000 | 110 |
| 2-ចំណូលសិទ្ធិជាវទឹក | 11,718,602,600 | 10,965,000,000 | 94 |
| 3-ចំណូលពីសេវាកម្ម | 15,528,729,500 | 15,773,893,000 | 102 |
| 4-ចំណេញលើអត្រាប្តូរប្រាក់ | 33,479,026,292 | 31,039,294,000 | 93 |
| 5-ចំណូលផ្សេងៗ | 31,737,809,296 | 28,469,608,000 | 90 |
| **សរុបចំណូល (រៀល)** | **404,608,480,388** | **430,705,831,000** | **106** |
| ខ. ចំណាយដំណើរការសហគ្រាស | | | |
| 1-ប្រាក់បៀវត្តន៍សុទ្ធ | 43,365,003,529 | 47,389,808,000 | 109 |
| 2-ប្រាក់បំណាច់ | 19,396,853,365 | 19,496,078,000 | 101 |
| 3-ប្រាក់ឧបត្ថម្ភ | 22,880,487,453 | 26,347,693,000 | 115 |
| 4-ជួសជុលបរិក្ខាផលិតកម្ម | 2,479,237,767 | 2,119,555,000 | 85 |
| 5-ជួសជុលបរិក្ខាប្រព័ន្ធចែកចាយ | 8,640,185,412 | 6,477,726,000 | 75 |
| 6-ជួសជុលយានយន្ត និងប្រេងឥន្ធនៈ | 4,263,246,531 | 4,505,598,000 | 106 |
| 7-វត្ថុធាតុដើមសំរាប់ប្រព្រឹត្តកម្មទឹកស្អាត | 17,935,822,514 | 18,419,614,000 | 103 |
| 8-អគ្គីសនី | 52,330,970,339 | 50,801,383,000 | 97 |
| 9-ទិញទឹកដុំ | - | 2,944,000,000 | - |
| 10-បោះពុម្ពវិក្កយបត្រថ្លៃទឹក | 1,211,634,220 | 1,341,107,000 | 111 |
| 11-រដ្ឋបាល | 7,324,556,849 | 6,394,649,000 | 87 |

| | | | |
|---|---|---|---|
| 12-សេវាកម្មរបស់សាខា | 9,938,387,700 | 10,095,291,000 | 102 |
| 17-បាត់បង់ក្រៅអាជីវកម្ម | 1,100,610,933 | 1,241,081,000 | 113 |
| **សរុបចំណាយដំណើរការសហគ្រាស (រៀល)** | **190,866,996,613** | **197,573,583,000** | **104** |
| 18-ដោះដូរនាឡិកា | 5,246,388,951 | 5,274,455,000 | 101 |
| 19-ចំណាយក្រៅដំណើរការសហគ្រាស | 5,527,297,282 | 2,623,817,000 | 47 |
| 20-ខាតលើអត្រាប្ដូរប្រាក់ | 33,292,214,287 | 24,226,727,000 | 73 |
| **សរុបចំណាយរង (រៀល)** | **234,932,897,132** | **229,698,582,000** | **98** |
| **ចំណេញ (ខាត)មុនដករំលស់(រៀល)** | **169,675,583,256** | **201,007,249,000** | **118** |
| 21-រំលស់ | 61,535,387,677 | 84,365,770,000 | 137 |
| 22-ការប្រាក់ | 15,229,994,111 | 15,149,127,000 | 99 |
| **សរុបចំណាយរួម (រៀល)** | **311,698,278,920** | **329,213,479,000** | **106** |
| **ចំណេញ (ខាត) មុនបង់ពន្ធ (រៀល)** | **92,910,201,468** | **101,492,352,000** | **110** |
| 23-ពន្ធលើប្រាក់ចំណេញ | 18,582,040,258 | 20,298,470,000 | 109 |
| **ចំណេញ (ខាត) ពិត (រៀល)** | **74,328,161,210** | **81,193,882,000** | **109** |

## ៤. ផែនការធនធានមនុស្ស

ការអនុវត្តវិធានការផ្តល់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំលើការងារធនធានមនុស្ស គឺជាមូលដ្ឋានក្នុងការជម្រុញលើកទឹកចិត្ត ដល់ការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ដើម្បីជំរុញឱ្យអង្គភាពដំណើរការបានកាន់តែប្រសើរ។ ក្នុងនោះផងដែរផែនការ ធនធានមនុស្សនាឆ្នាំ ២០២៥ ខាងមុខ រួមមាន៖

- គ្រោងដំឡើងកាំប្រាក់បៀវត្សចំនួន ០១កាំ ជូនមន្ត្រី-និយោជិតក្នុងក្របខណ្ឌទាំងបួន។
- គ្រោងជ្រើសរើសនិយោជិតអនុវត្តការងារល្អប្រសើរ តាមគោលការណ៍របស់ រ.ទ.ស.ភ។
- គ្រោងស្នើសុំផ្តល់ប្រាក់បុព្វលាភប្រចាំឆ្នាំជូនមន្ត្រី-និយោជិត។
- គ្រោងស្នើសុំផ្តល់ប្រាក់បំណាច់អតីតភាពជូនមន្ត្រី-និយោជិត។

# ៥. ផែនការវិនិយោគ

## ក. ពង្រីកសមត្ថភាពប្រព័ន្ធផ្គត់ផ្គង់ទឹក និងចែកចាយទឹក

### ក.1. ពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម

ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកស្អាតរបស់ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ រ.ទ.ស.ភ បាន អនុវត្តទៅលើផែនការវិនិយោគ ដោយស្របទៅនឹងបច្ចុប្បន្នភាពផែនការមេដំណាក់កាលទី៣ (ឆ្នាំ២០២១-២០៣០) ដែលមានដូចខាងក្រោម៖

ផែនការថវិកាសម្រាប់ពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម សម្រាប់ឆ្នាំ២០២៥

| លរ. | បរិមាណ | ថវិកា (រៀល) |
|---|---|---|
| **ក** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក** | |
| **ក.1** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម** | |
| **ក.1.1** | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ដំណាក់ទី១ ហិរញ្ញប្បទានលេខ 1176 01S (AFD) & (EIB)** | |
| 1 | សាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំណាក់ទី 1 | **6,912,272,500** |
| 2 | គម្រោងកសាងសមត្ថភាព (Capacity Building) | **1,034,840,000** |
| 3 | សវនកម្មលើគម្រោងបាក់ខែង ដំណាក់ទី1 | **38,540,000** |
| **ក.1.2** | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ដំណាក់ទី2 ហិរញ្ញប្បទានលេខ 1244 01M (AFD)** | |
| 1 | សាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំណាក់ទី 2 | **21,244,580,500** |
| 2 | ទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ដំណាក់ទី2 | **1,142,256,500** |
| 3 | សវនកម្មលើគម្រោងបាក់ខែង ដំណាក់ទី2 | **41,820,000** |
| **ក.1.3** | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ដំណាក់ទី3** | |
| 1 | សាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែងដំណាក់ទី 3 | **116,290,243,400** |
| 2 | ទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់រោងចក្រផលិតទឹកស្អាត | **6,658,400,000** |
| 3 | គម្រោងជួសជុល និងផ្លាស់ប្តូរឧបករណ៍ បរិក្ខារប្រព័ន្ធផលិតកម្មរបស់រោងចក្រជ្រោយចង្វារ | **48,175,000,000** |

| លរ. | បរិមាណ | ថវិកា (រៀល) |
|---|---|---|
| **ក** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក** | |
| 4 | ការងារសាងសង់អគារដ្ឋបាលថ្មី ( Institutional building) | **23,370,000,000** |
| 5 | សិក្សា Detailed Design សម្រាប់គម្រោងសាងសង់អគារដ្ឋបាលថ្មី | **4,510,000,000** |
| 6 | គម្រោងកសាងសមត្ថភាព (Capacity Building) | **8,200,000,000** |
| 7 | សវនកម្មលើគម្រោងបាក់ខែង ជំហានទី3 | **59,450,000** |
| **ក.1.4** | **របាយការណ៍អង្កេត និងតាមដានបរិស្ថាន** | |
| 1 | ការរៀបចំរបាយការណ៍អង្កេត និងតាមដានបរិស្ថានរបស់គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី1+2 **សម្រាប់ឆមាសទី2 ឆ្នាំ2024** | **61,500,000** |
| 2 | ការរៀបចំរបាយការណ៍អង្កេត និងតាមដានបរិស្ថានរបស់គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី1+2 **សម្រាប់ឆមាសទី2 ឆ្នាំ2025** | **61,500,000** |
| 3 | រៀបចំរបាយការណ៍ត្រួតពិនិត្យ និងតាមដានស្តីពីផលប៉ះពាល់បរិស្ថានគម្រោងផ្គត់ផ្គង់ទឹកបាក់ខែង ជំហានទី៣ | **123,000,000** |
| **ក.1.5** | **License** | |
| 1 | ទិញសិទ្ធប្រើប្រាស់ការងារវាស់វែង (DGPS) ដោយផ្កាយរណប | **24,600,000** |
| **ក.1.6** | **ច្បាប់ជីកាត់ថ្នល់** | |
| 1 | ការងារសុំច្បាប់ជីកកាត់ថ្នល់ | **50,000,000** |
| **ក.1.7** | **ការងារថែមម៉ោង** | |
| 1 | បំពេញការងារបន្ថែមម៉ោងលើការពង្រីកបណ្តាញមេនាំទឹក និងចែកចាយ នៃសាខាសេវាកម្មទឹកស្អាត និងអនាម័យ | **1,430,386,560** |
| សរុប (ក១) | | **239,428,389,460** |

## ក.២. ពង្រីកបណ្តាញចែកចាយទឹក និងឧបករណ៍ប្រព័ន្ធចែកចាយទឹក

នៅក្នុងផែនការឆ្នាំ ២០២៥ រ.ទ.ស.ភ គ្រោងដាក់បំពង់ចែកចាយទឹកប្រវែង ៥៧២.១០០ម៉ែត្រ ទូទាំងរាជធានីភ្នំពេញ ក្រុងតាខ្មៅ និងខេត្តត្បូងឃ្មុំ ព្រមទាំងឧបករណ៍ប្រព័ន្ធចែកចាយទឹក ដែលមានរៀបរាប់ដូចខាងក្រោមនេះ៖

| ក | គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក | | | ថវិកា (រៀល) |
|---|---|---|---|---|
| **ក** | **គម្រោងពង្រីកភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក** | | | |
| **ក.២** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធចែកចាយ** | | | |
| 1 | ដាក់បំពង់មេ និងបំពង់ចែកចាយទឹក | ម៉ែត្រ | 572,100 | **115,895,249,255** |
| 2 | ដំឡើងវ៉ង់ទូសទំហំ65មម-100មម | កន្លែង | 14 | **195,104,000** |
| 3 | ដំឡើងវ៉ង់ទូសទំហំ150មម-200មម | កន្លែង | 20 | **630,720,000** |
| 4 | ដំឡើងប្រអប់វ៉ាន់ធំៗ | កន្លែង | 18 | **3,494,448,000** |
| 5 | ដំឡើងនាឡិកាតំបន់ | កន្លែង | 15 | **2,220,847,500** |
| 6 | ដំឡើងទូ Data Logger និង Tramsitter | កន្លែង | 20 | **839,710,000** |
| 7 | ដំឡើង Data Logger នាឡិកាអតិថិជនធំៗ | កន្លែង | 20 | **264,000,000** |
| 8 | ដំឡើងChamber Wash Out | កន្លែង | 20 | **1,163,720,000** |
| 9 | ដំឡើងបង្គោលអគ្គីភ័យ | កន្លែង | 20 | **453,710,000** |
| សរុប (ក២) | | | | **125,157,508,755** |
| **សរុបរួម (ក): ក.១ និង ក.២** | | | | **<u>364,585,898,215</u>** |

## ខ. ឧបករណ៍ទ្រទ្រង់គម្រោង

| ខ | ឧបករណ៍ទ្រទ្រង់គម្រោង | ឯកតា | បរិមាណ | |
|---|---|---|---|---|
| **ខ.1** | **សម្ភារបរិក្ខារព័ត៌មានវិទ្យា** | | | |
| **ខ.1.1** | **បរិក្ខារកំព្យូទ័រ** | | | |
| 1 | ម៉ាស៊ីនកុំព្យូទ័រលើតុ Desktop | គ្រឿង | 98 | 794,220,000 |
| 2 | ម៉ាស៊ីនបោះពុម្ភ Printer | គ្រឿង | 10 | 223,650,000 |
| 3 | ម៉ាស៊ីនថតចម្លង | គ្រឿង | 7 | 220,080,000 |
| 4 | ម៉ាស៊ីន Scanner | គ្រឿង | 15 | 63,000,000 |
| 5 | Android Mobile | គ្រឿង | 73 | 122,640,000 |

| ខ | ឧបករណ៍ទ្រទ្រង់គម្រោង | ឯកតា | បរិមាណ | |
|---|---|---|---|---|
| 6 | Mobile Printer | គ្រឿង | 3 | 13,230,000 |
| 7 | ឧបករណ៍ Barcode Reader | គ្រឿង | 15 | 6,300,000 |
| 8 | ឧបករណ៍ Hand GPS | គ្រឿង | 14 | 23,520,000 |
| ខ.1.2 | **បរិក្ខារហេដ្ឋារចនាសម្ព័ន្ធ** | | | |
| 1 | Cisco Network Module | គ្រឿង | 2 | 36,120,000 |
| 2 | Cooling System | គ្រឿង | 2 | 382,200,000 |
| 3 | Router | គ្រឿង | 2 | 201,600,000 |
| 4 | Switch | គ្រឿង | 1 | 14,700,000 |
| ខ.1.3 | **អាជ្ញាប័ណ្ណ** | | | |
| 1 | Microsoft | រាយ | 4 | 310,800,000 |
| 2 | អាជ្ញាប័ណ្ណបន្ថែមប្រព័ន្ធ Spot Billing | រាយ | 3 | 25,830,000 |
| **សរុប ( ខ១ )** | | | | **2,437,890,000** |
| ខ.2 | **គ្រឿងសង្ហារឹមការិយាល័យ** | | | |
| 1 | តុការិយាល័យមានកែង ( តុឈើពណ៌.ស ) | គ្រឿង | 33 | 38,996,100 |
| 2 | តុការិយាល័យគ្មានកែង ( តុឈើពណ៌.ស ) | គ្រឿង | 1 | 888,500 |
| 3 | តុជើងដែកបត់បាន | គ្រឿង | 10 | 4,155,000 |
| 4 | ថតតុចល័ត | គ្រឿង | 1 | 380,000 |
| 5 | តុដាក់ទឹកតែ (ឈើផ្ទុងជើងគ្រុឌ ) | គ្រឿង | 10 | 10,000,000 |
| 6 | កៅអីថ្នាក់នាយកដ្ឋាន | គ្រឿង | 1 | 1,226,800 |
| 7 | កៅអីសម្រាប់ថ្នាក់ការិយាល័យ | គ្រឿង | 4 | 4,690,400 |
| 8 | កៅអីសម្រាប់ថ្នាក់ផ្នែក | គ្រឿង | 6 | 2,489,400 |
| 9 | កៅអីសម្រាប់និយោជិត | គ្រឿង | 38 | 10,970,600 |
| 10 | កៅអីប្រជុំមានធ្នាក់ដៃ | គ្រឿង | 20 | 5,774,000 |

| ខ | ឧករណ៍ទ្រទ្រង់គម្រោង | ឯកតា | បរិមាណ | |
|---|---|---|---|---|
| 11 | កៅអីប្រជុំមានផ្ដាក់ដៃសរសេរ | គ្រឿង | 50 | 13,500,000 |
| 12 | កៅអីខ្សែជាប់គ្នា៤ | គ្រឿង | 2 | 1,240,000 |
| 13 | ទូដាក់ឯកសារដែកផ្ដេក | គ្រឿង | 8 | 4,835,200 |
| 14 | ទូដាក់ឯកសារបញ្ឈរ | គ្រឿង | 2 | 1,560,600 |
| 15 | ទូដែកសុវត្ថិភាព | គ្រឿង | 1 | 2,520,000 |
| 16 | ម៉ាស៊ីនត្រជាក់កម្លាំង2.5HP-ព្យួរជញ្ជាំង | គ្រឿង | 1 | 3,890,000 |
| 17 | កាំបិតកាត់ក្រដាសធុនធំ | គ្រឿង | 1 | 287,000 |
| 18 | ម៉ាស៊ីនរាប់ប្រាក់ | គ្រឿង | 5 | 4,750,000 |
| 19 | ឧបករណ៍ធ្វើសៀវភៅ | គ្រឿង | 3 | 3,000,000 |
| **សរុប ខ.២** | | | | **115,153,600** |
| **ខ.3** | **សម្ភារមធ្យោបាយការដ្ឋាន** | | | |
| 1 | កៅឡាក់រ៉ត កម្លាំង 5តោន | រាយ | 2 | 1,700,000 |
| 2 | ម៉ូទ័របូមទឹក ទំហំ50mm និងទុយោសំពត់20m | គ្រឿង | 8 | 8,483,200 |
| 3 | ម៉ាស៊ីនបូមទឹក ទំហំ 75mm | គ្រឿង | 5 | 7,837,500 |
| 4 | ម៉ូទ័របាញ់ទឹកលាងសម្អាត( Kärcher K4 Premium Full Control Pressure Washer B01N9FGRAB) | កំប្លេរ | 1 | 2,000,000 |
| 5 | ឧបករណ៍វាស់កំរិតសំពាធទឹកមេកានិច (នាឡិការសម្ពាធ ១០បារ ) | រាយ | 10 | 3,000,000 |
| 6 | ម៉ូទ័របុកបេតុងប្រើចរន្តអគ្គិសនី( MH1812 - 28.6mm) 2000W | គ្រឿង | 1 | 4,394,500 |
| 7 | ម៉ូទ័របុកបេតុងប្រើចរន្តអគ្គិសនី( Makita HM1306) 1510W | គ្រឿង | 7 | 24,062,500 |
| 8 | ម៉ូទ័រស្វានបេតុង | គ្រឿង | 3 | 2,580,600 |
| 9 | ម៉ូទ័រស្វានបេតុង (HR2810-800W) ធំ | គ្រឿង | 1 | 1,260,000 |
| 10 | ម៉ាស៊ីនភ្លើង SH7600, 5KVA | គ្រឿង | 1 | 14,395,100 |
| 11 | ម៉ាស៊ីនភ្លើង SE8000, 7KVA | គ្រឿង | 3 | 22,664,400 |
| 12 | ម៉ាស៊ីនភ្លើង DG-6700SN. 5KVA | គ្រឿង | 2 | 15,456,000 |

| ខ | ឧបករណ៍ទ្រទ្រង់គម្រោង | ឯកតា | បរិមាណ | |
|---|---|---|---|---|
| 13 | ម៉ាស៊ីនអ៊ុតបំពង់ជ័រ (HDPE) ម៉ាក FRIAMAT | គ្រឿង | 2 | 53,451,200 |
| 14 | ម៉ាស៊ីនកាត់បេតុង (ផ្លែកាត់ទំហំ450mm) | គ្រឿង | 1 | 35,654,300 |
| 15 | ម៉ាស៊ីនកាត់បេតុង (ផ្លែកាត់ទំហំ350mm) | គ្រឿង | 1 | 19,616,300 |
| 16 | ម៉ូទ័រកាត់បំពង់ដែកប្រើឌីសធំ 350មម | គ្រឿង | 1 | 770,000 |
| 17 | ម៉ូទ័រជុសសម្អាតច្រែះ Model-GS6000 | គ្រឿង | 4 | 1,355,200 |
| 18 | ម៉ូទ័រកាត់និងឆាបដែក (ប្រើឌីសស្តួត ទំហំ 180mm) | គ្រឿង | 2 | 2,712,600 |
| 19 | ម៉ូទ័រកាត់និងឆាបដែក (ប្រើឌីសស្តួត ទំហំ 100mm) | គ្រឿង | 2 | 1,082,000 |
| 20 | ម៉ូទ័រជ្រៀកឈើ | គ្រឿង | 1 | 519,200 |
| 21 | ម៉ូទ័រស្វានចោះ និងមួលវីស | គ្រឿង | 2 | 580,000 |
| 22 | ម៉ូទ័របាញ់ខ្យល់ចូលក្នុងប្រអប់បេតុង ភ្ជាប់ទុយោសំពត់មុខកាត់300mm(SHT-30mm) | គ្រឿង | 7 | 7,280,000 |
| 23 | ម៉ូទ័របាញ់ខ្យល់ចូលក្នុងប្រអប់បេតុង ភ្ជាប់ទុយោសំពត់មុខកាត់350mm(SHT-35mm) | គ្រឿង | 2 | 2,080,000 |
| 24 | ម៉ូទ័រដោះប៉ូឡុង ប្រើថ្មសាក (TW001GM201/Z) | គ្រឿង | 1 | 4,311,000 |
| 25 | ម៉ូទ័រដោះបូឡុង និងស៊ីបូឡុង ប្រើថ្មម៉ាក Profix | គ្រឿង | 5 | 2,150,000 |
| 26 | ម៉ូទ័រសំលៀង M0910B | គ្រឿង | 2 | 2,558,600 |
| 27 | ម៉ូទ័រផ្លុំធូលី | គ្រឿង | 1 | 913,000 |
| 28 | ម៉ូទ័រខ្យល់បាញ់ថ្នាំពណ៌ | គ្រឿង | 1 | 240,000 |
| 29 | Auto Level Aluminium Staff ប្រវែង 7.0m | កំប្លេរ | 10 | 5,000,000 |
| 30 | ឧបករណ៍កាត់ប៊ូឡុង | គ្រឿង | 1 | 7,428,000 |
| 31 | ឧបករណ៍វាស់សំពាធទឹក (Pressure Guage-up to 5bar) | រាយ | 30 | 4,050,000 |
| 32 | ឧបករណ៍វាស់សំណើមឈើ | រាយ | 1 | 220,000 |
| 33 | ឧបករណ៍គៀបពេលអ៊ុតប៉េអឺ (គ្នៀប) Alignment clamp d 20 - d 63 | រាយ | 5 | 4,000,000 |

| ខ | ឧបករណ៍ទ្រទ្រង់គម្រោង | ឯកតា | បរិមាណ | |
|---|---|---|---|---|
| 34 | ឧបករណ៍កោសផ្ទៃក្រៅបំពង់ប៉េអឺ Scraper tool for pipes d 20 - d 63 (1/2" - 2" IPS) | រាយ | 1 | 1,000,000 |
| 35 | ឧបករណ៍កោសផ្ទៃក្រៅបំពង់ប៉េអឺ Compact scraper tool for pipe ends and outlet spigots d 25 - d 63 | រាយ | 1 | 500,000 |
| 36 | ក្បាលបាញ់បេតុងភ្ជាប់ជាមួយ Excavator | កំប្លេរ | 1 | 80,000,000 |
| 37 | ផ្លែបុកបេតុងភ្ជាប់ជាមួយ Backhoe loader | រាយ | 8 | 11,600,000 |
| 38 | ផ្លែបុកបេតុងភ្ជាប់ជាមួយ Excavator | រាយ | 5 | 8,200,000 |
| 39 | Portable Water Meter Test Kit | គ្រឿង | 6 | 181,595,700 |
| **សរុប ខ.៣** | | | | **546,700,900** |
| **សរុបរួម ( ខ ): ( ខ.១ ខ.២ ខ.៣ )** | | | | **3,099,744,500** |

## គ. ផែនការសំណង់ស៊ីវិល

| ល | ការងារសំណង់ស៊ីវិល | ឯកតា | បរិមាណ | ថវិកា ( រៀល ) |
|---|---|---|---|---|
| 1 | ជួសជុលអាងប្រោះលេខ ១៣ រោងចក្រភូមិព្រែក | កន្លែង | 1 | 175,000,000 |
| **សរុបរួម ( គ )** | | | | **175,000,000** |

## ឃ. បំណែងចែកប្រភពថវិកាវិនិយោគឆ្នាំ២០២៥

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ភ | សរុប |
|---|---|---|---|---|---|---|---|
| **ក** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក** | | | | | | |
| **ក.១** | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម** | | | | | | |
| **ក .១.១** | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ដំណាក់កាលទី ១ ហិរញ្ញប្បទានលេខ** 1176 01S ( AFD ) & ( EIB ) | | | | | | |
| 1 | សាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ដំណាក់កាលទី1 | ម៣/ថ្ងៃ | 195,000 | 3,110,522,600 | 3,801,749,900 | | **6,912,272,500** |
| 2 | គម្រោងកសាងសមត្ថភាព ( Capacity Building ) | - | - | 217,316,400 | 817,523,600 | | **1,034,840,000** |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| 3 | សវនកម្មលើគម្រោងបាក់ខែង ជំហានទី1 | - | - | | | 38,540,000 | **38,540,000** |
| ក. 1.2 | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី**2<br>**ហិរញ្ញប្បទានលេខ** 1244 01M ( AFD ) | | | | | | |
| 1 | សាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហាន2 | ម៣/ថ្ងៃ | 195,000 | 21,244,580,500 | | | **21,244,580,500** |
| 2 | ទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហានទី2 | - | - | 1,142,256,500 | | | **1,142,256,500** |
| 3 | សវនកម្មលើគម្រោងបាក់ខែង ជំហានទី2 | - | - | | | 41,820,000 | **41,820,000** |
| ក. 1.3 | **គម្រោងផ្គត់ផ្គង់ទឹកស្អាតបាក់ខែង ជំហានទី3** | - | - | | | | |
| 1 | សាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែង ជំហានទី3 | ម៣/ថ្ងៃ | 195,000 | 97,158,856,200 | | 19,131,387,200 | **116,290,243,400** |
| 2 | ទីប្រឹក្សាបច្ចេកទេសត្រួតពិនិត្យការងារសាងសង់រោងចក្រផលិតទឹកស្អាត | | | 6,658,400,000 | | | **6,658,400,000** |
| 3 | គម្រោងជួសជុល និងផ្លាស់ប្តូរ ឧបករណ៍ បរិក្ខារ ប្រព័ន្ធផលិតកម្មរបស់រោងចក្រជ្រោយចង្វារ | - | - | 48,175,000,000 | | | **48,175,000,000** |
| 4 | ការងារសាងសង់អគារដ្ឋបាលថ្មី ( Institutional building ) | - | - | 23,370,000,000 | | | **23,370,000,000** |
| 5 | សិក្សា Detailed Design សម្រាប់គម្រោងសាងសង់អគារដ្ឋបាលថ្មី | - | - | 4,510,000,000 | | | **4,510,000,000** |
| 6 | គម្រោងកសាងសមត្ថភាព ( Capacity Building ) | - | - | 8,200,000,000 | | | **8,200,000,000** |
| 7 | សវនកម្មលើគម្រោងបាក់ខែង ជំហានទី3 | - | - | | | 59,450,000 | **59,450,000** |
| ក. 1.4 | **របាយការណ៍អង្កេត និងតាមដានបរិស្ថាន** | - | - | | | | |
| 1 | ការរៀបចំរបាយការណ៍អង្កេត និងតាមដានបរិស្ថានរបស់គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី1+2 **សម្រាប់ឆមាសទី2 ឆ្នាំ**2024 | - | - | | | 61,500,000 | **61,500,000** |
| 2 | ការរៀបចំរបាយការណ៍អង្កេត និងតាមដានបរិស្ថានរបស់គម្រោងសាងសង់រោងចក្រផលិតទឹកស្អាតបាក់ខែងជំហានទី1+2 **សម្រាប់ឆមាសទី2 ឆ្នាំ**2025 | - | - | | | 61,500,000 | **61,500,000** |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| 3 | រៀបចំរបាយការណ៍ត្រួតពិនិត្យ និងតាមដានស្តីពីផលប៉ះពាល់ បរិស្ថានគម្រោងផ្គត់ផ្គង់ទឹកបាក់ខែងដំហានទី៣ | - | - | | | 123,000,000 | **123,000,000** |
| ក. 1.5 | License | - | - | | | | |
| 1 | ទិញសិទ្ធប្រើប្រាស់ការងារវាស់វែង (DGPS) ដោយផ្កាយរណប | រូប | 12 | | | 24,600,000 | **24,600,000** |
| ក. 1.6 | ច្បាប់ជីកកាត់ថ្នល់ | | | | | | |
| 1 | ការងារសុំច្បាប់ជីកកាត់ថ្នល់ | សំណើ | 100 | | | 50,000,000 | **50,000,000** |
| ក. 1.7 | ការងារថែមម៉ោង | | | | | | |
| 1 | បំពេញការងារបន្ថែមម៉ោងលើការពង្រីកបណ្តាញមេនាំទឹក និងចែកចាយ | ម៉ោង | 66,240 | | | 1,430,386,560 | **1,430,386,560** |
| | សរុប (ក1) | | | **213,786,932,200** | **4,619,273,500** | **21,022,183,760** | **239,428,389,460** |
| **ក**.2 | **គម្រោងពង្រីកសមត្ថភាពប្រព័ន្ធចែកចាយ** | | | | | | |
| 1 | ដាក់បំពង់មេ និងបំពង់ចែកចាយទឹក | ម៉ែត្រ | 572,100 | 60,143,783,700 | | 55,751,465,555 | **115,895,249,255** |
| 2 | ដំឡើងវ៉ង់ទូសទំហំ65មម-100មម | កន្លែង | 14 | 42,000,000 | | 153,104,000 | **195,104,000** |
| 3 | ដំឡើងវ៉ង់ទូសទំហំ150មម-200មម | កន្លែង | 20 | 240,000,000 | | 390,720,000 | **630,720,000** |
| 4 | ដំឡើងប្រអប់វ៉ានធំៗ | កន្លែង | 18 | 2,196,000,000 | | 1,298,448,000 | **3,494,448,000** |
| 5 | ដំឡើងនាឡិកាតំបន់ | កន្លែង | 15 | 1,500,000,000 | | 720,847,500 | **2,220,847,500** |
| 6 | ដំឡើងទូ Data Logger និង Tramsitter | កន្លែង | 20 | 186,000,000 | | 653,710,000 | **839,710,000** |
| 7 | ដំឡើង Data Logger នាឡិកាអតិថិជនធំៗ | កន្លែង | 20 | 132,000,000 | | 132,000,000 | **264,000,000** |
| 8 | ដំឡើងChamber Wash Out | កន្លែង | 20 | 200,000,000 | | 963,720,000 | **1,163,720,000** |
| 9 | ដំឡើងបង្គោលអគ្គីភ័យ | កន្លែង | 20 | 300,000,000 | | 153,710,000 | **453,710,000** |
| | **សរុប** (**ក**2) | | | **64,939,783,700** | | **60,217,725,055** | **125,157,508,755** |
| | **សរុបរួម ក:** | | | **278,726,715,900** | **4,619,273,500** | **81,239,908,815** | **364,585,898,215** |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| | (ក1) និង (ក2) | | | | | | |
| ខ | **ឧបករណ៍ទ្រទ្រង់គម្រោង** | | | | | | |
| ខ.1 | សម្ភារបរិក្ខារព័ត៌មានវិទ្យា | | | | | | |
| ខ.1.1 | បរិក្ខារកំព្យូទ័រ | | | | | | |
| 1 | ម៉ាស៊ីនកុំព្យូទ័រលើតុ Desktop | គ្រឿង | 98 | | | 794,220,000 | **794,220,000** |
| 2 | ម៉ាស៊ីនបោះពុម្ព Printer | គ្រឿង | 10 | | | 223,650,000 | **223,650,000** |
| 3 | ម៉ាស៊ីនថតចម្លង | គ្រឿង | 7 | | | 220,080,000 | **220,080,000** |
| 4 | ម៉ាស៊ីន Scanner | គ្រឿង | 15 | | | 63,000,000 | **63,000,000** |
| 5 | Android Mobile | គ្រឿង | 73 | | | 122,640,000 | **122,640,000** |
| 6 | Mobile Printer | គ្រឿង | 3 | | | 13,230,000 | **13,230,000** |
| 7 | ឧបករណ៍ Barcode Reader | គ្រឿង | 15 | | | 6,300,000 | **6,300,000** |
| 8 | ឧបករណ៍ Hand GPS | គ្រឿង | 14 | | | 23,520,000 | **23,520,000** |
| ខ.1.2 | បរិក្ខារហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| 1 | Cisco Network Module | គ្រឿង | 2 | | | 36,120,000 | **36,120,000** |
| 2 | Cooling System | គ្រឿង | 2 | | | 382,200,000 | **382,200,000** |
| 3 | Router | គ្រឿង | 2 | | | 201,600,000 | **201,600,000** |
| 4 | Switch | គ្រឿង | 1 | | | 14,700,000 | **14,700,000** |
| ខ.1.3 | អាជ្ញាប័ណ្ណ | | | | | | |
| 1 | Microsoft | រាយ | 4 | | | 310,800,000 | **310,800,000** |
| 2 | អាជ្ញាប័ណ្ណបន្ថែមប្រព័ន្ធ Spot Billing | រាយ | 3 | | | 25,830,000 | **25,830,000** |
| | **សរុប (ខ1)** | | | | | **2,437,890,000** | **2,437,890,000** |
| ខ.2 | គ្រឿងសង្ហារឹមការិយាល័យ | | | | | | |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ន.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| 1 | តុការិយាល័យមានកែង (តុឈើពណ៌ស) | គ្រឿង | 33 | | | 38,996,100 | **38,996,100** |
| 2 | តុការិយាល័យគ្មានកែង (តុឈើពណ៌ស) | គ្រឿង | 1 | | | 888,500 | **888,500** |
| 3 | តុជើងដែកបត់បាន | គ្រឿង | 10 | | | 4,155,000 | **4,155,000** |
| 4 | ថតតុចល័ត | គ្រឿង | 1 | | | 380,000 | **380,000** |
| 5 | តុដាក់ទឹកតែ (ឈើផ្ទុងជើងគ្រុឌ) | គ្រឿង | 10 | | | 10,000,000 | **10,000,000** |
| 6 | កៅអីថ្នាក់នាយកដ្ឋាន | គ្រឿង | 1 | | | 1,226,800 | **1,226,800** |
| 7 | កៅអីសម្រាប់ថ្នាក់ការិយាល័យ | គ្រឿង | 4 | | | 4,690,400 | **4,690,400** |
| 8 | កៅអីសម្រាប់ថ្នាក់ផ្នែក | គ្រឿង | 6 | | | 2,489,400 | **2,489,400** |
| 9 | កៅអីសម្រាប់និយោជិត | គ្រឿង | 38 | | | 10,970,600 | **10,970,600** |
| 10 | កៅអីប្រជុំមានផ្នាក់ដៃ | គ្រឿង | 20 | | | 5,774,000 | **5,774,000** |
| 11 | កៅអីប្រជុំមានផ្នាក់ដៃសរសេរ | គ្រឿង | 50 | | | 13,500,000 | **13,500,000** |
| 12 | កៅអីខ្សែជាប់គ្នា៤ | គ្រឿង | 2 | | | 1,240,000 | **1,240,000** |
| 13 | ទូដាក់ឯកសារដែកផ្តេក | គ្រឿង | 8 | | | 4,835,200 | **4,835,200** |
| 14 | ទូដាក់ឯកសារបញ្ឈរ | គ្រឿង | 2 | | | 1,560,600 | **1,560,600** |
| 15 | ទូដែកសុវត្ថិភាព | គ្រឿង | 1 | | | 2,520,000 | **2,520,000** |
| 16 | ម៉ាស៊ីនត្រជាក់កម្លាំង2.5HP-ព្យួរជញ្ជាំង | គ្រឿង | 1 | | | 3,890,000 | **3,890,000** |
| 17 | កាំបិតកាត់ក្រដាសធុនធំ | គ្រឿង | 1 | | | 287,000 | **287,000** |
| 18 | ម៉ាស៊ីនរាប់ប្រាក់ | គ្រឿង | 5 | | | 4,750,000 | **4,750,000** |
| 19 | ឧបករណ៍ធ្វើសៀវភៅ | គ្រឿង | 3 | | | 3,000,000 | **3,000,000** |
| | **សរុប** (ខ2) | | | | | **115,153,600** | **115,153,600** |
| ខ.3 | សម្ភារមធ្យោបាយការដ្ឋាន | | | | | | |
| 1 | កៅឡាក់រ៉ែត កម្លាំង 5តោន | រាយ | 2 | | | 1,700,000 | **1,700,000** |
| 2 | ម៉ូទ័របូមទឹក ទំហំ50mm និងទុយោសំពត់20m | គ្រឿង | 8 | | | 8,483,200 | **8,483,200** |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| 3 | ម៉ាស៊ីនបូមទឹក ទំហំ 75mm | គ្រឿង | 5 | | | 7,837,500 | **7,837,500** |
| 4 | ម៉ូទ័របាញ់ទឹកលាងសម្អាត(Kärcher K4 Premium Full Control Pressure Washer B01N9FGRAB) | កំប្លេរ | 1 | | | 2,000,000 | **2,000,000** |
| 5 | ឧបករណ៍វាស់កំរិតសំពាធទឹកមេកានិច (នាឡិការសម្ពាធ ១០បារ) | រាយ | 10 | | | 3,000,000 | **3,000,000** |
| 6 | ម៉ូទ័របុកបេតុងប្រើចរន្តអគ្គិសនី(MH1812 - 28.6mm) 2000W | គ្រឿង | 1 | | | 4,394,500 | **4,394,500** |
| 7 | ម៉ូទ័របុកបេតុងប្រើចរន្តអគ្គិសនី(Makita HM1306) 1510W | គ្រឿង | 7 | | | 24,062,500 | **24,062,500** |
| 8 | ម៉ូទ័រស្វានបេតុង | គ្រឿង | 3 | | | 2,580,600 | **2,580,600** |
| 9 | ម៉ូទ័រស្វានបេតុង (HR2810-800W) ធំ | គ្រឿង | 1 | | | 1,260,000 | **1,260,000** |
| 10 | ម៉ាស៊ីនភ្លើង SH7600, 5KVA | គ្រឿង | 1 | | | 14,395,100 | **14,395,100** |
| 11 | ម៉ាស៊ីនភ្លើង SE8000, 7KVA | គ្រឿង | 3 | | | 22,664,400 | **22,664,400** |
| 12 | ម៉ាស៊ីនភ្លើង DG-6700SN. 5KVA | គ្រឿង | 2 | | | 15,456,000 | **15,456,000** |
| 13 | ម៉ាស៊ីនអ៊ុតបំពង់ជ័រ (HDPE) ម៉ាក FRIAMAT | គ្រឿង | 2 | | | 53,451,200 | **53,451,200** |
| 14 | ម៉ាស៊ីនកាត់បេតុង (ផ្លែកាត់ទំហំ450mm) | គ្រឿង | 1 | | | 35,654,300 | **35,654,300** |
| 15 | ម៉ាស៊ីនកាត់បេតុង (ផ្លែកាត់ទំហំ350mm) | គ្រឿង | 1 | | | 19,616,300 | **19,616,300** |
| 16 | ម៉ូទ័រកាត់បំពង់ដែកប្រើឌីសធំ 350មម | គ្រឿង | 1 | | | 770,000 | **770,000** |
| 17 | ម៉ូទ័រជុសសម្អាតច្រែះ Model-GS6000 | គ្រឿង | 4 | | | 1,355,200 | **1,355,200** |
| 18 | ម៉ូទ័រកាត់និងធាបដែក (ប្រើឌីសស្ដួត ទំហំ 180mm) | គ្រឿង | 2 | | | 2,712,600 | **2,712,600** |
| 19 | ម៉ូទ័រកាត់និងធាបដែក (ប្រើឌីសស្ដួត ទំហំ 100mm) | គ្រឿង | 2 | | | 1,082,000 | **1,082,000** |
| 20 | ម៉ូទ័រជៀកឈើ | គ្រឿង | 1 | | | 519,200 | **519,200** |
| 21 | ម៉ូទ័រស្វានចោះ និងមួលវីស | គ្រឿង | 2 | | | 580,000 | **580,000** |
| 22 | ម៉ូទ័របាញ់ខ្យល់ចូលក្នុងប្រអប់បេតុង ភ្ជាប់ទុយោសំពត់មុខកាត់300mm(SHT-30mm) | គ្រឿង | 7 | | | 7,280,000 | **7,280,000** |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ត | សរុប |
|---|---|---|---|---|---|---|---|
| 23 | ម៉ូទ័របាញ់ខ្យល់ចូលក្នុងប្រអប់បេតុង ភ្ជាប់ទុយោ សំពត់មុខកាត់350mm( SHT-35mm ) | គ្រឿង | 2 | | | 2,080,000 | **2,080,000** |
| 24 | ម៉ូទ័រដោះប៉ូឡុង ប្រើថ្មសាក ( TW001GM201/Z ) | គ្រឿង | 1 | | | 4,311,000 | **4,311,000** |
| 25 | ម៉ូទ័រដោះប៉ូឡុង និងស៊ីប៉ូឡុង ប្រើថ្មម៉ាក Profix | គ្រឿង | 5 | | | 2,150,000 | **2,150,000** |
| 26 | ម៉ូទ័រសំលៀង M0910B | គ្រឿង | 2 | | | 2,558,600 | **2,558,600** |
| 27 | ម៉ូទ័រផ្លុំធូលី | គ្រឿង | 1 | | | 913,000 | **913,000** |
| 28 | ម៉ូទ័រខ្យល់បាញ់ថ្នាំពណ៌ | គ្រឿង | 1 | | | 240,000 | **240,000** |
| 29 | Auto Level Aluminium Staff ប្រវែង 7.0m | កំប្លេរ | 10 | | | 5,000,000 | **5,000,000** |
| 30 | ឧបករណ៍កាត់ប៊ូឡុង | គ្រឿង | 1 | | | 7,428,000 | **7,428,000** |
| 31 | ឧបករណ៍វាស់សំពាធទឹក ( Pressure Guage- up to 5bar ) | រាយ | 30 | | | 4,050,000 | **4,050,000** |
| 32 | ឧបករណ៍វាស់សំណើមឈើ | រាយ | 1 | | | 220,000 | **220,000** |
| 33 | ឧបករណ៍គៀបពេលអ៊ុតប៉េអឺ (ក្ដៀប) Alignment clamp d 20 - d 63 | រាយ | 5 | | | 4,000,000 | **4,000,000** |
| 34 | ឧបករណ៍កោសផ្ទៃក្រៅបំពង់ប៉េអឺ Scraper tool for pipes d 20 - d 63 ( 1/2" - 2" IPS ) | រាយ | 1 | | | 1,000,000 | **1,000,000** |
| 35 | ឧបករណ៍កោសផ្ទៃក្រៅបំពង់ប៉េអឺ Compact scraper tool for pipe ends and outlet spigots d 25 - d 63 | រាយ | 1 | | | 500,000 | **500,000** |
| 36 | ក្បាលបាញ់បេតុងភ្ជាប់ជាមួយ Excavator | កំប្លេរ | 1 | | | 80,000,000 | **80,000,000** |
| 37 | ផ្លែបុកបេតុងភ្ជាប់ជាមួយ Backhoe loader | រាយ | 8 | | | 11,600,000 | **11,600,000** |
| 38 | ផ្លែបុកបេតុងភ្ជាប់ជាមួយ Excavator | រាយ | 5 | | | 8,200,000 | **8,200,000** |
| 39 | Portable Water Meter Test Kit | គ្រឿង | 6 | | | 181,595,700 | **181,595,700** |
| | **សរុប** ( **ខ**3 ) | | | | | **546,700,900** | **546,700,900** |
| | **សរុបរួម** ( **ខ** ):<br>( **ខ**1 **ខ**2 **ខ**3 ) | | | | | **3,099,744,500** | **3,099,744,500** |
| គ | ការងារសំណង់ស៊ីវិល | | | | | | |

| ល.រ | បរិយាយ | ឯកតា | ចំនួន | ថវិកា AFD | ថវិកា EIB | រ.ទ.ស.ភ | សរុប |
|---|---|---|---|---|---|---|---|
| 1 | ជួសជុលអាងច្រោះលេខ13 រោងចក្រភូមិព្រែក | កន្លែង | 1 | | | 175,000,000 | **175,000,000** |
| | **សរុបរួម (គ)** | | | | | **175,000,000** | **175,000,000** |
| | **សរុបរួម (ក ខ គ)** | | | **278,726,715,900** | **4,619,273,500** | **84,514,653,315** | **367,860,642,715** |

| **សង្ខេបផែនការវិនិយោគ សម្រាប់ ឆ្នាំ២០២៥** | | **ថវិកា AFD (រៀល)** | **ថវិកា EIB (រៀល)** | **ថវិកា រ.ទ.ស.ភ (រៀល)** | **សរុបប្រចាំឆ្នាំ (រៀល)** |
|---|---|---|---|---|---|
| ក | គម្រោងពង្រីកសមត្ថភាពប្រព័ន្ធផលិតកម្ម និងចែកចាយទឹក | 278,726,715,900 | 4,619,273,500 | 81,239,908,815 | **364,585,898,215** |
| ខ | ឧករណ៍ទ្រទ្រង់គម្រោង | | | 3,099,744,500 | **3,099,744,500** |
| គ | ការងារសំណង់ស៊ីវិល | | | 175,000,000 | **175,000,000** |
| **សរុប (រៀល)** | | **278,726,715,900** | **4,619,273,500** | **84,514,653,315** | **367,860,642,715** |

# ឧបសម្ព័ន្ធ ៦

## សេចក្តីសម្រេចស្តីពី ការផ្ទេរសិទ្ធិលើការរៀបចំ មហាសន្និបាតភាគហ៊ុនិកលើកទី១៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ : ០០៦ ក្រុយក/គតរ

# សេចក្ដីសម្រេច
# ស្ដីពី
# ការផ្ទេរសិទ្ធិលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១៣

## ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០២ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្ដីពីការគ្រប់គ្រងទឹកស្អាត
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពីការកែសម្រួលមាត្រា៨ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្ដីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.តត ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញអនុក្រឹត្យលេខ៣០៦ អនក្រ.តត ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលសមាសភាពប្រធានក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្ទឹងត្រែង រដ្ឋាករទឹកបាត់ដំបង រដ្ឋាករទឹកពោធិ៍សាត់ រដ្ឋាករទឹកកំពត និងរដ្ឋាករទឹកក្រុងស្ទឹងសែន
- បានឃើញអនុក្រឹត្យលេខ៨២១ អនក្រ.តត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ស្ដីពីការតែងតាំងអគ្គនាយកនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញអនុក្រឹត្យលេខ៩៤៥ អនក្រ.តត ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាល រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់គណៈកម្មការមូលបត្រកម្ពុជា ស្ដីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- យោងគោលការណ៍ណែនាំលេខ០០៥/២១ ន.ម.ក./គ.ណ.ន. ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ របស់និយ័តករមូលបត្រកម្ពុជា ស្ដីពីមហាសន្និបាតភាគហ៊ុនិកសម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ
- យោងស្មារតីអង្គប្រជុំលើកទី១៥ របស់ក្រុមប្រឹក្សាភិបាលអាណត្តិទី៨ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥

# សម្រេច

**ប្រការ ១** : ផ្ទេរសិទ្ធិជូន **ឯកឧត្តម ឡុង ណារ៉ូ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឱ្យបំពេញភារកិច្ចរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១៣ ដោយអាចបង្កើតគណៈកម្មការ និងអនុគណៈកម្មការតាមការចាំបាច់ និងតាមតម្រូវការជាក់ស្តែងនៃការងារ។

**ប្រការ ២** : គ្រប់សមាជិកក្រុមប្រឹក្សាភិបាល សាមីខ្លួនដូចមានក្នុងប្រការ១ និងគ្រប់មន្ត្រីជាន់ខ្ពស់ក្នុងក្របខ័ណ្ឌរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២៥

**ជ. ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ឯក សុនចាន់**

**កន្លែងទទួល ៖**

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៧

## សេចក្តីសម្រេច ចាត់តាំងគណៈកម្មការរៀបចំ និង ដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ: ០៤១ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងគណៈកម្មការរៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិកលើកទី១៣

## ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរ.ទ.ស.ភ

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០២ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលមាត្រា៨ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣១ អនក្រ.តត ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញអនុក្រឹត្យលេខ៣០៦ អនក្រ.តត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលសមាសភាពប្រធានក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ រដ្ឋាករទឹកស្ទឹងត្រែង រដ្ឋាករទឹកបាត់ដំបង រដ្ឋាករទឹកពោធិ៍សាត់ រដ្ឋាករទឹកកំពត និងរដ្ឋាករទឹកក្រុងស្ទឹងសែន
- បានឃើញអនុក្រឹត្យលេខ៨២១ អនក្រ.តត ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញអនុក្រឹត្យលេខ៩៤៥ អនក្រ.តត ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៨
- បានឃើញលក្ខន្តិកៈបុគ្គលិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ កែសម្រួលលើកទី៦ និងអនុម័តដោយក្រុមប្រឹក្សាភិបាល អាណត្តិទី៦ សម័យប្រជុំលើកទី១៤ នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩
- បានឃើញប្រកាសលេខ០១១/១៨គមក.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រាសបោះផ្សាយលក់មូលបត្រជាសាធារណៈ

- យោងគោលការណ៍ណែនាំលេខ០០៥/២១ ន.ម.ក/គ.ណ.ន ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ស្តីពីមហាសន្និបាតភាគហ៊ុនិកសម្រាប់បុគ្គលចុះបញ្ជីលក់មូលបត្រ
- យោងសេចក្តីសម្រេចលេខ០០៦ ក្រប្រក/សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ ស្តីពីការផ្ទេរសិទ្ធិលើការរៀបចំមហាសន្និបាតភាគហ៊ុនិកលើកទី១៣

## សម្រេច

**ប្រការ ១** ៖ តែងតាំងគណៈកម្មការ និងបណ្តាអនុគណៈកម្មការដែលមានសមាសភាពដូចខាងក្រោមនេះ ឱ្យបំពេញបន្ថែមលើភារកិច្ចបច្ចុប្បន្ន នូវការងាររៀបចំ និងដំណើរការមហាសន្និបាតភាគហ៊ុនិកឱ្យបានស្របតាមលក្ខន្តិកៈ បទប្បញ្ញត្តិ និងច្បាប់រដ្ឋជាធរមាន ៖

### ក- សមាសភាពគណៈកម្មការកណ្តាល

| | | |
|---|---|---|
| ១. **ឯកឧត្តម ឡុង ណារ៉ូ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ប្រធាន |
| ២. លោក ដេង ប៉ូលីដែន | អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច | អនុប្រធាន |
| ៣. លោក ម៉ា ណូរ៉ាវីន | អគ្គនាយករងទទួលបន្ទុកអាជីវកម្ម | សមាជិក |
| ៤. លោកស្រី រឿន ណារី | អគ្គនាយករងទទួលបន្ទុករដ្ឋបាលនិងធនធានមនុស្ស | សមាជិកា |
| ៥. លោក ផេង ទី | អគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក | សមាជិក |
| ៦. លោក ជូ ផល្លា | អគ្គនាយករងទទួលបន្ទុកផែនការនិងគម្រោង | សមាជិក |
| ៧. លោក អ៊ូ គុណវឌ្ឍន៍ | អគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាតនិងអនាម័យ | សមាជិក |
| ៨. ឯកឧត្តម អ៊ិន សាកាន | អគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផលិតកម្ម | សមាជិក |
| ៩. លោក ហួត សុខហេង | ប្រធានអង្គភាពលេខាធិការសហគ្រាស | លេខា |
| ១០.កញ្ញា គង់ សុគន្ធារី | ប្រធានការិយាល័យទំនាក់ទំនងវិនិយោគិននិងផ្សារមូលបត្រ | លេខារង |

### ខ- សមាសភាពអនុគណៈកម្មការ

**ខ១- អនុគណៈកម្មការទទួលបន្ទុករៀបចំកន្លែងមហាសន្និបាត**

| | | |
|---|---|---|
| ១. លោក អ៊ូ គុណវឌ្ឍន៍ | អគ្គនាយករងទទួលបន្ទុកសាខាសេវាកម្មទឹកស្អាតនិងអនាម័យ | ប្រធាន |
| ២. លោក ទុយ ប៊ុនសេរីវុទ្ធ | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក | អនុប្រធាន |
| ៣. លោក រាំង ចាន់ភិរម្យ | ប្រធាននាយកដ្ឋានសាខាសេវាកម្មទឹកស្អាតនិងអនាម័យ | សមាជិក |
| ៤. លោកស្រី ងួន បុណ្ណារី | ប្រធានការិយាល័យរដ្ឋបាល | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចរៀបចំទីកន្លែងសម្រាប់មហាសន្និបាត រួមទាំង Backdrop, បដា និងផ្ទាំងរូបភាព, រោងនិងបញ្ជរចុះឈ្មោះ, វេទិកា កៅអី និងស្លាកឈ្មោះ, ឧបករណ៍បញ្ចាំងស្លាយ, វីដេអូខ្លីផ្សព្វផ្សាយពីសមិទ្ធផលរបស់ រ.ទ.ស.ភ, អាហារសម្រន់ និងភេសជ្ជៈ, ថតសកម្មភាពនានានៃមហាសន្និបាតទុកជាឯកសារ និងផ្សព្វផ្សាយតាមបណ្តាញសារព័ត៌មានក្នុងស្រុកអំពីការប្រារព្ធពិធីនៅក្រោយបញ្ចប់មហាសន្និបាត។

**ខ២- អនុគណៈកម្មការទទួលបន្ទុកឯកសារ និងរបាយការណ៍**

| | | |
|---|---|---|
| ១. លោក ដេង ប៉ូលីដែន | អគ្គនាយករងទទួលបន្ទុកហិរញ្ញកិច្ច | ប្រធាន |
| ២. លោក ជូ ផល្លា | អគ្គនាយករងទទួលបន្ទុកផែនការនិងគម្រោង | អនុប្រធាន |
| ៣. លោក សុខ ណារ៉េត | ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក ខឹម វិធ័យនីន | ប្រធាននាយកដ្ឋានផែនការនិងគម្រោង | សមាជិក |
| ៥. លោកស្រី កែវ សុកញ្ញា | ប្រធានការិយាល័យគណនេយ្យ | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចរៀបចំរាល់ឯកសារសម្រាប់មហាសន្និបាត និងចែកជូនអ្នកចូលរួមមហាសន្និបាត រួមទាំងស្លាយ Powerpoint សម្រាប់ធ្វើបទបង្ហាញក្នុងមហាសន្និបាត (ជាភាសាខ្មែរ និងអង់គ្លេស)។

## ២៣- អនុគណៈកម្មការទទួលបន្ទុកបដិសណ្ឋារកិច្ច

| | | |
|---|---|---|
| ១. លោក ម៉ា ណូរ៉ាវីន | អគ្គនាយករងទទួលបន្ទុកអាជីវកម្ម | ប្រធាន |
| ២. លោក រស់ ចិន | ប្រធាននាយកដ្ឋានអាជីវកម្ម | អនុប្រធាន |
| ៣. លោកស្រី ស៊ឹម វល្លិកា | ប្រធានអង្គភាពលទ្ធកម្ម | សមាជិកា |
| ៤. លោកស្រី ស៊ឹម ផល | អនុប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិកា |
| ៥. កញ្ញា ជា សុវណ្ណច័ន្ទបុប្ផា | ប្រធានផ្នែក នៃនាយកដ្ឋានផែនការនិងគម្រោង | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចទទួលបន្ទុកធ្វើបដិសណ្ឋារកិច្ចចំពោះរាល់គណៈអធិបតី, ភ្ញៀវកិត្តិយស, ភ្ញៀវ និងអ្នកចូលរួមទាំងអស់ក្នុងកម្មវិធីមហាសន្និបាតទាំងមូល។

## ២៤- អនុគណៈកម្មការទទួលបន្ទុកផ្សព្វផ្សាយ អញ្ជើញ និងចុះឈ្មោះ

| | | |
|---|---|---|
| ១. ឯកឧត្តម អ៊ិន សាកាន | អគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផលិតកម្ម | ប្រធាន |
| ២. លោក សាវុធ វឌ្ឍនា | ប្រធានមណ្ឌលព័ត៌មានវិទ្យា | អនុប្រធាន |
| ៣. លោក កែម កានវិចិត្រ | ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធផលិតកម្ម | សមាជិក |
| ៤. លោក អ៊ុំ ពិសិដ្ឋ | អនុប្រធានមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ៥. កញ្ញា គង់ សុគន្ធារី | ប្រធានការិយាល័យទំនាក់ទំនងវិនិយោគិននិងផ្សារមូលបត្រ | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចទទួលបន្ទុកផ្សព្វផ្សាយអំពីមហាសន្និបាត, ធ្វើលិខិតអញ្ជើញ និងអញ្ជើញអ្នកត្រូវចូលរួមមហាសន្និបាតទាំងអស់ (អធិបតី, ភ្ញៀវកិត្តិយស, ភ្ញៀវ), បង្កើតតំណ (Link) បន្ថែមមុខងារបកប្រែភ្ជាប់កម្មវិធី ZOOM និងជាវ License កម្មវិធី ZOOM សម្រាប់ការចូលរួមរបស់ភាគហ៊ុនិក, ដំឡើង Wi-Fi, ទទួលចុះឈ្មោះនៅទីតាំងប្រារព្ធមហាសន្និបាត និងតាម Online, កត់ត្រាវត្តមានអ្នកចូលរួមមហាសន្និបាតបង្ហាញស្ថិតិភាគហ៊ុនិក និងចំនួនភាគហ៊ុនក្នុងពិធីមហាសន្និបាត។

## ២៥- អនុគណៈកម្មការទទួលបន្ទុកបោះឆ្នោត

| | | |
|---|---|---|
| ១. លោកស្រី រឿន ណារី | អគ្គនាយករងទទួលបន្ទុករដ្ឋបាលនិងធនធានមនុស្ស | ប្រធាន |
| ២. លោក ផេង ទី | អគ្គនាយករងទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក | អនុប្រធាន |
| ៣. លោក សាវុធ វឌ្ឍនា | ប្រធានមណ្ឌលព័ត៌មានវិទ្យា | អនុប្រធាន |
| ៤. លោក សោម សុវណ្ណ | ប្រធានអង្គភាពច្រកចេញចូលតែមួយ | សមាជិក |
| ៥. លោក គឹម កែវពិសិដ្ឋ | អនុប្រធានមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ៦. លោក អ៊ុំ ពិសិដ្ឋ | អនុប្រធានមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ៧. លោក អ៊ូច វិមាន | អនុប្រធាននាយកដ្ឋាន នៃសាខាសេវាកម្មទឹកស្អាតនិងអនាម័យ | សមាជិក |
| ៨. លោក សួន សុភ័ក្ត្រ | ប្រធានផ្នែក នៃមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ៩. លោក ឯម ពិសាល | ប្រធានផ្នែក នៃមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ១០. លោក សុខ សុវណ្ណារ៉ា | ប្រធានផ្នែក នៃមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ១១. លោក លាង តារា | អនុប្រធានផ្នែក នៃមណ្ឌលព័ត៌មានវិទ្យា | សមាជិក |
| ១២. លោក ង៉ូវ សុធានិត | ប្រធានក្រុម នៃមណ្ឌលព័ត៌មានវិទ្យា | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចទទួលបន្ទុកសិក្សានិងកសាងនីតិវិធីបោះឆ្នោតតាម Online ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពចំពោះភាគហ៊ុនិក, ធ្វើបច្ចុប្បន្នភាពកម្មវិធីបោះឆ្នោតរួមទាំងរាប់សន្លឹកឆ្នោត, រៀបចំ Backdrop និង Slideshow ជា Soft, បញ្ជាដំណើរការកម្មវិធី ZOOM និងដំណើរការបោះឆ្នោត។

## ១៦- អនុគណៈកម្មការទទួលបន្ទុកកំណត់ហេតុ និងបូកសរុប

| | | |
|---|---|---|
| ១. លោក ហួត សុខហេង | ប្រធានអង្គភាពលេខាធិការសហគ្រាស | ប្រធាន |
| ២. លោកស្រី សេង ពុទ្ធារី | ប្រធានលេខាធិការ នៃអង្គភាពលេខាធិការសហគ្រាស | អនុប្រធាន |
| ៣. លោក ទ្រី វណ្ណថា | ប្រធានការិយាល័យ នៃអង្គភាពលេខាធិការសហគ្រាស | សមាជិក |
| ៤. កញ្ញា អ៊ឹម ចាន់លក្ខិណា | ប្រធានការិយាល័យ នៃអង្គភាពលេខាធិការសហគ្រាស | ពិធីការិនី |
| ៥. លោក ឈុន ស៊ាកលេង | ប្រធានការិយាល័យ នៃអង្គភាពលេខាធិការសហគ្រាស | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចទទួលបន្ទុកព្រាងសន្ទរកថាបើកនិងបិទរបស់ប្រធានគណៈអធិបតី, រៀបចំស្លាយអំពីកម្មវត្ថុបោះឆ្នោត, ពិធីករ (MC), ធ្វើកំណត់ហេតុមហាសន្និបាត និងធ្វើសេចក្តីប្រកាសព័ត៌មាន (ជាភាសាខ្មែរ និងអង់គ្លេស)។

## ១៧- អនុគណៈកម្មការទទួលបន្ទុកសន្តិសុខ និងសណ្តាប់ធ្នាប់

| | | |
|---|---|---|
| ១. លោក អឿ លុច | ប្រធាននាយកដ្ឋានរដ្ឋបាលនិងធនធានមនុស្ស | ប្រធាន |
| ២. លោក ប៉ឹក ងួន | ប្រធានផ្នែកប្រចាំការ និងសណ្តាប់ធ្នាប់ | អនុប្រធាន |
| ៣. លោក អ៊ុង រ័ត្ន | អនុប្រធានផ្នែកប្រចាំការ និងសណ្តាប់ធ្នាប់ | សមាជិក |
| ៤. លោក សុខ សៀម | អនុប្រធានផ្នែកប្រចាំការ និងសណ្តាប់ធ្នាប់ | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចថែរក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៃអង្គពិធីទាំងមូល។

## ១៨- អនុគណៈកម្មការទទួលបន្ទុកសម្របសម្រួល

| | | |
|---|---|---|
| ១. កញ្ញា ឈឹម កក្កដា | ប្រធានសវនកម្មផ្ទៃក្នុង | ប្រធាន |
| ២. កញ្ញា ហ៊ូ ស៊ីនួន | ជំនួយការអគ្គនាយក | អនុប្រធាន |
| ៣. លោកស្រី ហៃ យ៉េកហ៉ង | ជំនួយការអគ្គនាយក | លេខា |

អនុគណៈកម្មការនេះមានភារកិច្ចទទួលបន្ទុករៀបចំអ្នកបកប្រែភាសា (ខ្មែរ-អង់គ្លេស) និងឧបករណ៍បកប្រែ, តាមដានលទ្ធផលនៃការអនុវត្តរបស់អនុគណៈកម្មការនីមួយៗ និងរាយការណ៍ជូនគណៈកម្មការកណ្តាល ព្រមទាំងជួយសម្របសម្រួលការងារផ្សេងៗតាមការចាំបាច់។

**ប្រការ ២ ៖** គណៈកម្មការ និងអនុគណៈកម្មការ ត្រូវដឹកនាំការរៀបចំនិងដំណើរការមហាសន្និបាតភាគហ៊ុនិកឱ្យបានត្រឹមត្រូវតាមការកំណត់។ គ្រប់អនុគណៈកម្មការអាចចាត់តាំងមន្ត្រី-និយោជិតជំនាញក្រោមឱវាទរបស់ខ្លួនបន្ថែម ដើម្បីជួយបំពេញការងារតាមតម្រូវការចាំបាច់ជាក់ស្តែង។

**ប្រការ ៣ ៖** រាល់សេចក្តីសម្រេចពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤ ៖** គណៈកម្មការ និងអនុគណៈកម្មការ ព្រមទាំងគ្រប់អគ្គនាយករង ប្រធាននាយកដ្ឋាន, អង្គភាព និងការិយាល័យចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៥កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមេសា ឆ្នាំ២០២៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាអគ្គនាយក នៃរ.ទ.ស.ភ**

**ឡុង ណារ៉ូ**

ចម្លងជូន ៖
- ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៨
## សម្រង់ខ្លឹមសារនៃលក្ខន្តិកៈ វ.ទ.ស.ត

## ជំពូកទី ២-    ដើមទុន ភាគហ៊ុន ការកាន់កាប់ភាគហ៊ុន

### ប្រការ ១២  សិទ្ធិ  បុព្វសិទ្ធិ  និងលក្ខខណ្ឌរបស់ភាគហ៊ុន

#### ១២.១.  សិទ្ធិ និងលក្ខខណ្ឌរបស់ភាគហ៊ុនធម្មតា

ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតាទទួលខុសត្រូវត្រឹមតែតម្លៃនៃភាគហ៊ុនដែលខ្លួនបានទិញ និងមានសិទ្ធិដូចខាងក្រោមៈ

ក) សិទ្ធិក្នុងការបោះឆ្នោតនៅគ្រប់មហាសន្និបាតនៃភាគហ៊ុនិករបស់ រ.ទ.ស.ភ ។

ខ) សិទ្ធិក្នុងការទទួលភាគលាភដែលបានប្រកាសដោយ  រ.ទ.ស.ភ ។

គ) សិទ្ធិក្នុងការទទួលនូវទ្រព្យដែលនៅសេសសល់របស់ រ.ទ.ស.ភ នៅពេលមានការរំលាយ តាមសមាមាត្រភាគហ៊ុន។

ឃ) សិទ្ធិផ្សេងទៀតដែលកំណត់ដោយច្បាប់។

## ជំពូកទី ៣ - មហាសន្និបាតភាគហ៊ុនិក

### ប្រការ ២១  មហាសន្និបាតភាគហ៊ុនិក

១. សេចក្តីសម្រេចរបស់ភាគហ៊ុនិកនៅក្នុងមហាសន្និបាតភាគហ៊ុនិកអាចត្រូវបានអនុម័តទៅលើបញ្ហាទាំងឡាយ ដែលមានកំណត់នៅក្នុងលក្ខន្តិកៈនេះ ឬច្បាប់។

២. មហាសន្និបាតភាគហ៊ុនិករួមមានមហាសន្និបាតសាមញ្ញ និងមហាសន្និបាតវិសាមញ្ញ។

### ប្រការ ២២ ទីកន្លែងមហាសន្និបាតភាគហ៊ុនិក

មហាសន្និបាតភាគហ៊ុនិកត្រូវប្រារព្ធនៅទីស្នាក់ការ ឬទីកន្លែងណាមួយ ដែលមានកំណត់នៅក្នុងលិខិតកោះប្រជុំ ដែលទីកន្លែងនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២៣  ការកោះប្រជុំ និងអធិបតភាពនៃមហាសន្និបាតភាគហ៊ុនិក

១. មហាសន្និបាតសាមញ្ញភាគហ៊ុនិកត្រូវប្រារព្ធក្នុងរយៈពេលមិនលើសពី បីខែ(៣ខែ) ដោយគិតចាប់ពីថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធមុន។ មហាសន្និបាតវិសាមញ្ញភាគហ៊ុនិកអាចត្រូវបានកោះប្រជុំគ្រប់ពេលដោយអគ្គនាយក ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

២. មហាសន្និបាតវិសាមញ្ញភាគហ៊ុនិកអាចត្រូវប្រារព្ធនៅពេលចាំបាច់ ប្រសិនបើកូរ៉ុមដែលមានចែងក្នុងប្រការ២៤ មានគ្រប់គ្រាន់។ មហាសន្និបាតភាគហ៊ុនិកត្រូវប្រជុំក្រោមអធិបតីភាពរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយក ប្រសិនបើប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន។

៣. អគ្គនាយក រ.ទ.ស.ភ ត្រូវកោះប្រជុំ និងរៀបចំឱ្យមានមហាសន្និបាតភាគហ៊ុនិកតាមសំណើរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនធម្មតាយ៉ាងតិច ៥១%។ សំណើសុំកោះប្រជុំមហាសន្និបាតភាគហ៊ុនិកត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅអគ្គនាយកដោយមានបញ្ជាក់នូវរបៀបវារៈ និងត្រូវចុះហត្ថលេខាដោយភាគហ៊ុនិកដែលស្នើសុំនោះ។ ប្រសិនបើអគ្គនាយកមិនបានចេញលិខិតជូនដំណឹងកោះប្រជុំមហាសន្និបាតក្នុងរយៈពេល ម្ភៃមួយថ្ងៃ(២១ថ្ងៃ)បន្ទាប់ពីបានទទួលសំណើនេះ ភាគហ៊ុនិកដែលបាន

ដាក់សំណើអាចកោះប្រជុំមហាសន្និបាត ដោយអនុលោមតាមនីតិវិធីនៃការកោះប្រជុំមហាសន្និបាតភាគហ៊ុនិកដែលមានចែងក្នុងលក្ខន្តិកៈនេះ។

៤. លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពី ការកោះប្រជុំមហាសន្និបាតភាគហ៊ុនិកត្រូវផ្តល់ទៅឱ្យភាគហ៊ុនិកទាំងអស់ យ៉ាងតិចដប់ថ្ងៃ(១០ថ្ងៃ) មុនថ្ងៃបើកមហាសន្និបាតភាគហ៊ុនិកដោយអនុលោមតាមប្រការ៩[1]។ លិខិតជូនដំណឹងនោះត្រូវបញ្ជាក់ពីកាលបរិច្ឆេទ ពេលវេលា ទីកន្លែង និងរបៀបវារៈនៃមហាសន្និបាតភាគហ៊ុនិក។

## ប្រការ ២៤ កូរ៉ុម

១. មហាសន្និបាតភាគហ៊ុនិកត្រូវបានប្រារព្ធឡើងដោយត្រឹមត្រូវ ប្រសិនបើនៅពេលចាប់ផ្តើមមហាសន្និបាតភាគហ៊ុនិកមានវត្តមានភាគហ៊ុនិកដែលតំណាងឱ្យភាគហ៊ុន ដែលមានសិទ្ធិបោះឆ្នោតភាគច្រើនចូលរួមដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង។

២. ក្នុងករណីមហាសន្និបាតភាគហ៊ុនិកលើកទីមួយ មិនគ្រប់កូរ៉ុម មហាសន្និបាតភាគហ៊ុនិកលើកទីពីរត្រូវតែកោះអញ្ជើញក្នុងរយៈពេលមិនលើសពី សែសិបប្រាំថ្ងៃ(៤៥ថ្ងៃ)បន្ទាប់ពីកាលបរិច្ឆេទមហាសន្និបាតភាគហ៊ុនិកលើកទីមួយ។ កូរ៉ុមសម្រាប់មហាសន្និបាតភាគហ៊ុនិកលើកទីពីរនេះ គឺចំនួនភាគហ៊ុនិកដែលមានវត្តមានក្នុងមហាសន្និបាតភាគហ៊ុនិកនោះ។

## ប្រការ ២៥ ការតែងតាំងអាណត្តិគាហកៈ

ភាគហ៊ុនិកម្នាក់អាចតែងតាំងភាគហ៊ុនិកម្នាក់ទៀត ឬតតិយជនណាម្នាក់ ដើម្បីធ្វើជាតំណាង និងដើម្បីបោះឆ្នោតក្នុងនាមជាអាណត្តិគាហកៈជំនួសខ្លួនក្នុងមហាសន្និបាតភាគហ៊ុនិក។ ក្នុងករណីនេះ អាណត្តិគាហកៈត្រូវដាក់ជូននូវឯកសារ ដែលបញ្ជាក់ពីសិទ្ធិតំណាងរបស់ខ្លួននៅក្នុងមហាសន្និបាតភាគហ៊ុនិកនោះ។

## ប្រការ ២៦ សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក

១. សេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិកអាចធ្វើឡើងតាមរយៈ
   ក. ការលើកដៃ៖ ភាគហ៊ុនិកម្នាក់មានមួយសំលេង។
   ខ. ការបោះឆ្នោត៖ ភាគហ៊ុនិកម្នាក់ៗមានមួយសំលេងក្នុងមួយភាគហ៊ុន។

២. រាល់សេចក្តីសម្រេចនៅក្នុងមហាសន្និបាតភាគហ៊ុនិកត្រូវសម្រេចដោយការលើកដៃ លើកលែងមានការស្នើសុំណាមួយឱ្យមានការបោះឆ្នោតដោយបុគ្គលដូចខាងក្រោម៖
   ក. ភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥នាក់
   ខ. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥% នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត
   គ. តាមការណែនាំពីប្រធានគណៈអធិបតីនៃអង្គមហាសន្និបាតភាគហ៊ុនិក

---

[1] **ប្រការ ៩ មធ្យោបាយក្នុងការជូនដំណឹងជាសាធារណៈ**

១. មធ្យោបាយក្នុងការជូនដំណឹងជាសាធារណៈរបស់ រ.ទ.ស.ភ គឺធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិចលើកលែងតែច្បាប់ ឬលក្ខន្តិកៈចែងផ្សេងពីនេះ។ ក្នុងករណីដែល រ.ទ.ស.ភ មិនអាចជូនដំណឹងតាមរយៈប្រព័ន្ធអេឡិចត្រូនិចបានដោយប្រការណាមួយការជូនដំណឹងនេះនឹងត្រូវចុះផ្សាយក្នុងសារព័ត៌មានជាភាសាខ្មែរ ឬភាសាអង់គ្លេស។

២. ក្នុងករណី រ.ទ.ស.ភ បោះផ្សាយលក់មូលបត្រជាសាធារណៈ ការជូនដំណឹងជាសាធារណៈត្រូវចុះផ្សាយក្នុងសារព័ត៌មានជាភាសាខ្មែរ ឬភាសាអង់គ្លេស ដែលទទួលស្គាល់ដោយគណៈកម្មការមូលបត្រកម្ពុជា ("គ.ម.ក") ។

៣. លើកលែងតែបញ្ហាទាំងឡាយណា ដែលតម្រូវឱ្យមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ភាគហ៊ុនិក សេចក្តីសម្រេចសាមញ្ញរបស់មហាសន្និបាតភាគហ៊ុនិកត្រូវអនុម័តដោយសម្លេងគាំទ្រភាគច្រើនរបស់ភាគហ៊ុនិកដែលចូលរួមបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ។ ចំពោះសេចក្តីសម្រេចពិសេសរបស់មហាសន្និបាតភាគហ៊ុនិកត្រូវអនុម័តដោយសម្លេងយ៉ាងតិច ពីរភាគបី (២/៣) របស់ភាគហ៊ុនិកដែលចូលរួមបោះឆ្នោតដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកៈ។

### ប្រការ ២៧ កំណត់ហេតុមហាសន្និបាតភាគហ៊ុន

កំណត់ហេតុមហាសន្និបាតភាគហ៊ុនិកត្រូវធ្វើឡើងដោយកត់ត្រាសង្ខេបពីដំណើរការ និងបញ្ហាដែលបានពិភាក្សានៅក្នុងមហាសន្និបាតភាគហ៊ុនិក និងត្រូវចុះហត្ថលេខាដោយប្រធានគណអធិបតីមហា-សន្និបាតភាគហ៊ុនិក។